IDEA BOOK

សៀវភៅបណ្ដុះគំនិត

មត៌កដ៏ថ្លៃថ្លាជាអំណោយសម្រាប់មនុស្សជាតិ

**គឺពុទ្ធសាសនា**



# អក្សរសាស្ត្រ

# ពុទ្ធសាសនា ២

3

PB...2013........

895.932
សិក
ភាគ 2

សិក្សាអត្ថបទ

# អក្សរសាស្ត្រ ព្រះពុទ្ធសាសនា

## ភាគ២

រៀបរៀងដោយ

លោក ស៊ិន សុវណ្ណនិ

រក្សាសិទ្ធិគ្រប់យ៉ាង

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

00024966

អក្សរសាស្ត្រព្រះពុទ្ធសាសនា

រៀបរៀងដោយ **ស៊ិន សុវណ្ណនិ**
ពិនិត្យអក្ខរាវិរុទ្ធដោយ **យ៉ាន ហៀន**
កំណែកុំព្យូទ័រដោយ **ពូន សាមឿន**
រចនាទំព័រដោយ **ឈាវ រតនៈ**
រចនាគម្របដោយ **សុង បូរ៉ា**
អ្នកទីផ្សារ និងចែកចាយសៀវភៅដោយ **លាស់ សុច័ន្ទ អួង តាក**
រក្សាសិទ្ធិគ្រប់យ៉ាងដោយគ្រឹះស្ថានបោះពុម្ពផ្សាយ **IDEA BOOK**

ideabookcambodia@gmail.com
facebook.com/ideabookpublishing

បោះពុម្ពឆ្នាំ២០១២
ដោយ **Olympic Printing**

ISBN: 978999-6331-86-2

តម្លៃ : ១២ ៥០០ រៀល

# មាតិកា


១-ចុះពិភពលោកយើងនេះកើតឡើងដំបូងដោយសារអ្វី ?................. ៤
២-ឧត្តមគតិនៃព្រះពោធិសត្វ........................................................ ២១
៣-ប្រយោជន៍នៃព្រះពុទ្ធសាសនា................................................ ២៩
៤-តម្លៃនៃព្រះពុទ្ធសាសនា .......................................................... ៣៦
៥-ព្រះពុទ្ធសាសនាជាសាសនានាំទៅកាន់សេចក្តីសុខ...................... ៤៧
៦-រឿងសុនក្ខត្តលិច្ឆវិបុត្ត.......................................................... ៥៦
៧-ទស្សនវិជ្ជាសេដ្ឋកិច្ចពុទ្ធសាសនា............................................. ៦៣
៨-ការងារជារបស់មនុស្ស........................................................... ៧២
៩-ប្រវត្តិចំណីអាហារមនុស្សលោក................................................. ៧៥
១០-ព្រះពុទ្ធសាសនានិងផ្លូវលោក.................................................. ៨២
១១-បញ្ហានិងការដោះស្រាយស្តីពីហាយនៈ៤ និងធម្មទ្វេស៤........... ១០៦
១២-ទស្សននិយមប្លែកគ្នារវាងពាហិរសាសនា.............................. ១១៩
១៣-ការខ្វែងគំនិតមួយទៀតរវាងទស្សនៈពុទ្ធនិយមនិងព្រាហ្មណនិយម១២៨
១៤- ព្រះពុទ្ធបដិភាណ................................................................ ១៣៩
១៥-រឿងនិគ្រោធបរិព្វាជក............................................................ ១៥៩
១៦-គោលការណ៍នៃជីវិត............................................................. ១៦៥
១៧-ពាលសូត្រ........................................................................... ១៧១
១៨-ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា.......................................... ១៨០
១៩-រឿងគាមមណិចន្ទ................................................................. ១៩២

# ចុះពិភពលោកយើងនេះ កើតឡើងដំបូងដោយសារអ្វី?

សំណួរនេះ បើតាមទ្រឹស្តីសាសនាព្រាហ្មណ៍ ទ្រឹស្តីសាសនាគ្រិស្ត និងទ្រឹស្តីសាសនាឥស្លាម គេឆ្លើយស្របគ្នាតែម្យ៉ាងថា ពិភពលោកយើងនេះ កាលចាប់ផ្តើមកកើតឡើងជាដំបូង ដោយអាស្រ័យហេតុព្រះព្រហ្មឬព្រះម្ចាស់សួគ៌បានកសាង ជប់ឲ្យកើតឡើង មុនដំបូង លោកជប់ឲ្យកើតមានទឹក ភ្លើង ខ្យល់ បន្ទាប់មកទៀត ជប់ឲ្យកើតមានមនុស្ស សត្វ ព្រៃ ភ្នំ និងវត្ថុគ្រប់មុខ នៅលើផែនដី ដែលយើងហៅកាត់ខ្លីថា «ពិភពលោក»។

ចំណែកទ្រឹស្តីអ្នកវិទ្យាសាស្ត្រសម័យថ្មីឆ្លើយថា ពិភពលោកយើងនេះ ជាផ្ទៃផែនដីមួយដុំមូលប្រហែលផ្លែក្រូចថ្លុង ហើយវិលជុំវិញព្រះអាទិត្យ តែងកើតមាននៅជាប់ជានិច្ចកាល ឥតប្រែប្រួល ឥតរលត់រលាយ បាត់បង់ទៅហើយកកើតជាថ្មីវិញទៀតទេ។ ឯមនុស្សកើតក្លាយមកពីសត្វស្វាឬសត្វទោច។ សត្វទាំងអស់កើតមកពីធាតុដី ទឹក ភ្លើង ខ្យល់ និងធាតុអាកាស ចូលផ្សំត្រូវកម្រិតគ្នាហើយ ទើបកកើតឡើងជាសត្វបាន។ ស្មៅនិងដើមឈើ ក៏កើតមកពីធាតុចូលផ្សំត្រូវគ្នាដែរ។

ខាងទ្រឹស្តីពុទ្ធសាសនាវិញ ឆ្លើយខុសស្រឡះពីទ្រឹស្តីទាំង៤យ៉ាងខាងដើមនេះ។ ដូច្នេះ ខ្ញុំសូមស្រង់យកព្រះពុទ្ធដីកា ក្នុងអគ្គញ្ញសូត្រមកពណ៌នាមើលចុះ តើនឹងគួរជឿស្តាប់ទ្រឹស្តីណា ក្នុងបណ្តាទ្រឹស្តីទាំង៥ យ៉ាងដូចតទៅនេះ ៖

អគ្គញ្ញសូត្រ ក្នុងសុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ (ច្បាប់ព្រះត្រៃ-បិដកបាលីខ្មែរលេខទី១៨)

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទរបស់មិគារមាតា (នាងវិសាខា) ក្នុងវត្តបុព្វារាម ជិតក្រុងសាវត្ថី។ គ្រានោះ វាសេដ្ឋសាមណេរ

និងភារទ្វាជសាមណេរ (អដ្ឋកថាថា សាមណេរទាំងពីររូបនេះកើតក្នុងត្រកូលព្រាហ្មណមហាសាលមានទ្រព្យ៤០កោដិដូចគ្នា បានរៀនចេះចប់ត្រៃវេទ បានស្តាប់វាសេដ្ឋសូត្រហើយក៏ដល់សរណគមន៍ លុះស្តាប់តេវិជ្ជសូត្រហើយក៏បួសជាសាមណេរ ដល់ពេលនះចង់បួសជាភិក្ខុទៀត ទើបនៅតិត្ថិយបរិវាស) ចង់បួសជាភិក្ខុ ទើបធ្វើតិត្ថិយបរិវាសក្នុងសំណាក់ភិក្ខុទាំងឡាយ។ វេលាថ្ងៃរសៀល ព្រះពុទ្ធអង្គទ្រង់ចេញចាកទីសំងំ ហើយចុះអំពីប្រាសាទទៅចង្រ្កមក្នុងទីវាល ត្រង់ម្លប់ប្រាសាទ។ ឯវាសេដ្ឋសាមណេរនិងភារទ្វាជសាមណេរនាំគ្នាចូលទៅគាល់ព្រះពុទ្ធអង្គ ថ្វាយបង្គំរួចហើយ ដើរតាមក្រោយព្រះអង្គដែលកំពុងតែចង្រ្កម។ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សួរថា ម្នាលវាសេដ្ឋៈនិងភារទ្វាជៈ អ្នកទាំងពីរជាជាតិព្រាហ្មណ៍ ចេញចាកផ្ទះចូលមកកាន់ផ្នួស ចុះពួកព្រាហ្មណ៍ដ៏ប្រសើរមិនជេរមិនប្រទេចអ្នកទាំងពីរទេឬ ?។

វាសេដ្ឋសាមណេរក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍ជេរប្រទេចខ្ញុំព្រះអង្គទាំងពីរនាក់ ដោយពាក្យជេរប្រទេចតាមចិត្តគេពេញទី មិនមែនខ្វះកន្លះទេ។

- ចុះពួកព្រាហ្មណ៍ជេរប្រទេចអ្នក ដោយពាក្យជេរប្រទេចតាមចិត្តគេពេញទី មិនខ្វះកន្លះនោះតើដូចម្តេច ?

- បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍និយាយថា មានតែពួកព្រាហ្មណ៍មួយទេ ទើបជាវណ្ណៈ (ពាក្យថា វណ្ណៈនេះ សំដៅយកពណ៌សម្លៀកបំពាក់ ជាគ្រឿងសម្គាល់ជាតិ...) ប្រសើរបំផុត ពួកជនឯទៀតជាវណ្ណៈថោកទាប មានតែពួកព្រាហ្មណ៍មួយទេ ទើបជាវណ្ណៈស ពួកជនឯទៀតជាវណ្ណៈខ្មៅ មានតែពួកព្រាហ្មណ៍មួយទេ ទើបបរិសុទ្ធ ពួកជនដែលមិនមែនជាព្រាហ្មណ៍មិនបរិសុទ្ធទេ ពួកព្រាហ្មណ៍ជាបុត្រ ជាឱរសរបស់ព្រហ្ម កើតអំពីព្រះឱស្ឋព្រហ្ម កើតមកអំពីព្រហ្ម ព្រហ្មបានតាក់តែងមកជាទាយាទ (ញាតិអ្នកទទួលកេរសំបាច់) របស់ព្រហ្ម ឯអ្នកទាំងឡាយនោះលះចោលវណ្ណៈដ៏ប្រសើរចេញ ហើយត្រឡប់មក

និងភារទ្វារជសាមណេរ (អដ្ឋកថាថា សាមណេរទាំងពីររូបនេះកើតក្នុងត្រកូលព្រាហ្មណមហាសាលមានទ្រព្យ៤០កោដិដូចគ្នា បានរៀនចេះចប់ត្រៃវេទ បានស្តាប់វាសេដ្ឋសូត្រហើយក៏ដល់សរណគមន៍ លុះស្តាប់តេវិជ្ជសូត្រហើយក៏បួសជាសាមណេរ ដល់ពេលនះចង់បួសជាភិក្ខុទៀត ទើបនៅតិត្ថិយបរិវាស) ចង់បួសជាភិក្ខុ ទើបធ្វើតិត្ថិយបរិវាសក្នុងសំណាក់ភិក្ខុទាំងឡាយ។ វេលាថ្ងៃរសៀល ព្រះពុទ្ធអង្គទ្រង់ចេញចាកទីសំងំ ហើយចុះអំពីប្រាសាទទៅចង្រ្កមក្នុងទីវាល ត្រង់ម្លប់ប្រាសាទ។ ឯវាសេដ្ឋសាមណេរនិងភារទ្វាជសាមណេរនាំគ្នាចូលទៅគាល់ព្រះពុទ្ធអង្គ ថ្វាយបង្គំរួចហើយ ដើរតាមក្រោយព្រះអង្គដែលកំពុងតែចង្រ្កម។ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សួរថា ម្នាលវាសេដ្ឋៈនិងភារទ្វាជៈ អ្នកទាំងពីរជាជាតិព្រាហ្មណ៍ ចេញចាកផ្ទះចូលមកកាន់ផ្នួស ចុះពួកព្រាហ្មណ៍ដ៏ប្រសើរមិនជេរមិនប្រទេចអ្នកទាំងពីរទេឬ?។

វាសេដ្ឋសាមណេរក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍ជេរប្រទេចខ្ញុំព្រះអង្គទាំងពីរនាក់ ដោយពាក្យជេរប្រទេចតាមចិត្តគេពេញទី មិនមែនខ្វះកន្លះទេ។

- ចុះពួកព្រាហ្មណ៍ជេរប្រទេចអ្នក ដោយពាក្យជេរប្រទេចតាមចិត្តគេពេញទី មិនខ្វះកន្លះនោះតើដូចម្តេច?

- បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍និយាយថា មានតែពួកព្រាហ្មណ៍មួយទេ ទើបជាវណ្ណៈ (ពាក្យថា វណ្ណៈនេះ សំដៅយកពណ៌សម្លៀកបំពាក់ ជាគ្រឿងសម្គាល់ជាតិ...) ប្រសើរបំផុត ពួកជនឯទៀតជាវណ្ណៈថោកទាប មានតែពួកព្រាហ្មណ៍មួយទេ ទើបជាវណ្ណៈស ពួកជនឯទៀតជាវណ្ណៈខ្មៅ មានតែពួកព្រាហ្មណ៍មួយទេ ទើបបរិសុទ្ធ ពួកជនដែលមិនមែនជាព្រាហ្មណ៍មិនបរិសុទ្ធទេ ពួកព្រាហ្មណ៍ជាបុត្រ ជាឱរសរបស់ព្រហ្ម កើតអំពីព្រះឱស្ឋព្រហ្ម កើតមកអំពីព្រហ្ម ព្រហ្មបានតាក់តែងមកជាទាយាទ (ញាតិអ្នកទទួលកេរសំបាច់) របស់ព្រហ្ម ឯអ្នកទាំងឡាយនោះលះចោលវណ្ណៈដ៏ប្រសើរចេញ ហើយត្រឡប់មក

កាន់វណ្ណៈចោកទាបវិញ គឺត្រឡប់ចូលទៅក្នុងសំណាក់សមណៈត្រងោល ជាគហបតីវណ្ណៈខ្មៅ ជាពួកនៃមារកើតអំពីព្រះបាទព្រហ្ម ហេតុនោះពុំប្រពៃពុំសមគួរឡើយ។

- អើវាសេដ្ឋៈ ពួកព្រាហ្មណ៍របស់អ្នកមិនបានដឹងនូវការកកើតមានឡើងនៃលោកអំពីដើមដំបូងមកទេ ទើបបានជាហ៊ាននិយាយយ៉ាងនេះ។ ឯពួកព្រាហ្មណីដែលមានរដូវក្តី មានគភ៌ក្តី កំពុងសម្រាលកូនក្តី កំពុងបំបៅកូនក្តី សឹងប្រាកដដល់ពួកព្រាហ្មណ៍ គឺថាពួកព្រាហ្មណ៍បានឃើញដឹងច្បាស់ទែងផ្ទាល់ខ្លួនឯងស្រាប់ហើយ មិនបាច់តថាគតប្រាប់ទេ ឯពួកព្រាហ្មណ៍ទាំងនោះក៏សុទ្ធតែកើតមកអំពីយោនីនាងព្រាហ្មណី ប៉ុន្តែបែរជានិយាយថា មានតែពួកព្រាហ្មណ៍ទេ ទើបជាវណ្ណៈប្រសើរបំផុត។បេ។ ជាទាយាទរបស់ព្រហ្មដូច្នេះទៅវិញ ឯព្រាហ្មណ៍ទាំងនោះឈ្មោះថា និយាយបង្កាច់ព្រហ្មផង និយាយកុហកផង រមែងសោយនូវបាបច្រើន។

ម្នាលវាសេដ្ឋៈ វណ្ណៈមាន៤ពួកគឺ ខត្តិយៈ១ ព្រាហ្មណៈ១ វេស្សៈ១ សុទ្ទៈ១។ ខត្តិយៈពួកខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយពាក្យកុហក ពាក្យញុះញង់ ពាក្យទ្រគោះ ពាក្យឥតប្រយោជន៍ មានសេចក្តីលោភ មានចិត្តព្យាបាទ មានសេចក្តីយល់ខុសក៏មានដែរ។ ព្រោះហេតុនេះឯង ធម៌ទាំងឡាយឯណាជាអកុសលធម៌ ក៏រាប់ថាជាអកុសលដែលមានទោស ក៏រាប់ថាមានទោសដែលមិនគួរសេព ក៏រាប់ថា មិនគួរសេពដែលមិនសមគួរក្នុងអរិយភាពក៏រាប់ថាមិនសមគួរក្នុងអរិយភាព ជាធម៌ខ្មៅមានផលខ្មៅ ដែលវិញ្ញូជនតែងតិះដៀល។ ធម៌ទាំងនោះតែងប្រាកដក្នុងខត្តិយៈពួកខ្លះក្នុងលោកនេះឯង។ ព្រាហ្មណ៍ខ្លះ។បេ។ វេស្សៈខ្លះ។បេ។សុទ្ទៈខ្លះ។បេ។ ជាធម៌ខ្មៅ មានផលខ្មៅ ដែលវិញ្ញូជនតែងតិះដៀល ។ ធម៌ទាំងនោះតែងប្រាកដក្នុងសុទ្ទៈពួកខ្លះក្នុងលោកនេះឯង។

ខត្តិយៈពួកខ្លះក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត។បេ។ មិន

មានសេចក្តីលោភ មិនមានចិត្តព្យាបាទ មានសេចក្តីយល់ត្រូវក៏មានដែរ។ ព្រោះហេតុនេះឯង ធម៌ទាំងឡាយណាជាកុសល ក៏រាប់ថាជាកុសល ដែលឥតទោស ក៏រាប់ថាឥតទោសដែលគួរសេព ក៏រាប់ថាគួរសេពដែលសមគួរក្នុងអរិយភាព ក៏រាប់ថាសមគួរក្នុងអរិយភាព ជាធម៌ស មានផលស ដែលវិញ្ញូជនតែងសសើរ។ ធម៌ទាំងនេះតែងប្រាកដក្នុងខត្តិយៈពួកខ្លះក្នុងលោកនេះឯង។ ព្រាហ្មណ៍ខ្លះ។ បេ។ វេស្សៈខ្លះ។ បេ។ សុទ្ទៈខ្លះ។បេ។

ម្នាលវាសេដ្ឋៈ កាលបើវណ្ណៈទាំង៤ពួកនេះឯង ប្រព្រឹត្តច្រឡូកច្រឡំគ្នាក្នុងធម៌ពីរពួក គឺធម៌ខ្មៅនិងធម៌ស ដែលវិញ្ញូជនតែងតិះដៀលខ្លះ សរសើរខ្លះ បើពួកព្រាហ្មណ៍ ដែលកំពុងប្រព្រឹត្តក្នុងធម៌ខ្មៅនិងធម៌សនោះនិយាយថា មានតែពួកព្រាហ្មណ៍មួយទេ ទើបជាវណ្ណៈប្រសើរបំផុត ពួកជនឯទៀតជាវណ្ណៈថោកទាប។បេ។ ជាទាយាទរបស់ព្រហ្មដូច្នេះ។ វិញ្ញូជនទាំងឡាយមិនយល់ព្រមតាម គឺមិនសរសើរនូវពាក្យរបស់ពួកព្រាហ្មណ៍ទាំងនោះទេ ។ ដំណើរនោះតើព្រោះហេតុអ្វី ? ព្រោះថាបណ្តាវណ្ណៈទាំង៤ពួកនេះ វណ្ណៈណាជាភិក្ខុឆ្ងាយចាកកិលេស អស់អាសវៈ ហើយប្រព្រឹត្តព្រហ្មចារ្យរួចស្រេចហើយ បានធ្វើសោឡសកិច្ចស្រេចហើយ មានភារៈគឺកិលេសនិងខន្ធដាក់ចុះ ហើយបានសម្រេចប្រយោជន៍របស់ខ្លួនតាមលំដាប់ មានតណ្ហាជាគ្រឿងចងក្នុងភពអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ វណ្ណៈនោះប្រាកដជាបុគ្គលប្រសើរលើសជាងវណ្ណៈទាំងនោះ ដោយធម៌បីតិ មិនមែនដោយអធម៌ទេ ព្រោះថាធម៌ជាគុណប្រសើរបំផុតក្នុងប្រជុំជនទាំងបច្ចុប្បន្នទាំងបរលោក។

ម្នាលវាសេដ្ឋៈ ព្រះបាទបសេនទិកោសលទ្រង់ជ្រាបថា ព្រះសមណគោតម ជាបុគ្គលខ្ពង់ខ្ពស់ ចេញចាកសក្យត្រកូលមកទ្រង់ព្រះផ្នួស។ ប៉ុនអម្បាលពួកសក្យៈគង់ជាចំណុះព្រះបាទបសេនទិកោសលមិនមានចន្លោះ (អដ្ឋកថាថា ចុះចូលកោតខ្លាចព្រះបាទបសេនទិកោសលដូចជាត្រកូលរបស់ខ្លួន)។ ពួក

សក្យៈតែងធ្វើសេចក្ដីគោរព ថ្វាយបង្គំ ក្រោកទទួលអញ្ជលិកម្ម និងសាមីចិកម្ម ផ្សេងៗ ចំពោះព្រះបាទបសេនទិកោសល ឯព្រះបាទបសេនទិកោសលក៏ទ្រង់ធ្វើសេចក្ដីគោរព ថ្វាយបង្គំ ក្រោកទទួលអញ្ជលិកម្ម និងសាមីចិកម្មនោះៗ ចំពោះតថាគតដែរ ដោយទ្រង់ព្រះតម្រិះថា ព្រះសមណគោតម ព្រះអង្គមានជាតិបរិសុទ្ធ អាត្មាអញជាមនុស្សមានជាតិមិនបរិសុទ្ធទេ ព្រះសមណគោតម ព្រះអង្គមានកម្លាំង អាត្មាអញជាមនុស្សមានកម្លាំងថយ ព្រះសមណគោតម ព្រះអង្គមានសម្បុរជ្រះថ្លា អាត្មាអញជាមនុស្សមានសម្បុរសៅហ្មង ព្រះសមណគោតម ព្រះអង្គមានសក្តានុភាពច្រើន អាត្មាអញជាមនុស្សមានសក្តានុភាពតិច ដូច្នេះតពីនោះមក ទ្រង់ក៏ធ្វើសក្ការៈចំពោះធម៌នោះ ធ្វើសេចក្ដីគោរពធម៌ រាប់អានធម៌ បូជាធម៌ កោតក្រែងធម៌។ បើតាមបរិយាយនេះឯង អ្នកគប្បីដឹងថា ធម៌ជាគុណប្រសើរបំផុតក្នុងប្រជុំជនទាំងបច្ចុប្បន្នទាំងបរលោក។

ម្នាលវាសេដ្ឋៈនិងភារទ្វាជៈ អ្នកទាំងពីរមានជាតិផ្សេងៗគ្នា មានឈ្មោះផ្សេងៗគ្នា មានត្រកូលផ្សេងៗគ្នា ចេញចាកផ្ទះមកកាន់ផ្នួស បើមានគេសួរថា លោកទាំងឡាយជាអ្វី? ដូច្នេះចូរប្រាប់ទៅគេវិញថា យើងជាសមណ-សក្យបុត្រ។ បើជនណាមានសទ្ធា គឺការជឿស៊ប់ហើយមានឫសដុះតាំងខ្ជាប់មាំមួនក្នុងតថាគត ទោះបីសមណព្រាហ្មណ៍ ទេវតា ព្រហ្ម ឬក៏នរណាមួយក្នុងលោក ក៏មិនអាចនឹងបំបែរឲ្យត្រឡប់បានឡើយជនៈនោះគួរនិយាយថា ខ្ញុំជាបុត្រជាឱរសនៃព្រះដ៏មានព្រះភាគ កើតមកអំពីព្រះឱរសរបស់ព្រះដ៏មានព្រះភាគ កើតមកអំពីធម៌ ធម៌តាក់តែងមកជាទាយាទរបស់ធម៌។ ព្រោះហេតុអ្វីបានជាតថាគតថាដូច្នោះ ព្រោះពាក្យថា ធម្មកាយដូច្នេះក្តី ព្រហ្មកាយដូច្នេះក្តី ធម្មភូតដូច្នេះក្តី ព្រហ្មភូតដូច្នេះក្តី ជាឈ្មោះរបស់តថាគត។

# ពិភពលោកចាប់កកើតឡើងជាដំបូង

## ( ស្រង់កាត់ខ្លីៗតាមលម្អានព្រះពុទ្ធដីកាក្នុងអគ្គញ្ញសូត្រ )

ម្នាលវាសេដ្ឋៈ មានសម័យដែលលោកនេះត្រូវវិនាសម្តងៗ ដោយកាលកន្លងទៅជាយូរអង្វែង កាលដែលលោកកំពុងតែវិនាសទៅនោះ មានពួកសត្វបានទៅកើតក្នុងអាភស្សរព្រហ្មដោយច្រើន ជាអ្នកកើតដោយឈានចិត្ត (អដ្ឋកថាថា ក្នុងបឋមកប្បពួកសត្វលោកនោះ សូម្បីមកកើតក្នុងមនុស្សនេះ ក៏គង់កើតជាឱបបាតិកៈកំណើតដែរ គឺកើតឡើងឯង) មានបីតិជាងអាហារ (សត្វទាំងនោះមានបីតិជាអាហារក្នុងមនុស្សលោកនេះ ដូចព្រហ្មក្នុងព្រហ្មលោកនោះដែរ) មានរស្មីភ្លឺចេញឯង ត្រាច់ទៅក្នុងអាកាសបាន ស្ថិតនៅក្នុងវិមានដ៏ល្អនៅអស់កាលជាយូរអង្វែង។

ម្នាលវាសេដ្ឋៈ មានសម័យដែលលោកនេះត្រូវចម្រើនឡើងម្តងៗ ដោយកាលកន្លងទៅជាយូរអង្វែង កាលដែលលោកកំពុងតែចម្រើនឡើងនោះ សត្វទាំងឡាយច្យុតចាកអាភស្សរព្រហ្មមកកាន់ភាពជាមនុស្សនេះ ឯសត្វទាំងនោះជាអ្នកកើតដោយឈានចិត្ត មានបីតិជាអាហារ មានពន្លឺភ្លឺចេញឯង ត្រេចទៅក្នុងអាកាសបានស្ថិតនៅក្នុងវិមានដ៏ល្អអស់កាលជាយូរអង្វែង។

ម្នាលវាសេដ្ឋៈសម័យនោះចក្រវាលទាំងអស់ក៏រលាយទៅជាទឹកចូលគ្នា មានងងឹតអាប់សូន្យសុង ព្រះចន្ទនិងព្រះអាទិត្យក៏មិនបាក្រដ នក្ខត្តឫក្សដែលមានរូបជាផ្កាយទាំងឡាយក៏មិនប្រាកដ យប់និងថ្ងៃក៏មិនប្រាកដ ខែមួយនិងកន្លះខែក៏មិនប្រាកដ រដូវនិងឆ្នាំក៏មិនប្រាកដ ស្រីនិងប្រុសក៏មិនប្រាកដ។ សត្វទាំងឡាយក៏គ្រាន់តែរាប់ថា ជាសត្វប៉ុណ្ណោះឯង។

ម្នាលវាសេដ្ឋៈ លុះកាលកន្លងទៅអង្វែងម្តងៗ ផែនដីមានរសអណ្តែតជាសលើទឹកសម្រាប់សត្វទាំងនោះ ប្រាកដដូចជាទឹកដោះក្តៅ រលាយអណ្តែតជាសនៅលើទឹកដូច្នោះ ផែនដីមានរសនោះ មានសម្បុរល្អ មានក្លិនក្រអូប មាន

រសផ្អែម មានសម្បុរសដូចទឹកដោះថ្លា ឬដូចទឹកដោះខាប់ដែលមានរសផ្អែម ផែនដីនោះមានរសឆ្ងាញ់ពិសាដូចទឹកឃ្មុំដែលមានកូនឃ្មុំ ជាទឹកឥតមានទោស។ គ្រានោះ មានសត្វម្នាក់មានជាតិជាអ្នកលេះឡោះគិតថា យីអើនេះជាអ្វីអេះ ក៏យកចង្អុលដៃឆ្កឹះយកផែនដីមានរសមកលិទ្ធភ្លក់មើល រសផែនដីក៏ជ្រួតជ្រាបទៅសព្វសរសៃសម្រាប់ទទួលនូវរស ឯសេចក្ដីប្រាថ្នាក្នុងរស ក៏កើតដល់សត្វនោះ។ មានពួកសត្វដទៃទៀត កាលយកតម្រាប់តាមសត្វនោះនាំគ្នាយកចង្អុលដៃឆ្កឹះយកផែនដីមានរសមកលទ្ធភ្លក់មើល រសផែនដីក៏ជ្រួតជ្រាបទៅសព្វសរសៃសម្រាប់ទទួលនូវរស ឯសេចក្ដីប្រាថ្នាក្នុងរសក៏កើតឡើងដល់ពួកសត្វទាំងនោះ។ ពួកគេនាំគ្នាយកដៃកកាយផែនដីមានរសមកធ្វើជាពំនូត ហើយបរិភោគ ពន្លឺដែលភ្លឺចេញឯងអំពីកាយរបស់សត្វទាំងនោះក៏សាបសូន្យបាត់ទៅ ព្រះចន្ទនិងព្រះអាទិត្យក៏កើតប្រាកដឡើង នក្ខត្តឫក្សដែលមានរូបជាផ្កាយទាំងឡាយ ក៏កើតប្រាកដឡើង យប់និងថ្ងៃក៏កើតប្រាកដឡើង ខែមួយនិងកន្លះខែក៏កើតប្រាកដឡើង រដូវនិងឆ្នាំក៏កើតប្រាកដឡើង។ លោកនេះចម្រើនឡើងវិញដោយហេតុប៉ុណ្ណោះឯង។

ម្នាលវាសេដ្ឋៈ កាលពួកសត្វទាំងនោះ នាំគ្នាបរិភោគផែនដីមានរស ជាចំណីអាហារហើយ ស្ថិតនៅអស់កាលយូរអង្វែង សេចក្ដីរឹងប៉ឹងក្នុងរាងកាយរបស់សត្វទាំងនោះក៏កើតឡើង ទាំងពណ៌សម្បុរក៏ប្លែកៗគ្នាប្រាកដឡើង។ សត្វពួកខ្លះមានសម្បុរល្អ សត្វពួកខ្លះមានសម្បុរអាក្រក់។ ពួកសត្វមានសម្បុរល្អតែងមើលងាយពួកសត្វមានសម្បុរអាក្រក់ថា ពួកយើងមានសម្បុរល្អលើសជាងពួកសត្វនុ៎ះៗ មានសម្បុរអាក្រក់ជាងពួកយើង។ កាលសត្វទាំងនោះ មានសេចក្ដីប្រកាន់ខ្លួននិងការមើលងាយកើតឡើង ព្រោះបច្ច័យនៃសេចក្ដីមើលងាយនូវសម្បុរគ្នា ផែនដីមានរសក៏សាបសូន្យអស់ទៅ។ សត្វទាំងឡាយក៏ប្រជុំគ្នាហើយត្អូញត្អែរថា ឱ! រសឆ្ងាញ់របស់យើង ឱ! រសឆ្ងាញ់របស់យើង។ ហេតុនោះក៏ដូចគ្នានឹងមនុស្សទាំងឡាយក្នុងកាលឥឡូវនេះដែរ កាលដែលបានវត្ថុអ្វីមួយ

មានរសឆ្ងាញ់ហើយតែងនាំគ្នាលាន់មាត់ថា ឱ!រសឆ្ងាញ់របស់យើង ឱ!រសឆ្ងាញ់របស់យើង។ សត្វទាំងឡាយនាំគ្នានឹករកអក្ខរៈដែលជាច្បាប់ចាស់ (អដ្ឋកថាថា បាននឹងសម្ដីជាវង្សដែលកើតឡើងសម្រាប់លោក) នោះឯង ប៉ុន្តែមិនអាចដឹងយល់សេចក្ដីនៃអក្ខរៈនោះបានឡើយ។

ម្នាលវាសេដ្ឋៈ លុះផែនដីមានរសរបស់សត្វទាំងនោះសាបសូន្យអស់ទៅហើយ ក្រមរផែនដីក៏កើតប្រាកដឡើង។ ក្រមរផែនដីនោះ ដូចជាផ្សិតក្បាលពស់ បរិបូណ៌ដោយសម្បុរ មានក្លិនក្រអូប មានរសឆ្ងាញ់ មានពណ៌ដូចជាសប្បិសុទ្ធ ឬដូចជានវនីតសុទ្ធ មានរសឆ្ងាញ់ពិសាដូចទឹកឃ្មុំដែលមានកូនឃ្មុំ ជាទឹកឥតមានទោស។ សត្វទាំងនោះក៏នាំគ្នាបរិភោគក្រមរផែនដីជាចំណីអាហារស្ថិតនៅអស់កាលយូរអង្វែង។ សេចក្ដីរឹងប៉ឹងក្នុងរាងកាយរបស់ពួកសត្វទាំងនោះ ក៏កើតដោយក្រៃលែងលើសប្រមាណ ពណ៌សម្បុរក៏ប្លែកៗគ្នាប្រាកដឡើង។ សត្វពួកខ្លះមានសម្បុរល្អ សត្វពួកខ្លះមានសម្បុរអាក្រក់។ ពួកសត្វមានសម្បុរល្អរមែងមើលងាយពួកសត្វមានសម្បុរអាក្រក់ថា ពួកយើងមានសម្បុរល្អជាងពួកសត្វនុ៎ះ ពួកសត្វទាំងនុ៎ះមានសម្បុរអាក្រក់ជាងពួកយើង។

ម្នាលវាសេដ្ឋៈ កាលសត្វទាំងនោះមានសេចក្ដីប្រកាន់ខ្លួននិងមើលងាយកើតឡើង ព្រោះសេចក្ដីមើលងាយសម្បុរគ្នាជាបច្ច័យ ក្រមរផែនដីមានរសក៏សាបសូន្យអស់ទៅ ហើយបទាលតា (អដ្ឋកថាថា ជាឈ្មោះវល្លិមួយយ៉ាងមានរសផ្អែម) ក៏កើតប្រាកដឡើង។ បទាលតានោះកើតប្រាកដឡើងដូចជាវល្លិត្រកួន មានសម្បុរល្អ មានក្លិនក្រអូប មានរសឆ្ងាញ់ មានសម្បុរដូចជាសប្បិសុទ្ធឬដូចជានវនីតសុទ្ធមានរសឆ្ងាញពិសាដូចទឹកឃ្មុំដែលមានកូនឃ្មុំ ជាទឹកឥតមានទោស។ សត្វទាំងនោះក៏នាំគ្នាបរិភោគបទាលតាជាចំណីអាហារស្ថិតនៅអស់កាលយូរអង្វែង។ សេចក្ដីរឹងប៉ឹងក្នុងរាងកាយរបស់សត្វទាំងនោះក៏កើតឡើងដោយក្រៃលែងលើសប្រមាណ ទាំងពណ៌សម្បុរប្លែកៗគ្នា ខ្លះល្អ ខ្លះអាក្រក់ ទើបកើតចិត្តប្រកាន់ខ្លួននិងមើលងាយគ្នាដូចន័យខាងដើម។ ព្រោះចិត្ត

មើលងាយសម្បុរគ្នាជាបច្ច័យ បទាលតាក៏សាបសូន្យអស់ទៅ។ សត្វទាំងនោះមកប្រជុំគ្នាត្អូញត្អែរថា ឱហ្ន៎បទាលតារបស់យើងធ្លាប់មានហើយ ឱហ្ន៎ បទាលតារបស់យើងបាត់អស់ទៅហើយ។ ហេតុនោះក៏ដូចគ្នានឹងមនុស្សទាំងឡាយក្នុងកាលឥឡូវនេះដែរ ដែលធម៌ជាទុក្ខណាមួយប៉ះពាល់ ក៏និយាយគ្នាថា ឱហ្ន៎យើងធ្លាប់មាន ឱហ្ន៎ យើងសាបសូន្យអស់ហើយ។ សត្វទាំងឡាយនាំគ្នារកអក្សរដែលជាច្បាប់ចាស់នោះឯង ប៉ុន្តែមិនអាចនឹងយល់សេចក្តីនៃអក្សរនោះបានឡើយ។

ម្នាលវាសេដ្ឋៈ កាលបទាលតាសាបសូន្យអស់ទៅហើយ ស្រូវសាលីឆ្អិនឯង ជាស្រូវគ្មានកន្ទក់ គ្មានអង្កាម សស្អាតមានក្លិនក្រអូប មានផ្លែចេញមកជាអង្ករតែម្តងក៏កើតប្រាកដឡើង។ មនុស្សទាំងឡាយនាំយកស្រូវសាលីត្រង់ទីណាក្នុងវេលាល្ងាច សម្រាប់បរិភោគក្នុងវេលាល្ងាច លុះព្រឹកឡើងទីនោះក៏មានស្រូវសាលីដុះទ្រុបទ្រុលមានផ្លែទុំឡើងវិញមនុស្សទាំងឡាយនាំយកស្រូវសាលីត្រង់ទីណាក្នុងវេលាព្រឹក សម្រាប់បរិភោគក្នុងវេលាព្រឹក លុះវេលាល្ងាច ទីនោះក៏មានស្រូវសាលីដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញ ទីនោះក៏ប្រាកដហាក់ដូចជាមិនបានច្រូតឡើង។ សត្វទាំងឡាយក៏បរិភោគស្រូវសាលីឆ្អិនឯង ជាចំណីអាហារ ស្ថិតនៅអស់កាលយូរអង្វែង។ សេចក្តីរឹងប៉ឹងក្នុងរាងកាយរបស់ពួកសត្វទាំងនោះក៏កើតឡើងលើសប្រមាណ ទាំងពណ៌សម្បុរក៏ប្លែកៗគ្នាប្រាកដឡើង។ ភេទស្រីក៏ប្រាកដឡើងដល់ស្រី ភេទប្រុសក៏ប្រាកដឡើងដល់ប្រុស។ បានឮថា ស្រីសម្លឹងមើលប្រុសទាល់តែហួសវេលា ចំណែកខាងប្រុសក៏សម្លឹងមើលស្រីវិញទាល់តែហួសវេលាដែរ។ កាលសត្វទាំងនោះសម្លឹងមើលគ្នាទៅវិញទៅមកទាល់តែហួសវេលា តម្រេកក៏កើតឡើង សេចក្តីក្តៅក្រហាយព្រោះតម្រេកក៏ប្រជុំចុះក្នុងកាយ។ សត្វទាំងនោះក៏នាំគ្នាសេពមេថុនធម្ម ព្រោះសេចក្តីរោលរាលជាបច្ច័យ។ ពួកសត្វណាបានឃើញពួកសត្វដែលកំពុងតែសេពមេថុនធម្ម ពួកសត្វខ្លះក៏យកអាចម៍ដីបោះទៅ សត្វខ្លះយកផេះបាចដាក់ សត្វខ្លះ

យកអាចម៍គោបោះទៅ និយាយថា នែវសលិ (ជាពាក្យអាសគ្រាមសម្រាប់ជេរបញ្ចោរ) លាញទៅ នែវសលិលាញទៅ ហងលាញទៅ។ ចុះហេតុម្តេចបានជាសត្វហ៊ានធ្វើអំពើដល់សត្វយ៉ាងនេះ។ហេតុនោះក៏ដូចគ្នានឹងពួកមនុស្សក្នុងកាលឥឡូវនេះដែរ កាលបើស្រីក្នុងជនបទនីមួយមានគេចាប់នាំយកទៅ ពួកខ្លះក៏យកអាចម៍ដីបោះទៅ ពួកខ្លះក៏ទៅយកផេះបាចដាក់ ពួកខ្លះក៏យកអាចម៍គោបោះទៅ។ សត្វទាំងឡាយនាំគ្នានឹករកអក្សរដែលជាច្បាប់ចាស់នោះឯង ប៉ុន្តែមិនអាចនឹងយល់សេចក្តីនៃអក្សរនោះបានឡើយ។

ម្នាលវាសេដ្ឋៈ សម័យនោះឯង អំពើមានការបោះអាចម៍ដីជាដើមនោះ គេសន្មតថាមិនមែនធ៌ម តែអំពើនោះក្នុងកាលឥឡូវនេះគេត្រឡប់សន្មតថា ជាធម៌វិញ។ សម័យនោះ បើពួកសត្វណាសេពមេថុនធម្ម សត្វទាំងនោះមិនហ៊ានចូលមកកាន់ស្រុកឬនិគមអស់បីខែក៏មាន ពីរខែក៏មាន។ កាលណាបើពួកសត្វទាំងនោះដល់ស៊ប់នូវភាពជាអ្នកសេពចំពោះអសទ្ធម្មនោះហួសវេលាហើយ ក៏នាំគ្នាផ្តើមធ្វើផ្ទះដើម្បីបិទបាំងអសទ្ធម្មនោះឯង។

ម្នាលវាសេដ្ឋៈ គ្រានោះឯង មានសត្វម្នាក់ប្រកបដោយជាតិ ជាអ្នកខ្ជិលច្រអូសបានគិតថា យីអើ អាត្មាអញ កាលដែលនាំយកស្រូវសាលីក្នុងវេលាល្ងាច សម្រាប់បរិភោគក្នុងវេលាល្ងាច នាំយកស្រូវសាលីក្នុងវេលាព្រឹក សម្រាប់បរិភោគក្នុងវេលាព្រឹក ហៅពេញជាលំបាកខ្លួនអ្វីម្ល៉េះ ណ្ហើយចុះ អាត្មាអញគួរតែនាំយកស្រូវសាលីក្នុងវេលាល្ងាចតែម្តង ហើយទុកបរិភោគក្នុងវេលាព្រឹកផង។ សត្វនោះក៏ទៅយកស្រូវសាលីក្នុងវេលាល្ងាចតែម្តងប៉ុណ្ណោះ សម្រាប់បរិភោគក្នុងវេលាព្រឹកផង។ មានសត្វម្នាក់ចូលទៅរកសត្វនោះ បាននិយាយបបួលសត្វនោះថា នែសត្វដ៏ចម្រើន អ្នកចូរមក យើងនឹងទៅនាំយកស្រូវសាលីជាអាហារ។ សត្វនោះឆ្លើយថា នែសត្វដ៏ចម្រើន ណ្ហើយកុំ ខ្ញុំបាននាំយកស្រូវសាលីក្នុងវេលាល្ងាចតែម្តង ហើយទុកបរិភោគក្នុងវេលាព្រឹកផង។ ទើបសត្វនោះ បានយកតម្រាប់តាមសត្វម្នាក់ទៀត ក៏ទៅនាំយកស្រូវសាលីមកដោយ

គិតថា យីអើ ការដែលនាំយកស្រូវសាលីមកតែម្តងប៉ុណ្ណោះ សម្រាប់បរិភោគបានពីរថ្ងៃយ៉ាងនេះ ជាការស្រួលមែន។ មានសត្វម្នាក់ទៀតចូលទៅរកសត្វនោះបាន និយាយបបួលសត្វនោះទៅនាំយកស្រូវសាលីជាអាហារ។ សត្វនោះឆ្លើយថា ខ្ញុំបាននាំយកស្រូវសាលីក្នុងវេលាល្ងាចតែម្តង ហើយទុកបរិភោគវេលាព្រឹកផង។ ទើបសត្វនោះយកតម្រាប់តាម។បេ។ នាំយកស្រូវសាលីតែម្តង ហើយទុកបរិភោគបានបួនថ្ងៃ។បេ។ មានសត្វម្នាក់ទៀតយកតម្រាប់តាម។បេ។ ចាំយកស្រូវសាលីតែម្តង ហើយទុកបរិភោគបាន៨ថ្ងៃ។ លុះពួកសត្វទាំងនោះនាំគ្នាផ្តើមបរិភោគស្រូវសាលី ដែលខ្លួនសន្សំទុកក្នុងកាលឯណាហើយ កាលនោះឯងកន្ទក់ក៏រុំព័ទ្ធអង្ករ ទាំងអង្កាមក៏រុំព័ទ្ធអង្ករ សូម្បីកន្លែងដែលគេច្រូតហើយក៏លែងដុះឡើងវិញពេញដូចដើម ហើយស្រូវសាលីទាំងឡាយក៏ដុះមួយគុម្ពៗហាក់ដូចគេចងជាបាច់។

ម្នាលវាសេដ្ឋៈ គ្រានោះពួកសត្វទាំងនោះមកប្រជុំគ្នាត្អូញត្អែរថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន ឱហ្ន៎! ធម៌ដ៏លាមកទាំងឡាយបានកើតប្រាកដក្នុងពួកសត្វហើយ ព្រោះកាលពីដើម ពួកយើងជាអ្នកកើតដោយឈានចិត្ត មានបីតិជាអាហារ មានពន្លឺភ្លឺចេញឯងអំពីកាយ ត្រេចទៅក្នុងអាកាសបាន ស្ថិតនៅក្នុងទីដ៏ល្អ បានស្ថិតនៅអស់កាលយូរអង្វែង លុះកាលកន្លងយូរអង្វែងទៅ ផែនដីមានរស ក៏អណ្តែតដាសលើទឹកសម្រាប់ពួកយើង ឯផែនដីនោះមានសម្បុរល្អមានក្លិនក្រអូប មានរសផ្អែម ពួកយើងនាំគ្នាយកដៃកកាយផែនដីមានរសមកពូតជាពំនូត ហើយបរិភោគ កាលពួកយើងបរិភោគផែនដីមានរសនោះ ពន្លឺភ្លឺចេញឯងអំពីកាយក៏បាត់ទៅ ព្រះចន្ទនិងព្រះអាទិត្យកើតឡើង នក្ខត្តឫក្សមានរូបជាផ្កាយកើតឡើង យប់និងថ្ងៃកើតឡើង ខែមួយនិងកន្លះខែកើតឡើង រដូវនិងឆ្នាំកើតឡើង កាលពួកយើងបរិភោគផែនដីមានរសជាចំណីអាហារ ស្ថិតនៅអស់កាលយូរអង្វែង ស្រាប់តែផែនដីមានរសបាត់ទៅ ព្រោះហេតុនៃអកុសលធម៌ទាំងឡាយដ៏លាមកកើតដល់ពួកយើង លុះផែនដីមានរសបាត់ទៅហើយ

ក្រមរផែនដីមានសម្បុរល្អ មានក្លិនក្រអូប មានរសផ្អែមកើតឡើង ពួកយើងនាំគ្នាផ្ដើមបរិភោគក្រមរផែនដីនោះជាចំណីអាហារ ស្ថិតនៅអស់កាលយូរអង្វែង ស្រាប់តែក្រមរផែនដីនោះបាត់ទៅ ព្រោះហេតុនៃអកុសលធម៌ដ៏លាមកកើតដល់ពួកយើង លុះក្រមរផែនដីបាត់ទៅហើយ បទាលតាមានសម្បុរល្អ មានក្លិនក្រអូប មានរសផ្អែមកើតឡើង ពួកយើងនាំគ្នាផ្ដើមបរិភោគបទាលតាជាចំណីអាហារ ស្ថិតនៅអស់កាលយូរអង្វែង ស្រាប់តែបទាលតារនោះបាត់ទៅ ព្រោះហេតុនៃអកុសលធម៌ដ៏លាមកកើតដល់ពួកយើង លុះបទាលតានោះបាត់ទៅហើយ ទើបស្រូវសាលីឆ្អិនឯងឥតកន្ទក់ ឥតអង្កាម ជាស្រូវសស្អាត មានក្លិនក្រអូប មានផ្លែចេញមកជាអង្ករកើតឡើង ពួកយើងនាំយកស្រូវសាលី ត្រង់ទីណាក្នុងវេលាល្ងាច សម្រាប់បរិភោគក្នុងវេលាល្ងាច លុះព្រឹកឡើងក្នុងទីនោះក៏មានស្រូវសាលីដុះទ្រុបទ្រុលមានផ្លែទុំឡើងវិញ ពួកយើងនាំយកស្រូវសាលីត្រង់ទីណាមកក្នុងវេលាព្រឹក សម្រាប់បរិភោគក្នុងវេលាព្រឹក លុះវេលាល្ងាច ទីនោះក៏មានស្រូវសាលីដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញ ទីនោះប្រាកដហាក់ដូចជាមិនបានច្រូតឡើយ កាលពួកយើងបរិភោគស្រូវសាលីឆ្អិនឯង ជាចំណីអាហារស្ថិតនៅអស់កាលយូរអង្វែង ស្រាប់តែកន្ទក់រុំព័ទ្ធអង្ករ ទាំងអង្កាមក៏រុំព័ទ្ធអង្ករ សូម្បីទីដែលច្រូត ក៏មិនដុះឡើងវិញពេញដូចដើម ហើយស្រូវសាលីទាំងឡាយដុះមួយគុម្ពៗហាក់ដូចគេចងជាបាច់ ព្រោះហេតុនៃអកុសលធម៌ទាំងឡាយដ៏លាមកកើតដល់យើងបើដូច្នោះគួរតែយើងចែកស្រូវសាលីគ្នាគួរតែបោះព្រំខណ្ឌ។ សត្វទាំងឡាយក៏នាំគ្នាចែកស្រូវសាលី បោះព្រំខណ្ឌដោយខ្លួនៗ។

ម្នាលវាសេដ្ឋៈ គ្រានោះ មានសត្វម្នាល់ជាតិជាអ្នកឡេះឡោះលាក់សំចៃចំណែករបស់ខ្លួនទុក លួចយកចំណែករបស់អ្នកដទៃដែលគេមិនបានឲ្យមកបរិភោគ។ សត្វទាំងឡាយក៏ចាប់សត្វនោះបានហើយស្ដីឲ្យថា ឱសត្វអើយ ឯងធ្វើអំពើអាក្រក់ណាស់ មិនគួរបើឯងលាក់សំចៃចំណែករបស់ខ្លួនទុក លួចយកចំណែករបស់គេមកបរិភោគសោះ នែសត្វអើយ ឯងកុំធ្វើអំពើបែបនេះទៀត

ឡើយ។ សត្វនោះបានលួចយកចំណែករបស់គេជាគម្រប់ពីរដងផង។ ជាគម្រប់បីដងផង។ សត្វទាំងឡាយចាប់សត្វនោះបាន ហើយក៏ស្តីបន្ទោសហាមប្រាមដូចន័យខាងដើម។ ពួកសត្វខ្លះតប់ទះសត្វនោះនឹងដៃ ពួកសត្វខ្លះចោលនឹងដុំដី ពួកសត្វខ្លះវាយនឹងដំបង។

ម្នាលវាសេដ្ឋៈ ការលួចទ្រព្យក៏កើតប្រាកដឡើង ការតិះដៀលគ្នាក៏កើតប្រាដកឡើង ការនិយាយកុហកក៏កើតប្រាកដឡើង ការដាក់អាជ្ញា( ធ្វើទោស ) ក៏កើតប្រាកដឡើងតាំងពីកាលនោះជាដើមមក។ គ្រានោះ ពួកសត្វមកប្រជុំគ្នាហើយត្អូញត្អែរថា យីឱហ្ន៎! ធម៌ដ៏លាមកទាំងឡាយកើតប្រាកដដល់សត្វទាំងឡាយហើយព្រោះថាការលួចទ្រព្យគេក៏កើតប្រាកដឡើង។បេ។ការដាក់អាជ្ញាក៏កើតប្រាកដឡើង បើដូច្នោះ គួរតែពួកយើងសន្មតសត្វម្នាក់ឲ្យជាអ្នកបន្ទោសសត្វដែលគួរនឹងបន្ទោសតាមហេតុ ឲ្យតិះដៀលសត្វដែលគួរនឹងតិះដៀលតាមហេតុ ឲ្យបណ្តេញសត្វដែលគួរនឹង បណ្តេញតាមហេតុ ឲ្យដល់ពួកយើង ចំណែកខាងពួកយើង ត្រូវជូនចំណែកស្រូវសាលីទាំងឡាយឲ្យដល់សត្វនោះ។ ទើបពួកសត្វទាំងនោះ នាំគ្នាចូលទៅរកសត្វដែលជាអ្នកមានរូបល្អ គួររមិលមើលគួរជ្រះថ្លា មានសក្តិធំ ( អដ្ឋកថាថា គឺព្រះបរមពោធិសត្វនៃយើង ) ជាងពួកសត្វទាំងនោះ លុះចូលទៅដល់ហើយបាននិយាយថា បពិត្រសត្វដ៏ចម្រើន អ្នកចូរមកបន្ទោលសត្វដែលគួរបន្ទោសតាមហេតុ ចូរតិះដៀលសត្វដែលគួរតិះដៀលតាមហេតុ ចូរបណ្តេញសត្វដែលគួរបណ្តេញតាមហេតុចុះ ពួកយើងនឹងជូនចំណែកស្រូវសាលីទាំងឡាយដល់អ្នក។ សត្វនោះក៏ទទួលយល់ព្រមធ្វើតាមពាក្យរបស់សត្វទាំងនោះ។ ទើបអក្ខរៈ (អដ្ឋកថាថា បានដល់ពាក្យសម្រាប់កំណត់ សម្រាប់ចេញឈ្មោះ សម្រាប់បញ្ញត្តិ សម្រាប់និយាយ )ជាដំបូងកើតឡើងថា មហាសម្មតៈដូច្នេះ។ សត្វនោះជាអធិបតីនៃស្រែទាំងឡាយ ព្រោះហេតុនោះ ទើបអក្ខរៈទី២កើតឡើងថា ខត្តិយៈដូច្នេះ។ សត្វនោះ ញុំាងសត្វទាំងឡាយដទៃឲ្យពេញចិត្តដោយធម៌ ព្រោះហេតុនោះ ទើបអក្ខរៈទី៣ កើត

ឡើងថារាជាដូច្នេះ។ ហេតុដូច្នេះ អក្ខរៈដែលជាច្បាប់ចាស់បានកើតឡើងដល់ខត្តិយមណ្ឌលនោះយ៉ាងនេះ។ ការកើតនៃអក្ខរៈដល់ពួកសត្វទាំងនោះ ដូចគ្នានឹងសត្វទាំងឡាយដទៃដែរ មិនមែនខុសគ្នាទេ កើតឡើងតែដោយធម៌ប៉ុណ្ណោះឯង មិនមែនដោយខុសធម៌ទេ។ ព្រោះធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជនទាំងបច្ចុប្បន្ន ទាំងបរលោក។

បណ្តាសត្វទាំងនោះ សត្វពួកខ្លះគិតគ្នាថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ធម៌ដ៏លាមកទាំងឡាយកើតប្រាកដដល់ពួកសត្វហើយ ព្រោះការលួចទ្រព្យគេ ពាក្យតិះដៀលគ្នា ការនិយាយកុហក ការដាក់អាជ្ញា ការបណ្តេញ ក៏កើតមានប្រាកដឡើង បើដូច្នេះ ពួកយើងគួរតែបន្សាត់នូវធម៌ជាអកុសលដ៏លាមកទាំងឡាយចេញ។ ពួកសត្វទាំងនោះ ក៏បានបន្សាត់នូវធម៌ជាអកុសលដ៏លាមកចេញ ព្រោះហេតុនោះ ទើបអក្ខរៈទី១កើតឡើងថា ព្រាហ្មណៈដូច្នេះ។ សត្វទាំងនោះបានធ្វើជំរំស្លឹកក្នុងព្រៃរំលោង ហើយសម្លឹងអារម្មណ៍ក្នុងជំរំប្រក់ស្លឹកទាំងឡាយ។ ពួកសត្វទាំងនោះឥតភ្លើងផ្សែងទេ ឥតអង្រែទេ ត្រាច់ទៅកាន់ស្រុកនិគមនិងរាជធានី ស្វែងរកអាហារក្នុងវេលាល្ងាចសម្រាប់បរិភោគក្នុងវេលាល្ងាច ស្វែងរកវេលាព្រឹកសម្រាប់បរិភោគក្នុងវេលាព្រឹក។ ពួកសត្វទាំងនោះ លុះបានអហារហើយ ក៏នៅសម្លឹងអារម្មណ៍ក្នុងជំរំស្លឹកទាំងឡាយក្នុងព្រៃរំលោងទៀត។ មនុស្សទាំងឡាយ លុះបានឃើញសត្វទាំងនោះហើយ ក៏និយាយគ្នាថា នែគ្នាយើងអើយ ពួកសត្វទាំងនេះធ្វើជំរំស្លឹកក្នុងព្រៃរំលោង ហើយនៅសម្លឹងអារម្មណ៍ក្នុងជំរំស្លឹក ជាសត្វឥតភ្លើងផ្សែង ឥតអង្រែ តែងត្រាច់ទៅកាន់ស្រុកនិគមនិងរាជធានី ស្វែងរកអាហារក្នុងវេលាល្ងាច សម្រាប់វេលាល្ងាចស្វែងរកក្នុងវេលាព្រឹកសម្រាប់បរិភោគក្នុងវេលាព្រឹក។ពួកសត្វទាំងឡាយនោះ លុះបានអាហារហើយក៏សម្លឹងអារម្មណ៍ក្នុងជំរំស្លឹកក្នុងព្រៃរំលោងទៀត។ ព្រោះហេតុនោះ ទើបអក្ខរៈទី២កើតឡើងថា ឈាយិកា(អ្នកសម្លឹងអារម្មណ៍)។ បណ្តាសត្វទាំងនោះ សត្វពួកខ្លះកាលមិនអាចនឹងសម្លឹងអារម្មណ៍ក្នុងជំរំស្លឹក

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY

ក្នុងព្រៃរំលោងបាន ក៏ចូលទៅកាន់ស្រុកជិត និគមជិត តាក់តែងបង្រៀននូវគន្ថៈ គឺវេទមន្តរួចត្រឡប់មកវិញ។ ពួកមនុស្សលុះបានឃើញសត្វទាំងនោះហើយ និយាយគ្នាថា ម្នាលគ្នាយើងអើយ ពួកសត្វទាំងនេះមិនអាចនឹងសំឡឹងអារម្មណ៍។បេ។ រួចត្រឡប់មកវិញ។ ព្រោះហេតុនោះ ទើបអក្ខរៈទី៣កើតឡើងថា **អជ្ឈាយិកា** (អ្នកមិនសម្លឹងអារម្មណ៍)។ ក្នុងសម័យនោះ ការទ្រទ្រង់និងការបង្រៀននូវមន្ត គេសន្មតថា ជាការថោកទាបទេ តែក្នុងកាលឥឡូវនេះការទ្រទ្រង់និងការបង្រៀននូវមន្តនោះ គេសន្មតថា ជាការប្រសើរវិញ។ ហេតុដូច្នេះ អក្ខរៈដែលជាច្បាប់ចាស់ បានកើតឡើងដល់ព្រាហ្មណមណ្ឌលនោះយ៉ាងនេះ។ ការកើតនៃអក្ខរៈដល់ពួកសត្វទាំងនោះ ដូចគ្នានឹងសត្វទាំងឡាយដទៃដែរមិនមែនខុសគ្នាទេ កើតឡើងដោយធម៌តែម្យ៉ាងប៉ុណ្ណោះ មិនមែនដោយខុសធម៌ទេ។ ព្រោះធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជន ទាំងបច្ចុប្បន្ន ទាំងបរលោក។

ម្នាលវាសេដ្ឋៈ បណ្តាសត្វទាំងនោះ សត្វពួកខ្លះប្រព្រឹត្តមេថុនធម្មហើយប្រកបការងារផ្សេងៗគ្នា។ ព្រោះហេតុនោះ អក្ខរៈទើបកើតឡើងថា វេស្សៈដូច្នេះ។ ការកើតអក្ខរៈជាច្បាប់ចាស់ក៏មានឡើងដល់វេស្សមណ្ឌលនុ៎ះយ៉ាងនេះ។ សេចក្តីសង្ខេប

ម្នាលវាសេដ្ឋៈ អក្ខរៈជាច្បាប់ចាស់បានកើតឡើងដល់សុទ្ទមណ្ឌលនោះយ៉ាងនេះ ការកើតអក្ខរៈដល់ពួកសត្វទាំងនោះ ដូចគ្នានឹងសត្វទាំងឡាយដទៃដែរ។បេ។ ព្រោះធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជន ទាំងបច្ចុប្បន្ន ទាំងបរលោក។

ម្នាលវាសេដ្ឋៈ មានសម័យដែលខត្តិយខ្លះតិះដៀលធម៌របស់ខ្លួនហើយចេញចាកផ្ទះចូលមកបួសដោយបំណងថា អាត្មាអញនឹងធ្វើជាសមណៈដូច្នេះក៏មាន។ ព្រាហ្មណ៍ខ្លះ។ បេ។ វេស្សៈខ្លះ។បេ។ សុទ្ទៈខ្លះ។បេ។

ម្នាលវាសេដ្ឋៈ ការកើតឡើងនៃសមណមណ្ឌល ក៏មានឡើងដោយសារមណ្ឌលទាំង៤នេះឯង ការកើតឡើងនៃសមណមណ្ឌលដល់សត្វទាំងនោះ

ដូចគ្នានឹងសត្វទាំងឡាយដទៃដែរ។បេ។ ព្រោះធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជន ទាំងបច្ចុប្បន្ន ទាំងបរលោក។

ម្នាលវាសេដ្ឋៈ មានខត្តិយៈខ្លះប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវកម្មជាមិច្ឆាទិដ្ឋិ លុះស្លាប់ទៅកើតក្នុងកំណើតសត្វតិរច្ឆាន ប្រេតវិស័យ អសុរ កាយ នរក។ មានព្រាហ្មណ៍ខ្លះ។បេ។ មានវេស្សៈខ្លះ។បេ។ មានសុទ្ទៈខ្លះ។បេ។ មានសមណៈខ្លះប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត។បេ។ អសុរកាយ នរក។

ម្នាលវាសេដ្ឋៈមានខត្តិយៈខ្លះប្រព្រឹត្តល្អដោយកាយវាចាចិត្តជាសម្មាទិដ្ឋិ ប្រកាន់នូវកម្មជាសម្មាទិដ្ឋិ លុះស្លាប់ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ មានព្រាហ្មណ៍ខ្លះ។បេ។ មានវេស្សៈខ្លះ។បេ។ មានសុទ្ទៈខ្លះ។បេ។ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក។

ម្នាលវាសេដ្ឋៈ មានខត្តិយៈខ្លះជាអ្នកធ្វើអំពើទាំងពីរ គឺជួនកាលធ្វើអំពើអាក្រក់ ជួនកាលធ្វើអំពើល្អដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត មានទិដ្ឋិប្រទ្បំគ្នាផ្សេងៗ ប្រកាន់នូវកម្មដែលប្រទ្បំគ្នាផ្សេងៗ លុះស្លាប់ក៏បានទទួលសុខខ្លះ ទុក្ខខ្លះ។ មានព្រាហ្មណ៍ខ្លះ។បេ។ មានវេស្សៈខ្លះ។បេ។ មានសុទ្ទៈខ្លះ។បេ។ លុះស្លាប់ក៏បានទទួលសុខខ្លះ ទុក្ខខ្លះ។

ម្នាលវាសេដ្ឋៈ មានខត្តិយៈខ្លះ ជាអ្នកសង្រួមដោយកាយវាចាចិត្ត អាស្រ័យនូវការចម្រើនពោធិបក្ខិយធម៌៧ កង (ពោធិបក្ខិយធម៌ ៧កង រាប់យកសតិបដ្ឋាន៤ ជាកង១រហូតដល់អដ្ឋង្គិកមគ្គ ជាកងទីបំផុត) ក៏បរិនិព្វានក្នុងបច្ចុប្បន្ននេះ។ មានព្រាហ្មណ៍ខ្លះ។បេ។ មានវេស្សៈខ្លះ។បេ។ មានសុទ្ទៈខ្លះ។ បេ។

ម្នាលវាសេដ្ឋៈ បណ្តាវណ្ណៈទាំង៤នេះ វណ្ណៈណាជាភិក្ខុ ជាអរហន្ត ជាខីណាស្រព ប្រព្រឹត្តព្រហ្មចារ្យចស្រេចហើយ បានធ្វើសោទ្បសកិច្ចស្រេចហើយ មានភារៈដាក់ចុះហើយ បានសម្រេចប្រយោជន៍របស់ខ្លួនដោយលំដាប់ ហើយមានតណ្ហាជាគ្រឿងចងក្នុងភពអស់រលីង ហើយមានចិត្តផុតស្រឡះហើយ

ព្រោះបានត្រាស់ដឹងដោយប្រពៃ អ្នកនោះប្រាកដថា ជាបុគ្គលប្រសើរលើសជាងវណ្ណៈទាំង៤ នោះ តាមធម៌ពិត មិនមែនតាមអធម៌ទេ។ ព្រោះធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជន ទាំងបច្ចុប្បន្ន ទាំងបរលោក។ សូម្បីព្រហ្មឈ្មោះសនង្កុមារ ក៏បានពោលគាថាទុកថា

**ខត្តិយោ សេដ្ឋោ ជនេតស្មឹ យេ គោត្តប្បដិសារិនោ**
**វិជ្ជាចរណសម្បន្នោ សោ សេដ្ឋោ ទេវមានុសេតិ។**

ខត្តិយៈ ជាជាតិប្រសើរបំផុតក្នុងប្រជុំជន ជាអ្នកដែលរឭកដល់គោត្រ អ្នកដែលបរិបូណ៌ដោយវិជ្ជានិងចរណៈប្រសើរបំផុតក្នុងពួកទេវតានិងមនុស្ស។

ម្នាលវាសេដ្ឋៈ ឯគាថានេះឯង ព្រហ្មឈ្មោះសនង្កុមារបានពោលពីរោះហើយ មិនមែនពោលមិនពីរោះទេ បានសម្តែងល្អហើយ មិនមែនសម្តែងមិនល្អទេ ជាគាថាប្រកបដោយប្រយោជន៍ មិនមែនមិនប្រកបដោយប្រយោជន៍ឡើយ តថាគតក៏យល់ព្រមតាមដែរ។ ចំណែកតថាគតក៏បានពោលគាថាដូចគ្នានឹងគាថារបស់នង្កុមារព្រហ្មនោះរួចហើយដែរ។

លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងសូត្រនេះចប់ហើយ វាសេដ្ឋសាមណេរ និងភារទ្វាជសាមណេរ ក៏មានចិត្តត្រេកអររីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ។

# ឧត្តមគតិនៃព្រះពោធិសត្វ

(ដោយបង្ហាញក្នុងទសជាតករួមទាំងការបំពេញបារមីធម៌)

១- កាលសោយព្រះជាតិជា **តេមិយៈ** (ដីម៉ែ) ព្រះអង្គទ្រង់បម្រើមនុស្សខាងសន្តិធម៌ គឺក្នុងសម័យនោះមនុស្សក្នុងស្រុកក្នុងនគរមានវិបត្តិខាងផ្លូវសន្តិធម៌យ៉ាងខ្លាំង។ ចំណែកព្រះពោធិសត្វ សីម្បីខ្លួនព្រះអង្គជាអនាគតក្សត្រគ្រងផែនដី ក៏ព្រះអង្គលះបង់ប្រយោជន៍ផ្ទាល់ខ្លួននេះ ចេញបួសជាតាបសដើម្បីដឹកនាំមនុស្សឲ្យមានសន្តិធម៌ ដោយន័យថា ព្រះអង្គមិនសប្បាយព្រះទ័យនឹងសេចក្តីហ៊ឹហាប្រាសចាកសន្តិធម៌។

២- **ព្រះជនក** (ជីនក់) ទ្រង់បម្រើមនុស្សដោយសេចក្តីព្យាយាម គឺក្នុងសម័យដែលនគររបស់ព្រះអង្គ ជនរួមជាតិមិនសូវយកចិត្តទុកដាក់ធ្វើកសិកម្ម ពាណិជ្ជកម្ម បសុកម្ម។ល។ ដើម្បីលើកតម្កើងឋានៈជីវភាពរបស់ខ្លួន។ ព្រះអង្គទ្រង់ញ៉ាំងសេចក្តីព្យាយាមឲ្យមានកម្លាំងដល់កម្រិតជាន់ខ្ពស់ ទ្រង់ពុះពារតស៊ូធ្វើការទាំងអស់ ដើម្បីបម្រើគេផង ដើម្បីជាគំរូដល់គេផង។ នាវិក (អ្នកដើរទូក) របស់ព្រះអង្គស្លាប់អស់គ្មានសល់ ហើយព្រះអង្គខំបម្រើអ្នកដទៃលុះត្រាទីបំផុតនៃជីវិត ដោយន័យថា ព្រះអង្គស្អប់ខ្ពើមសេចក្តីខ្ជិល។

៣- **ព្រះសុវណ្ណសាម** កំណើតព្រះអង្គទ្រង់បម្រើមនុស្សដោយមេត្តាធម៌ជាពិសេសគឺបម្រើមាតាបិតារបស់ព្រះអង្គ ដែលមានភ្នែកខ្វាក់ទាំងពីរនាក់។ ការបម្រើនេះ បានជាគុណធម៌ទាក់ទាញទឹកចិត្តមនុស្សសត្វឲ្យមានសេចក្តីអាណិតអាសូរព្រះអង្គយ៉ាងខ្លាំង ដោយន័យថា ព្រះអង្គមិនចូលចិត្តអមេត្តាធម៌។

៤- **ព្រះនេមិរាជ** ព្រះអង្គទ្រង់បម្រើខ្លួន និងមនុស្សទាំងឡាយដោយអធិដ្ឋានធម៌ គឺកំណត់យកនូវមុខការមួយៗយ៉ាងទៀតទាត់ ដោយន័យថា ទ្រង់មិនរវើរវាយចំពោះមុខការដែលនឹងត្រូវធ្វើ។

៥- **ព្រះមហោសថ** ទ្រង់បម្រើមនុស្សដោយបញ្ញា តាមផ្លូវបង្ហាត់បង្រៀន នៅក្នុងរឿងនេះ ថ្ងៃក្រោយមកព្រះអង្គទ្រង់បានទទួលតំណែងជាទីប្រឹក្សានៃព្រះរាជាទ្រង់ ព្រះនាមវិទេហៈ និងបានទទួលតំណែងជាអាចារ្យនៃប្រជាជាតិក្នុងនគរនោះ។

៦- **ព្រះភូរិទត្ត** ព្រះអង្គទ្រង់បម្រើខ្លួននិងមនុស្សទាំងឡាយដោយសីលធម៌ ដោយន័យថា ព្រះអង្គទ្រង់រស់នៅក្នុងច្បាប់ ក្នុងវិន័យ ហើយដឹកនាំមនុស្សទាំងឡាយដទៃឲ្យរស់នៅក្នុងជាតុនេះ ដូចព្រះអង្គផង។

៧- **ព្រះចន្ទកុមារ** ព្រះអង្គទ្រង់បម្រើខ្លួននិងបម្រើអ្នកដទៃដោយខន្តីធម៌ ដោយន័យថា ព្រះអង្គរស់នៅក្នុងភាពអត់ធន់ មិនមានចិត្តឆ្គោរក្រមាល់ (ចិត្តធំ ចិត្តទ្រស?) ចំពោះអ្នកដទៃ ព្រះអង្គទ្រង់ប្រើធម៌នេះជាមធ្យោបាយសម្រាប់ជីវិតតស៊ូទាំងខ្លួនព្រះអង្គ ទាំងខ្លួនអ្នកទាំងឡាយដទៃ។

៨- **ព្រះនារទៈ** ព្រះអង្គទ្រង់បម្រើមនុស្សដោយឧបេក្ខាធម៌ គឺទ្រង់រស់នៅក្នុងឧបេក្ខាធម៌ បានដល់ការរស់នៅក្នុងគំនិតមើលឃើញខ្ពស់ហួសជាតិសាសន៍ វណ្ណៈ ពណ៌សម្បុរ យសសក្តិ ត្រកូល គោត្រ អំបូរ... ដោយន័យថា ព្រះអង្គទ្រង់រស់នៅជាមួយនឹងមនុស្សទាំងឡាយ ទាំងជាមិត្ត ទាំងជាសត្រូវ។

៩- **ព្រះវិធុរៈ** ព្រះអង្គទ្រង់បម្រើមនុស្សដោយសច្ចធម៌ គឺទ្រង់រស់នៅក្នុងសច្ចធម៌ បានដល់ការរស់នៅក្នុងសភាវៈពិតរបស់មនុស្ស របស់ធម្មជាតិ។ រាល់ទង្វើទាំងអស់ ទ្រង់ធ្វើតាមសេចក្តីពិត ដោយន័យថា ទ្រង់ធ្វើការគ្រប់យ៉ាងនៅក្នុងសេចក្តីពិត ទាំងផ្លូវកាយ ទាំងផ្លូវសម្តី ទាំងផ្លូវគំនិត។

១០- **ព្រះវេស្សន្តរ** ព្រះអង្គទ្រង់បម្រើមនុស្សដោយទ្រព្យសម្បត្តិ។ ក្នុងជាតិនេះ ព្រះអង្គទ្រង់បានដាក់ទានគ្រប់មុខទាំងអស់ដល់មនុស្សទ័លក្ររហូតដល់ឲ្យទានបុត្រធីតា និងភរិយាជាទីបំផុត។

**<u>សេចក្តីបញ្ជាក់:</u> ក្នុងបារមីទាំង១០របស់ព្រះពោធិសត្វ**

ដំណើរជីវិតរបស់ព្រះពោធិសត្វ គឺមិនពេញព្រះទ័យនឹង សេចក្តី

សប្បាយតាមផ្លូវកាមគុណដែលជាហេតុនាំឲ្យកើតទុក្ខដល់ខ្លួន ទើបចេញបួសសាង «**នេក្ខម្មបារមី**»។ មិនពេញព្រះទ័យនឹងភាពខ្ជិលច្រអូស ទើបតាំងសេចក្តីព្យាយាមធ្វើការងារ ប្រាសចាកទោសហៅថាសាង «**វិរិយបារមី**»។ មិនពេញព្រះទ័យនឹងធម៌ហិង្សា ទើបសាងមេត្តាធម៌ក្នុងព្រះទ័យ ហៅថាសាង «**មេត្តាបារមី**»។ មិនពេញព្រះទ័យនឹងភាពរវើរវាយ ទើបបង្កើតឲ្យមានអធិដ្ឋានធម៌ក្នុងព្រះទ័យ ហៅថាសាង «**អធិដ្ឋានបារមី**»។ មិនពេញព្រះទ័យនឹងភាពល្ងង់ខ្លៅ ទើបស្វែងរកបញ្ញា ហៅថាសាង «**បញ្ញាបារមី**»។ មិនពេញព្រះទ័យនឹងទ្រុស្តសីល ទើបធ្វើខ្លួនឲ្យមានសីល ហៅថាសាង «**សីលបារមី**»។ មិនពេញព្រះទ័យនឹងកំហឹង ទើបធ្វើចិត្តឲ្យមានអំណត់ ហៅថាសាង «**ខន្តីបារមី**»។ មិនពេញព្រះទ័យនឹងអគតិធម៌ ទើបដឹកនាំជីវិតឲ្យរស់នៅក្នុង គតិធម៌ ហៅថាសាង «**ឧបេក្ខាបារមី**»។ មិនពេញព្រះទ័យនឹងភាពមិនពិត ទើបញ៉ាំងជីវិតរបស់ខ្លួននិងអ្នកដទៃឲ្យរស់នៅក្នុងភាពពិត ហៅថាសាង «**សច្ចបារមី**»។ មិនពេញព្រះទ័យនឹងភាពកំណាញ់លោភលន់ ទើបរំដោះចិត្តឲ្យរួចចាកភាពនេះ ហៅថាសាង «**ទានបារមី**»។

# របៀបរស់នៅក្នុងសង្គមតាមទស្សនៈពុទ្ធសាសនា
## ស្ដីពី ការបែងចែកតួនាទី និងកាតព្វកិច្ចបុគ្គល

**ជាដំបូង អ្នករស់នៅក្នុងសង្គមត្រូវវៀរចាកអំពើអាក្រក់៤យ៉ាងគឺ**

១-បៀតបៀនគ្នា

២-លួចទ្រព្យសម្បត្តិគ្នា

៣-ក្បត់សេចក្ដីស្នេហាគ្នា

៤-ពោលពាក្យកុហក។

**វៀរចាកការប្រព្រឹត្តធម៌ ឬ ច្បាប់ប្រកបដោយអគតិ៤យ៉ាងគឺ**

១-លម្អៀងព្រោះមានចិត្តស្រឡាញ់

២-លំអៀងព្រោះមានចិត្តស្អប់

៣-លម្អៀងព្រោះមានសេចក្ដីល្ងង់

៤-លម្អៀងព្រោះមានសេចក្ដីខ្លាច។

**វៀរចាកអំពើដែលធ្វើឲ្យខ្លួនថោកទាប បង់ទ្រព្យសម្បត្តិ៦យ៉ាងគឺ**

១-ផឹកទឹកស្រវឹងនិងសេពគ្រឿងញៀន

២-ដើរលេងយប់

៣-ដើរមើលល្បែង

៤-លេងល្បែងភ្នាល់

៥-សេពគប់មិត្តអាក្រក់

៦-ខ្ជិលធ្វើការងារ។

**បុត្រធីតាគប្បីប្រតិបត្តិមាតាបិតាដោយករណីយកិច្ច៥យ៉ាងគឺ**

១-ចិញ្ចឹមថែទាំរក្សា

២-បម្រើដោយធ្វើកិច្ចការជំនួស

៣-រក្សាវង្សត្រកូលរបស់លោកឲ្យល្អ

៤-ទុកដាក់ខ្លួនឲ្យជាមនុស្សល្អ
៥-ក្រោយអំពីអនិច្ចកម្មរបស់លោក ធ្វើទក្ខិណានុប្បទានជូនផល។

**មាតាបិតាគប្បីអនុគ្រោះកូនដោយករណីយកិច្ច៥យ៉ាងគឺ**

១-ហាមមិនឲ្យធ្វើកម្មអាក្រក់
២-ដឹកនាំឲ្យធ្វើកម្មល្អ
៣-ទំនុកបម្រុងឲ្យសិក្សាវិជ្ជានានា
៤-រកស្វាមីភរិយាឲ្យតាមការគួរ
៥-ប្រគល់មត៌កឲ្យក្នុងពេលដ៏គួរ។

**គ្រូអាចារ្យអនុគ្រោះសិស្សដោយករណីយកិច្ច៥យ៉ាងគឺ**

១-អប់រំល្អ
២-បង្រៀនល្អ
៣-បង្រៀនឲ្យអស់ជើងមិនលាក់វិជ្ជា
៤-លើកតម្កើងសិស្សឲ្យប្រាកដច្បាស់លាស់ក្នុងទីប្រជុំ
៥-ការពារសិស្ស និង ធ្វើឲ្យសិស្សស្រឡាញ់រាប់អានគ្នា។

**សិស្សគប្បីប្រតិបត្តិគ្រូអចារ្យដោយករណីយកិច្ច៥យ៉ាគឺ**

១-ដោយការក្រោកទទួល
២-ដោយចូលទៅជិតដើម្បីបម្រើ
៣-ដោយយកចិត្តទុកដាក់ស្តាប់ឱវាទ
៤-ដោយទំនុកបម្រុងផ្គងផ្គើម
៥-ដោយគោរពស្មោះក្នុងពេលរៀន។

**បុរសជាស្វាមីគប្បីប្រតិបត្តិភរិយារបស់ខ្លួនដោយករណីយកិច្ច៥យ៉ាងគឺ**

១-ដោយរាប់អានលើកតម្កើងថាជាភរិយាពិតៗ
២-ដោយមិនប្រមាថមើលងាយ
៣-ដោយមិនប្រព្រឹត្តក្បត់ចិត្តស្នេហា ( មានស្រ្តីដទៃទៀត )

៤-ដោយប្រគល់ឥស្សរភាពឲ្យក្នុងគ្រួសារ

៥-ដោយឲ្យគ្រឿងសម្អាង និងគ្រឿងតែងកាយយ៉ាងសមរម្យ។

**ស្ត្រីជាភរិយាគប្បីប្រតិបត្តិស្វាមីរបស់ខ្លួនដោយករណីយកិច្ច៥យ៉ាងគឺ**

១-ចាត់ចែងការងារផ្ទះល្អ

២-សង្គ្រោះញាតិមិត្តខាងស្វាមីល្អ

៣-មិនប្រព្រឹត្តក្បត់ចិត្តស្នេហារបស់ស្វាមី (មិនមានបុរសដទៃទៀត)

៤-រក្សាទ្រព្យសម្បត្តិដែលស្វាមីរកបានមកឲ្យគង់

៥-ឧស្សាហ៍សង្វាតក្នុងមុខការទាំងឡាយ។

**កូននៃត្រកូលទាំងឡាយគប្បីទំនុកបម្រុងមិត្តភក្តិរបស់ខ្លួនដោយករណីយកិច្ច៤យ៉ាងគឺ**

១-ដោយចែកប្រយោជន៍ឲ្យ

២-ដោយនិយាយពាក្យពីរោះ

៣-ដោយប្រព្រឹត្តខ្លួនឲ្យជាបុគ្គលមានស្មើៗ គ្មានធំគ្មានតូចគ្រប់ពេលវេលា

៤-ដោយមិនពោលពាក្យឲ្យខុសអំពីសេចក្តីពិត។

**បុគ្គលជាមិត្តគប្បីទំនុកបម្រុងកូននៃត្រកូលទាំងឡាយដោយករណីយកិច្ច៥យ៉ាងគឺ**

១-រក្សាខ្លួនរបស់មិត្តដែលជាអ្នកមានសេចក្តីប្រមាទហើយ ឲ្យផុតចាកគ្រោះថ្នាក់

២-រក្សាទ្រព្យសម្បត្តិរបស់មិត្តដែលទុកមិនប្រយ័ត្ន មិនឲ្យបាត់បង់

៣-ពេលណាមិត្តមានអាសន្ន យកខ្លួនទៅជួយការពារ

៤-មិនលះបង់ចោលគ្នាក្នុងគ្រាមានវិបត្តិ

៥-រាប់អានគ្នារហូតដល់វង្សញាតិរបស់មិត្ត។

**បុគ្គលជានាយកគប្បីទំនុកបម្រុងកម្មកររបស់ខ្លួនដោយករណីយកិច្ច ៥យ៉ាងគឺ**

១-ចាត់ចែងការងារឲ្យធ្វើតាមសមគួរដល់កម្លាំងកាយនិងសមត្ថភាពនៃខ្លួក្បាល

២-ឲ្យអាហារនិងតម្លៃឈ្នួល( ប្រាក់ខែ )ឲ្យបានជួនល្មមដល់សាច់ការដែលធ្វើ

៣-រក្សាការពារយ៉ាងជិតដល់ក្នុងពេលមានជំងឺ

៤-ឲ្យរង្វាន់ជាពិសេសក្នុងលក្ខណៈពិសេសម្តងៗ ដែលយល់ឃើញថាគួរឲ្យ

៥-អនុញ្ញាតឲ្យឈប់ធ្វើការពេលដែលយល់ឃើញថាគួរឲ្យឈប់សម្រាក (បុណ្យជាតិ-សាសនា) ។

**បុគ្គលជាកម្មករគប្បីប្រតិបត្តិនាយកដោយករណីយកិច្ច៥ យ៉ាងគឺ**

១-ក្រោកឡើងធ្វើការមុនចៅហ្វាយនាយ

២-ទទួលទានដំណេកក្រោយចៅហ្វាយនាយ

៣-កាន់យកតែរបស់ណាដែលចៅហ្វាយនាយបានឲ្យ

៤-ធ្វើការដោយយកចិត្តទុកដាក់ប្រឹងប្រែងខ្នះខ្នែង

៥-ជួយគាំទ្រនូវកេរ្តិ៍ឈ្មោះ និង គុណសម្បត្តិល្អរបស់ចៅហ្វាយនាយ ។

**កូននៃត្រកូលជាគ្រហស្ថទាំងឡាយគប្បីប្រតិបត្តិសមណព្រាហ្មណ៍៦ ដោយករណីយកិច្ច៥ យ៉ាងគឺ**

១-គោរពដោយកាយកម្ម

២-គោរពដោយវចីកម្ម

៣-គោរពដោយមនោកម្ម

៤-គោរពដោយបើកចំហនូវទ្វារផ្ទះ គឺឲ្យចេញចូលតាមពេលដ៏សមគួរ

៥-គោរពដោយសេចក្តីសង្គ្រោះខាងបច្ច័យ៤។

សមណព្រាហ្មណ៍គប្បីទំនុកបម្រុងកុលបុត្រជាគ្រហស្ថដោយករណីយកិច្ច៦យ៉ាងគឺ

១-ការពារមិនឲ្យធ្វើសេចក្តីអាក្រក់

២-ឲ្យតម្កល់ខ្លួននៅក្នុងសេចក្តីល្អ

៣-អនុគ្រោះស្រោចស្រង់ដោយទឹកចិត្តល្អ

៤-ឲ្យបានស្តាប់ធម៌ ដែលមិនធ្លាប់បានស្តាប់

៥-ធ្វើសេចក្តីបំភ្លឺធម៌ដែលធ្លាប់បានស្តាប់ហើយឲ្យកាន់តែចូលចិត្តច្បាស់លាស់ឡើង

៦-ប្រាប់ផ្លូវសម្រាប់ដើរទៅកាន់សេចក្តីសុខចម្រើន។

# ប្រយោជន៍នៃព្រះពុទ្ធសាសនា

សាសនាទាំងអស់ក្នុងសកលលោក សុទ្ធតែមានបញ្ញត្តិ មានទ្រឹស្តី មានអត្ថបទ សម្រាប់ពន្យល់ដឹកនាំប្រៀនប្រដៅមនុស្សដើម្បីប្រយោជន៍ គ្រាន់តែមនុស្សជឿជាប់ចិត្ត បាក់ផ្ទត់ ទៅជាទំនៀមទម្លាប់ដោយឥតហេតុផលក៏មានប្រដៅមនុស្សឲ្យមានសីលធម៌ក៏មាន ប៉ុន្តែក្នុងទីនេះ យើងអ្នករៀបរៀងមិនមានបំណងអធិប្បាយអំពីប្រយោជន៍របស់សាសនាដទៃទេ សូមបង្ហាញតែប្រយោជន៍នៃព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជាយើងប៉ុណ្ណោះ ដូចមានសេចក្តីតទៅនេះ ៖

**វិជ្ជាពុទ្ធសាសនា** ជាវិជ្ជាដែលមានគុណភាព មានតម្លៃ គួរអ្នកសិក្សាចំណាយពេលវេលា ដើម្បីសិក្សាគម្ពីរព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋខ្មែរយើងឲ្យយល់ពីគោលបំណងរបស់ព្រះពុទ្ធ នឹងលោកអ្នកប្រាជ្ញក្នុងសម័យជាន់មុនផង ដើម្បីស្គាល់ច្បាស់នូវប្រយោជន៍របស់សាសនាក្នុងបច្ចុប្បន្ននិងបរលោកផង ព្រោះសាសនាទាំងអស់សុទ្ធតែមានទ្រឹស្តីសម្រាប់ប្រៀន-ប្រដៅមនុស្ស ឲ្យចុះចូលជឿតាមឱវាទរបស់គ្រូអ្នកប្រៀនប្រដៅ។ សាសនាខ្លះមានប្រយោជន៍ច្រើន សាសនាខ្លះពុំសូវមានប្រយោជន៍ ប៉ុន្តែទុកជាយ៉ាងណាក៏ដោយ យើងគួរតែសិក្សាឲ្យស្គាល់មូលហេតុនៃសាសនានោះ។ ដើម្បីជាគ្រឿងស្ទាបស្ទង់ប្តូរយោបល់អំពីសាសនា សម្រាប់លាតត្រដាង ទុកជាមេគំនិតក្នុងការពិចារណាមើលឲ្យកើតសតិបញ្ញាបរិបូណ៌ សម្រាប់ឋានៈនៃខ្លួនយើងជាអ្នកសិក្សា។ យើងអ្នកសិក្សា ដោយសារអានទ្រឹស្តីសាសនាច្រើន និងពិនិត្យពិចារណាច្រើន អាចឃើញប្រយោជន៍នៃព្រះពុទ្ធសាសនាច្រើនយ៉ាង ប៉ុន្តែក្នុងទីនេះសូមអធិប្បាយដោយសង្ខេប ដូចមានដំណើរសេចក្តីដែលត្រូវវែកញែកតទៅនេះ ៖

**១-ព្រះពុទ្ធសាសនាជាផ្លូវនៃសន្តិភាព** ព្រះពុទ្ធសាសនាសម្បូណ៌ដោយសីលធម៌ និងប្រពៃណីដ៏ល្អ ដែលគួរប្រតិបត្តិតាម ជាផ្លូវដើម្បីឲ្យកើតប្រាជ្ញាភ្លឺថ្លាឃើញធម៌រំលត់ទុក្ខ នាំសេចក្តីសុខមកឲ្យដល់មនុស្សអ្នកប្រតិបត្តិ ទុកដូចជាដួងប្រទីបមួយដ៏ធំក្នុងលោក សម្រាប់ទ្រោលបំភ្លឺមនុស្សលោកឲ្យឃើញផ្លូវប្រតិបត្តិ ដើរកាត់តម្រង់ទៅរកសន្តិភាព ទាំងក្នុងបច្ចុប្បន្ននិងបរលោកជាសាសនាវារកឃើញឫសគល់កិលេសមានលោភៈជាដើម ឃើញមគ្គផលនិព្វានបាន។ ព្រះពុទ្ធសាសនាមានគុណភាពប្រកបដោយប្រយោជន៍ជាច្រើនយ៉ាង ដូចយ៉ាងការរីកចម្រើនឈានលឿនទៅមុខរបស់មនុស្សលោក ក៏ច្រើនតែកើតមកពីព្រះពុទ្ធសាសនាជាអ្នកចង្អុលប្រាប់ជាដំបូង សូម្បីវេជ្ជសាស្ត្រនិងវិទ្យាសាស្ត្រដែលរាប់ថា ជាវិជ្ជាសម័យថ្មី ក៏ច្រើនតែកើតមកអំពីទ្រឹស្តីពុទ្ធសាសនាដែលអ្នកប្រាជ្ញចម្លងផ្តិតយករបៀបទុកជាមេគំនិត។

គ្រប់ប្រទេសទាំងអស់ ច្រើនតែទទួលដឹងថា សេចក្តីចម្រើនក្នុងសិល្បវិទ្យានិងសន្តិភាពនៃសង្គមមនុស្ស បានទទួលអំពីពុទ្ធសាសនាដោយពិត។ អ្នកប្រាជ្ញប្រវត្តិសាស្ត្រប្រទេសជប៉ុន បានសរសេរចុះក្នុងប្រវត្តិសាស្ត្រថា «ព្រះពុទ្ធសាសនា ជាសាសនានាំសេចក្តីចម្រើនមកប្រគល់ឲ្យប្រទេសជប៉ុន ព្រះពុទ្ធសាសនាបានបើកទ្វារប្រទេសជប៉ុន ដោយទ្រឹស្តីមុនដំបូងគេបង្អស់ ឲ្យប្រទេសជប៉ុនទទួលសុខសន្តិភាពឈមមុខទៅរកសេចក្តីចម្រើន មានកិត្តិសព្ទមុនគេក្នុងចំណោមជាតិភ្នែកខ្មៅ ព្រោះហេតុនោះ យើងជាជាតិជប៉ុននៅចុងប៉ូចបូព៌ាប្រទេស គួរណាស់តែសើរើសិក្សាអនុវត្តព្រះពុទ្ធសាសនា ដោយគោរពមិនត្រូវធ្វេសប្រហែស»។ បើមនុស្សក្នុងសកលលោកព្រមព្រៀងគ្នា កាន់ព្រះពុទ្ធសាសនាឲ្យត្រឹមត្រូវជិតដល់គ្រប់គ្នាទាំងអស់ ប្រាកដជាបានសន្តិភាពដោយពិតពុំខាន។

**២-ព្រះពុទ្ធសាសនាជាឃ្លាំងនៃការសិក្សា** ការសិក្សាពុទ្ធសាសនាគ្មានបំណងខាងសម្ភារនិយម ដូចវិជ្ជាបច្ចេកទេសក្នុងផ្លូវលោកដែលទាក់ទង

ដោយគ្រឿងសស្ត្រាវុធ គឺមានគោលដៅតែខាងចិត្តនិយម។ ប្រទេសកម្ពុជារបស់យើង ដែលបានទទួលគម្ពីរច្បាប់ព្រះពុទ្ធសាសនាមកសិក្សាឲ្យមានការចេះដឹង ក្នុងផ្លូវលទ្ធិសាសនាក្តី ក្នុងផ្លូវអក្សរសាស្ត្រក្តី ច្រើនតែកើតអំពីវត្តអារាមរបស់ព្រះពុទ្ធសាសនាជាដំបូង ឃើញថា ការសិក្សារបស់ខ្មែរឋិតនៅក្នុងឃ្លាំងគឺព្រះពុទ្ធសាសនាជាច្រើនណាស់ សូម្បីវិជ្ជាពេទ្យក៏ច្រើន តែកើតមកអំពីបព្វជិតពុទ្ធសាសនាដែរ ទោះបីមានវិន័យហាមមិនឲ្យបព្វជិតធ្វើពេទ្យមើលជំងឺ ក៏ហាមបានដោយក្រណាស់ដោយហេតុបព្វជិតមើលជំងឺឲ្យទទេ មិនបានយកថ្លៃ។

**៣-វត្តអារាមជាសភានៃមហាជន** ការប្រជុំគ្នាដើម្បីសន្ទនាពីធម៌អាថ៌ឬពីព្រឹត្តិការណ៍ណាមួយ តាមសេចក្តីចេះដឹងក្នុងសម័យនិយមនោះៗ ក៏ត្រូវតែធ្វើក្នុងវត្តអារាម។ មួយទៀត វត្តអារាមទុកជារោងហត្ថកម្មរបស់ការជាង មានការជាងឈើ ការកសាងសាលាវិហារជាដើម។ ប្រភពនៃសេចក្តីចម្រើនរបស់ប្រទេសយើង ដែលមានឈ្មោះជាប់មកថា ជាប្រទេសមានអក្សរសាស្ត្រ មានបុរាណវត្ថុជាកេរដំណែល មានប្រជាជាតិជាម្ចាស់ប្រទេស មានព្រះមហាក្សត្រសោយរាជ្យ ក៏ដោយសារអំណាចគុណនៃព្រះពុទ្ធសាសនា ឬថាព្រះពុទ្ធសាសនាទុកជាមន្ទីរសម្រាប់តាំងទុកឯកសារ ប្រជុំវប្បធម៌ខាងផ្នែកអក្សរសាស្ត្រ ប្រវត្តិសាស្ត្រនិងសិល្បហត្ថកម្មជាដើមរបស់ជាតិ ឲ្យជាតិមានជីវិតរស់នៅរហូតមករួមសេចក្តីថា «ព្រះពុទ្ធសាសនាមានវត្តនេះហើយ ជាទីមហាសន្និបាតរបស់អ្នកស្រុក»។

**៤-វត្តអារាមជាសាលារៀន** យើងបានឃើញជាក់ច្បាស់ហើយថា វត្តអារាមកាលដែលប្រទេសយើងមិនទាន់មានសាលារៀនអក្សរសាស្ត្រខាងក្រៅវត្តតាមផ្លូវការនៅឡើយ មានតែវត្តអារាមហ្នឹងឯងជាសាលារៀន កាលដែលមិនទាន់មានមន្ទីរពេទ្យព្យាបាលរោគ មានតែវត្តអារាមជាមន្ទីរពេទ្យ សម្រាប់មើលជំងឺមហាជន មិនត្រឹមតែមើលជំងឺក្នុងកាយប៉ុណ្ណោះទេ គឺមើលជំងឺក្នុងចិត្តថែមទៀត ព្រោះការកើតទុក្ខ ព្រួយបារម្ភក្នុងផ្លូវចិត្តនេះចាត់ជារោគមួយយ៉ាង

បណ្ណាល័យ ហ៊ុន សែន HUN SEN LIBRARY

ហោចណាស់ វត្តអារាមនៃពុទ្ធសាសនាឈ្មោះថា ជាកន្លែងសម្រាប់រំងាប់រោគកាយ ចិត្តរបស់ពុទ្ធបរិស័ទជើងវត្ត ដែលមានទុក្ខឲ្យធូរស្រាលឲ្យជាសះស្បើយទៅ។

**៥-វត្តអារាមជាកន្លែងអាហារូបករណ៍** រាជធានីភ្នំពេញមានវត្តឧណ្ណាលោម វត្តលង្កា វត្តបទុមវតីជាដើម ជាវត្តទទួលបន្ទុកនៃពួកភិក្ខុ សាមណេរ និងក្មេងតូចធំបានច្រើនណាស់។ វត្តនីមួយៗមានភិក្ខុ សាមណេរ និងក្មេងដែលចេញស្ទះពន្លះអំពីស្រុក ខេត្តផ្សេង មកសំណាក់អាស្រ័យនៅ ដើម្បីសិក្សារៀនសូត្រយកចំណេះវិជ្ជា ព្រោះក្រុងភ្នំពេញជាទីប្រជុំធំនៃវិជ្ជា សម្បូរណ៍ដោយការសិក្សាជាងទីឯទៀត។ ពួកភិក្ខុដែល មកនៅក្នុងវត្តទាំងនោះបានយូរឆ្នាំ ទាំងមានសមត្ថភាពគ្រាន់បើ ហើយបានធ្វើជាមេកុដិនៃវត្តនីមួយៗ អាចទទួលចិញ្ចឹមភិក្ខុ សាមណេរ និងក្មេងឲ្យរៀនសូត្រ ទាល់តែសម្រេច អាចទទួលលទ្ធផលនៃការសិក្សាបាន។ ពួកក្មេងដែលមកនៅអាស្រ័យជ្រកកោនក្នុងវត្តជាមួយនឹងព្រះសង្ឃនោះ សុទ្ធតែជាកូនអ្នកស្រែចម្ការក្រទ័លទ្រព្យសម្បត្តិ។ គួរឲ្យអាណោចអធ័ម អាណិតអាសូរពួកក្មេងកម្សត់ទាំងនេះពន់ពេក បើកុំតែមានវត្តព្រះពុទ្ធសាសនាជាកន្លែងអាហារូបករណ៍ ប្រហែលជាក្មេងកម្សត់ទាំងនោះមិនបានទទួលរស្មីការសិក្សាដូចកូនអ្នកមានទ្រព្យទេ បានសេចក្ដីថា «កូនអ្នកក្រីក្ររស់នៅដោយសារបាយវត្ត» ខំទ្រាំទ្រនៅបំពេញការសិក្សាទាំងរហេមរហាមទាល់តែសម្រេចផលនៃការសិក្សា អាចឡើងឋានៈទៅជាអ្នកមានជីវភាពខ្ពង់ខ្ពស់ តាមសមគួរដល់សមត្ថភាពរបស់ខ្លួនបាន។ ចំណែកខាងកូនអស់លោកឥស្សរជនឬកូនគហបតី គេមិនបាច់ត្រូវការឲ្យមកជ្រកកោននៅអាស្រ័យក្នុងវត្តឡើយ។

កូនចៅរបស់អ្នកក្រីក្រ បានទទួលសេចក្ដីសង្គ្រោះអំពីបព្វជិតក្នុងឆ្នាំនីមួយៗបានច្រើននាក់ណាស់ ដូចយ៉ាងវត្តធំៗមានក្មេងចំនួនពី ៣០០ ដល់ ៤០០នាក់។ ចំនួនពួកក្មេងទាំងនេះ បើរដ្ឋាភិបាលទទួលយកទៅចិញ្ចឹមនោះ ចំណាយថវិកាជាតិមិនតិចទេក្នុងមួយឆ្នាំៗ។ ក្មេងទាំងនោះ ឈ្មោះថារស់នៅដោយអាស្រ័យនឹងម្លប់ព្រះពុទ្ធសាសនា នៅជ្រកកោនក្រោមទង់ជ័យព្រះពុទ្ធ

សាសនា ហើយតស៊ូខំប្រឹងសិក្សា ទាល់តែបានលទ្ធផលនៃការសិក្សារបស់ខ្លួន។ ក្នុងករណីនេះឃើញថា ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាយើង មានប្រយោជន៍ធំទូលាយអាចជួយសង្គ្រោះទំនុកបម្រុងដល់ប្រទេសជាតិបាន គឺថាព្រះពុទ្ធសាសនាទុកដូចជាកន្លែងអាហារូបករណ៍មួយដ៏ប្រសើរ របស់ពួកក្មេងអ្នកក្រីក្រអាចចិញ្ចឹមជីវិតមនុស្សទ័លក្រ ដែលមិនមានលំនៅសម្រាប់ជ្រកកោននិងអាហារបរិភោគ។ វត្តពុទ្ធសាសនាឈ្មោះថា បានជួយសម្រាលភារៈនៃរដ្ឋាភិបាលឲ្យធូរស្រាលបានច្រើនណាស់។

**៦-វត្តអារាមគាំទ្រទាំងផ្លូវធម៌ទាំងផ្លូវលោក** លោកគ្រូចៅអធិការ ឬគ្រូសូត្រជាដើមក្នុងវត្តនីមួយៗ ត្រឹមតែសិក្សាធម្មវិន័យប៉ុណ្ណោះទេ បានយល់ផ្លូវសិក្សាតាមសម័យនិយមទៀត។ ការសិក្សាច្បាប់ព្រះពុទ្ធសាសនារបស់ព្រះសង្ឃនោះ ជាកម្លាំងមួយដែលនាំឲ្យមានប្រាជ្ញាស្មារតីបរិបូណ៌ ក្នុងផ្លូវធម៌ផងផ្លូវលោកផង គឺថាការសិក្សានោះអាចជួយឲ្យមានមធ្យោបាយ ជួយឲ្យមានយោបល់ល្អ ជួយឲ្យមានឧត្តមគតិ មានសមត្ថភាពដល់ខ្លួន ដល់ពួកឧបាសកជើងវត្តដែលជាអ្នកសិក្សា អាចដឹកនាំចិត្តឲ្យមានសទ្ធាជ្រះថ្លាក្នុងការកសាងសេនាសនៈសម្រាប់បម្រើព្រះពុទ្ធសាសនាផង បម្រើប្រទេសជាតិផង។ ដូចយ៉ាងសាលាសិក្សាអក្សរសាស្ត្រមានសាលាបឋមសិក្សាជាដើម ដែលកើតមានព្រោងព្រាតក្នុងស្រុក-ខេត្តផ្សេងៗ មានខេត្តកណ្ដាល តាកែវ ស្វាយរៀងជាដើម ច្រើនតែកើតអំពីចំហាយនៃការសិក្សាព្រះពុទ្ធសាសនាជាដើម គឺថាសាលាសិក្សាទាំងនោះកើតឡើងបានដោយសារស្នាដៃព្រះសង្ឃ មានលោកគ្រូចៅអធិការឬគ្រូសូត្រជាដើម ណែនាំពួកគ្រហស្ថជើងវត្តឲ្យកសាងដោយឥតមើលបំណាំរដ្ឋាភិបាលឡើយ លុះកសាងហើយ ជូនប្រគល់សាលាសិក្សានោះដល់រដ្ឋាភិបាល ដើម្បីឲ្យរាជការ ចាត់ចែងរកគ្រូបង្រៀនតាមផ្លូវការតទៅដែលអាចគាំពាររដ្ឋាភិបាល ជួយកម្លាំងឲ្យរដ្ឋាភិបាលចំណេញថវិកាជាតិបានច្រើនណាស់។

ដំណើរនេះសឲ្យឃើញថា «សាសនា កាលបើបុគ្គលណាមួយបានទទួលការអប់រំសិក្សាល្អហើយ នាំឲ្យឆ្លុះឃើញសារប្រយោជន៍ក្នុងផ្លូវធម៌ផងផ្លូវលោកផង»។ ព្រះពុទ្ធសាសនាឈ្មោះថា ជាសាសនាមួយជួយមហាជនប្រទេសកម្ពុជាឲ្យចេះស្រឡាញ់ប្រទេសជាតិរបស់ខ្លួនបានដោយបរិបូណ៌ ជាសាសនាមានទ្រឹស្តីល្អ អាចជួយសាងសាមគ្គីរបស់ជាតិឲ្យមានវឌ្ឍនធម៌ ឲ្យមានការគោរពជាតិ លើកតម្កើងជាតិ។

**៧-វត្តអារាមជាកន្លែងវប្បធម៌ជាតិ** អក្សរសាស្ត្ររបស់ជាតិ បើកុំតែបានវត្តអារាម ប្រហែលជាសាបសូន្យអស់ទៅហើយ។

ហេតុអ្វីក៏ពោលដូច្នេះ កាលប្រទេសយើងស្ថិតនៅក្រោមអំណាចអាណាព្យាបាល បរទេសគេប្រើភាសាខ្មែរគ្រាន់តែបង្គ្រប់ការប៉ុណ្ណោះក្នុងសាលារៀនមានបង្រៀនដែរតែមានភាពស្លួចស្តើងណាស់នៅតាមក្រសួងរាជការនានា ប្រើសុទ្ធតែភាសាបរទេស លើកលែងតែក្រសួងយុត្តិធម៌ចេញ ជាក្រសួងដែលមានប្រើភាសាខ្មែរភាគច្រើន។ ចុះហេតុអ្វីក៏ភាសាខ្មែរ អក្សរសាស្ត្រខ្មែរវប្បធម៌ខ្មែរមានអាយុរហូតមកដល់សព្វថ្ងៃនេះ? ព្រោះមានវត្តអារាមជាកន្លែងចិញ្ចឹមទុកឲ្យមានជីវិតរស់នៅ។ កុមារកូនអ្នកស្រុក តែងមករៀនអក្សរខ្មែរនៅវត្តអារាម ឧបាសកឧបាសិកាក៏រៀនធម៌ព្រះពុទ្ធសាសនា ដែលចារឹកជាអក្សរខ្មែរ ចំណែកភិក្ខុ សាមណេរក៏សិក្សាធម៌វិន័យព្រះសម្ពុទ្ធ ព្រមទាំងគម្ពីរតម្រាក្បួនច្បាប់ផ្សេងៗ ចារឹកជាអក្សរខ្មែរនៅតែក្នុងវត្តអារាមដែរ។ ដូច្នេះវត្តអារាមជាឃ្លាំងអក្សរសាស្ត្រខ្មែរ ដែលទុកជាពន្លឺរស្មីរបស់ជាតិ កាលបើបាត់អក្សរសាស្ត្រជាតិក៏អាប់ឱន សាបសូន្យទៅជាលំដាប់។ ដោយហេតុនេះ ពុទ្ធសាសនានៅប្រទេសយើងឈ្មោះថា ជាសាសនាជួយជ្រោមជ្រែងរក្សាទុកនូវវប្បធម៌អក្សរសាស្ត្រជាតិដោយពិត។

បព្វជិតពុទ្ធសាសនា ដែលបានរៀនក្នុងផ្លូវគន្ថធុរៈ គឺរៀនគម្ពីរបាលីព្រះត្រៃបិដក ចេះចាំយល់សព្វភាសាបាលី អាចប្រែពីបាលីមកជាភាសាខ្មែរយក

សេចក្ដីបានដោយងាយ និងនិពន្ធជាសៀវភៅសិក្សាជាដំបូន្មានអប់រំ ជាកវីនិពន្ធជារឿងល្បើកប្រកបដោយគតិវែងខ្លះ ខ្លីខ្លះ បានបោះពុម្ពផ្សាយជាសៀវភៅធម៌អាថ៌ធំតូចគរគោក។ សូមអញ្ជើញមើលក្នុងមន្ទីរ **ពុទ្ធសាសនបណ្ឌិត្យ** នឹងឃើញសៀវភៅខ្មែរដេរដាសមានព្រះត្រៃបិដកជាដើម ព្រមទាំងបណ្ណាគារផ្សេងៗ និងឃើញសៀវភៅខ្មែរផ្សាយផ្នែកព្រះពុទ្ធសាសនា ចេញព្រោងព្រាតច្រើនតែកើតអំពីស្នាដៃព្រះសង្ឃ ដែលបានរៀនក្នុងផ្លូវព្រះពុទ្ធសាសនា។ ដូច្នេះប្រទេសកម្ពុជាដែលមានវឌ្ឍនធម៌ចម្រើនរុងរឿងលឹមៗ មកនេះ ដោយកម្លាំងរស្មីវប្បធម៌ព្រះពុទ្ធសាសនាជាប្រាកដ។

**អ្នកកាន់ធម៌មិនដែលចាប់អារម្មណ៍ពីមានចំណេះដឹងខ្ពស់ឬទាប វិនាសឬគង់វង្សនោះទេ គេចាប់អារម្មណ៍តែពីមូលហេតុ ដែលធ្វើឲ្យកើតមានអ្វីៗគ្រប់យ៉ាងប៉ុណ្ណោះ។**

# តម្លៃនៃព្រះពុទ្ធសាសនា

**អស់លោកអ្នកអានជាទីគោរពទាំងឡាយ!**

វេលានេះខ្ញុំសូមរៀបរាប់អំពីតម្លៃនៃព្រះពុទ្ធសាសនាដែលខ្ញុំបានអាន បានយល់ តាមសតិបញ្ញាដូចតទៅនេះ ៖

ព្រះពុទ្ធសាសនានេះ គួរអស់លោកអ្នកអានទាំងឡាយជ្រាបថា ជាពាក្យប្រៀនប្រដៅមានតម្លៃយ៉ាងក្រៃលែង។ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធសុទ្ធតែជាពាក្យប្រៀនប្រដៅដឹកនាំមនុស្សសត្វ ព្រមទាំងទេពតាឲ្យដើរទៅរកសេចក្ដីសុខចម្រើន ទាំងក្នុងលោកនេះនិងលោកខាងមុខ។ បណ្ដាពាក្យប្រៀនប្រដៅទាំងនោះ មានពាក្យប្រៀនប្រដៅខ្លះ បានត្រូវគ្នានឹងសុភាសិតអ្នកប្រាជ្ញទាំងឡាយអំពីបុរាណក៏មាន មានពាក្យប្រៀនប្រដៅខ្លះទៀត ជាពាក្យប្រៀនប្រដៅផុតវិស័យគំនិតមនុស្សសត្វ ព្រមទាំងទេពតាទាំងអស់ ក្រៅតែអំពីព្រះសម្ពុទ្ធជាម្ចាស់ ឥតមានអ្នកណាម្នាក់អាចរកគិតបង្កើតឡើងបានដូចនោះក៏មាន។

ព្រះពុទ្ធសាសនា មានឡើងដំបូងនៅក្នុងមជ្ឈិមប្រទេស គឺប្រទេសឥណ្ឌាសម័យសព្វថ្ងៃនេះ។ នៅក្នុងមជ្ឈិមប្រទេសទាំងមូល កាលដែលមិនទាន់មានព្រះពុទ្ធសាសនានៅឡើយ មនុស្សទាំងអស់តែងនាំគ្នាប្រព្រឹត្តប្រតិបត្តិ តាមលទ្ធិសាសនាព្រាហ្មណ៍ តាមលទ្ធិសាសនាឯទៀតៗខ្លះ ដែលជាផ្លូវប្រតិបត្តិតឹងពេកក៏មាន ធូរពេកក៏មាន ដូចយ៉ាងប្រព្រឹត្តប្រតិបត្តិបង្អត់អាហារខ្លួន ឲ្យលំបាករូបកាយ ប្រព្រឹត្តទុកសក់ឲ្យវែងអន្លាយ ប្រព្រឹត្តដេកលើបន្លា ប្រព្រឹត្តអាំងភ្លើងក្នុងវេលាថ្ងៃនារដូវក្ដៅជាដើម ដែលសុទ្ធតែជាសេចក្ដីប្រតិបត្តិឥតប្រយោជន៍ទាំងអស់ ក៏ឥតមានមនុស្សណាម្នាក់គិតឃើញថា ជាសេចក្ដីប្រតិបត្តិឥតប្រយោជន៍ ហើយនឹងរើគំនិតរកផ្លូវប្រតិបត្តិជាថ្មីទៀតនោះសោះឡើយ។

លុះដល់ព្រះសម្ពុទ្ធជាម្ចាស់ បានត្រាស់ដឹងឡើងក្នុងលោក ព្រះអង្គបានសម្ដែងធម៌ទេសនាជាដំបូងចំពោះបញ្ចវគ្គិយភិក្ខុ ដើម្បីកែប្រែសេចក្ដីប្រតិបត្តិទាំងនោះ គឺពន្យល់មិនឲ្យប្រតិបត្តិតាម ដោយឥតប្រយោជន៍ ហើយឲ្យត្រឡប់មកប្រតិបត្តិតាមបែបដែលព្រះអង្គទ្រង់យល់ថា ជាផ្លូវប្រតិបត្តិមានប្រយោជន៍ពិតៗនោះវិញ។ ធម៌ទេសនាដែលព្រះអង្គបានសម្ដែងជាដំបូងនោះមានសេចក្ដីថា

**ទ្វេ មេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា** ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រតិបត្តិដ៏លាមកអាក្រក់ទាំងពីរយ៉ាងនេះ បព្វជិតមិនគួរសេព គឺថាមិនត្រូវប្រតិបត្តិឡើយ។ សេចក្ដីប្រតិបត្តិអាក្រក់ទាំងពីរយ៉ាងនោះគឺ កាមសុខល្លិកានុយោគ ការប្រកបខ្លួនឲ្យជាប់ជំពាក់ដោយសេចក្ដីសុខក្នុងកាមទាំងឡាយ១ អត្តកិលមថានុយោគ ការប្រកបសេចក្ដីលំបាកដល់ខ្លួនឲ្យនឿយលំបាកឥតប្រយោជន៍១។ សេចក្ដីប្រតិបត្តិទាំង២យ៉ាងនេះ ជាអំពើថោកទាបជាការនាំឲ្យសាបសូន្យ មិនជាសេចក្ដីចម្រើនទេ មិនតែប៉ុណ្ណោះថែមទាំងជាហេតុនាំឲ្យបានសេចក្ដីទុក្ខព្រួយថែមទៀត។

**ឯតេ តេ ភិក្ខវេ ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា** ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រតិបត្តិជាកណ្ដាល ដែលមិនបាច់អាស្រ័យនូវសេចក្ដីប្រតិបត្តិដ៏លាមកអាក្រក់ទាំង២យ៉ាងនោះ ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្ដីប្រតិបត្តិធ្វើឲ្យកើតប្រាជ្ញា ឲ្យកើតសេចក្ដីដឹងច្បាស់ប្រាកដ ប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់រំងាប់ដើម្បីសេចក្ដីដឹងក្រៃពេក ដើម្បីសេចក្ដីដឹងល្អ ដើម្បីព្រះនិព្វាន។

**សេយ្យថីទំ** សេចក្ដីប្រតិបត្តិជាកណ្ដាលនោះតើដូចម្ដេចខ្លះ ?

សេចក្ដីប្រតិបត្តិជាកណ្ដាលនោះ គឺធម៌ដែលគួរស្វែងរកមានអង្គ៨ ហៅថា **អដ្ឋង្គិកមគ្គ** ជាគ្រឿងចេញផុតចាកសត្រូវគឺកិលេស។ អដ្ឋង្គិកមគ្គនោះគឺ សម្មាទិដ្ឋិ ប្រាជ្ញាយល់ត្រូវ១ សម្មាសង្កប្បោ សេចក្ដីត្រិះរិះត្រូវ១ សម្មាវាចា សម្ដីនិយាយត្រូវ១ សម្មាកម្មន្តោ ការងារត្រូវ១ សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ

១ សម្មាវាយាមោ សេចក្ដីព្យាយាមត្រូវ១ សម្មាសតិ សេចក្ដីរំលឹកត្រូវ១ សម្មាសមាធិ កិរិយាតម្កល់ចិត្តត្រូវ១។

ពុទ្ធសាសនាមានធម៌ថ្នាក់ខ្ពស់ទៀត ហៅថា **សច្ចធម៌** ជាធម៌ប្រកាសនូវសេចក្ដីពិត ជាធម៌កំបាំងនឹងគំនិតប្រាជ្ញារបស់មនុស្សទេពតាទាំងអស់ កាលមុនដែលពុំទាន់មានព្រះពុទ្ធសាសនានោះឥតមានអ្នកណាមួយចេះប្រដៅគ្នាឲ្យយល់ពិតដូចជាសច្ចធម៌នេះឡើយ បើទុកជាមានបុគ្គលអ្នកឃើញខ្លះ ក៏ឃើញនោះគ្រាន់តែព្រិលៗមិនច្បាស់ណាស់ លុះដល់ព្រះពុទ្ធត្រាស់ដឹងឡើង ទើបព្រះអង្គសម្ដែងអំពីសច្ចធម៌នោះ ឲ្យដល់មនុស្សទេពតាទាំងអស់ បានស្គាល់ច្បាស់ច្រើនគ្នាឡើង ហៅថា **អរិយសច្ច**។ អរិយសច្ច នោះមាន៤យ៉ាងគឺ

**១-ទុក្ខំ** ការកើត ការចាប់កំណើត ការកើតប្រាកដនៃខន្ធប្រាំ ជាទុក្ខ១ ឈ្មោះថា ជាតិទុក្ខ ជរា គឺការចាស់ទ្រុឌទ្រោមគ្រាំគ្រានៃខន្ធប្រាំជាទុក្ខ១ ឈ្មោះថាជរាទុក្ខ សេចក្ដីស្លាប់ក៏ជាទុក្ខ១ ឈ្មោះថាមរណទុក្ខ សេចក្ដីស្ដាយស្រណោះអាឡោះអាល័យ ក្ដៅរំជួលខាងក្នុង ព្រោះសេចក្ដីវិនាសនៃញាតិសន្ដាន ទ្រព្យធនគូស្រករគ្រួសារជាដើម ជាទុក្ខ១ ឈ្មោះសោកទុក្ខ សេចក្ដីខ្សឹកខ្សួលយំសង្រេងសង្រៃអាល័យញាតិសន្ដាន ទ្រព្យធនគូស្រករគ្រួសារជាដើម ដែលវិនាសស្លាប់បាត់បង់ទៅ ជាទុក្ខ១ ឈ្មោះថា បរិទេវទុក្ខ ជំងឺតម្កាត់កើតមានក្នុងកាយ ធ្វើឲ្យលំបាករូបកាយ ជាទុក្ខ១ ឈ្មោះថាទុក្ខទុក្ខ សេចក្ដីតូចចិត្តលំបាកចិត្ត ជំងឺកើតអំពីចិត្ត ជាទុក្ខ១ ឈ្មោះថាទោមនស្សទុក្ខ សេចក្ដីខឹងក្រោធពិរោធ កើតអំពីសេចក្ដីលំពាកចិត្តខ្លាំងពេក ដោយហេតុវិនាសនៃញាតិសន្ដាន ទ្រព្យធនគូស្រករគ្រួសារជាដើម រួមសេចក្ដីទៅថា ការតានតឹងក្នុងចិត្ត ចង្អៀតចង្អល់ចិត្ត ជាទុក្ខ១ ឈ្មោះថា ឧបាយាសទុក្ខ ការជួបប្រទះនូវសត្វ (បានដល់រូបមនុស្ស សត្វទូទៅ) និងសង្ខារ (បានដល់រូប សំឡេង ក្លិន រស សម្ផស្ស) មិនជាទីស្រឡាញ់ ជាទុក្ខ១ ឈ្មោះថា អប្បិយសម្បយោគទុក្ខ ការព្រាត់ប្រាសនិរាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ ជាទុក្ខ១ ឈ្មោះ

ជា បិយវិប្បយោគទុក្ខ បុគ្គលប្រាថ្នានូវវត្ថុណាហើយ មិនមានបាននូវវត្ថុនោះដូច ប្រាថ្នាអំពើនោះជាទុក្ខ១ឈ្មោះថាឥច្ឆិតាលាភទុក្ខ។បើនិយាយឲ្យខ្លីឧបាទានក្ខន្ធ ទាំង៥ សុទ្ធតែជាទុក្ខទាំងអស់ហៅថា ឧបាទានក្ខន្ធទុក្ខ។

**២-ទុក្ខសមុទយោ** ហេតុដែលជាមេនាំបណ្តាលឲ្យកើតសេចក្តីទុក្ខនោះ ហៅថា អរិយសច្ច បានខាងតណ្ហាជាធម្មជាតិតាក់តែងនូវភពថ្មីជាប្រក្រតី ប្រកប ដោយសេចក្តីត្រេកត្រអាល ត្រេកអរក្នុងភពនោះៗ ឬក្នុងអារម្មណ៍នោះៗ។ តណ្ហានោះមាន៣យ៉ាងគឺ កាមតណ្ហា១ ភវតណ្ហា១ វិភវតណ្ហា១។

**៣-ទុក្ខនិរោធោ** ធម៌ជាគ្រឿងរលត់មិនសល់នៃតណ្ហានោះឯង ហៅថា អរិយសច្ច គឺសេចក្តីសាបរលាបទៅ និងសេចក្តីរលត់ទៅដោយមិនសល់នៃកិលេស មានតណ្ហាជាដើមនោះ។

**៤-ទុក្ខនិរោធគាមិនីបដិបទា**សេចក្តីប្រតិបត្តិធ្វើឲ្យអ្នកដែលប្រតិបត្តិតាម ឲ្យដល់នូវទុក្ខនិរោធ ហៅថា អរិយសច្ច បានខាងមគ្គដ៏ប្រសើរ មានអង្គ៨ មាន សម្មាទិដ្ឋិជាដើម មានសម្មាសមាធិជាទីបំផុត ដូចបានរៀបរាប់ពីខាងដើមរួច មកហើយ។

អរិយសច្ចធម៌ទាំង៤ប្រការនេះ មានអ្នកប្រាជ្ញជាច្រើនដែលបានរិះគិត បានស្តាប់ បានសិក្សា ទៅតាមលម្អានព្រះពុទ្ធដីកានេះហើយ មានសេចក្តីស្ងើច សរសើរថា ត្រូវពិត ឥតឃ្លៀងឃ្លាត។ សម័យសព្វថ្ងៃនេះ បានដំណឹងថា នៅក្នុង មហាប្រទេសទាំងឡាយនៅក្នុងទ្វីបអឺរ៉ុបដែលពីដើមគេមិនជឿព្រះពុទ្ធសាសនា សោះ លុះបានពិនិត្យដល់ព្រះពុទ្ធសាសនាត្រង់នេះ គេក៏ជឿ នាំគ្នាកាន់ តាមប្រតិបត្តិតាម។ ដូច្នេះ បានជាព្រះពុទ្ធសាសនាយើងឃើញមានប្រតិស្ឋាន នៅក្នុងទ្វីបអឺរ៉ុបស្ទើរតែគ្រប់ប្រទេស គ្រាន់តែច្រើននិងតិច ថ្កុំថ្កើងអន់ថយ ប៉ុណ្ណោះ។

ធម៌ជាពុទ្ធសាសនាម្យ៉ាងទៀត សម្រាប់ប្រដៅមនុស្សឲ្យចេះគិតពិចារ-ណាដល់រូបកាយ ឲ្យឃើញជាក់ច្បាស់ថាមិនទៀង ជាទុក្ខ និងមិនមែនជារបស់

ខ្លួនហៅថា **ព្រះត្រៃលក្ខណ៍** ជាប្រយោជន៍កុំឲ្យមនុស្សទាំងអស់មានសេចក្ដីស្រវឹងទៅក្នុងរូបកាយ ហើយធម៌ជារបៀបនៃពុទ្ធសាសនា ដែលនាំយកមកពន្យល់ក្នុងទីនេះបន្តិចបន្តួចប៉ុណ្ណោះ ដើម្បីឲ្យឃើញជាតួយ៉ាងនៃព្រះពុទ្ធសាសនាដែលមានតម្លៃពិសេស រស់នៅប្រចាំលោកជានិច្ចមិនចុះតម្លៃ ព្រោះជាពាក្យប្រៀនប្រដៅផុតវិស័យគំនិតមនុស្សសត្វ និងទេពតាទាំងអស់ ឥតមាននរណាមួយ ក្រៅអំពីព្រះពុទ្ធគិតប្រដៅឲ្យដូចបានឡើយ។ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់របៀបនេះនៅមានច្រើនណាស់ មិនអាចដកស្រង់យកមកពន្យល់ឲ្យសព្វគ្រប់បានទេ ព្រោះពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ដែលហៅថា **ព្រះធម៌** នោះមានដល់ទៅ៨ម៉ឺន៤ពាន់ព្រះធម្មក្ខន្ធ ដែលព្រះសង្គីតិកាចារ្យបានចែកចេញជាបិដកមាន៣គឺព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម។

ព្រះពុទ្ធសាសនាដែលថា ដឹកនាំប្រៀនប្រដៅមនុស្សសត្វ ឲ្យមានប្រយោជន៍ឲ្យបានសេចក្ដីសុខនោះ មិនមែនឲ្យបានប្រយោជន៍និងសេចក្ដីសុខក្នុងបរលោកដែលយើងមើលទៅមិនឃើញនោះទេ ជាពាក្យប្រៀនប្រដៅឲ្យបានប្រយោជន៍ ឲ្យបានសេចក្ដីសុខ ក្នុងលោកនេះទៀតផង ដូចពុទ្ធដីកា ដែលខ្ញុំសូមរៀបរាប់ខ្លះៗ ខាងក្រោមនេះ។

ក្នុងសិង្គាលោវាទសូត្រ គម្ពីរទីឃនិកាយ បាដិកវគ្គ ព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងអំពីអបាយមុខ៦យ៉ាងចំពោះសិង្គាលមាណពថា មិនឲ្យផឹកសុរា១ មិនឲ្យដើរលេងតាមច្រកល្ហកក្នុងវេលាយប់១ មិនឲ្យដើរមើលល្បែងមហាស្រព ១ មិនឲ្យលេងល្បែងស៊ីសង មានបៀប៉ោជាដើម១ មិនឲ្យសមគំនិតនឹងមនុស្សខូច យកធ្វើជាមិត្តសំឡាញ់១ មិនឲ្យខ្ជិលធ្វើការងាររកស៊ីចិញ្ចឹមជីវិត១។

**ក្នុងបរាភវសូត្រ គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** ព្រះពុទ្ធជាគ្រូនៃយើងទ្រង់បានសម្ដែងយ៉ាងច្បាស់លាស់ អំពីហេតុដែលនាំឲ្យបាននូវសេចក្ដីវិនាសផ្ទុយគ្នានឹងសេចក្ដីចម្រើន ចំពោះទេវតា១អង្គដែលមាននាមនិងគោត្រមិនប្រាកដ។

សូមដកស្រង់យកពុទ្ធភាសិតក្នុងបរាភវសូត្រនោះ មកបង្ហាញអស់

លោកអ្នកឲ្យបានជ្រាបដូចតទៅ ៖

**១- សុវិជានោ ភវំ ហោតិ ។ ល ។ ធម្មទេស្សី បរាភវោ**

សេចក្តីថា នរជនណាមួយមានចំណេះវិជ្ជា គឺចេះអក្សរសាស្ត្រ លេខ នពន្តគុណហារជាដើម ជាវិជ្ជាលោកីយក្តី វិជ្ជាលោកុត្តរក្តី នរជននោះនឹងបាន នូវសេចក្តីចម្រើនក្នុងលោកទាំងពីរ គឺក្នុងលោកនេះនិងលោកខាងមុខ។ នរជន ណាមួយ ទោះជាគ្រហស្ថក្តី បព្វជិតក្តី ដែលអាប់ឥតចំណេះវិជ្ជាអ្វីនៅក្នុងខ្លួន នរជននោះឈ្មោះថា នាំសេចក្តីវិនាស មកដាក់ខ្លួន ក្នុងលោកនេះនិងលោកខាង មុខមិនខាន។

**២-អសន្តស្ស បិយា ហោន្តិ។ល។ តំ បរាភវតោ មុខំ**

សេចក្តីថា នរជនណាមួយ យកមនុស្សអសប្បុរសពាលយង់ឃ្នង ដែល ប្រព្រឹត្តធ្វើតែអំពើលាមកអាក្រក់គ្រប់បែបគ្រប់យ៉ាង មានធ្វើអំពើបាណាតិបាត ជាដើម មិនជឿកម្មនិងផលរបស់កម្មនៃកុសលអកុសលឡើយ មកធ្វើជាមិត្ត សំឡាញ់ រួមសុខទុក្ខជាមួយគ្នា មិនសេពគប់នឹងអ្នកប្រាជ្ញជាមិត្តភ័ក្តិ រាប់អាន ចូលចិត្តតែនឹងអសប្បុរសទ្រុស្តមិត្តដូច្នេះ ជាហេតុជាប្រធានធ្វើឲ្យនរជននោះ ដល់នូវសេចក្តីវិនាសដែរ។

**៣-និទ្ទាសីលី សភាសីលី។ល។ តំ បរាភវតោ មុខំ**

សេចក្តីថា ជនណាមួយ ល្មោភដេកច្រើន ចូលចិត្តប្រជុំគ្នានិយាយលេង នូវពាក្យរោយរាយឥតប្រយោជន៍ ខ្ជិលច្រអូសមិនធ្វើការងារ លុះក្នុងអំណាច នៃសេចក្តីក្រោធ ចិត្តមូទូខឹងច្រើន យ៉ាងនេះក៏ជាឧបាយជាប្រធាននាំជននោះ ឲ្យដល់នូវសេចក្តីវិនាសដែរ។

**៤-យោ មាតរំ វា បិតរំ។ល។ តំ បរាភវតោ មុខំ**

សេចក្តីថា ជនណាមួយ មានទ្រព្យសម្បត្តិស្តុកស្តម្ភមាំមួន ឥតមានរោគា ព្យាធិអ្វីមកបៀតបៀន ឃើញមាតាបិតាចាស់ជរា មានវ័យកន្លងផុតទៅហើយ មិនជួយចិញ្ចឹមបីបាច់ថែរក្សា ដោយវត្ថុទាំងឡាយមានភោជនាហារជាដើម ជន

នោះឈ្មោះថា ជាមនុស្សអកតញ្ញូ មិនដឹងឧបការគុណលោកអ្នកដ៏មានគុណ នេះ ក៏ជាហេតុនៃសេចក្ដីវិនាសដែរ។

**៥-យោ ព្រាហ្មណំ សមណំ វា។ល។ តំ បរាភវតោ មុខំ**

សេចក្ដីថា នរជនណាមួយ បានឃើញសមណៈ គឺអ្នកបួសក្នុងព្រះពុទ្ធសាសនា ព្រាហ្មណ៍ ឬស្មូមយាចកណាមួយមករកបិណ្ឌបាត ឬសូមទាន ហើយខ្លួនពោលពាក្យទ្រគោះបោះបោកបញ្ឆោតដោយមុខសាវាទថា គ្មានអ្វីឲ្យទេ ដូច្នេះជាដើម អ្នកនោះឈ្មោះថា ជាមនុស្សកន្ទ្រឹះឬស្យាស្មូរទុជ៌ន ប្រទូស្តនឹងស្មូមនោះ ទោះបីឲ្យក្ដី មិនឲ្យក្ដី គប្បីពោលពាក្យសមគួរដោយវាចា។ ដែលពោលពាក្យអសុរោះ ទ្រគោះទៅរកសមណព្រាហ្មណ៍ ស្មូមយាចកនោះ ក៏ជាហេតុជាប្រធាននៃសេចក្ដីវិនាសដែរ។

**៦-បហុតវិត្តោ បុរិសោ។ល។ តំ បរាភវតោ មុខំ**

សេចក្ដីថា នរជនណាមួយ មានទ្រព្យសម្បត្តិច្រើន មានមាសប្រាក់កែវពិទូរ្យសូរ្យ ការន្តស្តុកស្តម្ភ មានទាំងគ្រឿងបរិភោគឧបភោគបរិបូណ៌គ្រប់គ្រាន់ តែចិត្តស្មូរទុជ៌ន កំណាញ់ស្វិតហួសហេតុ បានចំណីអាហារឆ្ងាញ់ពិសាពួនស៊ីតែម្នាក់ឯង មិនចែករំលែកឲ្យទៅអ្នកដទៃផងគ្នាបរិភោគផង នរជននោះឈ្មោះថា ជាមនុស្សអប្បលក្ខណ៍ឥតសិរី គ្មានអ្នកផងដទៃចូលចិត្តរាប់អាន។ នេះក៏ជាប្រធាននៃសេចក្ដីវិនាសដែរ។

**៧-ជាតិត្ថទ្ធោ ធនត្ថទ្ធោ។ល។ តំ បរាភវតោ មុខំ**

សេចក្ដីថា អ្នកណាមួយ មានជាតិខ្ពង់ខ្ពស់ មានគោត្រត្រកូលឧត្តុង្គឧត្តម មានសម្បត្តិច្រើន តែមានចិត្តឆ្មើងកន្ទ្រើង ប្រកាន់ជាតិត្រកូល អាងទ្រព្យសម្បត្តិ ចិត្តរបឹងរឹងរូស ឃើញញាតិសាលោហិតឬអ្នកដទៃដែលទីទ័លក្រ មានចិត្តប្រមាថមើលងាយ មិនរាប់អាន ធ្វើហាក់ដូចជាអ្នកកន្ទៀត ឬធ្វើជាមិនដឹង មិនឃើញប្រកាន់អស្មិមានះរពើតរពើងក្រអឺតក្រអោង កោងកាចអ្នកនោះឈ្មោះថា ស្វែងរកសេចក្ដីទុក្ខមកដាក់ខ្លួន អំពើដែលធ្វើទាំងអស់នេះក៏ជាប្រធាន ជា

ឧបាយបណ្តាលឲ្យបានសេចក្តីវិនាសដែរ។

**៨-ឥត្ថីធុត្តោ សុរាធុត្តោ។ល។ តំ បរាភវតោ មុខំ**

សេចក្តីថា ជនណាមួយ ប្រព្រឹត្តលេងស្រី ប្រព្រឹត្តផឹកស្រា ប្រព្រឹត្តលេងល្បែងស៊ីសងភ្នាល់គ្នា។ អ្នកលេងស្រីនោះត្រេកអរនឹងស្ត្រីភាព បានរបស់អ្វីៗមានមាសប្រាក់ជាដើមលបលាក់យកទៅឲ្យតែស្រីៗ ធ្វើឲ្យទ្រព្យសម្បត្តិរបស់ខ្លួនវិនាសអស់ ពីព្រោះតែស្រី អស់ទ្រព្យសម្បត្តិម៉្យាងចំពោះការស៊ីចាយ ដើម្បីឲ្យស្រីស្រឡាញ់ខ្លួន អស់ម៉្យាង ក្នុងការឲ្យទៅពួកស្រីៗ ដែលខ្លួនត្រូវការយកមកសប្បាយ អស់ម៉្យាងទៀតក្នុងការទិញថ្នាំយកមកចាក់ព្យាបាលរោគស្វាយប្រមេះទៀមឡា ឬទឹកនោមផ្អែម ដែលមានសមុដ្ឋានកើតមកអំពីស្ត្រីពេស្យាផ្កាមាសទាំងនោះ។ ឯអ្នកផឹកស្រា តែស្រវឹងឡើងកាលណា ក៏វង្វេងភ្លាំងភ្លេចស្មារតី មិនស្គាល់បាបបុណ្យ គុណទោស លែងស្គាល់អ្នកធំ អ្នកតូច យកខុសជាត្រូវ យកត្រូវជាខុសប្រទូស្តនឹងខ្លួនឯងឬអ្នកដទៃ រហូតដល់ហ៊ានប្រទូស្តចំពោះអ្នកមានសីល មានគុណវិសេស សូម្បីមាតាបិតាបង្កើត ក៏ហ៊ានប្រទូស្តតបផង។ ឯអ្នកដែលប្រព្រឹត្តលេងល្បែងភ្នាល់ស៊ីសង មានបៀ-អាប៉ោង-ជួជាដើមក៏ជាហេតុនាំឲ្យវិនាសទ្រព្យសម្បត្តិ ដែលរកបានមកដោយក្រ។ មិនតែប៉ុណ្ណោះ ថែមទាំងខាតពេលវេលាដែលត្រូវរកក៏ខានរក ព្រោះរវល់តែនឹងដើរលេង ខាតទាំងពេលវេលារៀនសូត្រ ( ចំពោះអ្នកសិក្សា ) ខូចទាំងពេលដេកពេលសម្រាកខូចចិត្តខូចគំនិតភ្លេចភ្លាំងស្មារតី នាំឲ្យអាប់កិត្តិយសឈ្មោះអាក្រក់ ចេះភូតកុហក លួចប្លន់បោកបញ្ឆោត ប្រវ័ញ្ចយកទ្រព្យរបស់អ្នកដទៃ ក្បត់រាជការផែនដី ក្បត់ជាតិ ក្បត់សាសនា និងក្បត់ព្រះមហាក្សត្រថែមទៀត។ កាលបើអំពើទាំងនេះកើតមានក្នុងខ្លួនហើយ ខ្លួនត្រូវមានការលក់ផ្ទះសំបែង លក់កេរកោះ លក់របស់ពីដូនពីតា លក់ស្រែចម្ការច្បារដំណាំអស់ រហូតដល់ ទៅមានទោសទុក្ខជាប់គុកច្រវាក់ ដោយសារតែខ្លួនប្រព្រឹត្តធ្វើនូវអំពើពុំគប្បី នាំឲ្យអប្រិយទុយ៌សធ្លាក់ដល់បាត់ជីវិតទៅក៏មាន។

ល្បែងទាំង៣ប្រការនេះ ជាហេតុជាប្រធាននាំឲ្យឆ្កួត នាំឲ្យវង្វេង នាំឲ្យវិនាស ហិនហោចទ្រព្យសម្បត្តិ។ នេះជាសេចក្ដីវិនាសយ៉ាងធំក្រៃលែង។ សមដូចសុភាសិតខ្មែរយើងមួយល្បះថា លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា ឆ្កួតមួយនឹងល្បែង អំពើពាលា បីនេះលោកថា មហាឆ្កួតកន្លង។

**៩-សេហិ ទារេហិ អសន្តុដ្ឋោ។ល។ តំ បរាភវតោ មុខំ**

សេចក្ដីថា បុរសឯណាមួយ មានចិត្តប្រកបដោយកាមរាគ មិនត្រេកអរនឹងភរិយារបស់ខ្លួន ត្រេកត្រអាលតែនឹងស្ត្រីដទៃ ប្រព្រឹត្តសេពសមនឹងស្ត្រីពេស្យាផ្កាមាស ឬភរិយារបស់អ្នកដទៃ។ គប់នឹងស្ត្រីពេស្យាផ្កាមាស នាំឲ្យវិនាសទ្រព្យសម្បត្តិ រហូតដល់ធ្លាក់ខ្លួនទៅជាកើតរោគាព្យាធិ៍ មានរោគស្វាយប្រមេះទៀមឡាជាដើម។ គប់នឹងភរិយាអ្នកដទៃ មានទោសជាទម្ងន់ក្នុងបច្ចុប្បន្នផង ក្នុងបរលោកផង។ ទោសក្នុងបច្ចុប្បន្ន គឺកើតទៅជាទាស់ទែងខ្វែងគំនិតគ្នានឹងភរិយាខ្លួនក៏មាន ស្វាមិគេខឹងប្តឹងផ្តល់ក៏មាន ទៅជាមានគំនុំគុំកួន លបចាក់កាប់សម្លាប់គ្នាក៏មាន ទាស់ខុសនឹងច្បាប់សម្រាប់ប្រទេស ត្រូវរាជការដាក់ពិន័យត្រូវជាប់ឃុំឃាំងមានដាក់ខ្នោះ ដាក់គុកច្រវាក់ក៏មាន បង់ទ្រព្យសម្បត្តិក៏មាន។ ទោសក្នុងបរលោក លុះធ្វើមរណកាលអំពីលោកនេះទៅកាន់ លោកខាងមុខ សោយទុក្ខក្នុងនរក ឡើងរកាដែកអស់កាលជាយូរ លុះសេសសល់ផលកម្មនោះ បានមកកើតជាមនុស្ស ទុព្វលភាពខ្វាក់ខ្វិន ភរិយាសោតក៏មានចិត្តមិនស្លូតត្រង់ចំពោះខ្លួន មិត្តភក្តិក៏មិនសូវសុចរិត មានចិត្តមិនស្មោះត្រង់នឹងខ្លួន កូនប្រុសស្រីក៏មិនលុះក្នុងដំបូន្មាន ទ្រព្យសម្បត្តិក៏អន្តរធាន ទាំងនេះក៏ជាហេតុជាប្រធានធ្វើបុរសនោះឲ្យដល់នូវសេចក្ដីវិនាសដែរ។

**១០-អតីតយោព្វនោ បោសោ។ល។ តំ បរាភវតោ មុខំ**

សេចក្ដីថា នរជនណាមួយ មានវ័យកន្លងហួសផុតទៅហើយ ធ្មេញបាក់គ្រហុប សក់ស្កូវព្រោង ភ្នែកងងឹតថែមវែនតាឡើងជាបួន សាច់ស្បែកជ្រីវជ្រួញយុរយារ មិនគិតរូបអាត្មា ទៅនាំយកឯស្រីក្រមុំដោះក្បំក្រពុំដូចផ្លែទម្លាប់ សាច់

ខ្ញីទន់ល្វន់ល្វាស សត្រសូលដូចបណ្ដូលចេក មកធ្វើជាភរិយា សេចក្ដីតម្រេកត្រេកត្រអាលដោយកាមរោគ មិនល្មមគ្រាន់ដល់ចិត្តភរិយា ដ្បិតខ្លួនគេក្មេងខ្លួនឯងចាស់ ធ្វើដូចម្ដេចគេនឹងស្រឡាញ់ពេញចិត្តបាន សេចក្ដីប្រច័ណ្ឌក៏កើតមានឡើង កើតទុក្ខក្ដៅក្រហាយរោលរាលក្នុងសន្ដាន ព្រោះរាគៈគ្របសង្កត់ ជួនកាលកើតទុក្ខស្លាប់ទាំងខ្លួនក៏មាន ហេតុនោះក៏ជាប្រធានៃសេចក្ដីវិនាសដែរ។

**១១-ឥត្ថី សោណ្ឌី វិកិរិណី។ ល។ តំ បរាភវតោ មុខំ**

សេចក្ដីថា បុរសណាមួយលើកតម្កើងនូវស្ត្រីអ្នកលេង ស៊ីផឹកខ្ជះខ្ជាយឲ្យជាធំក្នុងផ្ទះ ពុំនោះសោតស្ត្រីណាមួយលើកតម្កើងបុរសមានសភាពដូច្នោះដែរឲ្យជាម្ចាស់ផ្ទះ ជាមនុស្សខ្ជះខ្ជាយ ចាយវាយឥតសណ្ដាប់ធ្នាប់ បុរសស្ត្រីនោះនឹងមានសេចក្ដីហិនហោច ខ្សត់ខ្សោយក្រីក្រលំបាកវេទនា ហេតុនោះក៏ជាប្រធាននៃសេចក្ដីវិនាសដែរ។

**១២-អប្បភោគោ មហាតណ្ហា។ល។ តំ បរាភវតោ មុខំ**

សេចក្ដីថា បុរសណាមួយ កើតក្នុងត្រកូលក្សត្រមានភោគសម្បត្តិនិងបរិវារសម្បត្តិតិច ចំណេះវិជ្ជាតិច តែមានសេចក្ដីប្រាថ្នាលោភលន់ពន់ប្រមាណចង់សោយរាជ្យជាម្ចាស់ផែនដី ដែលមិនគប្បីខ្លួននឹងទទួលបាន ម្ល៉ោះហើយចែកចាយទ្រព្យសម្បត្តិ ដែលមានចំនួនតិចតួចស្ដួចស្ដើងបញ្ចុះបញ្ចូលមនុស្សទាំងឡាយ មានសេនាយោធាជាដើម លុះមិនបានសម្រេចដូចបំណងអាត្មា ខ្លួនដល់នូវទោសជាទម្ងន់ ហេតុនោះក៏ជាប្រធាននៃសេចក្ដីវិនាសដែរ។

ពុទ្ធដីកាក្នុងបរាភវសូត្រទាំង១២បទនេះ បើយើងពិនិត្យគិតតាមលម្អាននេះទៅ យើងនឹងបានយល់ថា ត្រូវពិតដូចព្រះពុទ្ធដីកានេះមែន។

ម្យ៉ាងទៀត ព្រះអង្គបង្ហាញប្រយោជន៍បច្ចុប្បន្ន៤យ៉ាងទៀតគឺ

**១-ឧដ្ឋានសម្បទា** ឲ្យមានព្យាយាមក្នុងការរកចិញ្ចឹមជីវិត។

**២-អារក្ខសម្បទា** ឲ្យចេះថែរក្សាទ្រព្យសម្បត្តិ ដែលកើតឡើងដោយសេចក្ដីព្យាយាមនោះ។

**៣-កល្យាណមិត្តតា** ឲ្យរកមនុស្សល្អធ្វើជាមិត្តភ័ក្តិ

**៤-សមជីវិតា** ឲ្យចេះចាយវាយទ្រព្យសម្បត្តិតាមសមគួរដល់របរដែលខ្លួនរកបាន។

- ព្រះអង្គប្រដៅមនុស្សទាំងអស់ឲ្យចេះសង្គ្រោះគ្នាទៅវិញទៅមកតាមជាន់តាមថ្នាក់ ដូចមាតាបិតានិងបុត្តធីតា គ្រូនិងសិស្ស ភរិយានិងស្វាមី មិត្តសំឡាញ់និងមិត្តសំឡាញ់ផងគ្នា ចៅហ្វាយនាយនិងកម្មករ ព្រះមហាក្សត្រនិងប្រជាពលរដ្ឋ។

- ព្រះអង្គប្រដៅមនុស្សឲ្យចេះសម្អាតរាងកាយ សម្អាតទីលំនៅនិងសម្លៀកបំពាក់ជាដើម ដែលក្នុងបាលីលោកហៅថា **វត្ថុវិសុទ្ធកិរិយា**។

ព្រះធម៌ ដែលនាំយកមកពន្យល់បន្តិចបន្តួចប៉ុណ្ណោះ គ្រាន់តែឲ្យឃើញថាជាពាក្យប្រៀនប្រដៅ មានប្រយោជន៍ក្នុងបច្ចុប្បន្ននេះឯង។

ព្រះពុទ្ធដីកានៃព្រះសម្ពុទ្ធទាំងអស់ បើអស់លោកអ្នកឯណាមួយបានសិក្សា បានសង្កេតពិនិត្យមើលឲ្យសព្វគ្រប់ ហើយប្រតិបត្តិតាម គង់នឹងបានដឹងថា ព្រះពុទ្ធប្រាកដជាអ្នកវិទ្យាសាស្ត្រខាងផ្លូវចិត្ត ជាអ្នកដឹកនាំមនុស្សឲ្យដើរតាមផ្លូវសន្តិភាព ស្ងប់កាយស្ងប់ចិត្ត មិនឲ្យកើតវិវាទឈ្លោះទាស់ទែងគ្នា ដែលក្លាយទៅជាសង្គ្រាម កាប់ចាក់សម្លាប់គ្នា បង្ហូរឈាមគ្នារវាងមនុស្សនិងមនុស្សឡើយ។

រៀបរាប់មកអំពីតម្លៃនៃព្រះពុទ្ធសាសនា ដែលដឹកនាំមនុស្សឲ្យមានប្រយោជន៍ក្នុងបច្ចុប្បន្ននិងបរលោកសន្មតថាចប់តែប៉ុណ្ណោះ។

# ព្រះពុទ្ធសាសនាជាសាសនា នាំទៅកាន់សេចក្ដីសុខ

ព្រះពុទ្ធសាសនា ជាសាសនានាំសេចក្ដីសុខមកឲ្យ:

**១-ចំពោះខ្លួន**

**២-ចំពោះគ្រួសារ**

**៣-ចំពោះជាតិ**

**៤-ចំពោះសកលលោក។**

## អធិប្បាយ

### ១-ព្រះពុទ្ធសាសនានាំសេចក្ដីសុខមកឲ្យចំពោះខ្លួន

អ្នកកាន់ព្រះពុទ្ធសាសនា ឬអ្នកដែលសិក្សាព្រះពុទ្ធសាសនា ដែលបានប្រតិបត្តិតាមព្រះពុទ្ធោវាទ មានធ្វើទាន រក្សាសីលជាដើម តែងបានសេចក្ដីសុខចំពោះខ្លួន។

ទាន គឺការធ្វើអំណោយចំពោះស្មូមយាចក ចំពោះអ្នកក្រីក្រលំបាកតោកយ៉ាក ចំពោះសមាគម ចំពោះក្រុម ចំពោះព្រះសង្ឃជាដើម ឈ្មោះថា ជាការសម្រាលនូវសេចក្ដីទុក្ខលំបាកចំពោះសត្វលោក ។ ការដែលធ្វើសេចក្ដីទុក្ខរបស់អ្នកដទៃឲ្យអន់ថយចុះ ឈ្មោះថា ឲ្យសុខដល់អ្នកដទៃ។ អ្នកណាឲ្យសុខដល់អ្នកដទៃ អ្នកនោះនឹងបានសុខមកខ្លួនវិញ។ បើទ្រង់ស្ដេចយាងទៅកន្លែងណា ប្រជារាស្ត្រខ្មែរទាំងប្រុស ស្រី ក្មេង ចាស់ អ្នកមាន អ្នកក្រ តែងតែចាំទទួលត្រេកអរចំពោះព្រះអង្គមានខ្លះអុជទៀនធូបធ្វើសក្ការបូជាព្រះអង្គទុកព្រះអង្គជាព្រះមហាវីរបុរសនៃប្រជាជាតិខ្មែរទាំងមូល។ នេះមិនមែនមកពីអ្វី គឺមកពីទ្រង់មានព្រះមហាករុណាទិគុណ ទ្រង់ធ្វើព្រះអំណោយឥតចំពោះមុខ គឺថាអ្នកណា

មាន ទុក្ខព្រះអង្គទ្រង់ជួយសម្រាលទុក្ខទៅ អ្នកណាមានភ័យ ទ្រង់ព្រះពិចារណា លៃលកធ្វើភ័យនោះឲ្យបាត់ទៅ ដូចជាទ្រង់កសាងគេហដ្ឋានប្រទានដល់អ្នកក្រីក្រ ឬសាងសាលារៀន ឬក៏ទ្រង់ចូលព្រះរាជកុសលសាងវត្តអារាម កុដិព្រះវិហារជាដើម ទាំងអស់នេះធ្វើឲ្យព្រះអង្គមានព្រះអាយុ ព្រះវណ្ណៈ ព្រះយស ព្រះកេរ្តិ៍ឈ្មោះ សុខ និងកម្លាំងដ៏លើសលុប សមដូចពុទ្ធភាសិតក្នុងខុទ្ទកនិកាយ ឥតិវុត្តកៈ សុត្តន្តបិដកថា

**អគ្គស្មិំ ទានំ ទទតំ អគ្គំ បុញ្ញំ បវឌ្ឍតិ**

**អគ្គំ អាយុ ច វណ្ណោ ច យសោ កិត្តិ សុខំ ពលំ ។**

ប្រែថា បុណ្យដ៏ប្រសើរលើស រមែងចម្រើនដល់ពួកជនអ្នកឲ្យទានក្នុងវត្ថុ (អ្នកទទួល) ដ៏ប្រសើរលើស អាយុ វណ្ណៈ យស កេរ្តិ៍ឈ្មោះ សុខ និងកម្លាំងដ៏ប្រសើរលើសក៏ចម្រើនដែរ។

ព្រោះហេតុដូច្នេះ ទានដែលបុគ្គលធ្វើដោយល្អចំពោះជនដទៃតែងនាំសុខមកឲ្យចំពោះខ្លួនវិញ សមដូចពុទ្ធភាសិតក្នុងគម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាត ទានវគ្គថា

**សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ។**

ប្រែថា អ្នកមានប្រាជ្ញា ជាអ្នកឲ្យនូវសេចក្តីសុខ ( ដល់អ្នកឯទៀតហើយ ) រមែងបាននូវសេចក្តីសុខ ( នោះមកខ្លួនវិញ )។

មិនតែប៉ុណ្ណោះ អ្នកធ្វើទានរមែងចម្រើនដោយបុណ្យជាយ៉ាងក្រៃពេក ព្រមទាំងអាយុ វណ្ណៈ យស កេរ្តិ៍ឈ្មោះ សុខ និងកម្លាំងដ៏លើស ។ អ្នកធ្វើទានរមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃជនទាំងឡាយដ៏ច្រើន។

ព្រោះហេតុដូច្នេះ អ្នកធ្វើទានតែងមានចិត្តភក្តី កិត្តិនាមល្បីខ្ចរខ្ចាយទៅគ្រប់ទិសទាំង៨ ដូចសម្តេចព្រះឧបយុវរាជ ទ្រង់បានស្ថាបនានូវក្រុមសង្គហ-ជាតិ ដើម្បីទ្រង់ធ្វើព្រះអំណោយ ចំពោះអ្នករងគ្រោះថ្នាក់ដោយអគ្គិភ័យ ឃាតកភ័យ និងចំពោះសេចក្តីទុក្ខគ្រប់យ៉ាងរបស់ជនតូចតាចជាដើម ។ល។ ទ្រង់បាន

បំពេញព្រះរាជបេសកកម្ម ព្រមទាំងធ្វើជាតិឲ្យបានឯករាជ្យ ដោយសម្បូណ៌ ឧបត្ថម្ភព្រះពុទ្ធសាសនាឲ្យរុងរឿងចម្រើនបានជាព្រះកិត្តិនាមរបស់ព្រះអង្គ លេចឮរន្ទឺ ទៅដល់ពលរដ្ឋខ្មែរគ្រប់រូបក្នុងព្រះរាជអាណាចក្រទាំងមូល ព្រមទាំង នានាប្រទេសពេញសកលលោក។ ដោយហេតុនេះហើយ បានជា ពលរដ្ឋខ្មែរ មានសេចក្ដីស្នេហាស្រឡាញ់ព្រះអង្គ ថ្វាយព្រះនាមព្រះអង្គថា ព្រះបិតា ឯករាជ្យ។

ចំណែកសីលនោះ ក៏ឲ្យសុខចំពោះខ្លួនដែរ ព្រោះថា អ្នកមានសីល៥គឺ ការមិនសម្លាប់សត្វ១ ការមិនលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ១ ការមិនប្រព្រឹត្ត កន្លងក្នុងកាម១ ការមិនភូតកុហក១ ការមិនសេពសុរានិងមេរ័យ១ ។ សីល ទាំង៥នេះ ជាករណីយកិច្ចរបស់ឧបាសក ឧបាសិកាទាំងឡាយ។ បើពុទ្ធមាមក ជនបានប្រព្រឹត្តប្រតិបត្តិតាមព្រះពុទ្ធោវាទនេះពេញលក្ខណៈហើយ ក៏អាចនឹង ចៀសវាងនូវកំហុសក្នុងលោកិយ មានការក្ដីក្ដាំ ការឈ្លោះទាស់ទែងគ្នា ការ ទទួលទណ្ឌកម្ម មានការជាប់គុកច្រវាក់ខ្នោះឃ្នងជាដើម។ ការធ្វើខ្លួនឲ្យផុតពី ទណ្ឌកម្មខាងផ្លូវលោកនេះឯងហើយថា បានសុខចំពោះខ្លួន។

សីលធម៌នេះជាទីពឹងផ្អែករបស់កុលបុត្រទាំងឡាយ ក្នុងព្រះពុទ្ធសាសនា ជាទឹកដ៏បរិសុទ្ធស្អាត សម្រាប់ជម្រះនូវមន្ទិលរបស់សត្វទាំងឡាយក្នុងលោក នេះ ជាគុណជាតិដ៏ត្រជាក់ក្រៃលែង អាចរំងាប់នូវសេចក្ដីក្រហល់ក្រហាយ របស់សត្វទាំងឡាយបាន ជាក្លិនដែលអាចបក់ទៅបាន ទាំងបណ្ដោយខ្យល់ ទាំងច្រាសខ្យល់ ជាជណ្ដើរកែវសម្រាប់ឡើងទៅកាន់ស្ថានសួគ៌ ស្ថានព្រហ្ម ជា មាគ៌ាដ៏វិសេសវិសាល សម្រាប់ទៅកាន់លោកុត្តរភូមិ និងព្រះនិព្វាន។ សីលជា មូលដ្ឋាននៃគុណទាំងឡាយ មានអានិសង្សអាចឲ្យសុខចំពោះខ្លួនមែនពិត។

ត្រង់បទនេះមានសម្អាងដូចពុទ្ធគាថាមួយបទក្នុងសុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថា ថា

**សីលំ សេតុ មហេសក្ខោ សីលំ គន្ធោ អនុត្តរោ**

**សីលំ វិលេបនំ សេដ្ឋំ យេន ជាតិ ទិសោ ទិសំ។**

ប្រែថា សីលជាស្ពានដ៏មានសក្តិធំ សីលជាក្លិនដែលមិនមានក្លិនដទៃប្រសើរជាង សីលជាគ្រឿងលាបលនយ៉ាងប្រសើរខ្ចរខ្ចាយទៅគ្រប់ទិស។

ដោយហេតុនេះហើយ បានជាថាទាននិងសីល បើអ្នកណាបានបំពេញហើយ រមែងនាំសុខមកឲ្យចំពោះខ្លួនមែនពិត។

ក្រៅពីនេះនៅមានធម៌ឯទៀត គឺកតញ្ញូតាធម៌សេចក្តីដឹងចំពោះគុណអ្នកដ៏មានគុណ មានមាតាបិតា គ្រូបាអាចារ្យ និងសច្ចធម៌ សប្បុរិសធម៌។ល។ ក៏នាំសុខមកឲ្យចំពោះខ្លួនដែរ។ ព្រោះហេតុនេះបានជាថា ព្រះពុទ្ធសាសនាជាសាសនានាំសុខមកឲ្យចំពោះខ្លួន។

**២-ព្រះពុទ្ធសាសនា នាំសេចក្តីសុខមកឲ្យចំពោះគ្រួសារ**

គ្រួសារគឺមាតាបិតា បុត្រធីតា កូនប្រសាប្រុស កូនប្រសាស្រី ជីដូនជីតាក្មួយ មាមីងជាដើម។ អ្នកទាំងអស់ក្នុងគ្រួសារ ត្រូវមានករណីយកិច្ច ដែលត្រូវបំពេញទៅវិញទៅមក គឺស្វាមីចំពោះភរិយា មាតាបិតាចំពោះបុត្រធីតាជាដើម។ ដូចព្រះពុទ្ធោវាទក្នុងសិង្គាលោវាទសូត្រ ដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងចំពោះសិង្គាលមាណពថា

ករណីយកិច្ចដែលមាតាបិតា ត្រូវទំនុកបម្រុងបុត្រធីតា មានស្ថាន៥គឺ

១- ហាមមិនឲ្យបុត្រធីតាប្រព្រឹត្តអំពើទុច្ចរិត

២- ទូន្មានបុត្រធីតាឲ្យតាំងនៅក្នុងកុសលធម៌

៣- ទូន្មានបុត្រធីតាឲ្យសិក្សាសិល្បៈវិជ្ជា

៤- រកភរិយាឲ្យបុត្រ ឬស្វាមីឲ្យធីតា តាមសមគួរ

៥- ចែកទ្រព្យសម្បត្តិដល់បុត្រធីតា តាមសមគួរ។

បើមាតាបិតា បានប្រព្រឹត្តករណីយកិច្ចទាំង៥ស្ថាន ចំពោះបុត្រធីតាតាមព្រះពុទ្ធោវាទខាងលើនេះ ឈ្មោះថា មាតាបិតានាំសេចក្តីសុខមកឲ្យចំពោះបុត្រធីតា ហើយគ្រួសារនេះ នឹងបានសេចក្តីសុខជាភិយ្យោភាពតទៅ។

លំដាប់តមក ព្រះអនាវរណញ្ញាណទ្រង់ទូន្មានសិង្គាលមាណពថា

មាតាបិតាទុកជាបុរត្ថិមទិស (ទិសបូព៌ា) គឺបុត្រធីតាគប្បីទំនុកបម្រុងដោយស្ថាន៥គឺ

១- លោកបានចិញ្ចឹមខ្លួមកហើយ ត្រូវខ្លួនចិញ្ចឹមលោកវិញ

២- ជួយធ្វើកិច្ចការរបស់លោក

៣- ទំនុកបំរុងវង្សត្រកូលមិនឲ្យសាបសូន្យ

៤- ប្រតិបត្តិខ្លួនឲ្យសមគួរជាអ្នកទទួលមត៌ក

៥- កាលបើលោកធ្វើមរណកាល ត្រូវធ្វើបុណ្យឧទ្ទិសផលជូនលោក។

ភរិយាទុកជាបច្ឆិមទិស (ទិសបស្ចិម) គឺស្វាមីគប្បីទំនុកបម្រុងដោយស្ថាន៥គឺ

១- រាប់អានលើកមុខថាជាភរិយា

២- មិនមើលងាយភរិយា

៣- មិនប្រព្រឹត្តកន្លងចិត្ត គឺមិនក្បត់ចិត្តភរិយា

៤- ប្រគល់ភារៈជាធំក្នុងផ្ទះឲ្យ

៥- ឲ្យគ្រឿងតែងខ្លួន។

ភរិយាគប្បីប្រតិបត្តិស្វាមីដោយស្ថាន៥គឺ

១- ចាត់ការងារដោយល្អ

២- សង្គ្រោះញាតិខាងស្វាមីដោយល្អ

៣- មិនប្រព្រឹត្តកន្លងចិត្តស្វាមី គឺមិនក្បត់ចិត្តប្ដី

៤- រក្សាទ្រព្យដែលស្វាមីរកបានមក

៥- មិនខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង។

ចៅហ្វាយនាយទុកជាហេដ្ឋិមទិស (ទិសខាងក្រោម) គឺចៅហ្វាយនាយគប្បីទំនុកបម្រុងដោយស្ថាន៥គឺ

១- ចាត់ការងារឲ្យធ្វើតាមសមគួរដល់កម្លាំង

២- ឲ្យភោជនាហារនិងរង្វាន់
៣- ព្យាបាលក្នុងវេលាមានជំងឺ
៤- ចែកភោជនាហារដ៏មានឱជារសប្លែកៗឲ្យបរិភោគ
៥- បើកឲ្យសប្បាយក្នុងកាលគួរ។

ទាសកម្មករគប្បីប្រតិបត្តិចៅហ្វាយនាយដោយស្ថាន៥គឺ
១- ក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ
២- លែងធ្វើការងារក្រោយចៅហ្វាយនាយ
៣- កាន់យកតែរបស់ដែលចៅហ្វាយនាយឲ្យ
៤- ធ្វើការងារដោយយកចិត្តទុកដាក់
៥- នាំគុណសម្បត្តិរបស់ចៅហ្វាយនាយទៅសរសើរក្នុងទីដទៃ។

ព្រះពុទ្ធោវាទចំពោះសិង្គាលមាណពនេះ បើគ្រួសារនីមួយៗយកទៅប្រព្រឹត្ត ប្រតិបត្តិតាម មុខជានឹងបានសេចក្តីសុខចម្រើនយ៉ាងពិតប្រាកដ ព្រោះថាព្រះពុទ្ធោវាទនេះ ព្រះអង្គទ្រង់លៃទៅតាមអជ្ឈាស្រ័យលក្ខណៈចិត្ត ចរិត និស្ស័យ គុណសម្បត្តិ គុណវិបត្តិ មនោសញ្ចេតនា។ល។ នៃមនុស្សខាងលើ បានជាថា ករណីយកិច្ចដែលមនុស្សទាំងឡាយត្រូវបំពេញនោះ នឹងមានផល មានប្រយោជន៍ពិតៗ។ ដោយហេតុនេះហើយ បានជាថា ព្រះពុទ្ធសាសនាជាសាសនានាំសុខមកឲ្យចំពោះគ្រួសារ។

## ៣-ព្រះពុទ្ធសាសនានាំសេចក្តីសុខមកឲ្យចំពោះជាតិ

នៅប្រទេសកម្ពុជាយើង មានព្រះភិក្ខុសង្ឃជាធម្មកថិក តែងនិមន្តទៅគ្រប់និគម ជនបទ ដើម្បីនឹងសម្តែងធម៌ទេសនាចំពោះមហាជនខ្មែរ ពន្យល់បំភ្លឺពួកពុទ្ធសាសនិកជន ឲ្យប្រព្រឹត្តប្រតិបត្តិតាមព្រះពុទ្ធោវាទ ឲ្យមានសាមគ្គីភាព ដូច្នេះឈ្មោះថាលោកនាំសុភមង្គល និងសេចក្តីសុខមកឲ្យពលរដ្ឋខ្មែរ។ ម្យ៉ាងទៀត គោលបំណងនៃពុទ្ធសាសនាគឺ វិសិដ្ឋភាពជាមនុស្សជាតិ១ ការលើកនិងសម្អាតទឹកចិត្ត១ ការស្វែងរកសុភមង្គលនិងសេចក្តីស្ងប់១ ការប្រយុទ្ធនឹង

រោគាពាធនិងទុគ្គតភាព១ ការរំកិលទៅជិតព្រះនិព្វានបើមិនទាន់បានដល់១។ បើជនជាតិខ្មែរប្រតិបត្តិទៅតាមគោលបំណងនៃព្រះពុទ្ធសាសនានេះ ព្រះពុទ្ធសាសនានឹងបានឡើងទៅកាន់វឌ្ឍនភាព ជាតិខ្មែរនឹងបានជួបប្រទះនូវសុភមង្គល និងសម្បូណ៌សប្បាយពុំខាន មិនតែប៉ុណ្ណោះអ្នកដែលប្រតិបត្តិតាមព្រះពុទ្ធោវាទ នឹងបានជួបប្រទះនូវលាភ យស សេចក្តីសរសើរគ្រប់យ៉ាងមិនខាន សមដូចពុទ្ធភាសិតក្នុងខុទ្ទកនិកាយធម្មបទថា **ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ។**

ប្រែថា យសតែងចម្រើនដល់អ្នកមានព្យាយាមវាងវៃ១ អ្នកមានស្មារតី១ អ្នកមានការងារស្អាត១ អ្នកមានប្រក្រតីពិចារណារួចទើបធ្វើ១ ប្រុងប្រយ័ត្ន១ អ្នកមានប្រក្រតីរស់នៅដោយធម៌១ អ្នកមិនប្រមាទ១។

ពុទ្ធសាសនាមានពុទ្ធភាសិតជាអនេកប្បការ តែខ្ញុំគ្រាន់តែយកគាថាមួយបទមកចុះក្នុងទីនេះ ដើម្បីបង្ហាញបងប្អូនរួមជាតិថា ការប្រព្រឹត្តប្រតិបត្តិទៅតាមពុទ្ធភាសិតនេះ អាចរចនាបុគ្គលនីមួយៗឲ្យមានគុណធម៌ សីលធម៌ដ៏ឧត្តុង្គឧត្តម បើបុគ្គលចម្រើនហើយ ជាតិក៏ចម្រើនដែរ។

ដើម្បីនឹងឲ្យជនជាតិខ្មែរចេះវិជ្ជាខាងព្រះពុទ្ធសាសនា មានតែព្រះសង្ឃនេះឯង ជាមគ្គុទ្ទេសក៍ណែនាំពន្យល់បំភ្លឺពួកពុទ្ធបរិស័ទទាំងឡាយឲ្យដើរតាមពីក្រោយ។ ពិតមែនតែព្រះសង្ឃទាំងឡាយនេះមិនមែនជាព្រះខីណាស្រេពឋិតនៅជាសម្មតិសង្ឃនៅឡើយ ក៏គង់ការទេសនារបស់លោក ជាទេសនាល្មមជឿតដោយយកពុទ្ធភាសិតជាមូលដ្ឋាន។ ឧបាសក ឧបាសិកាណាបានស្តាប់ធម៌ទេសនានេះហើយ ត្រង់សេចក្តីណាដែលងឿងឆ្ងល់ បានសាកសួរពន្យល់សព្វគ្រប់ហើយ យកពុទ្ធភាសិតដែលស្តាប់បាន យល់ច្បាស់លាស់នោះ មកអនុវត្តចំពោះជីវភាពប្រចាំថ្ងៃ ឬជាមូលដ្ឋាននៃការប្រព្រឹត្តប្រតិបត្តិ ឧបាសក ឧបាសិកានោះ ឈ្មោះថាបានរចនាខ្លួនឲ្យផុតចាកអបាយភូមិទាំង៤ និងផុតចាកអកុសលទាំងឡាយបាន តាំងខ្លួននៅក្នុងសង្គមដោយប្រពៃ ដូចបានយក

ថ្មមួយដុំមកសាងគេហស្ថានជាតិ គឺប្រទេសកម្ពុជាឲ្យបានមុតមាំឡើង។ ព្រោះហេតុដូច្នេះ បានជាថាព្រះពុទ្ធសាសនានាំសុខមកឲ្យចំពោះជាតិ។

**៤-ព្រះពុទ្ធសាសនានាំសេចក្តីសុខមកឲ្យចំពោះសកលលោក**

សម្តេចព្រះឧបយុវរាជ ទ្រង់មានព្រះបន្ទូល១វគ្គ ក្នុងព្រះរាជសុន្ទរកថាដែលទ្រង់ថ្លែងក្នុងឱកាសបើកការសិក្សាពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងសម្ពោធគ្រឹះស្ថានព្រះសីហនុ កាលពីថ្ងៃទី១០ មិថុនា ១៩៥៨ថា

**ទោះបីនៅក្នុងសម័យបរមាណូយើងនេះក៏ដោយ ព្រះពុទ្ធសាសនាក៏នៅតែមានស្ថិរភាពនិងជាក់ស្តែងដដែល។ ពិភពលោកសព្វថ្ងៃដែលឋិតនៅក្នុងការព្រួយបារម្ភដោយអនាគតមិនភ្លឺស្វាង បើប្រសិនជាយកធម៌ព្រះពុទ្ធមកពិចារណា អាចនឹងដោះស្រាយអស់ទាំងបញ្ហាគ្រប់យ៉ាងរបស់ខ្លួនបាន ទុកជាបញ្ហានោះស្មុគស្មាញយ៉ាងណាក៏ដោយ។ នេះហើយដែលជាសេចក្តីជឿស៊ប់នៃប្រជាជាតិ ដែលមានចំនួនកាន់តែច្រើនឡើងក្នុងលោក សូម្បីតែអ្នកកាន់សាសនាដទៃ ក៏ចាប់ផ្តើមសិក្សាលទ្ធិព្រះពុទ្ធសាសនាដែរ។ ស្ទើរតែគ្រប់ប្រទេសក្នុងពិភពលោក មានអ្នករាប់អាននិងសមាគមអ្នកពិនិត្យស្រាវជ្រាវនូវធម៌នៃព្រះពុទ្ធអង្គ។**

មែនពិត ព្រះរាជបន្ទូលនៃសម្តេចសហជីវិន ដែលទ្រង់ថ្លែងខាងលើនេះ គឺទ្រង់បញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធសាសនា ជាសាសនាដោះស្រាយនូវបញ្ហាពិភពលោក ដែលឋិតនៅក្នុងការតានតឹងព្រួយបារម្ភ ឲ្យរួចចាកការតានតឹងព្រួយបារម្ភបាន បើពិភពលោកបានយកទៅពិចារណា ទៅពិសោធ ទៅប្រតិបត្តិតាមដោយម៉ឺងម៉ាត់។

ព្រះបន្ទូលនេះ មានអត្ថន័យគម្ពីរភាពជ្រាលជ្រៅ ត្រូវតាមគោលពុទ្ធភាសិតពិតមែន ព្រោះព្រះពុទ្ធសាសនា ជាសាសនាប្រដៅឲ្យលះបង់អកុសលធម៌ មានទិដ្ឋិ មានះ លោភៈ ទោសៈ មោហៈ ជាដើម ឲ្យចម្រើនកុសលធម៌មានអហិង្សា និងមេត្តាករុណាជាដើម បើមហាអំណាចក្នុងពិភពលោកបាន

យកព្រះពុទ្ធសាសនាទៅត្រិះរិះពិចារណា ទៅពិសោធ ទៅប្រតិបត្តិតាម ព្រមទាំងបានលះបង់អកុសលធម៌ ចម្រើនកុសលធម៌ទាំងនោះ តាមគន្លង ដែលព្រះពុទ្ធសាសនាប្រៀនប្រដៅហើយ មុខជាឈប់ប្រកាន់គ្នា ស្រឡាញ់រាប់អានយោគយល់គ្នាទៅវិញទៅមក ឥតទាស់ទែងខ្វែងគំនិតគ្នា ឥតធ្វើសង្គ្រាមនឹងគ្នា ឡើយ កាលបើដូច្នេះ លោកសន្និវាសនេះ មុខជានឹងទៅជាស្ថានសួគ៌មួយ មានតែសេចក្តីសុខសេចក្តីចម្រើន ឥតទុក្ខព្រួយជាពិតប្រាកដពុំខាន។

ព្រោះហេតុនោះ បានជាថា ព្រះពុទ្ធសាសនាជាសាសនានាំសេចក្តីសុខមកឲ្យចំពោះសកលលោក។

# រឿងសុនក្ខត្តលិច្ឆវិបុត្ត

## ក្នុងសុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសក ត្រង់សុនក្ខត្តសូត្រ ហេតុអ្វីបានជាពួកមនុស្សបុថុជ្ជនមានអធ្យាស្រ័យ ឱនទៅរកលោកាមិសខ្លាំងម្ល៉េះ ?

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ជិតក្រុងវេសាលី។ គ្រានោះ មានភិក្ខុជាច្រើនរូបប្រកាសអរហត្តផលក្នុងសំណាក់ព្រះដ៏មានព្រះភាគថា «ខ្ញុំព្រះអង្គទាំងឡាយដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ខ្ញុំព្រះអង្គទាំងឡាយបានចប់ហើយ កិច្ចដែលគួរធ្វើបានធ្វើស្រេចហើយ កិច្ចដទៃទៀតក្រៅពីនេះគ្មានទៀតទេ»។

សុនក្ខត្តលិច្ឆវិបុត្តបានឮពាក្យភិក្ខុទាំងនោះប្រកាសអរហត្តផល ដូច្នេះហើយក៏នឹកសង្ស័យ ទើបចូលទៅគាល់ព្រះសាស្តាក្រាបថ្វាយបង្គំរួចហើយទូលសួរថា «បពិត្រព្រះអង្គដ៏ចម្រើន! ភិក្ខុទាំងនោះបានប្រកាសអរហត្តផលដោយប្រពៃមែនពិតឬ ភិក្ខុពួកខ្លះក្នុងទីនុ៎ះបានប្រកាសអរហត្តផលដោយការស្មានដែរ ?»។

ព្រះដ៏មានព្រះភាគត្រាស់ថា «ម្នាលសុនក្ខត្ត! ភិក្ខុពួកខ្លះប្រកាសអរហត្តផល ដោយប្រពៃមែនក៏មាន ដោយការស្មានក៏មាន។ ម្នាលសុនក្ខត្ត! កាមគុណមាន៥ប្រការគឺរូប១ សំឡេង១ ក្លិន១ រស១ ផោដ្ឋព្វៈ១ ដែលគួរដឹងច្បាស់ដោយភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួរជាទីរីករាយ។

ម្នាលសុនក្ខត្ត! មួយទៀត ហេតុដែលនាំឲ្យបុគ្គលពួកខ្លះក្នុងលោកនេះមានអធ្យាស្រ័យឱនទៅរកលោកាមិសរមែងមាន។ ពាក្យសម្តីរបស់បុគ្គលដែលមានអធ្យាស្រ័យឱនទៅរកលោកាមិស តាំងផ្តើមនិយាយឡើងតែងទៅរកកាមគុណ

ផង បុគ្គលនោះតែងត្រិះរិះរឿយៗ ពិចារណារឿយៗនូវហេតុដែលប្រព្រឹត្តទៅតាមកាមគុណនោះផង តែងគប់រកបុរសបែបនេះឯង តែងគោរពតាមបុរសបែបនោះផង ចំណែកខាងពាក្យសម្តីដែលគេនិយាយប្រកបដោយអានេញ្ជសមាបត្តិ បុគ្គលនោះ មិនចង់ស្តាប់ផង មិនផ្ទង់ត្រចៀកផង មិនតាំងចិត្តចង់ដឹងផង មិនគប់រកបុរសបែបនោះផង មិនគោរពតាមបុរសបែបនោះផង ប្រៀបដូចជាបុរសចេញអំពីស្រុកឬនិគមរបស់ខ្លួនដែលជាទីធ្លាប់នៅយូរហើយ។ បុរសនោះកាលបើឃើញអ្នកណាមួយទើបនឹងចេញពីស្រុកឬនិគមនោះមក ក៏សាកសួរអំពីស្រុកនិគមនោះ ដែលជាដែនមានសេចក្តីក្សេមក្សាន្តផង ជាដែនមានភិក្ខាហារដ៏សម្បូណ៌ផង ជាដែន គ្មានអាពាធផង ចំពោះបុរសនោះៗ និយាយប្រាប់សព្វគ្រប់ហើយ។ ចុះអ្នកសួរនោះ គប្បីស្តាប់ពាក្យសម្តីរបស់គេផ្ទង់ត្រចៀក តាំងចិត្តចង់ដឹង គប់រកបុរសនោះផង គោរពតាមបុរសនោះផងដែរឬទេ? សុនក្ខត្តលិច្ឆវិបុត្តក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ។ ម្នាលសុនក្ខត្តលិច្ឆវិបុត្ត! បុគ្គលដែលមានអធ្យាស្រ័យឱនទៅរកលោកាមិស ក៏ដូចជាបុរសអ្នកសួរគេអំពីស្រុកឬនិគមដែលខ្លួនធ្លាប់នៅពីមុននោះដែរ។

ម្នាលសុនក្ខត្ត! មួយទៀត ហេតុដែលនាំឲ្យបុគ្គលពួកខ្លះក្នុងលោកនេះមានអធ្យាស្រ័យឱនទៅរកអានេញ្ជសមាបត្តិរមែងមាន។ ពាក្យសម្តីរបស់បុគ្គលដែលមានអធ្យាស្រ័យឱនទៅរកអានេញ្ជសមាបត្តិ តាំងផ្តើមនិយាយឡើងតែងទៅរកអានេញ្ជសមាបត្តិនោះ បុគ្គលនោះរមែងត្រិះរិះរឿយៗ ពិចារណារឿយៗនូវហេតុដែលប្រព្រឹត្តទៅតាមអានេញ្ជសមាបត្តិនោះផងតែងគប់រកបុរសបែបនោះផង តែងគោរពបុរសបែបនោះផង ចំណែកខាងពាក្យសម្តីដែលគេនិយាយ ប្រកបដោយលោកាមិស បុគ្គលនោះមិនចង់ស្តាប់ផង មិនគោរពតាមបុរសបែបនោះផង។ ម្នាលសុនក្ខត្ត! ស្លឹកឈើទុំមានពណ៌លឿងជ្រុះចេញចាកទងហើយ មិនគួរនៅខៀវ ខ្ចី ទៀតបានឡើយ យ៉ាងណាមិញ បុគ្គលដែលមានអធ្យាស្រ័យឱនទៅរកអានេញ្ជ សមាបត្តិ រមែងជ្រុះចាកការប្រកបក្នុងលោកាមិស

ក៏យ៉ាងនោះដែរ។

ម្នាលសុនក្ខត្ត! មួយទៀតហេតុដែលនាំឲ្យបុគ្គលពួកខ្លះក្នុងលោកនេះ មានអធ្យាស្រ័យឱនទៅរកអាកិញ្ចញ្ញាយតនសមាបត្តិរមែងមាន។ ពាក្យសម្ដីរបស់បុគ្គលដែលមានអធ្យាស្រ័យឱនទៅរកអាកិញ្ចញ្ញាយតនសមាបត្តិ តាំងផ្ដើមនិយាយឡើង តែងទៅរកអាកិញ្ចញ្ញាយតនសមាបត្តិនោះ តែងគោរពតាមបុរសបែបនោះ ចំណែកខាងពាក្យសម្ដី ដែលគេនិយាយប្រកបដោយអានេញ្ជសមាបត្តិ បុគ្គលនោះមិនចង់ស្ដាប់ផង មិនគោរពតាមបុរសបែបនោះផង។ ប្រៀបដូចដុំថ្មក្រាស់បែកចេញជាពីរភាគមិនជាប់គ្នាវិញបាន យ៉ាងណាមិញ បុគ្គលដែលមានអធ្យាស្រ័យឱនទៅរក អាកិញ្ចញ្ញាយតនសមាបត្តិ ក៏យ៉ាងនោះឯង។

ម្នាលសុនក្ខត្ត! មួយទៀត ហេតុដែលនាំឲ្យបុគ្គលពួកខ្លះក្នុងលោកនេះមានអធ្យាស្រ័យឱនទៅរកនេវសញ្ញានាសញ្ញាយតនសមាបត្តិរមែងមាន។ ពាក្យសម្ដីរបស់បុគ្គលដែលមានអធ្យាស្រ័យឱនទៅរកនេវសញ្ញានាសញ្ញាយតនសមាបត្តិ តាំងផ្ដើមនិយាយឡើង តែងទៅរកនេវសញ្ញានាសញ្ញាយតនសមាបត្តិនោះផង គោរពតាមបុរសបែបនោះផង ចំណែកខាងពាក្យសម្ដី ដែលគេនិយាយប្រកបដោយអាកិញ្ចញ្ញាយតនសមាបត្តិ ក៏បុគ្គលនោះមិនចង់ស្ដាប់ផង មិនគោរពតាមបុរសបែបនេះផង។ ប្រៀបដូចបុរសបរិភោគបាយជាទីគាប់ចិត្តឆ្អែតឆ្អន់ហើយលែងប្រាថ្នាបាយនោះទៀត ព្រោះបាយនោះគេសន្មតថាជារបស់បដិកូល។ ម្នាលសុនក្ខត្ត! បុគ្គលដែលមានអធ្យាស្រ័យឱនទៅរកនេវសញ្ញានាសញ្ញាយតនសមាបត្តិ រមែងខ្ចាក់ចោលនូវ ការប្រកបក្នុងអាកិញ្ចញ្ញាយតនសមាបត្តិនោះយ៉ាងនេះឯង។

ម្នាលសុនក្ខត្ត! មួយទៀត ហេតុដែលនាំឲ្យបុរសបុគ្គលពួកខ្លះក្នុងលោកនេះ មានអធ្យាស្រ័យឱនទៅរកព្រះនិព្វានដោយប្រពៃរមែងមាន។ ពាក្យសម្ដីរបស់បុគ្គលដែលមានអធ្យាស្រ័យឱនទៅរកព្រះនិព្វានដោយប្រពៃ តាំងចាប់

ផ្ដើមនិយាយឡើងតែងទៅរកតែព្រះនិព្វាននោះផង គោរពតាមបុរសបែបនោះផង ចំណែកខាងពាក្យសម្ដីដែលគេនិយាយប្រកបដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ ក៏បុគ្គលនោះមិនចង់ស្ដាប់ផង មិនគោរពតាមបុរសបែបនោះផង។ ប្រៀបដូចដើមត្នោតកំបុតចុង ដុះលូតលាស់ឡើងវិញមិនបាន យ៉ាងណាមិញ បុគ្គលដែលមានអធ្យាស្រ័យឱនទៅរកព្រះនិព្វានដោយប្រពៃ រមែងផ្ដាច់ផ្ដិលនូវការប្រកបក្នុងនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឲ្យអស់រលីងដូចជាដើមត្នោត ដែលគេក្របែលគាស់រំលើងឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយឲ្យជាធម៌លែងមានកំណើតតទៅមុខទៀតហើយ ក៏យ៉ាងនេះឯង។

ម្នាលសុនក្ខត្ត! ហេតុដែលនាំឲ្យភិក្ខុពួកខ្លះក្នុងសាសនានេះ មានសេចក្ដីត្រិះរិះថា សរគឺតណ្ហា និងទោសជាពិសគឺអវិជ្ជា ដែលព្រះសមណៈត្រាស់ហើយថា តែកម្រើកដោយឆន្ទរាគនិងព្យាបាទ សរគឺតណ្ហានោះជារបស់ដែលអាត្មាអញបានលះបង់ហើយ ទោសជាពិសគឺអវិជ្ជា ជារបស់ដែលអាត្មាអញបាននាំចេញហើយដែរ អាត្មាអញមានអធ្យាស្រ័យឱនទៅរកព្រះនិព្វានដោយប្រពៃហើយ សេចក្ដីត្រិះរិះយ៉ាងនេះជាដើមជាសេចក្ដីត្រិះរិះមានប្រយោជន៍ដូច្នេះរមែងមាន។ ភិក្ខុនោះប្រកបរឿយៗនូវអារម្មណ៍មិនជាទីសប្បាយរបស់បុគ្គលដែលមានអធ្យាស្រ័យឱនទៅរកព្រះនិព្វានដោយប្រពៃ។ ភិក្ខុ នោះប្រកបរឿយៗនូវរូបមិនជាទីសប្បាយដោយចក្ខុ ប្រកបរឿយៗនូវសំឡេងមិនជាទីសប្បាយដោយសោតៈ។បេ។ ប្រកបរឿយៗ នូវធម៌ជាទីសប្បាយដោយចិត្ត។ កាលភិក្ខុនោះប្រកបរឿយៗនូវការឃើញរូបមិនជាទីសប្បាយដោយចក្ខុ។ បេ។ រាគៈក៏គ្របសង្កត់ចិត្ត។ ភិក្ខុនោះ លុះត្រូវរាគៈគ្របសង្កត់ចិត្តហើយ ក៏ដល់នូវមរណៈគឺសឹក ឬដល់នូវសេចក្ដីទុក្ខស្មើរតែមរណៈ។ ប្រៀបដូចជាបុរសដែលត្រូវសរត្រាំដោយថ្នាំពិសជោកជាំ ហើយមិត្តអាមាត្យញាតិសាលោហិតរបស់បុរសនោះ ក៏ឲ្យពេទ្យវះយ៉ាងស្ទាត់ជំនាញ។ ពេទ្យវះនោះក៏វះមុខដំបៅរបស់បុរស

នោះដោយសស្ត្រា លុះវះរួចហើយ រាវរកសរដោយគ្រឿងសម្រាប់រាវរក (តង្កៀប) រួចដកសរដែលមានពិសជាទោសសេសសល់នៅឲ្យអស់ចេញ ក៏ដឹងថាពិសជាទោសគ្មានសេសសល់នៅទេ ទើបពេទ្យវះប្រាប់បុរសនោះថា «សររបស់អ្នកយើងបានដកចេញហើយ ពិសជាទោសយើងបាននាំចេញ ហើយឥតមានសេសសល់ឡើយ ល្មមគ្មានអន្តរាយដល់អ្នកហើយ អ្នកគួរបរិភោគតែភោជនដែលជាទីសប្បាយ អ្នកកុំបរិភោគភោជនមិនជាទីសប្បាយឲ្យដំបៅរីកឡើយ អ្នកគួរលាងនិងលាបមុខដំបៅតាមកាលដ៏សមគួរ លុះអ្នកលាងនិងលាបរួចហើយ កុំរុំមុខដំបៅដែលមានខ្ទុះនិងឈាមឡើយ អ្នកកុំដើរហាលខ្យល់នឹងកំដៅថ្ងៃ កាលបើអ្នកដើរ ហាលខ្យល់និងកម្ដៅថ្ងៃ កុំឲ្យលម្អងធូលីរុំមុខដំបៅបានឡើយ។ បុរសនោះគិតថា សររបស់អាត្មាអញ ពេទ្យបានដកចេញហើយ ពិសជាទោស ពេទ្យបាននាំចេញហើយគ្មានសេសសល់ទេ ល្មមគ្មានអន្តរាយដល់អញហើយ។ បុរសនោះបរិភោគភោជនមិនជាទីសប្បាយ ដំបៅក៏រីកឡើង ទាំងមិនលាងមិនលាបមុខដំបៅតាមកាលគួរ ខ្ទុះនិងឈាមក៏រុំមុខដំបៅ បុរសនោះចេះតែដើរហាលខ្យល់និងកម្ដៅថ្ងៃ សត្រូវគឺធូលីក៏រុំមុខដំបៅ មិនរក្សាដំបៅផង មិនផ្សះដំបៅផង មុខដំបៅចេះតែដោរឡើង។ បុរសនោះក៏ដល់នូវមរណៈឬដល់នូវទុក្ខស្មើរតែមរណៈដោយដំបៅដែលដោរឡើងនោះ សេចក្ដីនេះមានឧបមាយ៉ាងណា ឯភិក្ខុអ្នកត្រេកអរទៅក្នុងកាមគុណក៏មានឧបមេយ្យយ៉ាងនោះដែរ។

ម្នាលសុនក្ខត្ត មួយទៀត ហេតុដែលនាំឲ្យភិក្ខុខ្លះក្នុងសាសនានេះមានសេចក្ដីត្រិះរិះថា សរគឺតណ្ហា ទោសជាពិសគឺអវិជ្ជា ដែលព្រះសមណៈត្រាស់ហើយថា តែងកម្រើកឡើងដោយឆន្ទរាគនិងព្យាបាទ សរគឺតណ្ហានោះអាត្មាអញបានលះបង់ហើយ ទោសជាពិសគឺអវិជ្ជា អាត្មាអញបាននាំចេញហើយ អាត្មាអញមានអធ្យាស្រ័យឱនទៅរកព្រះនិព្វានដោយប្រពៃហើយ ដូច្នេះរមែងមាន។ កាលដែលគេកំពុងមានអធ្យាស្រ័យឱនទៅរកព្រះនិព្វានដោយ

ប្រពៃ ភិក្ខុនោះមិនប្រកបរឿយៗនូវអារម្មណ៍មិនជាទីសប្បាយ របស់បុគ្គលអ្នកមានអជ្ឈាស្រ័យឱនទៅរកព្រះនិព្វានដោយប្រពៃឡើយ មិនប្រកបរឿយៗនូវការឃើញរូបមិនជាទីសប្បាយដោយចក្ខុ។បេ។ មិនប្រកបរឿយៗនូវធម៌ជាទីសប្បាយដោយចិត្ត។ កាលភិក្ខុនោះមិនប្រកបរឿយៗនូវអារម្មណ៍មិនជាទីសប្បាយ ដូច្នោះហើយរាគៈក៏មិនគ្របសង្កត់ចិត្តបាន។ កាលភិក្ខុនោះមិនត្រូវរាគៈគ្របសង្កត់ចិត្តហើយ ក៏មិនដល់នូវមរណៈ (មិនសិក) ឬថាមិនដល់នូវទុក្ខស្មើរតែមរណៈ។ ប្រៀបដូចបុរសត្រូវសរត្រាំដោយថ្នាំពិសយ៉ាងជោកជាំ ហើយឲ្យពេទ្យវះមុខដំបៅក៏ខំថែទាំរក្សាដំបៅឲ្យសះជាតាមបណ្ដាំពេទ្យគ្រប់ប្រការ ឥតធ្វេសប្រហែសឡើយបុរសនោះក៏មិនស្លាប់ ឬមិនកើតទុក្ខជិតស្លាប់ សេចក្ដីនេះមានឧបមាយ៉ាងណាភិក្ខុអ្នកមិនត្រេកអរក្នុងកាមគុណក៏មានឧបមេយ្យដូច្នោះដែរ។

ម្នាលសុនក្ខត្ត! ភិក្ខុនោះឯង ជាអ្នកសង្រួមក្នុងផស្សាយតនៈទាំង៦ ដឹងច្បាស់ថា កិលេសជាឫសគល់នៃសេចក្ដីទុក្ខ លុះដឹងដូច្នេះហើយ ក៏ជាអ្នកគ្មានកិលេស ជាអ្នករួចស្រឡះហើយ ព្រោះការអស់ទៅនៃកិលេស នឹងបង្អោនកាយឬនឹងផ្ដេកផ្ដួលចិត្តទៅក្នុងកិលេស ហេតុដូច្នេះមិនដែលមានឡើយ។ ម្នាលសុនក្ខត្ត! ដូចផ្ដិលសំរឹទ្ធិមានពណ៌ មានក្លិន មានរសល្អ តែផ្ដិលនោះប្រឡាក់ថ្នាំពិស។ កាលបើមានបុរសអ្នកចង់តែរស់ មិនចង់ស្លាប់ ចង់តែសុខ ខ្ពើមទុក្ខមកដល់។ បុរសនោះគួរផឹកទឹកផ្ដិលសំរឹទ្ធិនោះដែលខ្លួនដឹងថា អាត្មាអញផឹកទឹកនេះទៅហើយ នឹងដល់នូវមរណៈឬដល់នូវសេចក្ដីទុក្ខស្មើរតែមរណៈដែរទេ?

បពិត្រព្រះអង្គដ៏ចម្រើនគេមិនផឹកទឹកនឹងផ្ដិលសំរឹទ្ធិនោះទេ។

មួយទៀតដូចជាអាសិរពិសមានពិសដ៏សាហាវ។

កាលបើបុរសអ្នកចង់តែរស់ មិនចង់ស្លាប់ ចង់តែសុខ ខ្ពើមទុក្ខ មកដល់។ បុរសនោះគួរហុចដៃទាំងអស់ឬហុចតែមេដៃឲ្យអាសិរពិសមានពិសដ៏សាហាវនោះដែលខ្លួនដឹងថា អាសិរពិសនេះចឹកអាត្មាអញហើយ នឹងដល់នូវមរណៈ ឬដល់នូវសេចក្ដីទុក្ខស្មើរតែមរណៈដែរឬទេ? បពិត្រព្រះអង្គដ៏ចម្រើន! គេមិនហុច

ដៃឲ្យអាសិរពិសនោះចឹកទេ។

ម្នាលសុនក្ខត្ត! ភិក្ខុនោះឯងជាអ្នកសង្រួមក្នុងផស្សាយតនៈទាំង៦ ដឹងថាកិលេសជាឫសគល់នៃសេចក្តីទុក្ខ លុះដឹងដូច្នេះហើយ ក៏ជាអ្នកគ្មានកិលេសរួចស្រឡះហើយ ព្រោះតែការអស់ទៅនៃកិលេស នឹងបង្អោនកាយឬផ្តេកផ្តួលចិត្តទៅរកកិលេស ហេតុដូច្នេះ មិនដែលមានឡើយ ក៏យ៉ាងនោះឯង។

លុះព្រះដ៏មានព្រះភាគសម្តែងព្រះសូត្រនេះចប់ហើយ **សុនក្ខត្តលិច្ឆវិបុត្ត** មានចិត្តត្រេកអររីករាយចំពោះភាសិតរបស់ព្រះដ៏មានព្រះភាគ។

ដែឲ្យអាសិរពិសនោះចឹកទេ។

ម្នាលសុនក្ខត្ត! ភិក្ខុនោះឯងជាអ្នកសង្រួមក្នុងផស្សាយតនៈទាំង៦ ដឹងថាកិលេសជាឫសគល់នៃសេចក្ដីទុក្ខ លុះដឹងដូច្នេះហើយ ក៏ជាអ្នកគ្មានកិលេសរួចស្រឡះហើយ ព្រោះតែការអស់ទៅនៃកិលេស នឹងបង្អោនកាយឬផ្ដេកផ្ដួលចិត្តទៅរកកិលេស ហេតុដូច្នេះ មិនដែលមានឡើយ ក៏យ៉ាងនោះឯង។

លុះព្រះដ៏មានព្រះភាគសម្ដែងព្រះសូត្រនេះចប់ហើយ **សុនក្ខត្តលិច្ឆវិបុត្ត** មានចិត្តត្រេកអររីករាយចំពោះភាសិតរបស់ព្រះដ៏មានព្រះភាគ។

# ទស្សនវិជ្ជាសេដ្ឋកិច្ចពុទ្ធសាសនា

សេដ្ឋកិច្ចវិទ្យា គឺជាមែកធាងនៃចំណេះដែលសិក្សាអំពីការដែលចម្រើនលូតលាស់ជារូបវន្ត (រីកចម្រើនខាងសម្ភារៈ) របស់មនុស្ស។ ជាបឋម ទ្រឹស្តីពុទ្ធសាសនាតម្រង់ឆ្ពោះទៅរកការរីកចម្រើនខាងស្មារតី។ ទោះបីស្ថិរភាពសេដ្ឋកិច្ចមានតួនាទីសំខាន់សម្រាប់ជីវភាពប្រចាំថ្ងៃក៏ដោយ ក៏ពុទ្ធសាសនាមិនបានជំរុញឬលើកទឹកចិត្តដល់ការរីកចម្រើនខាងសម្ភារៈដែរ ពីព្រោះពុទ្ធសាសនាប្រៀនប្រដៅថា អ្វីៗទាំងអស់ ត្រូវទទួលរងការប្រែប្រួល ហើយគ្មានភាពឋិតថេរទេ។ ដោយសារមានហេតុផលនេះ ទើបមានមនុស្សខ្លះជឿថា ពុទ្ធសាសនា គឺជាសាសនា (Religion) ដែលមិនជួយឲ្យមានវឌ្ឍនភាពខាង សេដ្ឋកិច្ច ហើយសាបព្រោះវិធីសាស្ត្រទុទ្ទិដ្ឋិនិយមចំពោះការចម្រើនលូតលាស់ខាងសម្ភារៈនៃពិភពលោក។

តទៅនេះ គឺជាទឡ្ហីករណ៍សម្រាប់គាំទ្រទស្សនៈរបស់គេ ៖

**១-ពុទ្ធសាសនា** គឺជាសាសនាដែលជួយធ្វើឲ្យជីវិតយើងក្នុងជាតិមុខមានសុភមង្គល ហើយមិនជួយធ្វើឲ្យជីវិតយើងនៅក្នុងលោកនេះ បានរីកចម្រើនទេ។

**២-ពុទ្ធសាសនាទទួលស្គាល់ថា** . លោកនេះពោរពេញដោយទុគ្គតភាព និងសេចក្តីទុក្ខព្រួយ។ ពុទ្ធសាសនា បានប្រៀនប្រដៅទ្រឹស្តី ដែលជួយលុបបំបាត់ចំណង ដែលទៅរកការធ្វើឲ្យបានសម្រេចនូវវឌ្ឍនភាពលោកិយនេះ។

**៣-ការប្រៀនប្រដៅអំពី** «កម្មៈ» ដែលចែងនៅក្នុងទ្រឹស្តីពុទ្ធសាសនា គឺជារបាំងរាំងខ្ទប់ចំណង់ ដើម្បីសម្រេចវឌ្ឍនភាពនៅក្នុងជីវិតនេះ។

**៤-ពាក្យប្រៀនប្រដៅ** ដែលឲ្យវៀរចាកសេចក្តីសប្បាយក្នុងលោកិយនេះ និងពាក្យប្រៀនប្រដៅឲ្យរស់នៅក្នុងជីវិតសាមញ្ញ គឺជាឧបសគ្គដល់វឌ្ឍនភាព

ខាងសេដ្ឋកិច្ច។

ដោយហេតុនេះ មនុស្សភាគច្រើនដែលបានយល់ច្រឡំ ឬយល់ស្រពេចស្រពិល ហេតុការណ៍ខ្លះ ដែលមានចែងនៅក្នុងពុទ្ធសាសនា ក៏បានប្រកាសថាគ្មានទស្សនវិជ្ជាខាងសេដ្ឋកិច្ចនៅក្នុងទ្រឹស្តីពុទ្ធសាសនាទេ។ ប៉ុន្តែ ពេលដែលយើងពិនិត្យទស្សនៈនេះមើលទៅ យើងកើតមានគំនិតផ្ទាល់ខ្លួនថា នៅក្នុងធម៌ដែលព្រះពុទ្ធបានទេសនា មានពាក្យយោងជាច្រើនទាក់ទងដល់ទស្សនវិជ្ជាច្បាស់លាស់ ដែលស្តីពីបុគ្គលនៅក្នុងសេដ្ឋកិច្ចសង្គម។

គ្មានការអធិប្បាយនៅក្នុងទីណាមួយ ដែលថាគោលការណ៍ល្អទាំងអស់ប្រៀនប្រដៅនៅក្នុងពុទ្ធសាសនា ត្រូវបានកំណត់តែនៅក្នុងក្របខណ្ឌ ឬនាំទៅរកគោលដៅ ដែលបញ្ចប់ត្រឹមបានសម្រេចលទ្ធផលបរិបូណ៌ក្នុងជាតិក្រោយតែប៉ុណ្ណោះនោះទេ។ ការរំដោះផុតពីសង្សារ (ការកើត-ស្លាប់) ដែលជាគោលដៅទីបំផុតក្នុងពុទ្ធសាសនា អាចត្រូវបានសម្រេចនៅក្នុងលោកនេះដោយផ្ទាល់ ប្រសិនបើគេខំព្យាយាមតឹងតែងដើម្បីឲ្យបានសម្រេចនោះ។ បាលីមួយឃ្លានេះថា «**ធម្មចារី សុខំ សេតិ អស្មិ លោកេ បរម្ហិ ច**» មានន័យថា មនុស្សដែលដឹកនាំត្រឹមត្រូវ តែងបានរស់នៅជាសុខក្នុងលោកនេះ ក៏ដូចក្នុងលោកខាងមុខ។ នេះមានន័យយ៉ាងច្បាស់ទៀតថា សុភមង្គលដែលផ្តល់ឲ្យក្នុងលោកខាងមុខ អាស្រ័យទាំងស្រុងលើជីវិតត្រឹមត្រូវ និងប្រកបដោយផលល្អកើតមាននៅក្នុងលោកនេះ។ ម្យ៉ាងទៀត គ្មានពាក្យប្រៀនប្រដៅណានៅក្នុងទ្រឹស្តីពុទ្ធសាសនាដែលចង្អុលប្រាប់ថា បុគ្គលត្រូវរងទុក្ខសោកក្នុងជាតិនេះសិន ដើម្បីឲ្យបានសោយសុខនិងសេចក្តីចម្រុងចម្រើនក្នុងជាតិក្រោយនោះទេ។ ក្នុងបែបដូច្នេះនេះ ព្រះពុទ្ធបានចង្អុលបង្ហាញថា ទុក្ខគ្រប់យ៉ាងនៅក្នុងលោកនេះបានកើតមក មិនមែនដោយអានុភាពរបស់អាទិទេពណាមួយនោះទេ ប៉ុន្តែគឺដោយសារផលនៃអំពើរបស់ខ្លួនឯងផ្ទាល់ ។ ម្យ៉ាងវិញទៀត ពុទ្ធសាសនាក៏បានបញ្ជាក់យ៉ាងច្បាស់ថា ដើម្បីអាចឆ្លងផុតពីទុក្ខ និងភាពតានតឹងគ្រប់យ៉ាងក្នុង

ជីវិត គេត្រូវបំពេញការងារដោយសេចក្ដីព្យាយាម និងប្រកបដោយឆន្ទៈមោះមុត។

កាលណានិយាយយោងដល់ **កម្ម:** គេបានចង្អុលប្រាប់ថា នេះមិនមែនជាហេតុតែមួយទេ ដែលជះឥទ្ធិពលមកលើជីវិតមនុស្សលើផែនដីនេះ។ ប៉ុន្តែ **កម្ម:** គ្រាន់តែជាឥទ្ធិពលមួយបែបនោះតែប៉ុណ្ណោះ។ វាគ្មានចំណុចណាដើម្បីនឹកគិតតែពី **កម្ម:** នោះទេ។ **វិរិយ:** និង **ឆន្ទ:** គួរតែត្រូវបានផ្ដល់អាទិភាពខ្ពស់លើសលុបជាង **កម្ម:** ទៅទៀត។ នេះគឺជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដល់សាវ័ករបស់ព្រះអង្គក្នុងឱកាសផ្សេងៗ។

ទស្សនវិជ្ជាស្ដីពីទុក្ខ: ដែលមានចែងនៅក្នុងទ្រឹស្ដីពុទ្ធសាសនា **កម្ម:** និងពាក្យប្រៀនប្រដៅទាក់ទងនឹងលោកខាងមុខ មិនមែនជារបាំងរាំងរាដល់ **ការអភិវឌ្ឍខាងសេដ្ឋកិច្ចជាបុគ្គល ឬសមូហភាព** នោះទេ។

ឥឡូវចូរយើងពិនិត្យមើលសេដ្ឋសាស្ត្រជាក់ស្ដែងដែលពុទ្ធសាសនាបានបង្រៀនយើងតាមទស្សនវិជ្ជាសម្រាប់ការរស់នៅប្រកបដោយជោគជ័យ។ទស្សនវិជ្ជាស្ដីពីសេដ្ឋកិច្ចរបស់ពុទ្ធសាសនាមិនដូចគោលការណ៍សេដ្ឋកិច្ចបច្ចុប្បន្ននេះគឺមិនផ្ដល់សារៈសំខាន់តែទៅលើការរីកចម្រើនខាងមូលដ្ឋានសម្ភារៈប៉ុណ្ណោះទេ ប៉ុន្តែ បានផ្ដោតការយកចិត្តទុកដាក់ដល់ **អជ្ឈត្តិកប្បញ្ញា** (the inner interllect) បុគ្គលថែមទៀត។

សេដ្ឋវិទ្យា គឺជាវិទ្យាសាស្ត្រដែលកំណត់បញ្ជាក់ថា តើសេចក្ដីត្រូវការខាងរូបកាយរបស់មនុស្ស ត្រូវបំពេញយ៉ាងដូចម្ដេចដើម្បីឲ្យមនុស្សបានសប្បាយរីករាយ។ ទ្រឹស្ដីដ៏ ច្បាស់លាស់នៅក្នុងពិភពលោកនេះថា «**ធនធានរបស់ពិភពលោកមានកម្រិតឯសេចក្ដីត្រូវការរបស់មនុស្សមិនមានកម្រិតទេ**» ទ្រឹស្ដីនេះក៏ត្រូវបានចែងនៅក្នុងពុទ្ធសសនាដែរ។

**នៅក្នុងរដ្ឋបាលសូត្រ នៃមជ្ឈិមនិកាយ** មានការនិយាយដល់ហេតុការណ៍ដែលថាមនុស្សទាំងឡាយនៃពិភពលោកនេះពុំមានភាពសុក្រឹតទេ ហើយមនុស្សទាំងឡាយនោះ ក៏គ្មានសេចក្ដីរីករាយដែរ។ គេទាំងឡាយនោះ

ក្លាយជាទាសករនៃតណ្ហា។

**សេដ្ឋវិទូលោកខាងលិច** ដែលបានលើកយកបញ្ហារវាងធនធានមានកម្រិតនិងសេចក្ដីត្រូវការមិនមានកម្រិតមកបង្ហាញ ក៏បានឆក់យកឱកាសនេះដើម្បីជំរុញអ្នកប្រើប្រាស់ឲ្យបង្កើនការបរិភោគការប្រើប្រាស់ច្រើនឡើងថែមទៀត។ ទោះបីប្រព័ន្ធនេះ មានភាពចាំបាច់សម្រាប់ប្រព័ន្ធសេដ្ឋកិច្ចមូលធនក៏ដោយ ក៏អ្នកទាំងឡាយដែលមានសេចក្ដីត្រូវការបន្តិចបន្តួចយល់ឃើញថា អ្នកទាំងឡាយដែលមានឥទ្ធិពល និងឯកសិទ្ធិ កំពុងបំផ្លាញធនធាន បង្កើតឲ្យមានចំណោទខាងសេដ្ឋកិច្ចកាន់តែច្រើនឡើងៗ។ ពុទ្ធសាសនាគាំទ្រទស្សនៈដែលថា ជីវភាពសាមញ្ញនឹងជួយឲ្យយើងប្រើប្រាស់ធនធាន ដែលមានកម្រិតបានត្រឹមត្រូវ ហើយដោះស្រាយបាននូវបញ្ហាសេដ្ឋកិច្ច ដែលបង្កើតឡើងដោយចំណង់និងតម្រេករបស់យើង ដែលគ្មានកម្រិតនោះ។

ពេលនិយាយអំពីទស្សនវិជ្ជា ស្ដីពីសេដ្ឋកិច្ចរបស់ពុទ្ធសាសនា ទស្សនៈទាំងឡាយដែលចែងនៅក្នុងទ្រឹស្ដីរបស់ព្រះពុទ្ធទាក់ទងនឹងធនធាន បានក្លាយជាទស្សនៈដ៏មានសារៈសំខាន់។ គោលការណ៍ ដែលគេបានប្រើដើម្បីវាយតម្លៃទ្រព្យសម្បត្តិរបស់គេ គឺប្រាក់។ ប្រាក់ ត្រូវគេប្រើជាមធ្យោបាយទាក់ទងដើម្បីសម្រេចចំណង់និងតម្រេកខាងសម្ភារៈ។ ស្របតាមនេះដែរ ទ្រឹស្ដីរបស់ពុទ្ធសាសនាក៏ទទួលយកទស្សនៈដែលថា ដើម្បីរស់នៅឲ្យបានហំហួន គេគប្បីប្រមូលឲ្យបានទ្រព្យសម្បត្តិយ៉ាងច្រើន។

នៅក្នុងបួនដំណាក់កាល ពុទ្ធសាសនាបាននិយាយដល់ការចម្រើនដុះដាលរបស់បុគ្គល។ ឱកាសមួយបែបនោះ គឺឱកាសបង្កឡើងដើម្បីទទួលសោយសេចក្ដីសប្បាយដែលថា គេបានប្រមូលទ្រព្យសម្បត្តិបានច្រើន។ នេះជាហេតុផលដើម្បីសប្បាយរីករាយ ព្រះក៏បានទ្រង់សម្ដែងដែរថា ទ្រព្យសម្បត្តិដែលប្រមូលបានយ៉ាងនេះ គេគប្បីប្រមូលបានដោយពលកម្មយ៉ាងតឹងតែងហើយទ្រព្យសម្បត្តិប្រមូលបាននោះ គប្បីការពារកុំឲ្យខ្ចះខ្ចាយ។ ខ្លឹមសារនេះ

មាននិយាយនៅក្នុង**ព្យគ្ឃបជ្ជសូត្រ** និង**សិង្គាលោវាទសូត្រ**។ នៅក្នុងទ្រឹស្តីរបស់ពុទ្ធសាសនា បែបបទដែលទ្រព្យសម្បត្តិគប្បីប្រមូលទុកដាក់ និងការចំណាយប្រាក់កាសគប្បីប្រព្រឹត្តទៅយ៉ាងណានោះ បានពន្យល់យ៉ាងច្បាស់នៅក្នុងអត្ថបទពុទ្ធសាសនា។

**យោងតាមសិគាលោវាទសូត្រ** ប្រាក់ដែលសន្សំបាន គប្បីចំណាយជាដំបូងបង្អស់សម្រាប់អាហារ សម្លៀកំពាក់ លំនៅឋាន ថ្នាំពេទ្យ។ល។ កុំឲ្យលំបាកវេទនា។ ក្នុងន័យដូចគ្នា ភាពសម្បូរសប្បាយរបស់បុគ្គល គឺព្រះពុទ្ធទ្រង់បានពិពណ៌នានៅក្នុងពាក្យប្រៀនប្រដៅរបស់ព្រះអង្គហើយ ហេតុការណ៍ដែលថា បុគ្គលបានចំណាយប្រាក់របស់ខ្លួន ដើម្បីបំពេញសេចក្តីត្រូវការនិងការចាំបាច់របស់ខ្លួន... គប្បីធ្វើឲ្យបុគ្គលមានអារម្មណ៍ថា ខ្លួនបានចំណាយប្រាក់ដើម្បីចាប់យកសេចក្តីសុខ ហើយទ្រព្យសម្បត្តិត្រូវប្រើប្រាស់ ដើម្បីបុព្វហេតុដ៏ល្អ។ នេះគួរតែផ្តល់ឲ្យបុគ្គលនោះ នូវសេចក្តីរីករាយទាំងខាងផ្លូវចិត្ត ទាំងខាងផ្លូវកាយ។ ក្នុងទីនោះ ព្រះពុទ្ធទ្រង់បានបំភ្លឺថា ប្រាក់សន្សំបាន គប្បីចំណាយសម្រាប់អត្ថប្រយោជន៍របស់ខ្លួនផ្ទាល់ ក៏ដូចជាសម្រាប់បុគ្គលក្រោមអាណាព្យាបាលរបស់ខ្លួន និងអ្នកឯទៀតកំពុងរស់នៅជាមួយផង កុំឲ្យគេរងការអត់ឃ្លាន។ បែបបទដែលប្រាក់សន្សំបាន គប្បីចាយវាយយ៉ាងណា គឺនឹងមាននិយាយនៅក្នុង **អបុល្លកសូត្រ នៃសំយុត្តនិកាយ**។

តាមទស្សនៈនេះ វាពុំមានន័យថា ពុទ្ធសាសនាបន្ទច់បង្អាក់មនុស្សមិនឲ្យចាយប្រាក់ដែលខំរកបាន សម្រាប់សេចក្តីត្រូវការប្រចាំថ្ងៃនោះទេ។ តែពុទ្ធសាសនាលើកស្ទួយទស្សនៈដែលថា ទ្រព្យសម្បត្តិទាំងឡាយគប្បីប្រើប្រាស់បរិភោគ សម្រាប់ជាប្រយោជន៍របស់ខ្លួន ក៏ដូចជាសម្រាប់ប្រយោជន៍ដល់អ្នកដទៃ។ ដូច្នេះ ទស្សនវិជ្ជាពុទ្ធសាសនា ជួយលើកទឹកចិត្តដល់ផលិតកម្ម។ ប៉ុន្តែអ្វីដែលយើងត្រូវចងចាំ គឺពុទ្ធសាសនាមិនយល់ព្រមចំពោះការប្រមូលទ្រព្យសម្បត្តិដោយគ្មានកំណត់ព្រំដែននោះឡើយ។

បែបបទដែលផលិតកម្ម ត្រូវបានលើកទឹកចិត្ត មិនគ្រាន់តែតាមរយៈការប្រើប្រាស់ប៉ុណ្ណោះទេ ប៉ុន្តែតាមរយៈការវិនិយោគទុនផង។ ទស្សនៈនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់ដោយពាក្យយោងថា«**ទ្វីហិកម្មំ បោយជយេ**» ដែលមានន័យថា ពីរភាគបួននៃប្រាក់សន្សំបាន គប្បីវិនិយោគ ឬរក្សាទុកសម្រាប់ការប្រើប្រាស់ទៅអនាគត ដោយទុកដាក់ក្នុងធនាគារ។ល។ ថ្វីបើមានមធ្យោបាយជាច្រើន ដែលតាមរយៈនេះប្រាក់អាចវិនិយោគក៏ដោយ ក៏ខ្សែបន្ទាត់នៃគំនិតបច្ចុប្បន្នតែងគាំទ្រទស្សនៈលើកឡើងដោយទ្រឹស្តីពុទ្ធសាសនាដែរ។ ប៉ុន្តែជាការជាក់ច្បាស់ណាស់ថា បែបបទពុទ្ធសាសនាចំពោះការវិនិយោគ និងការស្វែងរកទ្រព្យសម្បត្តិ គឺផ្សេងពីបច្ចេកទេស ដែលមានចែងនៅក្នុងសេដ្ឋសាស្ត្រសម័យថ្មី។

កាលណាប្រមូលបានទ្រព្យសម្បត្តិ ឬវិនិយោគប្រាក់លើរបរជំនួញផ្សេងៗ មតិដែលថា តើវិធីដោះស្រាយបញ្ហាត្រូវ ឬខុសយ៉ាងណានោះ មិនទាន់បានបំភ្លឺដោយទស្សនវិជ្ជាសេដ្ឋកិច្ចលោកខាងលិចទេ។ គោលដៅ គឺការរកចំណេញប៉ុណ្ណោះ។ ផ្ទុយទៅវិញ យោងតាមទស្សនវិជ្ជាសេដ្ឋកិច្ចពុទ្ធសាសនា រកប្រាក់បានដោយមិនត្រឹមត្រូវ តាមមធ្យោបាយបោកប្រាស់ និងដោយវិធីទាំងឡាយដែលបង្ខូចប្រយោជន៍សង្គម មិនត្រូវបានទទួលយកទុកជាមាគ៌ាត្រឹមត្រូវក្នុងការរកប្រាក់ទេ។ មានពាក្យយោងជាច្រើន ទាក់ទងនឹងការស្វែងរកទ្រព្យសម្បត្តិ ៖

ឧទាហរណ៍ **ធម្មេន ធម្មលទ្ធា** «ប្រាក់រកបានមកដោយមធ្យោបាយត្រឹមត្រូវ» **សេទា វក្កិតេហិ** «ប្រាក់រកបានមកដោយញើសនិងពលកម្ម» ទស្សនៈនេះត្រូវបានយល់ព្រម និងគាំទ្រ។

«**ពលកម្ម**» គឺជាទិដ្ឋភាពមួយទៀតនៃផលិតកម្ម បើយោងតាមសេដ្ឋសាស្ត្រ។ សូម្បីនៅក្នុងវិធីសេដ្ឋកិច្ចពុទ្ធសាសនា ពលកម្មដើរតួនាទីមួយដ៏លេចធ្លោបំផុត ហើយវាបានបង្ហាញឲ្យឃើញថា កាលណាប្រាក់ឈ្នួលខ្ពស់ត្រូវបានផ្តល់ឲ្យទៅពលករ ផលិតកម្មកាន់តែចម្រើនឡើងៗឥតឈប់ឈរ។ ព្រះពុទ្ធទ្រង់

បានរិះគន់ជានិច្ចចំពោះមនុស្សទាំងឡាយដែលគិតតែរកចំណេញប៉ុណ្ណោះ ដោយសារការកេងប្រវញ្ចលើពលកម្ម។ នៅក្នុងសង្គាលោវាទសូត្រ ព្រះពុទ្ធបានបំភ្លឺយ៉ាងច្បាស់ថា ពលកម្មគប្បីផ្តល់ប្រាក់បំណាច់ឲ្យយ៉ាងសមស្រប ហើយប្រាក់លើកទឹកចិត្ត (ប្រាក់ទឹកតែ) ។ល។ ត្រូវផ្តល់ឲ្យក្នុងបែបបទត្រឹមត្រូវដល់ពលករ។ ការងារប្រគល់ឲ្យពលករធ្វើ ត្រូវតែជាការងារដែលពលករអាចធ្វើ ឬអាចបំពេញបាន។

កាលណាគេពិចារណាថ្នាក់ប្រទេស ហើយមិនមែនថ្នាក់បុគ្គល ឬថ្នាក់អង្គភាពទេ កត្តាជាច្រើនដែលអាចរួមវិភាគទានជួយឲ្យបានសម្រេចនូវវឌ្ឍនភាពសេដ្ឋកិច្ច ហាក់ដូចជាមានចែងនៅក្នុងទស្សនវិជ្ជាសេដ្ឋកិច្ចពុទ្ធសាសនារួចហើយ។

ព្រះពុទ្ធចាត់ទុកយ៉ាងសមស្របបំផុតថា ទុគ្គតភាពរបស់ប្រទេស បណ្តាលមកពីការថ្លោះធ្លោយខ្លះ ដែលអាចកើតមានទាក់ទងទៅនឹងការបែងចែកទ្រព្យសម្បត្តិ។

ដូចគ្នានេះដែរ នៅក្នុងចក្កវត្តិសីហនាទសូត្រ ព្រះពុទ្ធបានសម្តែងអំពីប្រធានបទនេះ ហើយទ្រង់បានបញ្ជាក់ថា ករណីកិច្ចរបស់រដ្ឋាភិបាល គឺត្រូវផ្តល់មូលធនសម្រាប់ឲ្យសហគ្រិន ធ្វើវិនិយោគប្រាក់លើការរកស៊ីរបស់សហគ្រាសនានា។ រដ្ឋាភិបាលគប្បីផ្តល់ការងាយស្រួលផង ដូចជាជី ទៅឲ្យពួកកសិករឧស្សាហករ។ល។ យោងតាមទ្រឹស្តីសេដ្ឋកិច្ច ពន្ធអាករគឺជាប្រភពសំខាន់នៃចំណូលសម្រាប់រដ្ឋាភិបាល។ រដ្ឋាភិបាលប្រើប្រាស់ចំណូលនេះ សម្រាប់ការងារសុខុមាលភាពនិងការអភិវឌ្ឍ។ ទន្ទឹមនឹងទទួលយកមនោគមវិជ្ជានេះជាគោលការណ៍ ក៏បានបង្ហាញទស្សនៈមួយរបស់ព្រះពុទ្ធសាសនា ស្តីពីប្រធានបទនេះដែរ។ នៅពេលព្រះពុទ្ធអង្គមានពុទ្ធដីកាយោងដល់ស្តេច «**លិច្ឆវី**» ទ្រង់បានបញ្ជាក់ថា **ការប្រមូលពន្ធអាករដោយមិនត្រឹមត្រូវ គឺជាការខុសឆ្គង ហើយថាពន្ធអាករ ត្រូវតែរដ្ឋាភិបាលប្រមូលយកពីប្រជានុរាស្ត្រ ដោយមិន**

**បន្ថែមបន្ទុកលើប្រជារាស្ត្រ ជាមួយនឹងបន្ទុកពន្ធអាករតាមបែបបទដែលឃ្មុំជញ្ជក់យកទឹកអំពីផ្កាដោយមិនធ្វើឲ្យផ្កាខូចខាតឬអន្តរាយ។** ព្រះពុទ្ធទ្រង់មានពុទ្ធដីកាទៀតថា វាជាករណីយកិច្ចរបស់ប្រជានុរាស្ត្រ ដើម្បីបង់ពន្ធអាករទាន់ពេលវេលា ដោយមិនលាក់បំពួនព័ត៌មាន ស្តីពីការបង់ពន្ធអាករ។ ពាក្យថា «**រាជពលី**» គឺត្រូវបានប្រើតាមសម្រាប់កត់សម្គាល់ពន្ធអាករដែលត្រូវបង់ជូនរដ្ឋ។

ដូច្នេះយើងឃើញថា ពុទ្ធសាសនាដោយសារមានទស្សនវិជ្ជាសេដ្ឋកិច្ចរបស់ខ្លួនច្បាស់លាស់ អាចត្រូវគេចាត់ទុកមិនត្រឹមតែជាទ្រឹស្តីមួយ ដែលនិយាយអំពីជីវិតខាងមុខប៉ុណ្ណោះទេ ប៉ុន្តែគេចាត់ទុកជាទ្រឹស្តីមួយ ជាសាសនាមួយ ដែលនិយាយអំពីមាគ៌ា និងមធ្យោបាយសំរាប់ធ្វើឲ្យសង្គម និងបុគ្គលបានរីកចម្រើនថែមទៀត។ **គម្ពីរព្រះត្រៃបិដក** ពោរពេញដោយពាក្យប្រៀនប្រដៅដែលជាភស្តុតាងបញ្ជាក់ថា ពុទ្ធសាសនាមិនគ្រាន់តែនិយាយអំពីជីវិតខាងមុខប៉ុណ្ណោះទេ ប៉ុន្តែ ជួយបុគ្គលនិងសង្គម ឲ្យមានជីវិតរស់នៅចម្រុងចម្រើននៅក្នុងសង្គម ដោយសារទស្សនវិជ្ជាសេដ្ឋកិច្ចច្បាស់លាស់ ដែលមាននៅក្នុងទ្រឹស្តីពុទ្ធសាសនាទាំងមូល។

**យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ**
**ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ។**

បុគ្គលណាខ្ជិលច្រអូស មានសេចក្តីព្យាយាមអន់ថយ ទោះបីរស់នៅមួយរយឆ្នាំ ក៏មិនប្រសើរស្មើនឹងការរស់នៅសូម្បីមួយថ្ងៃរបស់បុគ្គលអ្នកមានសេចក្តីព្យាយាមខ្ជាប់ខ្ជួនឡើយ ។

**អត្តានមេវ បឋមំ បដិរូបេ និវេសយេ**
**អថញ្ញមនុសាសេយ្យ ន កិលិស្សេយ្យ បណ្ឌិតោ។**

បុគ្គលគួរតម្កល់ខ្លួនឯងឲ្យតាំងនៅក្នុងគុណធម៌ដ៏សមគួរជាមុនសិន ចាំប្រដៅអ្នកដទៃជាក្រោយ ទើបមិនលំបាក។ ( ធម្មបទ )

**ហីនំ ធម្មំ ន សេវេយ្យ បមាទេន ន សំវសេ**

**មិច្ឆាទិដ្ឋិ ន សេវេយ្យ ន សិយា លោកវឌ្ឍនោ។**

បុគ្គលមិនគួរប្រព្រឹត្តអំពើថោកទាប មិនគួររស់នៅដោយសេចក្តីប្រមាទ មិនគួរប្រកាន់យកនូវទស្សនៈខុស មិនគួរជាអ្នករស់នៅឲ្យគ្រាន់តែចង្អៀតលោកឡើយ។ ( ធម្មបទ )

# ការងារជារបស់មនុស្ស

## កសិភារទ្វាជសូត្រ

## សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត

សម័យមួយនោះ ព្រះមានព្រះភាគទ្រង់យាងទៅគង់សម្រាកសម្រាន្ត ព្រះឥរិយាបថ នៅទក្ខិណាគិរិមហាវិហារ ជាស្រុកព្រាហ្មណ៍ឈ្មោះឯកនាឡា ក្នុងដែនមគធៈ។ ពេលព្រឹក ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ យាងប្រោសសត្វ សំដៅទៅត្រង់កន្លែងប្រកបការងារកសិកម្ម របស់កសិភារទ្វាជព្រាហ្មណ៍ ដែល កំពុងប្រព្រឹត្តទៅយ៉ាងគគ្រឹកគគ្រេង គឺភ្ជួររាស់សាបព្រោះដោយនង្គ័លប្រមាណ ៥០០ គ្រឿង។ ទ្រង់យាងទៅដល់ ត្រូវគ្នានឹង ពេលដែលគេឈប់សម្រាប់ការងារ ហើយកំពុងរៀបចំចាត់ចែងបរិភោគអាហារ ទ្រង់ទៅឈរយ៉ាងស្រួលខាងមុខ រោងកត្ត របស់កសិភារទ្វាជព្រាហ្មណ៍។ ព្រាហ្មណ៍ឃើញដូច្នោះ ដឹងថា ព្រះអង្គ យាងមកបិណ្ឌបាតក៏ពោលពាក្យផ្ដេផ្ដាថា

បពិត្រព្រះសមណៈ ខ្ញុំព្រះអង្គភ្ជួររាស់ផង សាបព្រោះផង ទើបបានជា បរិភោគអាហារ ចំណែកព្រះអង្គ សូមទៅភ្ជួររាស់សាបព្រោះទៅ បើត្រូវការ បរិភោគអាហារ។

**ព្រះគោតម** : ម្នាលព្រាហ្មណ៍ តថាគត ភ្ជួររាស់ផង សាបព្រោះផង ទើប បរិភោគអហារដូចអ្នកដែរ។

**ព្រាហ្មណ៍** : បពិត្រព្រះគោតម យើងខ្ញុំពុំដែលបានឃើញនឹមនង្គ័ល ជាល ជន្លួញ និងគោពាហនៈ របស់ព្រះអង្គម្ដងណាសោះ ចុះហេតុដូចម្ដេចទើប ព្រះអង្គមានព្រះបន្ទូលថា តថាគតភ្ជួររាស់ សាបព្រោះ ហើយទើបបរិភោគ ដូចខ្ញុំព្រះអង្គដែរ ។ សូមព្រះអង្គប្រាប់យើងខ្ញុំឲ្យបានយល់ផងមើល។

ព្រះពុទ្ធអង្គទ្រង់ត្រាស់អំពីការភ្ជួររាស់សាបព្រោះរបស់ព្រះអង្គប្រាប់ទៅព្រាហ្មណ៍ថាៈ

តថាគត មានសទ្ធាជាពូជ មានតបធម៌ជាភ្លៀង មានប្រាជ្ញាជានឹមនិងនង្គ័ល មានហិរិជាចន្ទោល មានចិត្តជាខ្សែ មានសតិជាផាលនិងជន្លួញ។ តថាគតជាអ្នកគ្រប់គ្រងរក្សាកាយវាចា (ប្រយ័ត្នមិនឲ្យមានទោស) សង្រួមអាហារក្នុងផ្ទៃ ជម្រះនូវស្មៅគឺកិលេសដោយសច្ចៈ មានការស្ងប់ស្ងៀមជាគ្រឿងឈប់សម្រាក។ សេចក្តីព្យាយាមរបស់តថាគត ជានឹមសម្រាប់អូសទាញទម្លាក់ចោលនូវគ្រឿងធ្ងន់គ្រប់យ៉ាង (របស់បញ្ចក្ខន្ធ) ជាហេតុឲ្យបាននូវព្រះនិព្វានដែលជាទីក្សេមក្សាន្តចាកកិលេសជាគ្រឿងប្រកបគ្រប់យ៉ាង ជាទីដែលគេមិនសោកសៅ មិនវិលត្រឡប់មកវិញ។ ការភ្ជួររាស់ដែល តថាគតធ្វើយ៉ាងនេះរមែងមានផលជាអមតៈ គឺមិនចេះស្លាប់ បុគ្គលណាធ្វើការភ្ជួររាស់បែបនេះ បុគ្គលនោះរមែងរួចចាកទុក្ខទាំងពួង។

គ្រាន់តែប៉ុណ្ណោះ កសិភារទ្វាជព្រាហ្មណ៍ក៏ទៅដោះបាយដាក់ក្នុងភាជន៍សំរឹទ្ធិយ៉ាងធំ បង្អោនចូលទៅថ្វាយព្រះអង្គដោយពាក្យថា សូមព្រះអង្គសោយបាយបាយាសនេះចុះ បើព្រះអង្គក៏ជាអ្នកភ្ជួររាស់ដែរ ហើយការភ្ជួររាស់របស់ព្រះអង្គបានផលជាអមតៈ គឺមិនចេះស្លាប់។

**ព្រះគោតម** : ម្នាលព្រាហ្មណ៍ ភោជនដែលកើតឡើងដោយតថាគតពោលឆ្លើយឆ្លងជាមួយនឹងអ្នកបែបនេះ ជារបស់មិនគួរបរិភោគទេ ទាំងពុំមែនជាទំនៀមរបស់អ្នកប្រាជ្ញ ដែលឃើញច្បាស់នូវអាជីវបារិសុទ្ធិទៀតផង។ ព្រះសម្ពុទ្ធគ្រប់ព្រះអង្គ តែងតែបន្ទោបង់ចោលនូវភោជនដែលកើតឡើងបែបនេះ។ ម្នាលព្រាហ្មណ៍ កាលណាមានការ ស្វែងរកប្រកបដោយធម៌ ទើបមានការប្រព្រឹត្តចិញ្ចឹមជីវិតដោយប្រពៃដែរ។ ដូច្នេះ អ្នកចូរផ្គត់ផ្គង់ចំពោះលោកណាដែលស្វែងរកគុណដ៏ធំ ព្រមទាំងបរិបូណ៌ដោយគុណធម៌គ្រប់យ៉ាង មានការធ្វើចិត្តឲ្យរួចចាកកិលេសាសវៈ ស្ងប់រំងាប់ចាកសេចក្តីសង្ស័យជាដើម ដោយវត្ថុមានបាយ

និងទឹកជាដើមចុះ ព្រោះថាការផ្តត់ផ្គង់នោះជាបុញ្ញក្ខេត្ត គឺជាស្រែបុណ្យរបស់បុគ្គលអ្នកប្រាថ្នាបុណ្យ។

# ប្រវត្តិចំណីអាហារមនុស្សលោក

តាមប្រវត្តិចាស់បរមបុរាណជាងគេ បានប្រាប់យើងឲ្យដឹងថា ទឹក ដី ភ្លើង ខ្យល់ អាកាស គឺលោកធាតុជាទីអាស្រ័យរបស់មនុស្សសត្វនេះមានអាយុជីវិតដូចមនុស្សសត្វដែរ កាលបើដល់កំណត់អាយុហើយ ត្រូវស្លាប់វិនាសបាត់បង់អស់ទៅ ទើបសង្ខារលោកបង្កើតជាថ្មីទៀត មានមនុស្សសត្វថ្មី មកកើតនៅជាដំបូងលើផែនដីថ្មីនោះ។ ឯមនុស្សថ្មីនោះ មុនដំបូងនាំគ្នាយកពពុះដីជាដំណើអាហារ បន្ទាប់មក យកក្រមរដីជាចំណីអាហារ បន្ទាប់មកទៀតយកស្រូវសាលីឆ្អិនស្រាប់ជាចំណីអាហារ ចុងក្រោយបំផុត យកស្រូវដូចសព្វថ្ងៃជាចំណីអាហាររហូតមក ដោយស្រូវនេះមិនសូវមានរសជាតិ ទើបមនុស្សយកត្រីសាច់ អំបិលស្ករ បន្លែផ្លែឈើ ប្រេងខ្លាញ់ មកផ្សំធ្វើជាចំណីថែមទៀតជាប់មកដល់សព្វថ្ងៃនេះ។ តទៅអនាគតមនុស្សយកស្មៅជាចំណីអាហារ។

ប្រវត្តិនោះមានតំណាលក្នុងសុត្តន្តបិដក គម្ពីរទីឃនីកាយថា មនុស្សដើមបំផុតនៃពិភពលោកនេះ មានចិត្តគំនិតល្អណាស់ បរិសុទ្ធស្អាតដូចដុំពេជ្រ សូម្បីនិយាយកុហកលេងបន្តិចបន្តួចក៏គ្មានដែរ ព្រោះមនុស្សកើតលើផែនដីថ្មីជាដំបូងបំផុតនោះសុទ្ធតែច្យុតពីព្រហ្មលោកមកកើត។ (រឿងនេះមិនមែនរឿងដើមកំណើតចិត្តវិញ្ញាណថ្មីរបស់មនុស្សសត្វឡើយ គឺរឿងចិត្តវិញ្ញាណចាស់ ដែលមកកើតនៅលើផែនដីថ្មីមុនគេបំផុត)។

ពេលនោះ មិនទាន់មានពន្លឺព្រះអាទិត្យព្រះចន្ទនៅឡើយ មនុស្សទាំងនោះ មានពន្លឺភ្លឺចេញអំពីកាយគ្រប់គ្នា ហោះទៅតាមអាកាសបាន ភេទប្រុសស្រីក៏គ្មាន គឺជាមនុស្សវិសេសគ្មានទ្វារបន្ទោបង់មូត្រលាមកឡើយ រស់នៅដោយអំណាចឈានមានបីតិជាអាហារ។ ដល់យូរទៅ ដោយអំណាចពពុះដីថ្មីមានក្លិនឈ្ងុយ មានរសជាតិឆ្ងាញ់ ក៏នាំគ្នាផ្ដិះយកមកភ្លក់មើលសេចក្ដីស្រេច

ឃ្លានក៏កើតមានពីពេលនោះមក ហើយមនុស្សនាំគ្នាយកពពុះដីនោះជាចំណីអាហារ ស្រាប់តែពន្លឺដែលភ្លឺចេញពីកាយបាត់អស់ទៅ ការហោះទៅតាមអាកាសក៏ហោះមិនបាន។ ពិភពលោកមានងងឹតសូន្យសុង មនុស្សទាំងនោះមានសេចក្តីតក់ស្លុតភ័យខ្លាចគ្រប់ៗគ្នា។

គ្រានោះសង្ខារលោក បង្កើតឲ្យមានពន្លឺព្រះអាទិត្យព្រះចន្ទឡើង យប់ថ្ងៃផ្កាយ នក្ខត្តឫក្ស រដូវឆ្នាំខែ ទ្វីប ភ្នំ ចក្រវាល សមុទ្រ ក៏កើតឡើងដំណាលគ្នា។ ពេលកើតសង្ខារលោកដូចខាងលើនេះ បុរាណបណ្ឌិតកំណត់ថា ថ្ងៃ១៥កើតខែផល្គុនដូចមានប្រាប់ក្នុងគម្ពីរវិសុទ្ធិមគ្គ ត្រង់អភិញ្ញានិទ្ទេសថា «**តេ ច ខោ អបុព្វំ អចរិមំ ផគ្គុណបុណ្ណមីទិវសេយេវ បាតុភវន្តិ**» ប្រែថា សង្ខារលោកទាំងនោះឯង កើតឡើងប្រាកដដំណាលគ្នា ក្នុងថ្ងៃពេញបូណ៌មីខែផល្គុន។

កាលមនុស្សទាំងនោះ យកពពុះដីជាចំណីអាហារហើយ រស់នៅអស់កាលយូរអង្វែង ពលភាពនៃរូបកាយក៏រឹងប៉ឹងឡើង មានពណ៌សម្បុរប្លែកៗគ្នា ខ្លះស ខ្លះខ្មៅ ខ្លះលឿង ខ្លះមានរូបល្អ ខ្លះមានរូបអាក្រក់ ប្រែតាមអំពើដែលខ្លួនបានសាងពីជាតិមុនៗមក ការមើលងាយគ្នាព្រោះប្រកាន់ថា អញល្អ ឯងអាក្រក់ ក៏កើតឡើងក្នុងចិត្តគំនិតមនុស្សទាំងនោះ។ គ្រាន់តែមានចិត្តអាក្រក់មើលងាយគ្នាប៉ុណ្ណោះ ដល់ពេលស្រេកឃ្លានទៅយកពពុះដីមកបរិភោគ ស្រាប់តែបាត់ឱជារសអស់ទៅ។

គ្រានោះក្រមរដីកើតមានឡើង មានសណ្ឋានដូចផ្សិតក្បាលពស់ មានរសជាតិយ៉ាងឆ្ងាញ់ មនុស្សទាំងឡាយនាំគ្នាបរិភោគក្រមរដីនោះ រស់នៅអស់កាលយូរអង្វែងទៅទៀត។ ពលភាពនៃរូបកាយកាន់តែចម្រើនឡើងប្លែកៗគ្នា ការប្រកាន់ខ្ជាប់មើលងាយគ្នា ក៏កាន់តែចម្រើនឡើងទៀត ក្រមរដីនោះក៏បាត់អស់ទៅ។

ពេលនោះ វល្លិឈ្មោះបទាលតាកើតឡើង មានរសជាតិយ៉ាងឆ្ងាញ់ មនុស្សទាំងឡាយនាំគ្នាស៊ីវល្លិនោះ រស់នៅយូរអង្វែងទៅទៀត ការប្រកាន់ខ្លួន

មើលងាយគ្នា ក៏កាន់តែចម្រើនឡើងជាងមុន វល្លិនោះក៏បាត់អស់ទៅ។

គ្រានោះស្រូវសាលីឆ្អិនស្រាប់ គ្មានកន្ទក់ គ្មានអង្កាមសស្អាត មានក្លិនក្រអូបឈ្ងុយ មានឱជារសយ៉ាងឆ្ងាញ់បានកើតឡើងគ្រប់ទីកន្លែង មានផ្លែជាចង្កោមៗ។ មនុស្សទាំងឡាយនាំគ្នាបេះស៊ីក្នុងវេលាព្រឹកត្រង់ទីណា ដល់វេលាល្ងាចស្រូវដុះឡើងត្រង់ទីនោះវិញដដែល នាំគ្នាបេះស៊ីទៀតឥតលំបាកដើរទៅរកទីដទៃឡើយ។

កាលមនុស្សទាំងនោះ នាំគ្នាបរិភោគស្រូវនោះហើយ ការរឹងប៉ឹងនៃសរីរៈកើតឡើងលើសប្រមាណ ពណ៌សម្បុរ សម្រស់រូបកាយក៏កាន់តែប្លែកៗគ្នាប្រាកដឡើង។ ពេលនោះទ្វារតូចធំ សម្រាប់បន្ទោបង់មូត្រលាមក និងភេទប្រុសស្រីក៏កើតប្រាកដឡើងក្នុងលោក។ ពួកស្រីៗ សម្លឹងមើលពួកប្រុសៗ ឯពួកប្រុសៗសម្លឹងមើលពួកស្រីៗហួសពេលវេលា ព្រោះសុទ្ធតែអាក្រាតកាយដូចគ្នាផង ទើបនឹងឃើញភាពបុរសស្ត្រីក្នុងពេលនោះផង។ ចំណង់ក្នុងកាមក៏កើតឡើងដោយមានរោគជាបច្ច័យ បាននាំគ្នាផ្ដើមសេពមេថុនមួយគូៗតាមចិត្តស្ម័គ្រ។ ការសេពមេថុនក៏ចាប់កើតមានក្នុងលោកពីពេលនោះមក។

សម័យនោះមានមនុស្សខ្លះអៀនខ្មាស ចំពោះការសេពមេថុននោះ បានឃើញពួកអ្នកកំពុងសេពកណ្ដាលទីវាល ក៏យកដុំដីគប់ហើយស្ដីបន្ទោស។ កាលបើមនុស្សទាំងនោះដល់នូវភាពជាអ្នកសេពមេថុនស៊ប់ហើយ ត្រូវគេស្ដីបន្ទោសផង ក៏នាំគ្នាធ្វើខ្ទមធ្វើផ្ទះបិទបាំងការសេពមេថុននោះ។ ខ្ទមផ្ទះក៏កើតមានក្នុងលោកពីពេលនោះមក។

គ្រាក្រោយយូរអង្វែងមក មានមនុស្សខ្ជិលមានចិត្តគំនិតអាក្រក់លោភលន់ ក៏ទៅប្រមូលយកស្រូវសាលីម្ដងៗ ឲ្យបានច្រើនល្មមបរិភោគបាន២ថ្ងៃ ៣ថ្ងៃ ឬច្រើនថ្ងៃ ជាងនោះក៏មាន។ មនុស្សដទៃដឹងថា ធ្វើយ៉ាងនោះស្រួល ក៏យកតម្រាប់តាមគ្នាដណ្ដើមគ្នាយកស្រូវមកទុកឲ្យបានច្រើនរៀងៗខ្លួន។

ពេលនោះស្រូវសាលីដែលឆ្អិនស្រាប់ក៏បាត់អស់ទៅ កើតស្រូវមានកន្ទក់

មានអង្កាមរុំអង្ករដូចស្រូវសព្វថ្ងៃនេះ។ សូម្បីកន្លែងដែលធ្លាប់ដុះ ក៏លែងដុះឯងៗដូចមុនទៀត។

គ្រានោះមនុស្សទាំងឡាយភ័យព្រួយបានប្រជុំគ្នាថា កាលពីដើមពួកយើងជាអ្នកកើតដោយឈានចិត្ត មានបីតិជាអាហារ មានពន្លឺចេញពីកាយត្រាច់ទៅតាមអាកាសបានដូចបំណង។ ឥឡូវសូម្បីតែស្រូវសាលីក៏មានកន្ទក់មានអង្កាម ទីដែលច្រូតហើយលែងដុះវិញ ព្រោះតែអំពើអាក្រក់របស់យើង។ ដូច្នេះគួរយើងចែកពូជស្រូវ ចែកដីគ្នាដាំស្រូវរៀងៗខ្លួនៗ។ តមកមានមនុស្សខ្លះខិលខូចលួចស្រូវគេ ម្ចាស់គេចាប់បាននាំគ្នាស្តីបន្ទោស ហាមឃាត់មិនឲ្យធ្វើអំពើអាក្រក់នោះទៀត។ មនុស្សពួកនោះមិនរាងចាលចេះតែលួចទៀតដល់គម្រប់បីដង ម្ចាស់ស្រូវគេនាំគ្នាទះទប់ខ្លះ វាយនឹងដំបងខ្លះ។

ក្នុងពេលនោះ អំពើអាក្រក់ពុករលួយក៏ចាប់កើតឡើង គឺការលួច ការតិះដៀល ការនិយាយកុហក និងការដាក់អាជ្ញាក៏កើតប្រាកដឡើងក្នុងលោក។ ពួកមនុស្សទាំងនោះ បាននាំគ្នារើសយកអ្នកមានសមត្ថភាពម្នាក់ គឺព្រះពោធិសត្វ ឲ្យធ្វើព្រះរាជាត្រួតត្រាពួកមនុស្ស កុំឲ្យមានរឿងហេតុព្រោះតែចំណីអាហារជាដើមនោះ។ ព្រះពោធិសត្វព្រមទទួលហើយ វាស់ដីចែកគ្នាឲ្យធ្វើស្រែចម្ការ និងនិយាយប្រៀនប្រដៅឲ្យស្គាល់ខុសត្រូវ ឲ្យមានចិត្តរីករាយចំពោះអំពើល្អ។ ពាក្យថាមហាសម្មតៈ ថាខត្តិយៈ ថាក្សត្រ ថាព្រះរាជា ក៏កើតមានក្នុងលោកតាំងពីពេលនោះមក។

ពួកមនុស្សនាំគ្នាធ្វើស្រែចម្ការច្បារដំណាំធ្វើជំនួញ និងធ្វើការគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមជីវិតរៀងរហូតមក។ ឯអំពើអាក្រក់របស់ពួកមនុស្ស ក៏ចេះតែចម្រើនឡើង ហើយពរ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ចេះតែថយចុះ គឺថយពីមនុស្សមានអាយុរាប់មិនអស់ ជាលំដាប់មកដល់ពុទ្ធកប្បយើងនេះ មនុស្សមានអាយុនៅត្រឹម១០០ឆ្នាំ។

ចាប់តាំងពីព្រះពុទ្ធបរិនិព្វានទៅមកដល់សព្វថ្ងៃនេះ ពរ៤ប្រការរបស់

មនុស្សចេះតែថយចុះជានិច្ច តាមលក្ខណៈចិត្តគំនិតរបស់មនុស្ស កាន់តែអាក្រក់ឡើងជានិច្ចដែរ។ កាលបើពួកមនុស្សនៅតែមានចិត្តអាក្រក់យ៉ាងនេះ ក្នុងមួយសតវត្ស ត្រូវថយអាយុអស់មួយឆ្នាំ។ បច្ចុប្បន្ននេះ អាយុក្ខ័យមនុស្សនៅតែ៧ឆ្នាំទេ ថយអស់២៥ឆ្នាំ ហើយនឹងចេះតែថយទៅទៀត ដរាបដល់មនុស្សមានអាយុត្រឹម១០ឆ្នាំស្លាប់ ដូចពុទ្ធភាសិតក្នុងគម្ពីរទីឃនិកាយថា

**ភវិស្សតិ ភិក្ខវេ សោ សមយោយំ ឥមេសំ មនុស្សានំ ទសវស្សាយុកា បុត្តាភវិស្សតិ។ល។**ម្នាលភិក្ខុទាំងឡាយតទៅខាងមុខនឹងមានសម័យដែលកូនអ្នកទាំងនោះមានអាយុត្រឹម១០ឆ្នាំ ពួកស្ត្រីមានអាយុ៥ឆ្នាំល្មមឲ្យមានប្តី។ សម័យនោះ រសជាតិដ៏ប្រសើរ គឺទឹកឃ្មុំ ទឹកដោះខាប់ ប្រេង ទឹកអំពៅ អំបិល នឹងវិនាសអស់គ្មានសល់ក្នុងលោក ព្រោះទឹកសមុទ្រធ្លាប់ប្រៃក្លាយទៅជាសាប ទឹកអំពៅទឹកត្នោតជាដើមធ្លាប់ផ្អែមក្លាយទៅជាសាបទាំងអស់។ ពួកមនុស្សយកស្មៅគែលលកជាចំណីអាហារ កុសលកម្មបថ១០វិនាសបាត់អស់អកុសកម្មបថ១០ ចម្រើនឡើង ជាអតិបរមាក្នុងលោក។

សម័យនោះមនុស្សអស់ជំនឿចំពោះបុណ្យបាប លែងស្គាល់ឪពុកម្តាយ ឥតស្គាល់ល្អអាក្រក់ដូចសត្វតិរច្ឆាន មានចិត្តក្លាហាន គិតតែធ្វើគ្រឿងសស្ត្រាវុធគ្រប់ៗគ្នា។ ពេលនោះត្រូវកើតអន្តរជានយ៉ាងធំហៅថា កើតសត្ថន្តរកប្ប សម្លាប់គ្នាឥតរើសមុខ គឺកូនកាប់សម្លាប់ឪពុកម្តាយ ឪពុកម្តាយកាប់សម្លាប់កូនតែរៀងៗខ្លួន គ្រប់គ្រួសារទាំងអស់ក្នុងលោក ចំនួនមួយសប្តាហ៍ មនុស្សស្លាប់គរលើផែនដី។ល។

សម័យដែលមនុស្សអស់ចំណីអាហារបរិភោគត្រឡប់ជាស៊ីស្មៅដូចសត្វ និងសម័យដែលមានអាយុត្រឹម១០ឆ្នាំស្លាប់នោះ បើគិតពីត្រឹមពុទ្ធសតវត្សទី២៥ នេះទៅមុខ នៅ៩៣ពាន់៥រយឆ្នាំទៀតដល់ហើយ។ ពេលនោះហើយដែលចាស់ៗធ្លាប់តំណាលថា មនុស្សដាក់ជណ្តើរឡើងដើមត្រប់។

អត្ថបទផ្ទៃរឿងប្រវត្តិចំណីអាហារនេះ យើងដឹងច្បាស់ថា មិនមែនមាន

មូលហេតុមកពីធម្មជាតិទេ ដែលធ្វើឲ្យចំណីអាហារវិនាសបាត់អស់នោះ គឺមនុស្សនេះឯងធ្វើឲ្យវិនាសបាត់ចំណីអាហារអស់ នាំឲ្យពិបាកដល់ខ្លួន។ ដូចជាគុកនិងសោមិនមែនកើតពីរដ្ឋការទេ គឺកើតពីមនុស្សខិលខូច កើតពីចោរទើបមានគុកមានសោសម្រាប់ចាកលាក់ ទុករបស់ទ្រព្យ។ ចំពោះបញ្ហាចំណីអាហារនេះ បើមនុស្សលោកមិនខ្ជិលខិលខូច មិនមានចិត្តគំនិតអាក្រក់នោះ បញ្ហាចំណីអាហារមិនចោទធ្ងន់ចំពោះមនុស្សលោក ដូចសព្វថ្ងៃនេះឡើយ។

រឿងប្រវត្តចំណីអាហារដូចពោលខាងលើនេះ ពិតជាមានអ្នកខ្លះឆ្ងល់ថាធម្មជាតិគ្មានចិត្តវិញ្ញាណទេ ហេតុអ្វីក៏ចេះដេញជើងមនុស្ស ចេះដាក់ទោសឲ្យមនុស្សកាន់តែតឹងឡើងៗយ៉ាងនេះ។ អំណាចរបស់ធម្មជាតិក៏ខ្លាំងម្ល៉េះអាចបំបាត់ផលរុក្ខជាតិធញ្ញជាតិ បំបាត់ជាតិប្រៃរបស់មហាសមុទ្រឲ្យសាបអស់ និងបំបាត់ជាតិផ្អែមឲ្យបាត់អស់ពីក្នុងលោកបានយ៉ាងនេះ។ ក្រែងរឿងនោះមិនពិតទេដឹង។ បើជារឿងពិតវិញ តើមានហេតុផលយ៉ាងណា?

រឿងនេះពិតទាំងអស់ សូម្បីព្រះសម្ពុទ្ធមិនបានសម្ដែងក៏យើងជឿថាពិតបាន ព្រោះមានហេតុផលបច្ចុប្បន្នជាភស្តុតាងនៃការពិតស្រាប់។

មើលចុះក្នុងបច្ចុប្បន្ននេះ សូម្បីមានដើមត្នោតដែលជាអណ្ដូងស្ករ នៅជិតមាត់ជណ្ដើរផ្ទះស្រាប់ ក៏មនុស្សខ្ជិលខិលខូចរកស្ករត្នោតស៊ីមិនបានដែរ ព្រោះក្នុងខ្លួនមនុស្សនោះវាខ្សោយអស់ជាតិផ្អែមទៅហើយ មានតែជាតិអាក្រក់ គឺអំពើទុច្ចរិត លោភ ទោសៈ មោហៈ គិតតែពីប្រព្រឹត្តអបាយមុខ ស្រាស្រី ល្បែងភ្នាល់ និងខ្ជិលដេកទម្រន់ ដល់ក្រពះឃ្លាន ចិត្តចង់មានចង់បានក៏តាំងលួចប្លន់កេងកិបស៊ីសំណូក ដែលជាអំពើពុករលួយតែប៉ុណ្ណោះ។

កាលបើមនុស្សអាក្រក់បែបនេះ កាន់តែមានចំនួនច្រើនឡើងៗក្នុងលោក ហើយ ប្រវែងអាយុ ពណ៌សម្បុរល្អ សេចក្ដីសុខ និង រសជាតិចេះតែថយចុះ។ ទោះបីសម័យ វិទ្យាសាស្ត្រនេះខំបង្កើតឱសថ បង្កើតសម្ភារៈឲ្យបានសុខស្រួល និងបង្កើតរសជាតិ ដូចវីតាមីន ប៊ីចេងយ៉ាងណាក៏បាន តែជាគ្រឿងអបស្វបក្រៅ

បន្តិចបន្តួចគ្រាន់តែឲ្យល្អមើលប៉ុណ្ណោះ ឯខ្លឹមសារពិតប្រាកដនោះគ្មានសោះឡើយ។ សូម្បីតែរបស់កំប៉ិកំប៉ុក ដូចទឹកត្រី ទឹកស៊ីអ៊ីវ ជាដើម កាលពីសាមសែសិបឆ្នាំមុននេះ មានរសជាតិឆ្ងាញ់ល្អ តាមរសធម្មជាតិពិតៗ ដល់មកមនុស្សកាន់តែអាក្រក់ កាន់តែលោភច្រើនឡើងៗ គិតធ្វើយ៉ាងណា ឲ្យតែបានចំនួនច្រើននោះ មុនដំបូងក្លែងកុហកអ្នកប្រើខំធ្វើយ៉ាងឆ្ងាញ់ ល្អតាមរសធម្មជាតិពិតៗ ដល់បន្តិចមកបន្ថយរសធម្មជាតិចេញខ្លះ ថែមទឹកអំបិលបង់ប៊ីចេង នាំឲ្យខូចគុណភាពអស់។ នេះជាជំហានតូចមួយឈានទៅរកការបាត់បង់រសជាតិចំណីអាហារពីក្នុងលោក។

ផ្នែកទស្សនវិជ្ជាបានប្រាប់ថា មនុស្សសត្វ ព្រៃព្រឹក្សា និងធាតុដី ទឹក ភ្លើង ខ្យល់ អាកាស ជាធម្មជាតិដូចគ្នា ព្រោះរូបកាយ ចិត្តវិញ្ញាណ មនុស្សសត្វ និងព្រៃព្រឹក្សា កើតពីធាតុដី ទឹក ភ្លើង ខ្យល់ អាកាស ដែលជាតួធម្មជាតិនោះដែរ គឺមនុស្សសត្វជាធម្មជាតិក្នុងដី ទឹក ភ្លើង ខ្យល់ អាកាសជាធម្មជាតិក្រៅ។ បើនិយាយពីធាតុវិញ ដី ទឹក ភ្លើង ខ្យល់ ជាធាតុសុទ្ធឬធាតុក្រៅ រូបកាយចិត្តវិញ្ញាណមនុស្សសត្វ និងព្រៃព្រឹក្សាជាធាតុផ្សំ ឬធាតុក្នុង។

ចំពោះចម្ងល់ថា ធម្មជាតិចិត្តវិញ្ញាណទេ ហេតុអ្វីក៏ចេះដេញដើងមនុស្សអាក្រក់បង្អត់ចំណីអាហារបំបាត់មិនឲ្យមានជាតិប្រៃផ្អែមក្នុងលោកជាដើមនោះ ដូចបាននិយាយខាងដើមហើយថា មិនមែនមានមូលហេតុកើតពីធម្មជាតិដោយឯកឯងទេ គឺបណ្ដាលមកពីចិត្តគំនិត ពីអំពើអាក្រក់របស់មនុស្ស ដូចក្នុងដំណើររឿងប្រវត្តិចំណីអាហារនោះស្រាប់។

# ព្រះពុទ្ធសាសនានិងផ្លូវលោក

កាលពីសម័យបុរាណជាយូរយារណាស់មកហើយ មានមនុស្សមួយពួក ដែលចូលចិត្តប្រៀនប្រដៅគេឲ្យបដិបត្តិធម៌ ដោយយល់ថា ជាការធ្វើខ្លួនឯងមិនឲ្យសូន្យបាកប្រយោជន៍ ក្នុងការដែលបានកើតមកជាមនុស្ស និងជាការជួយសង្គ្រោះមហាជនឲ្យបានសម្រេចប្រយោជន៍ដ៏ធំធេង។ មនុស្សជំពូកនេះ យ៉ាងជាន់ខ្ពស់ស៊ូលះបង់សេចក្ដីសុខផ្ទាល់ខ្លួន លះទ្រព្យសម្បត្តិ សក្តិយស ហើយចេញទៅទ្រទ្រង់ភេទជាអ្នកបួស ស្វែងរកផ្លូវបដិបត្តិដែលខ្លួនយល់ឃើញថាត្រូវមានប្រយោជន៍ នាំយកមកទូន្មានដឹកនាំមហាជនឲ្យបដិបត្តិតាម។

ក្នុងចំណោមមនុស្សពួកនេះ ព្រះបរមសាស្ដារបស់យើងក៏មួយព្រះអង្គនឹងគេដែរ ដែលពេញព្រះទ័យនឹងដឹកនាំគេឲ្យប្រព្រឹត្តធម៌ ដោយព្រះអង្គហ៊ានលះបង់គ្រប់បែបយ៉ាង ដើម្បីប្រយោជន៍ដល់មហាជន។ សេចក្ដីអស្ចារ្យរបស់ព្រះអង្គ ក្នុងការបំពេញប្រយោជន៍សាធារណៈ ដែលប្រជាពលលោកគួរកោតស្ញប់ស្ញែង និងគួរកត់សម្គាល់ នោះមាន៣ប្រការគឺ

១-ការចេញទ្រង់ព្រះផ្នួស ព្រះអង្គជាមកុដរាជកុមារ ដែលត្រូវបានទទួលរាជសម្បត្តិព្រះវង្សពីព្រះវររាជបិតា ហើយតាមទំនាយថ្វាយថា ត្រូវបានជាស្ដេចចក្កពត្តិដ៏ធំសម្បើមថែមទៀតផង។ តែព្រះអង្គបានទ្រង់លះបង់ចោលអស់ ហើយចេញទ្រង់ព្រះផ្នួស ដោយឥតមានព្រះទ័យនឹកអាល័យស្ដាយក្រោយទាល់តែសោះ។

២-ទុក្ករកិរិយា ក្នុងការស្វែងរកមោក្ខធម៌ ព្រះអង្គទ្រង់បានបដិបត្តិយ៉ាងតឹងរ៉ឹងបំផុត គឺទ្រង់អត់ព្រះក្រយាស្ងោយ រហូតដល់ព្រះកាយស្គាំងស្គមទៀបនឹងអស់ព្រះជន្ម តែព្រះអង្គមិនរវល់នឹងព្រះជន្មឡើយ។

៣-ការប្រោសសត្វ ពេលដែលព្រះអង្គទ្រង់ត្រាស់ដឹងហើយ ព្រះអង្គមិន

បានសំងំយកសុខតែមួយព្រះអង្គឯងប៉ុណ្ណោះ ទ្រង់ខំព្យាយាមសម្តែងធម៌ទូន្មានប្រៀនប្រដៅសត្វ គ្មានសម្រាកថ្ងៃណាមួយ រហូតទល់គ្នានឹងថ្ងៃដែលទ្រង់បរិនិព្វាន។

ក្នុងការប្រោសសត្វនេះសោត ព្រះអង្គទ្រង់បានសម្តែងបញ្ជាក់ថា នរណាបូជាតថាគតដោយអាមិសបូជា អ្នកនោះមិនឈ្មោះថាស្រឡាញ់តថាគតទេ នរណាបូជាតថា គតដោយការបដិបត្តិតាមពាក្យប្រៀបប្រដៅរបស់តថាគត អ្នកនោះទើបឈ្មោះថា ស្រឡាញ់តថាគត។ ព្រះពុទ្ធដីកានេះសឲ្យឃើញច្បាស់ថា ព្រះអង្គគ្មានប្រាថ្នាលាភសក្ការៈឬប្រយោជន៍ផ្ទាល់ព្រះអង្គឡើយ ដែលប្លែកពីគណាចារ្យមេលទ្ធិដទៃៗក្នុងសម័យនោះ។

ពាក្យប្រៀនប្រដៅដែលព្រះអង្គទ្រង់ខំសម្តែងអស់រយៈពេល៤៥ឆ្នាំ គឺចាប់ពីពេលត្រាស់ដឹងរហូតដល់ពេលបរិនិព្វាននោះ ហៅថាព្រះពុទ្ធសាសនា។ ព្រះពុទ្ធសាសនាបានឋិតនៅក្នុងលោកនេះជាង២៥០០ឆ្នាំហើយ។ មនុស្សជំនាន់ក្រោយខ្លះ ដែលបានសិក្សាវិជ្ជាការខាងផ្លូវលោកមកហើយច្រើនតែងរិះគន់ថា ព្រះពុទ្ធសាសនាមានប្រយោជន៍សម្រាប់តែអ្នកបួស និងមនុស្សចាស់ៗ ដែលកាន់ឈើច្រត់ហើយប៉ុណ្ណោះទេ គ្មានប្រយោជន៍អ្វីសម្រាប់ក្មេងៗ និងមនុស្សអ្នកប្រកបការងារចិញ្ចឹមជីវិតទេ។ តាមការពិត ព្រះពុទ្ធសាសនាមានប្រយោជន៍សម្រាប់មនុស្សគ្រប់ភេទ គ្រប់វ័យ គ្រប់ជាន់ថ្នាក់។

គោលធម៌មួយរបស់ព្រះពុទ្ធសាសនា ដែលហៅថា ឥទ្ធិបាទធម៌ គឺជាវិធីការដែលមនុស្សបដិបត្តិតាមហើយ នឹងឲ្យសម្រេចប្រយោជន៍ដូចសេចក្តីប្រាថ្នាសម្រាប់មនុស្សគ្រប់គ្នាគ្មានរើសមុខឡើយ។ ឥទ្ធិបាទធម៌នោះមាន៤យ៉ាងគឺ

**១-ឆន្ទៈ** សេចក្តីពេញចិត្តក្នុងកិច្ចការដែលធ្វើ

**២-វិរិយៈ** សេចក្តីប្រឹងប្រែងព្យាយាមធ្វើកិច្ចការនោះ

**៣-ចិត្តៈ** ការយកចិត្តទុកដាក់ក្នុងកិច្ចការនោះ

**៤-វិមំសា** ការពិនិត្យពិច័យកិច្ចការដែលធ្វើនោះ

គប្បីសង្កេតមើលថា ក្មេងបើគ្មានឆន្ទៈ គឺសេចក្តីពេញចិត្តនឹងទៅរៀន តើ

ក្មេងនោះទៅរៀនកើតឬទេ ? ទោះជាត្រូវមនុស្សចាស់បង្ខិតបង្ខំក៏ដោយចុះ បើក្មេងនោះមិនពេញចិត្តនឹងទៅទេ ក៏មិនអាចនឹងទៅបានឡើយ យើងអាចឃើញបានដូចក្មេងដែលគេចវេះជាដើម។ អ្នកធ្វើការរាជការ អ្នកធ្វើស្រែចម្ការ បើគ្មានឆន្ទៈគឺសេចក្តីពេញចិត្តក្នុងការងារនោះ តើនឹងទៅធ្វើកើតដែរឬទេ ? ហើយបើមានតែឆន្ទៈពេញចិត្តនឹងធ្វើ តែខ្វះសេចក្តីប្រឹងប្រែង បើមានសេចក្តីពេញចិត្តនឹងការប្រឹងប្រែងហើយ តែខ្វះការយកចិត្តទុកដាក់ក្នុងកិច្ចការនោះ ឬបើមានគ្រប់ទាំង៣ខាងដើមហើយ តែខ្វះខទី៤ គឺពេញចិត្តប្រឹងប្រែង និងយកចិត្តទុកដាក់ធ្វើហើយ តែមិនមានការត្រួតពិនិត្យមើល ធ្វើទៅដោយខ្ជីខ្ជា តើកិច្ចការនោះនឹងបានផលបរិបូណ៌ដែរឬទេ ? តាមការពិត មិនបានផលឡើយ បើនឹងបានក៏បានបន្តិចបន្តួច មិនសមល្មមនឹងទំហំកិច្ចការ គឺសម្រេចផលតិចច្រើនទៅតាមលំដាប់អង្គនោះឯង បើខ្វះទាំង៤ តែម្តងនោះ ក៏នឹងមិនបានសម្រេចផលអ្វីសោះតែម្តង។ មនុស្សដែលធ្វើការអ្វីទៅហើយ មិនបានទទួលលទ្ធផលអ្វីសោះនោះ បើពិនិត្យស្រាវជ្រាវទៅហើយនឹងឃើញបានថា ខ្វះគោលណាមួយក្នុងបណ្តាគោលទាំង៤នោះ ឬក៏ខ្វះទាំងអស់តែម្តង។ សេចក្តីអធិប្បាយយ៉ាងខ្លីប៉ុណ្ណេះ បញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធសាសនាមានប្រយោជន៍ដល់មនុស្សគ្រប់ភេទវ័យ និងគ្រប់ជាន់ថ្នាក់ មិនមែនសម្រាប់តែមនុស្សពួកណាភេទណាទេ។ អ្នកខ្លះទៀតទិទៀនថា ព្រះពុទ្ធសាសនាធ្វើឲ្យមនុស្សខ្ជិល មិនទាន់សម័យចាញ់ផ្លូវលោកគេឆ្ងាយណាស់ អ្នកប្រាជ្ញខាងផ្លូវលោក គេបានរៀបចំឲ្យមានរបៀបបែបផែនក្បួនតម្រា ដែលមានផលប្រយោជន៍ដល់ជីវិតមនុស្ស តាមដែលមនុស្សត្រូវការជាចាំបាច់ ដូចរឿងសង្គមសាស្ត្រនិងសេដ្ឋកិច្ចជាដើម។ ឯព្រះពុទ្ធសាសនាគ្មានទូន្មានបង្ហាត់បង្រៀនអំពីវិជ្ជាទាំងនេះ ដែលជាប្រយោជន៍ដល់ជីវិតមនុស្សដូចគេសោះ។ អ្នកដែលទិទៀនបែបនេះ មិនមកពីអ្វីទេ គឺមកពីអ្នកនោះឯងសិក្សារឿងព្រះពុទ្ធសាសនាតិចពេក។ តាមការពិត វិជ្ជាទាំងនោះ ខាងព្រះពុទ្ធសាសនាមានទាំងអស់ ហើយមានមុនផ្លូវលោកទៀតផង គឺព្រះពុទ្ធជា

ម្ចាស់បានទ្រង់ត្រាស់សម្ដែងទុកមកជាង២៥០០ឆ្នាំហើយ ឯអ្នកប្រាជ្ញខាងផ្លូវលោក ទើបនឹងបង្កើតវិជ្ជាទាំងនោះឡើង នៅពេលក្រោយនេះទេ។

ដើម្បីនឹងដោះស្រាយរឿងនេះ អ្នកសរសេរទើបនាំយកគោលធម៌ខាងព្រះពុទ្ធសាសនាខ្លះមកធ្វើអត្ថាធិប្បាយ ប្រៀបធៀបនឹងហេតុការណ៍ដែលកើតមានឡើងក្នុងលោក ដើម្បីឲ្យលោកអ្នកអានបានស្គាល់នូវតម្លៃនិងគុណប្រយោជន៍នៃព្រះពុទ្ធសាសនា។ ហេតុនោះ ទើបឲ្យឈ្មោះរឿងព្រះពុទ្ធសាសនា និងផ្លូវលោក ដោយអធិប្បាយប្រៀបធៀបគ្នាជាលំដាប់ៗតទៅ។

## អំពីសន្តិភាព

មនុស្សក្នុងលោកទាំងមូលនេះ មិនថាជាតិណា សាសន៍ណា ប្រុសឬស្រី ក្មេងឬចាស់ទេ សុទ្ធតែចង់បានសេចក្ដីសុខ ស្អប់ខ្ពើមទុក្ខដូចគ្នាទាំងអស់។ តែតាំងពីបុរាណកាលមក ការស្វែងរកសេចក្ដីសុខផ្លូវលោក ច្រើនតែជាការបៀតបៀនគ្នា ដែលជាហេតុឲ្យកើតសេចក្ដីទុក្ខក្ដៅក្រហាយដល់គ្នានឹងគ្នាទៅវិញ។ ពលរដ្ឋនៃប្រទេសមួយលើកទ័ពទៅច្បាំងកាប់សម្លាប់ពលរដ្ឋក្នុងប្រទេសមួយទៀតដោយសង្ឃឹមថាកាលបើបង្ក្រាបបានហើយខ្លួនក៏នឹងបានសេចក្ដីសុខព្រោះនឹងមានអំណាចលើប្រទេសនោះគ្រប់បែបយ៉ាង តែតាមការពិត ប្រទេសដែលចាញ់គេនោះ ខាងផ្លូវចិត្តឥតព្រមចុះចាញ់ទាល់តែសោះ តែដោយខ្លួនទន់ខ្សោយខាងផ្លូវកម្លាំង មិនអាចតស៊ូនឹងគេបាន ក៏ត្រូវតែអត់ទ្រាំទទួលបរាជ័យទៅសិន ដោយមានគំនិតគិតចងគំនុំគុំគួនព្យាបាទ គិតរកឧបាយ ដើម្បីនឹងបំបាក់បំបបគូសត្រូវរបស់ខ្លួនយកជ័យជម្នះមកវិញជានិច្ច។ លុះពេលដែលមានកម្លាំងល្មមនឹងតស៊ូបាន អ្នកចាញ់នោះក៏លើកទ័ពទៅធ្វើសង្គ្រាមកាប់សម្លាប់យកជ័យជម្នះពីអ្នកដែលបំបាក់បំបបខ្លួនពីកាលមុននោះ ជាហេតុឲ្យអ្នកដែលគិតថានឹងបានសុខស្រួលពីមុននោះ ត្រឡប់ទៅជាបានសេចក្ដីទុក្ខក្ដៅក្រហាយឡើងវិញ។ ការស្វែងរកសេចក្ដីសុខខាងផ្លូវលោកបែបនេះ មិនបានសេចក្ដីសុខ

សមតាមប្រាថ្នាសោះ ផ្ទុយទៅវិញ ត្រឡប់ជាបានតែសេចក្តីទុក្ខក្តៅក្រហាយជានិច្ច។ ទើបអ្នកដែលខំស្វែងរកសេចក្តីសុខ សន្តិភាពខាងផ្លូវលោក ចេះតែខំព្យាយាមផ្លាស់ប្តូរមធ្យោបាយជាលំដាប់ៗមក។ លុះមកដល់ពេលមុននឹងកើតសង្គ្រាមលោកលើកទី១ ព្រះមហាក្សត្រនិកូឡាសទី២ នៃប្រទេសរុស្ស៊ី ទ្រង់បានស្នើឲ្យមានការប្រជុំរវាងប្រជាជាតិនានា ពិភាក្សាបញ្ហាបន្ថយសព្វាវុធ ដើម្បីចៀសវាងការធ្វើសង្គ្រាមកាប់សម្លាប់គ្នា។ តែការស្នើរបស់ព្រះអង្គមិន បានសម្រេចផល ទើបនៅឆ្នាំ១៩១៤ ក៏កើតសង្គ្រាមលោកលើកទី១ឡើង។ លុះមកដល់ឆ្នាំ១៩១៨ ពេលដែលសង្គ្រាមលោកលើកទី១ស្ងប់ហើយ ប្រជាជាតិនានាបានរួបរួមគ្នា ផ្តើមចាត់តាំងអង្គការមួយឡើង ហៅថា «សន្និបាតជាតិ» សម្រាប់ជាទីប្រជុំពិភាក្សាបញ្ហាផ្សេងៗរវាងប្រទេស។ អង្គការនេះមានគោលបំណងធំបំផុត គឺដើម្បីរក្សាសុវត្ថិភាពនិងសន្តិភាពនៃប្រជាពលរដ្ឋក្នុងប្រទេសនានា និងពួតដៃគ្នារវាងប្រទេស ដើម្បីជួយទំនុកបម្រុងឲ្យសាកលលោកមានសេចក្តីចម្រើនលូតលាស់ ដែលជាហេតុឲ្យកើតសេចក្តីសុខសន្តិភាព។ តែអង្គការនេះសោត ក៏មិនអាចផ្តល់សន្តិភាពដ៏បរិបូណ៌ដល់ ប្រជាពលលោកបានទើបនៅឆ្នាំ១៩៣៦ សង្គ្រាមលោកលើកទី២ ក៏បានផ្ទុះឡើងទៀត លុះសង្គ្រាមលោកលើកទី២នេះស្ងប់ចុះហើយ នៅឆ្នាំ១៩៤៥ គឺចិន សហរដ្ឋអាមេរិក បារាំងសែស អង់គ្លេស និងរុស្ស៊ី ក៏បានប្រជុំព្រមព្រៀងគ្នាបង្កើតអង្គការមួយថ្មីទៀត មានឈ្មោះថា អង្គការសហប្រជាជាតិ បានចាប់ផ្តើមអនុវត្តកិច្ចការឡើងក្នុងឆ្នាំ១៩៤៨ នោះឯង។ គោលបំណងធំបំផុតនៃអង្គការនេះ គឺដើម្បីស្វែងរកសន្តិភាពឲ្យដល់សាកលលោក ដោយប្រើវិធីប្រជុំពិភាក្សាប្តូរយោបល់គ្នារវាងប្រជាជាតិនានាក្នុងសាកលលោក សម្តែងគោលបំណងរៀងៗខ្លួនចំពោះទីប្រជុំ និងជួយដោះស្រាយបញ្ហាផ្សេងៗដែលកើត នៅប្រទេសនោះៗ ដើម្បីការពារកុំឲ្យកើតសង្គ្រាមកាប់សម្លាប់គ្នាបាន ហើយនឹងចាត់ឲ្យមានផ្នែកសម្រាប់ជួយសង្គ្រោះប្រទេសនានាដែលខ្វះខាតជាដើម។ ទាំងនេះដោយយល់ឃើញថា មនុស្ស

យើងតែងចង់បានសេចក្ដីសុខដូចៗគ្នាទាំងអស់ កាលបើចូលមករួមប្រជុំសម្ដែងយោបល់ ឲ្យមានការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមកហើយ ក៏មុខជានឹងមានសេចក្ដីមេត្តាករុណាអាណិតអាសូរគ្នានឹងគ្នា លែងបៀតបៀនគ្នា ដែលជាហេតុឲ្យកើតសេចក្ដីស្ងប់សុខឡើង ហេតុនោះ ទើបព្រមព្រៀងគ្នាចាត់តាំងអង្គការនេះឡើង ដោយមានទីស្នាក់ការធំនៅក្រុងញូវយ៉ក សហរដ្ឋអាមេរិក ហើយនឹងប្រទេសនានាក៏បានជួយឧបត្ថម្ភគាំទ្រ ជាហេតុឲ្យបានគង់វង្សនៅរហូតមកដល់បច្ចុប្បន្នកាលនេះ តែទុកជាយ៉ាងនេះ ក៏សាកលលោកនៅតែមិនបានសេចក្ដីស្ងប់សុខ សមតាមសេចក្ដី ប្រាថ្នារបស់មនុស្សទូទៅ។ ការធ្វើសង្គ្រាមកាប់សម្លាប់គ្នា ការបៀតបៀនគ្នា ក៏នៅតែមាន មិនបានសាបសូន្យឡើយ។ នេះឯងគឺជាវិធីស្វែងរកសេចក្ដីសុខសន្តិភាពខាងផ្លូវលោក ដែលមានដំណើរការជាការចងពៀរ ទើបប្រជាពលលោកមិនបានសេចក្ដីសុខសមតាមសេចក្ដីប្រាថ្នា។

ខាងផ្លូវព្រះពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ជ្រាបច្បាស់ថា មនុស្សទូទៅ ពេលដែលនឹងស្វែងរកសេចក្ដីសុខ ក៏គិតតែត្រឹមខ្លួនឯងមួយប៉ុណ្ណោះ ត្រង់ការស្វែងរកសេចក្ដីសុខរបស់ខ្លួននោះប៉ះទង្គិចទៅលើប្រយោជន៍អ្នកដទៃ ធ្វើឲ្យអ្នកដទៃកើតសេចក្ដីទុក្ខក្ដៅក្រហាយនោះ មិនបានគិតដល់សោះ។ យើងអាចសង្កេតឃើញបាន ដូចអ្នកសម្លាប់សត្វមានមាន់ទាជាដើម តែងតែគិតសប្បាយរីករាយក្នុងចិត្តថា នឹងបានឆ្ងាញ់ពិសាដោយបានបរិភោគសាច់មាន់ទានោះ ត្រង់ដែលសត្វនោះបានទទួលសេចក្ដីទុក្ខភ័យស្លាយជីវិតយ៉ាងណានោះ ខ្លួនគ្មានគិតទាល់តែសោះ។ តែពេលដែលមានអ្នកណាមួយមានចិត្តក្លាហាន មិនចាំបាច់ដល់ទៅយកអាវុធមកកាប់សម្លាប់អ្នកដែលកាប់សម្លាប់សត្វ មានមាន់ជាដើមនោះឡើយ គ្រាន់តែយកដៃទះទប់ឬហៅអាមឹងមួយម៉ាត់ប៉ុណ្ណោះ អ្នកនោះឯងរមែងច្រឡោតក្រោធខឹង កើតសេចក្ដីក្ដៅក្រហាយក្នុងចិត្ត ព្រោះប្រកាន់ថាគេមើលងាយខ្លួន តែត្រង់ដែល

ខ្លួនយកសត្វមានជីវិត ស្រឡាញ់ជីវិតទៅកាប់សម្លាប់ផ្តាច់ជីវិតគេនោះ ខ្លួនគ្មានគិតដល់សេចក្តីទុក្ខរបស់គេសោះ។ ម្យ៉ាងទៀត អ្នកដែលមានសេចក្តីទុក្ខលំបាក ព្រោះការខ្វះអាហារទទួលទាន ខ្វះសំពត់ស្លៀកពាក់ ហើយមិនខំស្វែងរកដោយផ្លូវសុចរិត បែរជាខំលួចប្លន់ឆក់ដណ្តើមទ្រព្យរបស់អ្នកដទៃ យកមកបំពេញសេចក្តីខ្វះខាតរបស់ខ្លួន ឲ្យខ្លួនបានសុខ ត្រង់ដែលគេបានទុក្ខក្តៅក្រហាយស្តាយទ្រព្យសម្បត្តិ ព្រោះតែខ្លួនទៅលួចប្លន់នោះ ខ្លួនគ្មានគិតបន្តិចបន្តួចសោះ សម្លឹងយកសេចក្តីសុខចំពោះតែខ្លួនឯងម្នាក់ប៉ុណ្ណោះ។ ឯអ្នកម្ខាងសោតក៏មានការគុំកួននិងរកឱកាសព្យាបាទតបវិញដែរដែលជាហេតុនាំឲ្យមានការចងពៀរនឹងគ្នា បៀតបៀនគ្នាមិនចេះអស់មិនចេះហើយ។ ព្រះពុទ្ធជាម្ចាស់ទើបទ្រង់ត្រាស់សម្តែងទុកថា «ពៀរមិនដែលស្ងប់ដោយការចងពៀរបានទេ» គឺថាបើនៅតែមានការចងចិត្តប្រទូសរ៉ាយគ្នាទៅវិញទៅមកនោះមនុស្សមិនអាចនឹងស្រឡាញ់សះស្រួលគ្នាបានទេ ហើយសត្វទាំងឡាយតែងតក់ស្លុតចំពោះអាជ្ញា គឺការបៀតបៀនពីអ្នកដទៃ ជីវិតជាទីស្រឡាញ់របស់សត្វទាំងពួង មនុស្សត្រូវយកខ្លួនឯងជាគ្រឿងប្រៀបធៀប ហើយកុំបៀតបៀន កុំសម្លាប់អ្នកដទៃ «អ្នកណាស្វែងរកសុខដល់ខ្លួន ហើយបៀតបៀនសត្វដទៃ ដែលគេប្រាថ្នាសុខដែរនោះ អ្នកនោះមិនបានជួបប្រទះនឹងសេចក្តីសុខជាដាច់ខាត»។ តាមន័យព្រះពុទ្ធភាសិតនេះឃើញថា មនុស្សយើងគ្រប់រូប ដែលស្រឡាញ់សុខ ត្រូវកុំបៀតបៀនគេព្រោះគេស្រឡាញ់សុខដូចយើងដែរកាលបើយើងទៅបៀតបៀនគេ គេក៏ក្តៅក្រហាយ ហើយនឹងបៀតបៀនយើងវិញ ជាហេតុឲ្យយើងមិនបានសុខដែរ ដែលជាការចងពៀររកទីបំផុតគ្មាន។ កាលបើការចងពៀរ ការបៀតបៀនគ្នា មានដរាបណា សេចក្តីទុក្ខក្តៅក្រហាយ ក៏មាននៅដរាបនោះដែរ នឹងរកសេចក្តីសុខស្ងប់ស្ងៀមមិនបានឡើយ លុះត្រាតែមនុស្សឈប់បៀតបៀនគ្នានោះ ទើបនឹងបានសេចក្តីសុខសមតាមប្រាថ្នា ហើយសមនឹងព្រះពុទ្ធភាសិតមួយបទទៀតថា «ការមិនបៀតបៀនគ្នា ជាសុខក្នុងលោក»។ ដោយអាស្រ័យ

ហេតុនេះហើយ ទើបព្រះពុទ្ធជាម្ចាស់ដែលជាសាស្តាឯកក្នុងលោក ព្រះអង្គទ្រង់ត្រាស់សម្តែងនូវវិធីបំបាត់ការចងពៀរនឹងគ្នា ដើម្បីបំបាត់ការធ្វើសង្គ្រាម កាប់សម្លាប់គ្នានេះទុកមក ដោយទ្រង់សម្តែងទាំងផ្លូវវិន័យទាំងផ្លូវធម៌ ដែលហៅថា «សីលធម៌» គឺសីល៥ និងធម៌៥ ដូចតទៅនេះ ៖

## បញ្ចសីល

១-ទ្រង់ហាមមិនឲ្យសម្លាប់សត្វបំបាត់ជីវិតគេ តាំងអំពីសត្វជាន់ទាបរហូតដល់មនុស្ស។

២-ទ្រង់ហាមមិនឲ្យលួចប្លន់ឆក់ដណ្តើមទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិរបស់អ្នកដទៃ។

៣-ទ្រង់ហាមមិនឲ្យប្រព្រឹត្តខុសក្នុងកាម គឺមិនឲ្យរំលោភលើប្រពៃណីគេ រំលោភលើបុត្រធីតាភរិយាគេ ។

៤-ទ្រង់ហាមមិនឲ្យនិយាយកុហកបញ្ឆោតអ្នកដទៃ។

៥-ទ្រង់ហាមមិនឲ្យផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាហេតុឲ្យកើតសេចក្តីប្រមាទ ខូចសតិស្មារតី ហ៊ានធ្វើអំពើអាក្រក់ផ្សេងៗដោយឥតអៀនខ្មាស។

## បញ្ចធម៌

១-ទ្រង់ប្រដៅឲ្យមានមេត្តា ករុណា អាណិតអាសូរដល់មនុស្សសត្វទូទៅ។

២-ទ្រង់ប្រដៅឲ្យប្រកបការចិញ្ចឹមជីវិតតាមសម្មាជីវៈ គឺរកទទួលទានចិញ្ចឹមជីវិតដោយសុចរិតត្រឹមត្រូវ តាមគន្លងធម៌ ចៀសវាងការចិញ្ចឹមជីវិតដោយផ្លូវទុច្ចរិត។

៣-ទ្រង់ប្រដៅឲ្យសង្រួមក្នុងកាម ឲ្យត្រេកអរតែនឹងភរិយារបស់ខ្លួន។

៤-ទ្រង់ទូន្មានឲ្យនិយាយតែសេចក្តីពិត និយាយតែពាក្យផ្អែមល្ហែម មានផលមានប្រយោជន៍។

៥-ទ្រង់ប្រដៅឲ្យតាំងសតិសម្បជញ្ញៈសង្រួមរវាងក្នុងអារម្មណ៍ផ្សេងៗជានិច្ច។

សីលធម៌៥ និងធម៌៥ ដូចរៀបរាប់មកខាងលើនេះ គឺជាពុទ្ធវិធីដ៏វិសេសមួយ សម្រាប់ឲ្យមនុស្សបដិបត្តិតាម ដើម្បីកុំឲ្យមានការចងពៀរនឹងគ្នា កុំឲ្យបៀតបៀនគ្នា ដោយឲ្យចេះគិតយកចិត្តអ្នកដទៃមកដាក់នឹងចិត្តខ្លួន គឺឲ្យចេះគិតពិចារណាប្រៀបធៀបថា ចិត្តរបស់យើងស្រឡាញ់សេចក្ដីសុខ ស្រឡាញ់ជីវិត ស្អប់ខ្លាចទុក្ខលំបាកយ៉ាងនោះដែរ។ គេបៀតបៀនយើងដោយកាយវាចា បានសេចក្ដីទុក្ខក្ដៅក្រហាយយ៉ាងណា យើងបៀតបៀនគេវិញក៏មានសេចក្ដីទុក្ខក្ដៅក្រហាយដូចយើងយ៉ាងនោះដែរ។ កាលពិចារណាឃើញដូច្នេះហើយ ត្រូវចេះផ្សាយមេត្តាអាណិតអាសូរដល់គ្នានឹងគ្នា តាំងចិត្តចៀសវាងការបៀតបៀនគ្នាប្រទូសរ៉ាយគ្នាតរៀងទៅ ដែលជាហេតុឲ្យកើតសេចក្ដីសុខ សន្តិភាពដល់មនុស្សគ្រប់ៗគ្នា។ អាចនឹងមានសំណួរថា បើពិតដូច្នេះមែន ចុះហេតុអ្វី ក៏ប្រទេសដែលកាន់ព្រះពុទ្ធសាសនាដូចគ្នា នៅតែមានការទាស់ទែងខ្វែងគំនិតគ្នាមានការបៀតបៀនដែរ? ឆ្លើយថា ព្រោះពលរដ្ឋនៃប្រទេសទាំងនោះល្មើសព្រះពុទ្ធដីកា គឺមិនបដិបត្តិតាមឱវាទពាក្យប្រដៅរបស់ព្រះពុទ្ធជាម្ចាស់។ ពាក្យថាពុទ្ធសាសនិកជន គឺអ្នកកាន់ព្រះពុទ្ធសាសនានោះ មិនមែនមានន័យថាពលរដ្ឋទាំងនោះសុទ្ធតែគោរពបដិបត្តិ តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ទាំងអស់ទេ ជនពួកខ្លះគ្រាន់តែជាពុទ្ធសាសនិកដោយកំណើតប៉ុណ្ណោះក៏មាន គឺថាមាតាបិតាជាពុទ្ធសាសនិកដែរ តែគ្មានបានសិក្សាព្រះពុទ្ធសាសនាសោះក៏មាន ខ្លះក៏បានសិក្សាខ្លះដែរ តែមិនបដិបត្តិតាម ប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិរបស់ព្រះពុទ្ធជាម្ចាស់ក៏មាន ។ ប្រៀបដូចជាច្បាប់សម្រាប់ប្រទេសនីមួយៗកើតឡើងអំពីឆន្ទៈរបស់ប្រជាពលរដ្ឋ ហើយត្រូវតាំងឡើងដើម្បីការពារកុំឲ្យពលរដ្ឋប្រព្រឹត្តអាក្រក់មានលួចប្លន់ជាដើម ចុះហេតុដូចម្ដេចបានជានៅតែមានមនុស្សលួចប្លន់មិនចេះអស់? ឆ្លើយថា ព្រោះពលរដ្ឋមិនគោរពច្បាប់ ច្បាប់មានក៏

ពិតមែន តែបើពលរដ្ឋល្មើស មិនព្រមបដិបត្តិតាម ការលួចប្លន់ជាដើមក៏មិនអាច អស់ទៅបាន ហេតុនោះការដែលមានច្បាប់ហើយ នៅតែមានចោរលួចប្លន់នោះ មិនមែនមកអំពីច្បាប់ទេ គឺមកពីអំពីមនុស្សមិនព្រមគោរពច្បាប់នោះឯង សេចក្តីនេះយ៉ាងណាមិញ ប្រទេសដែលកាន់ពុទ្ធសាសនានៅតែមានការឈ្លោះវិវាទគ្នា នោះ ក៏មិនមែនមកអំពីព្រះពុទ្ធសាសនាទេ គឺមកអំពីពលរដ្ឋនៃប្រទេសនោះៗ មិនព្រមបដិបត្តិតាមព្រះពុទ្ធោវាទយ៉ាងនោះដែរ។ សរុបសេចក្តីថា ការដែល ប្រទេសកាន់ព្រះពុទ្ធសាសនា នៅតែមានការបៀតបៀនគ្នានោះ មិនមែនមកពី ព្រះពុទ្ធសាសនាទេ ព្រះពុទ្ធសាសនា មានគោលការណ៍សុទ្ធតែនាំឲ្យកើត សេចក្តីស្ងប់សុខ ឲ្យចៀសវាងការបៀតបៀនប្រទូសរ៉ាយគ្នាទាំងអស់។ តាម គោលការណ៍បញ្ចសីលបញ្ចធម៌ដូចពោលមកនេះ ប្រសិនបើមនុស្សបដិបត្តិ តាមឲ្យដិតដល់ហើយ រមែងបានទទួលលទ្ធផល គឺសេចក្តីសុខសេចក្តីចម្រើន សមដូចសេចក្តីប្រាថ្នាជាមិនខាន។ ឧទាហរណ៍ដូចមនុស្ស៣នាក់នៅជាមួយគ្នា ហើយតាំងចិត្តរៀងៗខ្លួន គឺអ្នកទី១ តាំងចិត្តថា នឹងមិនបៀតបៀនអ្នកទី២ និងអ្នកទី៣ អ្នកទី២ក៏តាំងចិត្តថា នឹងមិន បៀតបៀតនអ្នកទី១ និងអ្នកទី៣ ឯអ្នកទី៣ក៏តាំងចិត្តថា នឹងមិនប្រទូសរ៉ាយអ្នកទី១ និងអ្នកទី២។ កាលបើតាំង ចិត្តនឹងបដិបត្តិយ៉ាងតឹងរ៉ឹងបានយ៉ាងនេះ អ្នកទាំង៣ ក៏នឹងមិនមានការ ប៉ះទង្គិចគ្នា មិនមានការបៀតបៀនប្រទូសរ៉ាយគ្នានឹងគ្នាឡើយ បើគ្មានការបៀត បៀនគ្នាហើយ សេចក្តីទុក្ខសេចក្តីក្តៅក្រហាយក៏គ្មាន អ្នកទាំង៣នឹងមានតែ សេចក្តីសុខក្សេមក្សាន្តជាដរាប បើមនុស្ស១០នាក់ដែលនៅជាមួយគ្នាធ្វើបាន យ៉ាងនេះ មនុស្សទាំង១០នាក់នោះ ក៏នឹងមានសេចក្តីសុខស្ងប់ស្ងៀម គ្មាន សេចក្តីទុក្ខឡើយ បើពលរដ្ឋនៅក្នុងប្រទេសជាមួយគ្នាធ្វើបានយ៉ាងនេះ ពលរដ្ឋ ទាំងនោះក៏នឹងបានសេចក្តីសុខ សេចក្តីចម្រើនគ្រប់ៗគ្នា ហេតុនេះ ប្រសិនបើ មនុស្សនៅក្នុងសាកលលោកទាំងមូលនេះបដិបត្តិយ៉ាងនេះ សាកលលោក ទាំងមូលក៏នឹងមានតែសេចក្តីស្ងប់រៀបរយ គ្មានការកាប់សម្លាប់គ្នា គ្មាន

ការធ្វើសង្គ្រាមបង្ហូរឈាមឡើយ មនុស្សក្នុងសាកលលោក ក៏នឹងមានតែសេចក្តីសុខក្សេមក្សាន្ត ប្រាសចាកសេចក្តីទុក្ខក្តៅក្រហាយជាពិតប្រាកដ។

នេះឯង គឺជាវិធីស្វែងរកសេចក្តីសុខសន្តិភាព ខាងផ្លូវព្រះពុទ្ធសាសនា ដែលមនុស្សអនុវត្តតាមហើយ នឹងបានសម្រេចផលតាមសេចក្តីប្រាថ្នា គឺជាវិធីការដែល ប្រសើរ មិនអន់ថយជាងវិជ្ជាឬវិធីការខាងផ្លូវលោក ឬក៏អន់ថយជាងគោលនៃសាសនាដទៃនោះទេ ហើយមិនមែនគ្រាន់តែជាសាសនា ដែលមានគោលការណ៍ទាន់សម័យប៉ុណ្ណោះទេ តែជាសាសនាដែលមានគោលការណ៍នាំមុខវិធីការខាងផ្លូវលោកថែមទៀតផង ព្រោះព្រះពុទ្ធជាម្ចាស់ទ្រង់បានសម្តែងពុទ្ធវិធីនេះទុកមកជាង២៥០០ឆ្នាំហើយ ឯវិធីការផ្សេងៗខាងផ្លូវលោក ទើបនឹងកើតមានឡើងនៅពេលក្រោយនេះឯង។ ហេតុនោះ អស់លោកអ្នកអានទាំងឡាយដែលជាពុទ្ធសាសនិកជន កុំគប្បីនឹកតូចចិត្តនឹងព្រះពុទ្ធសាសនារបស់យើងថាជាសាសនាអន់ថយជាងវិជ្ជាការខាងផ្លូវលោកឡើយ គួរត្រិះរិះពិចារណាសាជាថ្មី ហើយសេចក្តីរីករាយពេញចិត្តចំពោះព្រះពុទ្ធសាសនា ដែលជាសាសនារបស់ជាតិថា យើងជាអ្នកមានភ័ព្វវាសនាធំណាស់ ដែលបានកើតមកទាន់ព្រះឱវាទពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលជាព្រះឱវាទដ៏មានតម្លៃទាន់សម័យ និងមានសភាពស័ក្តិសិទ្ធិអាចធ្វើឲ្យយើងជាពុទ្ធសាសនិកអ្នកបដិបត្តិតាមយ៉ាងជិតដល់ បានសម្រេចប្រយោជន៍តាមសមគួរដល់ការបដិបត្តិចិត្តរៀងៗខ្លួន ពោលគឺអាចជួយឲ្យមនុស្សអ្នកបដិបត្តិតាមបានផុតអំពីសេចក្តទុក្ខភ័យ ហើយបានជួបប្រទះនឹងសេចក្តីសុខក្សេមក្សាន្ត ដូចសេចក្តីដែលបានធ្វើអត្ថាធិប្បាយមកដូច្នេះឯង។

## អត្ថបទស៊ីអំពី

១-សេចក្តីចោទឆ្លើយរវាងព្រាហ្មណ៍និងព្រាហ្មណ៍ ដែលមានទស្សនៈ

មិនស្របគ្នា ។

២-សេចក្តីចោទឆ្លើយរវាងព្រះពុទ្ធនិងសោណទណ្ឌព្រាហ្មណ៍ អភិបាលស្រុកចម្បា។

៣-នយលក្ខណៈដែលជាទស្សនៈនៃអ្នកប្រែរៀបរៀងអត្ថបទនេះ។

សេចក្តីស្រង់ប្រែសម្រួល អំពីសោណទណ្ឌសូត្រ គម្ពីរទីឃនិកាយ សីលក្ខន្ធវគ្គ សុត្តន្តបិដក។

គ្រាមួយនោះ ព្រះពុទ្ធជាម្ចាស់ ព្រមដោយភិក្ខុសង្ឃ៥០០អង្គសុទ្ធតែជាអ្នកទ្រទ្រង់នូវគុណធម៌ដ៏ធំ ស្តេចយាងចូលទៅក្នុងខេត្រដែនអង្គរដ្ឋ ទ្រង់គេចចេញអំពីផ្លូវ ចូលទៅគង់ឈប់សម្រាកជិតឆ្នេរស្រះគគ្គរា នាស្រុកចម្បា (ដែនអង្គរដ្ឋ)។ ក្នុងកាលនោះ សោណទណ្ឌព្រាហ្មណ៍ជាអ្នកគ្រប់គ្រងស្រុកចម្បា បានឃើញព្រាហ្មណ៍និងគហបតីទាំងឡាយនៅស្រុកចម្បា នាំគ្នាដើរឈមមុខទៅកាន់ស្រះគគ្គរា ក៏បានសាកសួរអាមាត្យម្នាក់ លុះបានដឹងថា ពួកជនទាំងនោះនាំគ្នាទៅគាល់ព្រះពុទ្ធជាម្ចាស់ ដែលមានព្រះកិត្តិសព្ទល្បីល្បាញថា

ព្រះសមណគោតម ព្រះរាជបុត្រស្តេចសាក្យៈ ទ្រង់យាងចេញព្រះផ្នួសអំពីសាក្យត្រកូល ព្រមដោយភិក្ខុសង្ឃ៥០០អង្គ ស្តេចមកគង់សម្រាក នៅឆ្នេរស្រះគគ្គរា ជិតស្រុកចម្បា។

ព្រះសមណគោតមនោះ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានព្រះដំណើរដ៏ប្រពៃ ជាអ្នកត្រាស់ដឹងក្នុងត្រៃលោក ជាអ្នកហ្វឹកហ្វឺនដ៏ប្រសើរបំផុត ជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ជាអ្នកដាស់តឿនឲ្យភ្ញាក់រលឹក ទ្រង់មានភាគធម៌ចែកផ្សាយដល់មនុស្សនិងទេព្តា ដូច្នេះ។ ទើបពួកគេនាំគ្នាចង់ចូលទៅគាល់ព្រះអង្គ ឯសោណទណ្ឌព្រាហ្មណ៍បានដឹងដូច្នេះ ក៏បានបញ្ជាអាមាត្យនោះ ឲ្យប្រញាប់ប្រញាល់ទៅប្រាប់ពួកជនទាំងនោះឲ្យរង់ចាំសិន។

ឯក្នុងគ្រានោះ មានពួកព្រាហ្មណ៍៥០០នាក់ មកអំពីអាណាចក្រផ្សេងៗ

គ្នា ចូលមកស្នាក់នៅស្រុកចម្បាដែរ ក៏បាននាំគ្នាទៅហាមឃាត់ថា សូមលោកសោណទណ្ឌព្រាហ្មណ៍ កុំបីចូលទៅរកព្រះសមណគោតមឡើយ ប្រសិនបើលោកសោណទណ្ឌព្រាហ្មណ៍ ចូលទៅរកព្រះសមណគោតម កិត្តិយសរបស់លោកសោណទណ្ឌព្រាហ្មណ៍ នឹងសាបសូន្យ ឯកិត្តិយសរបស់ព្រះសមណគោតមនឹងរីកចម្រើនឡើង នេះជាបុព្វហេតុទី១ ដែលលោកសោណទណ្ឌព្រាហ្មណ៍ មិនគួរចូលទៅរកព្រះសមណគោតម។

គេសម្អាងទៀតថា លោកសោណទណ្ឌព្រាហ្មណ៍ ជាអ្នកមានជាតិកំណើតល្អ បរិសុទ្ធទាំងសងខាង គឺខាងផ្ទៃកមាតា ខាងផ្ទៃកបិតាមាន៧ជួរមនុស្សហើយ នេះជាបុព្វហេតុទី២ ដែលលោក...។

គេសម្អាងថា លោកសោណទណ្ឌព្រាហ្មណ៍ជាអ្នកស្តុកស្តម្ភ មានទ្រព្យសម្បត្តិច្រើន មានគ្រឿងឧបភោគបរិភោគច្រើន នេះជាបុព្វបុរសទី៣ ដែលលោក...។

គេសម្អាងថា លោកសោណទណ្ឌព្រាហ្មណ៍ ជាអ្នកចេះដឹងផ្ទះធ្លាយក្នុងគម្ពីរព្រាហ្មណ៍ នេះជាបុព្វហេតុទី៤ ដែលលោក...។

គេសម្អាងថា លោកសោណទណ្ឌព្រាហ្មណ៍ជាអ្នកមានរូបឆោមល្អសម្បុរស្បែកល្អស្រស់ គួរជាទីពិតពិលរមិលមើលយ៉ាងក្រៃលែង នេះជាបុព្វហេតុទី៥ ដែលលោក...។

គេសម្អាងថា លោកសោណទណ្ឌព្រាហ្មណ៍ ជាអ្នកមានសីលដ៏ចម្រើន នេះជាបុព្វហេតុទី៦ ដែលលោក...។

គេសម្អាងថា លោកសោណទណ្ឌព្រាហ្មណ៍ ជាអ្នកមានពាក្យសម្តីល្អ មានពាក្យសម្តីទន់ភ្លន់ មានសម្តីពីរោះស្រួយមិនស្អកស្អា នេះជាបុព្វហេតុទី៧ ដែលលោក... ។

គេសម្អាងថា លោកសោណទណ្ឌៈជាគ្រូអាចារ្យធំ របស់មនុស្សដ៏ច្រើន ធ្លាប់បានបង្ហាត់បង្រៀនពួកមាណព ដែលមកអំពីទិសនិងជនបទផ្សេងៗជាច្រើន

នេះជាបុព្វហេតុទី៨ ដែលលោក...។

គេសម្អាងថា លោកសោណទណ្ឌៈ ជាអ្នកចាស់ទុំហើយ ឯព្រះសមណគោតម ឋិតនៅក្នុងយុវវ័យ វ័យក្មេងកំលោះ នេះជាបុព្វហេតុទី៩ ដែលលោក...។

គេសម្អាងថា លោកសោណទណ្ឌៈ ជាទីសក្ការបូជារាប់អានរបស់ព្រះបាទពិម្ពិសារ ព្រះមហាក្សត្រមគធរដ្ឋ និងរបស់បោក្ខរសាតិព្រាហ្មណ៍ នេះជាបុព្វហេតុទី១០ ដែលលោក...។

គេសម្អាងថា លោកសោណទណ្ឌៈ ជាអ្នកគ្រប់គ្រងស្រុកចម្បា ដែលព្រះបាទពិម្ពិសារ ទ្រង់បានព្រះរាជទាន នេះជាបុព្វហេតុទី១១ ហើយគ្រប់ៗខពួកគេយល់ថា សោណទណ្ឌព្រាហ្មណ៍ មិនសមគួរចូលទៅរកព្រះសមណគោតមឡើយ គឺគួរតែព្រះសមណគតោមទេត្រូវចូលមករកសោណទណ្ឌព្រាហ្មណ៍វិញ (ពួកព្រាហ្មណ៍៥០០នាក់ មកពីអាណាចក្រផ្សេងៗ ស្នាក់នៅក្នុងស្រុកចម្បា នាំគ្នាទៅហាមឃាត់សោណទណ្ឌព្រាហ្មណ៍មិនឲ្យចូលគាល់ព្រះពុទ្ធជាម្ចាស់ ដោយសម្អាងហេតុផលផ្សេងៗ ដល់១១ប្រការ ទាំងនេះបញ្ជាក់ឲ្យយើងឃើញថា សោណទណ្ឌព្រាហ្មណ៍នេះជាឥស្សរជនជាន់ខ្ពស់១រូប ដែលមានកិត្តិយសកិត្តិសព្ទល្បីខ្ចរខ្ចាយច្រើន ព្រមទាំងមានរូបសម្បត្តិ ទ្រព្យសម្បត្តិ គុណសម្បត្តិ វិជ្ជាសម្បត្តិដ៏បរិបូណ៌ក្នុងសម័យនោះ ទាំងជាអ្នកមាន ទស្សននិយមសមហេតុសមផលច្រើន គួរស្ងើចសរសើរជាខ្លាំង តែមនុស្សទាំងឡាយ ជាពិសេសក្នុងសង្គមពួកព្រាហ្មណ៍ភាគច្រើនបានខិតខំខាំងរាំងរាមិនឲ្យព្រាហ្មណ៍នេះចូលគាល់ព្រះអង្គ ក្រែងនាំឲ្យសាបរលាបដល់កិត្តិយសរបស់ពួកព្រាហ្មណ៍។ ប៉ុន្តែ សោណទណ្ឌព្រាហ្មណ៍ឥតយល់ស្របតាមទេ ដោយសម្អាងហេតុផលផ្សេងៗ ដូចលោកអ្នកអាននឹងឃើញក្នុងអត្ថបទជាបន្តបន្ទាប់)។

កាលពួកព្រាហ្មណ៍ទាំងនោះប្រឆាំងជំទាស់ ដូចពោលមកនេះហើយ ទើបសោណទណ្ឌព្រាហ្មណ៍បានពោលឡើងថា បើដូច្នេះចូរអស់លោកចាំស្តាប់សម្តីទស្សនៈរបស់ខ្ញុំបន្តិចមើល៍ ខ្ញុំនឹងសម្តែងឲ្យស្តាប់ដែលយើងគួរតែចូលទៅ

រកព្រះសមណគោតម ឯព្រះសមណគោតមមិនគួរចូលមករកយើងទេ ដោយហេតុផលច្រើនប្រការ ដែលយើងធ្លាប់បានដឹងបានឮមកថា

៦១ ព្រះសមណគោតម ជាអ្នកមានជាតិត្រកូលបរិសុទ្ធល្អមក៧ជួរគោត្រហើយ។

៦២ ព្រះសមណគោតម បានលះបង់ក្រុមព្រះញាតិដ៏ច្រើនចេញទៅព្រះផ្នួស។

៦៣ ព្រះសមណគោតម ទ្រង់បានលះបង់មាសប្រាក់ដ៏ច្រើនចេញទៅព្រះផ្នួស។

៦៤ ព្រះសមណគោតម បានយាងចេញទៅព្រះផ្នួស ក្នុងពេលកំពុងមានវ័យដ៏ស្រស់បស់ ( យុវវ័យ )។

៦៥ ព្រះសមណគោតម បានកោរព្រះកេសា និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាវពស្ត្រ ទ្រង់ព្រះផ្នួសក្នុងវេលាដែលព្រះបិតា និងព្រះញាតិវង្ស មិនចង់ឲ្យទ្រង់ចេញទៅសាងព្រះផ្នួសសោះ។

៦៦ ព្រះសមណគោតម ជាអ្នកមានសម្បុរស្បែកយ៉ាងល្អស្រស់ក្រៃលែង។

៦៧ ព្រះសមណគោតម ជាអ្នកមានអរិយសីល មានសីលដ៏ប្រសើរក្រៃលែង។

៦៨ ព្រះសមណគោតម មានព្រះវាចាពីរោះស្រួយ (គួរចង់ឲ្យស្តាប់ណាស់)។

៦៩ ព្រះសមណគោតម ជាគ្រូអាចារ្យធំរបស់គ្រូអាចារ្យទាំងឡាយ។

៦១០ ព្រះសមណគោតម អស់តម្រេកត្រេកត្រអាលក្នុងកាមារម្មណ៍ទាំងឡាយ។

៦១១ ព្រះសមណគោតម ជាកម្មវាទី ជាកិរិយវាទី ជាអ្នកធ្វើធម៌ដ៏ថ្លៃថ្នូរឲ្យចេញមុខ ជាប្រមុខនៃប្រជាជនទាំងឡាយរហូតដល់ពួកព្រាហ្មណ៍ផង។

៦១២ ព្រះសមណគោតម ទ្រង់យាងចេញព្រះផ្នួស អំពីត្រកូលខ្ពស់

ជាត្រកូលក្សត្រ ដែលមានព្រះរាជវង្សជាប់តៗមកមិនមែនដាច់សោះឡើយ។

២១៣ ព្រះសមណគោតម ទ្រង់យាងចេញព្រះផ្នួស អំពីត្រកូលដ៏ស្តុកស្តម្ភ មានទ្រព្យសម្បត្តិច្រើន មានគ្រឿងឧបភោគបរិភោគច្រើន។

២១៤ ពួកមនុស្សអំពីខេត្រដែនផ្សេងៗ ស្រុកផ្សេងៗ ដ៏ច្រើននាំគ្នាទៅក្រាបទូលសួរខសង្ស័យនឹងព្រះសមណគោតម។

២១៥ ពួកទេវតាទាំងពាន់ៗបានរាប់អានទទួលយកព្រះសមណគោតមជាទីពឹង។

២១៦ ព្រះសមណគោតម មានព្រះកិត្តិសព្ទល្បីខ្ចរខ្ចាយថា ជាព្រះអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានព្រះដំណើរល្អ ទ្រង់ត្រាស់ដឹងក្នុងត្រៃលោក ទ្រង់ជាអ្នកហ្វឹកហ្វឺនបុរសឥតអ្នកប្រៀបផ្ទឹមបាន ជាសាស្តានៃទេវតានិង មនុស្សទាំងឡាយ ជាអ្នកដាស់តឿនឲ្យភ្ញាក់រលឹក ទ្រង់មានភាគធម៌ចែកផ្សាយដល់ទេវតានិងមនុស្សទាំងឡាយដូច្នេះ។

២១៧ ព្រះសមណគោតម មានប្រក្រតីអញ្ជើញត្មៀវមុនជានិច្ច មានព្រះវាចាពីរោះស្រួយធ្វើឲ្យកើតសេចក្តីរីករាយសប្បាយដល់អ្នកដែលចូលទៅរកព្រះអង្គ រីករាយមិនក្រញូវហើយទ្រង់តែងមានព្រះបន្ទូលមុន។

២១៨ ព្រះសមណគោតម ជាទីសក្ការបូជារាប់អាននៃពួកបរិស័ទទាំង៤។

២១៩ ទេវតានិងមនុស្សដ៏ច្រើនមានចិត្តជ្រះថ្លាយ៉ាងក្រៃលែងចំពោះព្រះសមណគោតម។

២២០ ព្រះសមណគោតម ទ្រង់ស្នាក់អាស្រ័យនៅជិតស្រុកណា ជិតនិគមណា។ អមនុស្សទាំងឡាយ មិនហ៊ានយាយីបៀតបៀនមនុស្សទាំងឡាយក្នុងស្រុកនោះ ក្នុងនិគមនោះទេ។

២២១ ព្រះសមណគោតម គណាចារ្យឯក ប្រាកដជាក់ស្តែងដល់អន្យតិរ្ថិយទាំងឡាយកិត្តិយសរបស់សមណព្រាហ្មណ៍ដទៃ មិនដូចកិត្តិយសរបស់ព្រះសមណគោតមទេ ដែលទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ។

២២២ ព្រះបាទពិម្ពិសារ ព្រមទាំងព្រះឱរស ព្រះមហេសី និងមិត្តអាមាត្យ រាជបរិវារ នាំគ្នារាប់អានព្រះសមណគោតម។

២២៣ ព្រះបាទបសេនទិកោសល ព្រមទាំងព្រះឱរស ព្រះមហេសី និង មិត្តអមាត្យ រាជបរិវារ នាំគ្នារាប់អានព្រះសមណគោតម។

២២៤ បោក្ខរសាតិព្រាហ្មណ៍ ព្រមទាំងបុត្រភរិយា មិត្ត អមាត្យ បរិវារ ក៏រាប់អានព្រះសមណគោតមដែរ។

២២៥ ព្រះសមណគោតម ជាទីសក្ការៈគោរពបូជារាប់អានរបស់ព្រះបាទពិម្ពិសារ។

២២៦ ព្រះសមណគោតមជាទីសក្ការៈគោរពបូជារាប់អានរបស់ព្រះបាទបសេនទិកោសល។

២២៧ ព្រះសមណគោតមជាទីសក្ការៈគោរពបូជារបស់បោក្ខរសាតិព្រាហ្មណ៍។

២២៨ ព្រះសមណគោតមបានមកដល់ស្រុកចម្បាហើយ ទ្រង់ស្នាក់នៅឯស្រះគគ្គរា មិនថាសមណព្រាហ្មណ៍ពួកណាទេ តែបានចូលមកដល់ស្រុកទេសរបស់យើងហើយ សុទ្ធតែត្រូវជាភ្ញៀវរបស់យើងទាំងអស់ យើងគួរធ្វើសក្ការៈគោរពបូជាចំពោះភ្ញៀវរបស់យើង។ ដោយហេតុទាំងនេះហើយ អ្នកទាំងឡាយ ខ្ញុំសូមប្រាប់អ្នករាល់គ្នាថា ពួកយើងទាំងអស់គ្នា គួរតែចូលទៅរកព្រះសមណគោតម ខ្ញុំបានពណ៌នាគុណសម្បត្តិរបស់ព្រះសមណគោតមបានត្រឹមប៉ុណ្ណេះមិនមែនថា ព្រះសមណគោតមមានព្រះគុណសម្បត្តិត្រឹមប៉ុណ្ណេះក៏ទេដែរ គឺថាព្រះសមណគោតមមានគុណសម្បត្តិប្រមាណពុំបានឡើយ។

កាលសោណទណ្ឌព្រាហ្មណ៍ បានឆ្លើយតបយ៉ាងក្បោះក្បាយយ៉ាងនេះហើយ ទើបពួកព្រាហ្មណ៍ទាំងនោះពោលឡើងថា ប្រសិនបើព្រះសមណគោតមមានគំនិតប្រាកដ ដូចសម្ដីដែលលោកបានពោលមកនេះមែន ទោះបីព្រះសមណគោតម ឋិតនៅឆ្ងាយរាប់រយយោជន៍ក្ដី ទោះបីត្រូវខ្វះបាយម្ហូបក្នុងការ

ធ្វើដំណើរក្តី ក៏គួរតែកុលបុត្រអ្នកមានសទ្ធាចូលទៅរកព្រះអង្គដែរ។

ហេតុដូច្នេះ ពួកយើងត្រូវចូលទៅរកព្រះសមណគោតម ទាំងអស់គ្នា ទើបសោណទណ្ឌព្រមជាមួយនឹងពួកព្រាហ្មណ៍ដ៏ច្រើន នាំគ្នាដើរសំដៅទៅកាន់ស្រះគគ្គរា។ លុះព្រាហ្មណ៍ដើរជិតទៅដល់ក៏គិតក្នុងចិត្តថា បើអញសួរបញ្ហាចំពោះព្រះសមណគោតម ប្រសិនជាព្រះសមណគោតមត្រាស់ថា មិនត្រូវសួរយ៉ាងនេះ គួរតែយ៉ាងនោះវិញ។ មនុស្សទាំងឡាយនឹងមើលងាយថា អញល្ងង់ខ្លៅ នឹងធ្វើឲ្យអញខូចបង់កិត្តិយស យសសក្តិបរិវារ។ ប្រសិនបើព្រះសមណគោតម ត្រាស់សួរបញ្ហានឹងអញវិញ បន្ទាប់មកព្រះអង្គត្រាស់ថា មិនត្រូវឆ្លើយយ៉ាងនេះទេ គួរតែឆ្លើយយ៉ាងនោះវិញ។ មនុស្សទាំងឡាយគង់នឹងមើលងាយថា អញល្ងង់ខ្លៅដែលធ្វើឲ្យកិត្តិយសអញសាបរលាបបានដែរ។ ប្រសិនបើអញទៅជិតដល់ហើយគេចមុខចេញ មិនឲ្យព្រះសមណគោតមទតឃើញមុខទេ។ មនុស្សទាំងឡាយនឹងមើលងាយអញថា ជាមនុស្សកំសាកឬជាអ្នកប្រកាន់ខ្លួន ក៏ធ្វើឲ្យកិត្តិយសអញសាបរលាបដែរ។ បើដូច្នេះ គួរអញធ្វើដូម្តេចអេះ ?

កាលសោណទណ្ឌព្រាហ្មណ៍គិតក្នុងចិត្តយ៉ាងនេះហើយ ក៏បានទៅដល់ស្រះគគ្គរា ហើយចូលទៅគាល់ព្រះពុទ្ធជាម្ចាស់ ពោលពាក្យប្រស្រ័យរាក់ទាក់ហើយក៏អង្គុយចុះ។

ឯពួកព្រាហ្មណ៍ និងគហបតីអ្នកស្រុកចម្បាមានអាកប្បកិរិយាផ្សេងៗគ្នា គឺពួកខ្លះគ្រាន់តែថ្វាយបង្គំហើយអង្គុយនៅស្ងៀម ពួកខ្លះគ្រាន់តែសម្តែងសេចក្តីត្រេកអររីករាយ ពួកខ្លះគ្រាន់តែពោលពាក្យប្រស្រ័យ ពួកខ្លះលើកដៃប្រណម្យ ពួកខ្លះស្រែកប្រកាសនាមនិងគោត្ររបស់ខ្លួន ពួកខ្លះគ្រាន់តែនៅស្ងៀម។ កាលពួកព្រាហ្មណ៍និងគហបតីទាំងនោះ នាំគ្នាអង្គុយរៀបរយហើយ។ ឯសោណទណ្ឌព្រាហ្មណ៍នៅតែអង្គុយគិតនឹកដូចមុនដដែល ដោយខ្លាចក្រែងខ្លួននឹងត្រូវសាបរលាបចាកកិត្តិយសរហូតដល់លាភសក្ការៈផ្សេងៗ ទើបគិតសម្រេចជាចុងក្រោយថា សូមឲ្យព្រះសមណគោតមត្រាស់សួរបញ្ហាអំពីវិជ្ជា៣ ដែលជា

សេចក្ដីចេះដឹងរបស់គ្រូអាចារ្យខ្លួន ខ្លួននឹងអាចឆ្លើយដោះស្រាយបានត្រូវល្អតែម្ដង។

គ្រានោះព្រះពុទ្ធជាម្ចាស់ទ្រង់ជ្រាបនូវវារៈចិត្តរបស់សោណទណ្ឌព្រាហ្មណ៍ថា ព្រាហ្មណ៍មានសេចក្ដីលំបាកចិត្តណាស់ មានបំណងចង់ឲ្យតថាគតសួរបញ្ហាក្នុងវិជ្ជា៣ ដែលជាចំណេះនៃគ្រូអាចារ្យគេ ទើបជាងាយស្រួល (ត្រង់ឃ្លានេះបញ្ជាក់ឲ្យយើងបានដឹងជាក់ច្បាស់ថា ព្រះពុទ្ធទ្រង់ត្រាស់ដឹងវិជ្ជាខាងផ្លូវចិត្តរបស់សត្វលោកពិតប្រាកដណាស់ ដែលលទ្ធិពុទ្ធនិយម ហៅថា ចេតោបរិយញ្ញាណ (ការកំណត់ដឹងច្បាស់នូវចិត្តគំនិតរបស់អ្នកដទៃ)។ ឯវិជ្ជាលោកិយដែលហៅថា ចិត្តសាស្ត្រ គ្រាន់តែជាទ្រឹស្ដីរបស់ប្រាជ្ញក្នុងលោកិយយើងនេះ ឯការអនុវត្តមិនសូវមានលទ្ធផលជាប្រាកដនិយមទាំងអស់ទេ)។

(ក្នុងអដ្ឋកថា លោកបានពោលពន្យល់បន្ថែមថា ចាប់តាំងអំពីសោណទណ្ឌព្រាហ្មណ៍មកដល់ ក៏អង្គុយជ្រប់ឱនមុខខ្លួនរឹង។ ព្រះអង្គទ្រង់ទតឃើញដូច្នោះ ក៏ទ្រង់រំពឹងមើលហេតុអ្វីព្រាហ្មណ៍នេះអង្គុយជ្រប់មុខស្ងៀមឈឹង តើគេកំពុងគិតពីអ្វី? ព្រះអង្គទ្រង់បានជ្រាបចិត្តគំនិតរបស់គេហើយ ទើបទ្រង់ត្រាស់សួរបញ្ហាតាមគំនិតដែលគេចង់ឲ្យសួរដោយព្រះមេត្តាករុណា)។

គ្រានោះ ព្រះអង្គទ្រង់ត្រាស់សួរថា «ម្នាលព្រាហ្មណ៍ តើពួកព្រាហ្មណ៍បានបញ្ញត្តចំពោះអ្នក ប្រកបដោយអង្គប៉ុន្មានថាជាព្រាហ្មណ៍? អ្នកដែលហៅខ្លួនឯងថាជាព្រាហ្មណ៍ កាលបើនឹងហៅឲ្យបានត្រឹមត្រូវកុំមានសម្ដីមុសាវាទ តើត្រូវហៅខ្លួនឯងនិងអ្នកដទៃ ដែលប្រកបដោយអង្គប៉ុន្មានថាជាព្រាហ្មណ៍។

កាលសោណទណ្ឌព្រាហ្មណ៍ បានស្ដាប់ព្រះពុទ្ធតម្រាស់យ៉ាងនេះក៏នឹកសប្បាយចិត្តណាស់ថា អញត្រូវការយ៉ាងណា មានបំណង់យ៉ាងណា ប៉ុនប៉ងយ៉ាងណា ក៏បានយ៉ាងដូច្នោះមែន អញនឹងដោះស្រាយបញ្ហានេះ ឲ្យត្រូវព្រះទ័យរបស់ព្រះសមណគោតម។

កាលសោណទណ្ឌព្រាហ្មណ៍គិតយ៉ាងនេះហើយ ក៏ងើបមុខឡើងក្រឡេក

មើលទីប្រជុំជនខាងនេះម្តង ខាងនោះម្តង ដើម្បីបង្ហាញសេចក្តីអង់អាចក្លាហាន របស់ខ្លួនឲ្យគេបានឃើញជាក់ស្តែង ហើយក្រាបទូលឆ្លើយតបថា «បពិត្រព្រះគោតម ព្រាហ្មណ៍ទាំងឡាយបានបញ្ញត្តអ្នកដែលប្រកបដោយអង្គ៥ថាជាព្រាហ្មណ៍។ អ្នកដែលហៅខ្លួនឯងក្តី អ្នកដទៃក្តី ថាជាព្រាហ្មណ៍ បើនឹងហៅឲ្យបានត្រឹមត្រូវកុំមុសាវាទ ត្រូវហៅអ្នកប្រកប ដោយអង្គ ៥ ថាជាព្រាហ្មណ៍។ ចុះអង្គ៥គឺអ្វីខ្លះ? គឺមានមាតាបិតាជាព្រាហ្មណ៍តៗមក៧ជួរជំនាន់មនុស្ស១ ជាអ្នកចេះដឹងធ្លុះធ្លាយក្នុងត្រៃវេទនិងគម្ពីរព្រាហ្មណ៍ផ្សេងៗ១ ជាអ្នកមានរូបរាងស្រស់សម្បុរស្បែកល្អ១ ជាអ្នកមានសីល១ ជាបណ្ឌិតចេះដឹងល្អ១ ហើយជាអ្នកទី១ ឬទី២ របស់ពួកព្រាហ្មណ៍ដែលបានទទួលសក្ការបូជាយ៉ាងនេះឯងព្រះអង្គ (ចម្លើយនេះតើលោកអ្នកអានយល់ថាត្រឹមត្រូវសមហេតុសមផលទេ? ឬតើព្រះអង្គយល់ស្របតាមបទបញ្ញត្តិរបស់គេឬទេ? តើអស់លោកអាចមានទស្សនៈប្រឆាំងជំទាស់ដូចម្តេចឬគ្មានទេ? បើមិនអាចសម្រេចចិត្តទេ សូមអានអត្ថបទបន្តទៅទៀតចុះ) ។

ព្រះអង្គទ្រង់ត្រាស់សួរបញ្ជាក់តទៅទៀតថា ម្នាលព្រាហ្មណ៍ បណ្តាអង្គទាំង៥នេះ តើគេអាចលុបចោលអង្គណាមួយទុកត្រឹម៤អង្គបានឬទេ?

ព្រាហ្មណ៍ទូលតបថា បពិត្រព្រះគោតមគេអាចលុបចោលអង្គ១ចេញបានដែលស្តីអំពីពណ៌សម្បុរស្បែក ព្រោះពណ៌សម្បុរស្បែក នឹងធ្វើប្រយោជន៍អ្វីបាន ទុកត្រឹមតែ៤ខ គឺខដែលស្តីអំពីមាតាបិតាជាព្រាហ្មណ៍តាំងពី៧ ជួរមនុស្សមកហើយ១ ស្តីអំពីការចេះដឹងក្នុងគម្ពីរវេទ និងគម្ពីរព្រាហ្មណ៍ផ្សេងៗទៀត១ ស្តីអំពីសីល១ ស្តីអំពីជាបណ្ឌិតមានប្រាជ្ញា១ ត្រឹម៤ខប៉ុណ្ណោះ ក៏ចាត់ជាព្រាហ្មណ៍បាន។

ទ្រង់ត្រាស់សួរបញ្ជាក់ទៀតថា ម្នាលព្រាហ្មណ៍ចុះក្នុង៤ខនេះ គេអាចលុបចោល១ខទៀតបានឬមិនបាន ទុកត្រឹមតែ៣ខ?

ព្រាហ្មណ៍ទូលតបថា បពិត្រព្រះអង្គ គេអាចលុបចោលខដែលស្តីអំពី

ត្រៃវេទចេញក៏បាន ទុកឲ្យសល់នៅត្រឹម៣ខ គឺខដែលស្ដីអំពីមានមាតាបិតាជាព្រាហ្មណ៍តៗមក ៧ជួរជំនាន់មនុស្សហើយ១ មានសីលបរិសុទ្ធល្អ១ ជាបណ្ឌិតមានប្រាជ្ញា១ ត្រឹម៣អង្គប៉ុណ្ណោះ ក៏ចាត់ជាព្រាហ្មណ៍បាន។

ទ្រង់ត្រាស់សួរបញ្ជាក់ទៀតថា «ចុះក្នុង៣ខនេះ គេអាចនឹងលុបចោល ១ទៀត តើបានឬមិនបាន?

ព្រាហ្មណ៍ទូលតបថា «បានព្រះអង្គ! គឺខដែលស្ដីអំពីមាតាបិតាជាព្រាហ្មណ៍ តាំងអំពី៧ជួរមនុស្សចេញ ព្រោះជាតិកំណើតនឹងធ្វើប្រយោជន៍អ្វីបានទុកឲ្យនៅសល់ត្រឹម២ខ គឺខដែលស្ដីពីអ្នកមានសីលល្អ១ ស្ដីពីអ្នកជាបណ្ឌិតមានប្រាជ្ញា១ ត្រឹមប៉ុណ្ណោះក៏បាន ដ្បិតបុគ្គលប្រកបដោយអង្គ២ប៉ុណ្ណោះហៅថាជាព្រាហ្មណ៍បានមិនខុសទេព្រះអង្គ។ សេចក្ដីចោទសួរនឹងឆ្លើយតបនេះអស់លោកអ្នកអាន គង់នឹកកោតស្ញើចសរសើរ។

កាលសោណទណ្ឌព្រាហ្មណ៍ ក្រាបទូលឆ្លើយតបយ៉ាងនេះហើយ ពួកព្រាហ្មណ៍ដែលបិតនៅក្នុងទីប្រជុំនោះ បានស្រែកហាមឃាត់ឆោឡោឡើងថា «សូមលោកសោណទណ្ឌៈកុំនិយាយយ៉ាងនេះ កុំបដិសេធខពណ៌សម្បុរស្បែកត្រៃវេទ និងជាតិកំណើតឲ្យសោះ។ លោកសោណទណ្ឌៈលង់តាមសម្ដីរបស់ព្រះសមណគោតមតែម្ដង។ ប្រសិនបើអ្នកដែលប្រកបដោយជាតិត្រកូលព្រាហ្មណ៍ អ្នកដែលមានពណ៌សម្បុរល្អស្រស់ អ្នកដែលមានចំណេះក្នុងគម្ពីរព្រាហ្មណ៍មិនមែនជាព្រាហ្មណ៍តើនឹងមាននរណាផ្សេងទៀតក្នុងលោកនេះនឹងចាត់ទុកជាព្រាហ្មណ៍បាន!។

កាលពួកព្រាហ្មណ៍ទាំងនោះ ស្រែកឆោឡោហាមឃាត់យ៉ាងនេះហើយ ទើបព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា «ប្រសិនបើពួកព្រាហ្មណ៍រាល់គ្នាយល់ឃើញថា សោណទណ្ឌៈជាអ្នកសិក្សារៀនសូត្រតិច មានវាចាមិនល្អ មិនមានប្រាជ្ញាមិនអាចឆ្លើយឆ្លងនឹងសមណគោតមបាន ចូរឲ្យសោណទណ្ឌៈឈប់ស្ងៀមសិនចុះ។ ចូរឲ្យអ្នករាល់គ្នាជាព្រាហ្មណ៍ចូលមកនិយាយតទល់នឹងតថាគតវិញចុះ។

ប៉ុន្តែប្រសិនបើអ្នករាល់គ្នាយល់ឃើញថា សោណទណ្ឌៈជាអ្នកសិក្សារៀនសូត្រច្រើន មានវាចាល្អ ជាបណ្ឌិតមានប្រាជ្ញា មានសមត្ថភាពឆ្លើយឆ្លងនឹងសមណគោតមបាន ចូរអ្នករាល់គ្នានៅស្ងៀមទុកឲ្យសោណទណ្ឌៈនិយាយតទល់នឹងយើងវិញ។

ព្រះពុទ្ធតម្រាស់នេះ បានធ្វើឲ្យពួកព្រាហ្មណ៍ទាំងអំបាលនោះស្ងាត់មាត់ជ្រៀបជាប្រក្រតី ប្រសិនបើព្រះអង្គមិនត្រាស់យ៉ាងនេះទេ នឹងមានសូរសំឡេងខ្សឹបខ្សៀវគ្នាអ៊ូឡើងក្នុងទីប្រជុំនោះ ការសន្ទនាតទល់គ្នានឹងប្រព្រឹត្តទៅមិនបានស្រួលឡើយ ហើយការប្រជុំគ្នាក្នុងពេលនោះនឹងគ្មានបានលទ្ធផលអ្វីដែរ។

កាលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់យ៉ាងនេះហើយ ទើបសោណទណ្ឌព្រាហ្មណ៍ ក្រាបទូលឡើងថា សូមព្រះគោតមគង់នៅឲ្យស្ងៀមចុះ ទុកឲ្យទូលព្រះបង្គំនិយាយតទល់ជាមួយនឹងពួកគេវិញ។ លុះព្រាហ្មណ៍ក្រាបទូលយ៉ាងនេះហើយ ទើបនិយាយទៅកាន់ពួកព្រាហ្មណ៍ទាំងនោះថា «ពួកអ្នករាល់គ្នាកុំពោលថាយ៉ាងនេះៗឡើយ ពួកអ្នករាល់គ្នាកុំពោលថា សោណទណ្ឌៈបដិសេធរូបរាងពណ៌សម្បុរ បដិសេធគម្ពីរត្រៃវេទ បដិសេធវង្សត្រកូលព្រាហ្មណ៍ លង់ទៅតាមពាក្យសម្ដីរបស់ព្រះសមណគោតមតែម្តងឡើយ។ យើងមិនបានជំទាស់នឹងរូបរាងសម្បុរស្បែកថាមិនល្អ មិនបានជំទាស់គម្ពីរត្រៃវេទថាមិនល្អ មិនបានជំទាស់នឹងវង្សត្រកូលព្រាហ្មណ៍ថាមិនល្អឡើយ។

លុះព្រាហ្មណ៍ពោលដូច្នេះហើយ ក៏ចង្អុលបង្ហាញរូបអង្គកមាណពដែលជាក្មួយរបស់ខ្លួនបិតនៅក្នុងទីប្រជុំនោះថា «នេះនៃអ្នកទាំងឡាយ អង្គកមាណពនេះជាអ្នកមានរូបរាងពណ៌សម្បុរល្អស្រស់នៅក្នុងទីប្រជុំនេះ លើកលែងព្រះសមណគោតមចេញ គ្មានអ្នកណាមួយមានរូបរាងពណ៌សម្បុរល្អស្រស់ ដូចអង្គកមាណពនេះឡើយ។ម្យ៉ាងទៀតអង្គកមាណពនេះក៏ជាអ្នកចេះដឹងផ្ទះធ្លាយក្នុងគម្ពីរព្រាហ្មណ៍ អង្គកមាណពមានមាតាបិតាជាព្រាហ្មណ៍មក៧តំណមនុស្សមកហើយ។ ក៏ប៉ុន្តែប្រសិនបើអង្គកមាណពនេះបំផ្លាញជីវិតអ្នកដទៃលួចទ្រព្យ

សម្បត្តិអ្នកដទៃ សេពគប់នឹងភរិយាអ្នកដទៃ និយាយពាក្យភរភូត ផឹកទឹកស្រវឹង តើរូបរាងពណ៌សម្បុរល្អនឹងមានប្រយោជន៍អ្វី ជាតិត្រកូលរបស់ព្រាហ្មណ៍នឹងមានប្រយោជន៍អ្វី របស់ទាំងអស់នេះនឹងជួយធ្វើអ្វីបាន។ ប៉ុន្តែដោយហេតុតែព្រាហ្មណ៍ ជាអ្នកមានសីលបរិសុទ្ធល្អ ជាបណ្ឌិតមានប្រាជ្ញា ត្រាតែបានជាទី១ ឬទី២របស់អ្នកបានទទួលគ្រឿងសក្ការបូជា នេះហើយដែលគេគួរហៅថាព្រាហ្មណ៍បាន ឥតទាស់អ្វីឡើយ។

ក្រោយសោណទណ្ឌព្រាហ្មណ៍បានដោះស្រាយការប្រឆាំងជំទាស់ជំទាស់ពួកព្រាហ្មណ៍ក្នុងទីប្រជុំរួចស្រេចហើយ ទើបព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សួរបញ្ជាក់តទៅទៀតថា «ម្នាលព្រាហ្មណ៍ ក្នុងអង្គទាំងពីររបស់ព្រាហ្មណ៍ គឺខដែលស្តីពីសីលនិងបញ្ញានេះ បើគេលុបអង្គណាមួយទៀត ទុកនៅសល់អង្គតែមួយប៉ុណ្ណោះថាជាព្រាហ្មណ៍ តើបានឬមិនបាន ?

ព្រាហ្មណ៍ឆ្លើយតបថា មិនបានទេព្រះអង្គ ព្រោះបញ្ញាបរិសុទ្ធបានដោយសីល ឯសីលក៏បរិសុទ្ធបានដោយបញ្ញាដែរ។ សីលមានក្នុងបុគ្គលណា បញ្ញាក៏មានក្នុងបុគ្គលនោះ បញ្ញាមានក្នុងបុគ្គលណាសីលក៏មានក្នុងបុគ្គនោះដែរ បញ្ញាមានដល់បុគ្គលអ្នកមានសីល ឯសីលក៏មានដល់បុគ្គលអ្នកមានបញ្ញាដែរ សីលនិងបញ្ញាទាំងពីរនេះជាធម៌ប្រសើរក្នុងលោក។

«បពិត្រព្រះគោតម បុគ្គលត្រូវលាងដៃដោយដៃ ត្រូវលាងជើងដោយជើង យ៉ាងណាមិញ បញ្ញាបរិសុទ្ធដោយសីល ឯសីលក៏បរិសុទ្ធដោយបញ្ញាក៏យ៉ាងនោះដែរ។ សីលមានក្នុងបុគ្គលណា បញ្ញាក៏មានក្នុងបុគ្គលនោះ។ បញ្ញាតែងមានដល់អ្នកមានសីល ឯសីលក៏តែងមានដល់អ្នកមានបញ្ញាដែរ សីលនិងបញ្ញាទាំងពីរនេះជាធម៌ប្រសើរក្នុងលោកព្រះអង្គ! (សេចក្តីឆ្លើយតបរបស់ព្រាហ្មណ៍ដូចបានពោលខាងលើនេះ បញ្ជាក់ឲ្យយើងយល់ថា ទស្សនៈរបស់ព្រាហ្មណ៍អភិបាលស្រុកចម្បា មានលក្ខណៈសមហេតុសមផលច្រើន ថែមទាំងហ៊ានប្រឆាំងបដិសេធចោលនូវគោលការណ៍ខ្លះនៃបទបញ្ញត្តិរបស់ព្រាហ្មណ៍។

ទស្សនៈបែបនេះហាក់ដូចជួយគាំទ្រពេញទី ចំពោះទស្សនៈពុទ្ធនិយមដែរ ព្រោះពុទ្ធនិយម ឥតមានប្រកាន់យកជាតិកំណើត វណ្ណៈរូបរាងពណ៌សម្បុរ ទ្រព្យសម្បត្តិ យសសក្តិបរិវារ ឬរឿងឧបភោគបរិភោគអ្វីធ្វើជាមូលដ្ឋានសម្រាប់លើកតម្កើងតម្លៃរបស់មនុស្សសោះឡើយ។ ពុទ្ធនិយមប្រកាន់យកអំពើល្អអាក្រក់របស់មនុស្សធ្វើជាប្រធាន ជាមូលដ្ឋាននៃតម្លៃរបស់មនុស្សម្នាក់ៗ ( **យាទិសំ វប្បតេ ពីជំ តាទិសំ លព្ភតេ ផលំ** ) បុគ្គលព្រោះសាបពូជយ៉ាងណា គេនឹងបានទទួលផលដូច្នោះដែរ។ ( **កល្យាណការី កល្យាណំ បាបការី ច បាបកំ** ) អ្នកធ្វើល្អតែងបានល្អ អ្នកធ្វើអាក្រក់បានអាក្រក់។ ហេតុដូច្នេះហើយ ទើបព្រះអង្គត្រាស់បញ្ជាក់ថា យ៉ាងនេះមែនព្រាហ្មណ៍...។

ព្រះអង្គត្រាស់បញ្ជាក់ថែមថា យ៉ាងនេះមែនព្រាហ្មណ៍ សេចក្តីដែលអ្នកពោលមកនេះត្រឹមត្រូវល្អហើយសេចក្តីពិតគឺយ៉ាងនេះឯង ( ព្រះពុទ្ធតម្រាស់នេះជាកិច្ចលើកទឹកចិត្តសោណទណ្ឌព្រាហ្មណ៍ ជាអតិបរមានាកណ្តាលមហាសន្និបាតនៃអ្នកមុខអ្នកការពួកព្រាហ្មណ៍ )។

ក្រោយបានទទួលព្រះពុទ្ធតម្រាស់គាំទ្រសម្តីរបស់ខ្លួនយ៉ាងនេះហើយ ទើបសោណទណ្ឌព្រាហ្មណ៍ក្រាបបង្គំទូលសួរអំពីខដែលស្តីពីសីលនិងបញ្ញា សូមឲ្យព្រះអង្គត្រាស់សម្តែងឲ្យខ្លួនស្តាប់ដោយពិស្តារ។ ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីចុល្លសីល មជ្ឈិមសីល និងមហាសីល ហើយទ្រង់ត្រាស់សម្តែងឈាន៤ និងអភិញ្ញា៦ ឲ្យព្រាហ្មណ៍បានស្តាប់ដោយពិស្តារ។

សោណទណ្ឌព្រាហ្មណ៍ បានក្រាបទូលសរសើរព្រះធម៌ទេសនា ប្រកាសថ្វាយខ្លួនជាឧបាសកក្នុងពុទ្ធសាសនាចាប់តាំងពីថ្ងៃនោះជាដើមទៅ។ ដល់ព្រឹកឡើងបានប្រកាសនិមន្តព្រះពុទ្ធអង្គ ព្រមទាំងភិក្ខុសង្ឃ ដើម្បីទទួលចង្ហាន់នៅគ្រឹះស្ថានរបស់ខ្លួន។

( ចប់ សោណទណ្ឌសូត្រ ត្រឹមប៉ុណ្ណេះ )

# បញ្ហានិងការដោះស្រាយ ស្ដីពីហាយនៈ៤ និងធម្មុទ្ទេស៤

(សេចក្ដីខាងក្រោមនេះមាននៅក្នុងរដ្ឋបាលសូត្រ គម្ពីរមជ្ឈិមនិកាយ មជ្ឈិម
បណ្ណាសកៈ។ ផ្នែកខាងដើមនៃសូត្រនេះ ជាសេចក្ដី
តំណាលអំពីជីវប្រវត្តិរបស់រដ្ឋបាលកុលបុត្រយ៉ាងសង្ខេប
ដល់ផ្នែកកណ្ដាលនិងខាងចុងអត្ថបទ
ទើបមានការចោទ និងដោះស្រាយស្ដីពីធម្មុទ្ទេស៤ និងហាយនៈ៤)។

មានសេចក្ដីតំណាលថា ព្រះដ៏មានព្រះភាគជាម្ចាស់ ស្ដេចចូលទៅក្នុងរដ្ឋកុរុជាមួយនឹងព្រះភិក្ខុសង្ឃដ៏ច្រើន យាងចូលទៅក្នុងនិគមរបស់ពួកកុរុឈ្មោះថុល្លកោដ្ឋិតនិគម។

ព្រាហ្មណ៍និងគហបតីទាំងឡាយ អ្នកស្រុកថុល្លកោដ្ឋិតនិគម បានដឹងព័ត៌មាននោះ ក៏នាំគ្នាចូលទៅគាល់។

គ្រានោះ មានកុលបុត្រម្នាក់ឈ្មោះរដ្ឋបាល ជាបុត្រទោលរបស់ត្រកូលដ៏ខ្ពង់ខ្ពស់ក្នុងនិគមនោះ បានចូលទៅអង្គុយក្នុងទីប្រជុំជននោះដែរ បានស្ដាប់ធម៌របស់ព្រះពុទ្ធជាម្ចាស់ ហើយក៏គិតថា «មិនមែនជាការងាយទេ ដែលអ្នកនៅគ្រប់គ្រងផ្ទះនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិសុទ្ធបរិបូណ៌អស់ជើង ដូចស័ង្ខដែលគេខាត់បាន ទុកជាយ៉ាងណាក៏ដោយ យើងត្រូវកោរសក់ កោរពុកមាត់ ស្លៀកដណ្ដប់សំពត់ជ្រលក់ដោយទឹកអម្ចត់រួចចេញសាងផ្នួស»។

លុះពួកព្រាហ្មណ៍និងគហបតីក្រាបថ្វាយបង្គំលាចេញទៅវិញហើយ ទើបរដ្ឋបាលកុលបុត្រចូលទៅថ្វាយបង្គំសូមបព្វជ្ជាចំពោះព្រះពុទ្ធជាម្ចាស់ ព្រះអង្គត្រាស់សួរថា ចុះមាតាបិតារបស់អ្នកអនុញ្ញាតឲ្យអ្នកបព្វជ្ជាហើយឬ?

ក្រាបទូលថា មិនទាន់បានអនុញ្ញាតទេ ព្រះអង្គ!។

ទ្រង់ត្រាស់ថា ព្រះតថាគតទាំងឡាយមិនអនុញ្ញាតបព្វជ្ជាដល់កុលបុត្រដែលមាតាបិតាមិនព្រមអនុញ្ញាតឲ្យនោះទេ។

កុលបុត្រក្រាបទូលថា បើដូច្នេះ ទូលព្រះបង្គំនឹងត្រឡប់ទៅសុំអនុញ្ញាតអំពីមាតាបិតាសិន ហើយក្រាបថ្វាយបង្គំលាទៅ បានថ្លែងបំណងរបស់ខ្លួនដល់មាតាបិតា តែអ្នកទាំងពីរមិនព្រមអនុញ្ញាត កុលបុត្រសុខចិត្តដេកអត់អាហារអស់៧ថ្ងៃ។ ទើបពួកមិត្តរបស់គេបានទៅជួយសុំអង្វរដល់មាតាបិតាគេ ត្រាតែមាតាបិតាគេយល់ព្រមអនុញ្ញាតឲ្យកុលបុត្រទៅបព្វជ្ជាបាន។ កុលបុត្រក្រោកឡើងបរិភោគអាហារ មានកម្លាំងគ្រប់គ្រាន់ហើយ ក៏ចូលទៅគាល់ព្រះអង្គទូលសូមបព្វជ្ជា។

លុះកុលបុត្របានបព្វជ្ជាឧបសម្បទហើយបានកន្លះខែ ព្រះពុទ្ធជាម្ចាស់ស្តេចចេញអំពីថុល្លកោដ្ឋិតនិគមស្តេចចូលទៅកាន់ក្រុងសាវត្ថីវិញ។ ឯរដ្ឋបាលភិក្ខុតាំងចិត្តបំពេញសមណធម៌មិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្ត។ លុះបានសម្រេចជាព្រះអរហន្តហើយ លោកក៏ថ្វាយបង្គំលាព្រះអង្គវិលទៅកាន់ថុល្លកោដ្ឋិតនិគមវិញ ហើយបានទៅសម្រាកនៅឯមិគាចីរឧទ្យានក្នុងថុល្លកោដ្ឋិតនិគមនោះឯង។

ដល់ព្រឹកឡើង លោកចូលទៅបណ្ឌិបាតតាមលំដាប់ត្រកូល រហូតដល់មាត់ទ្វារផ្ទះបិតារបស់លោក។ ក្នុងខណៈនោះ បិតារបស់លោកបានចេញទៅមើលការគួរគំនូរត្រង់ទ្វារសាលាកណ្តាលនិគម បានក្រឡេកឃើញលោកអំពីចម្ងាយដែរ តែចាំមិនបាន ទើបពោលឡើងក្នុងពេលនុំះថា សមណៈនេះឯងបានឲ្យបព្វជ្ជាដល់កូនតូចតែមួយ ដែលជាទីស្រឡាញ់ពេញចិត្តរបស់យើង។ លោកមិនបានអ្វីអំពីផ្ទះបិតាលោកទេ គ្រាន់តែឮពាក្យថា និមន្តទៅមុខទៅក៏គ្មានដែរ បានត្រឹមតែពាក្យជេរប៉ុណ្ណោះ។

ក្នុងគ្រានោះ ទាសីនៃញាតិរបស់លោកកំពុងនាំយកនំផ្អូមទៅចាក់ចោល ទើបលោកពោលថា បើរបស់នុ៎ះ ត្រូវចាក់ចោល ចូរដាក់មកក្នុងបាត្ររបស់

អាត្មាវិញចុះ។ ទាសីនោះក៏ចាក់នំផ្អម ក្នុងបាត្ររបស់លោកទៅ។ នាងចាំដៃជើងនិងសំឡេងរបស់លោកបាន ទើបត្រឡប់ទៅជម្រាបដល់មាតារបស់លោកថា «អយ្យបុត្ររបស់អ្នកម្ចាស់ដែលឈ្មោះ រដ្ឋបាល បានត្រឡប់មកដល់ហើយ»។ មាតាលោកក៏និយាយថា «បើឯងនិយាយពាក្យពិត អញមិនឲ្យឯងធ្វើជាទាសីតទៅទៀតទេ» ថាហើយក៏ទៅរកបិតាលោកប្រាប់ថា លោកគហបតីចូរលោកដឹងចុះ រដ្ឋបាលបុត្ររបស់លោកបានមកដល់ហើយ។

ក្នុងវេលានោះ ព្រះរដ្ឋបាលត្ថេរអង្គព្រះអរហន្ត កំពុងគង់ឆាន់នំផ្អមត្រង់ម្លប់ដំបូលផ្ទះរបស់ជនម្នាក់។ បិតារបស់លោក បានទៅតាមរកជួបហើយពោលថា «រដ្ឋបាលកូនគួរឬ ដែលកូនមកស៊ីនំផ្អមដូច្នេះ គួរតែកូនត្រឡប់ទៅឯផ្ទះរបស់យើងវិញមែនទេ» លោកឆ្លើយថា «លោកគហបតី ផ្ទះរបស់អាត្មាជាអ្នកបួសគ្មានទេ អាត្មាបានទៅឯផ្ទះរបស់លោកហើយ ឥតបានអ្វីទេ សូម្បីគ្រាន់តែប្រាប់ថាឲ្យត្រឡប់ទៅវិញក៏គ្មានដែរ បានត្រឹមតែពាក្យជេរប៉ុណ្ណោះ»។ គហបតីបិតាលោកពោលថា មកចុះរដ្ឋបាល ទៅឯផ្ទះ( យើង )វិញ។ លោកតបថា «កុំអីលោកគហបតី ថ្ងៃនេះអាត្មាឆាន់រួចហើយ» បិតាក៏និយាយថា បើដូច្នេះ ពេលព្រឹកសូមនិមន្តលោកទៅឆាន់ឯផ្ទះវិញចុះ។ លោកព្រមទទួលដោយស្ងាត់ស្ងៀម។

លំដាប់នោះ មាតាបិតារបស់លោក ក៏នាំគ្នាត្រឡប់ទៅផ្ទះវិញ ចាត់ចែងរៀបចំផ្ទះឲ្យស្អាតល្អ ហើយប្រើឲ្យគេជញ្ជូនយកមាសប្រាក់មកគរទុកជាគំនរធំៗ២គំនរ គឺប្រាក់១គំនរ មាស១គំនរ ក្នុងគំនរមួយៗខ្ពស់លេចក្បាលបុរសហើយឲ្យគេយកកន្ទេលគ្របទុក តាំងអាសនៈទុកត្រង់ពាក់កណ្ដាលគំនរមាសប្រាក់នោះ រួចបញ្ជាដល់ពួកភរិយារបស់ព្រះរដ្ឋបាលត្ថេរថា ពួកនាងរាល់គ្នាធ្លាប់តែងខ្លួនយ៉ាងណា ទើបជាទីស្រឡាញ់ពេញចិត្ត របស់រដ្ឋបាលកូនយើង ចូរនាំគ្នាតែងខ្លួនយ៉ាងនោះចុះ។

លុះដល់ព្រឹកឡើង បិតារបស់ព្រះរដ្ឋបាលត្ថេរ បញ្ជាឲ្យរៀបចំអាហារស្រេចហើយ ឯព្រះរដ្ឋបាលត្ថេរប្រដាប់ដោយបាត្រចីវរ និមន្តចូលទៅឯផ្ទះ

របស់បិតា ហើយគង់លើអាសនៈដែលគេរៀបចំបម្រុងទុក បិតាលោកបានឲ្យគេបើកគំនរប្រាក់គំនរមាសឡើង ហើយប្រាប់ថា រដ្ឋបាលកូន ទ្រព្យរបស់មាតាមានប៉ុណ្ណោះ ទ្រព្យរបស់បិតាមានប៉ុណ្ណោះ របស់ជីតាមានប៉ុណ្ណោះ រដ្ឋបាលអាចនឹងប្រើប្រាស់ អាចនឹងធ្វើបុណ្យទានតាមសប្បាយបាន ចូរកូនសឹកមកប្រើប្រាស់ធ្វើបុណ្យទានតាមសប្បាយចុះ។

ព្រះរដ្ឋបាលត្ថេរតបទៅវិញថា លោកគហបតី បើលោកអាចធ្វើតាមពាក្យរបស់អាត្មាភាពបាន អាត្មានឹងប្រាប់ គឺសុំឲ្យលោកជញ្ជូនយកគំនរមាសប្រាក់នេះផ្ទុកលើរទេះ ហើយយកទៅចាក់ចោលក្នុងទន្លេគង្គាឲ្យអស់ទៅ ទើបគ្មានការសោកសៅសង្រេងសង្រែ ទុក្ខទោមនស្ស តានតឹងចិត្ត កើតឡើងដល់លោកព្រោះតែមាសប្រាក់នេះឯង ជាដើមហេតុ។

លំដាប់នោះ ពួកភរិយាចាស់របស់លោកនាំគ្នាឈូឈរចូលទៅ ដើម្បីចាប់ជើង ព្រមដោយពាក្យអង្វរករថា បពិត្រព្រះអយ្យបុត្រជាម្ចាស់ ពួកនាងអប្សរដែលនាំឲ្យព្រះអយ្យបុត្រខំប្រព្រឹត្តព្រហ្មចរិយធម៌នះ តើមានសម្រស់ដូចម្ដេចទៅ?

លំដាប់នោះ ព្រះរដ្ឋបាលត្ថេរតបថា យើងមិនបានប្រព្រឹត្តព្រហ្មចរិយធម៌ព្រោះតែយល់ឃើញដល់ពួកនាងអប្សរទេ។

ពួកភរិយាចាស់ទាំងនោះក៏ខូចទឹកចិត្ត ទៅជាខ្យល់ចាប់ដួលរងោករងល់ទៅ។ លំដាប់នោះ ព្រះរដ្ឋបាលត្ថេរប្រាប់បិតាថា លោកគហបតី បើមានអាហារដែលត្រូវឲ្យអាត្មាក៏ចូរឲ្យមកចុះ កុំធ្វើឲ្យអាត្មាលំបាកពេកឡើយ។ ទើបបិតាប្រាប់ថាឆាន់ចុះរដ្ឋបាល អាហាររួចស្រេចហើយ ហើយក៏ចាត់អាហារដ៏ប្រណីតប្រគេនព្រះរដ្ឋបាលត្ថេរ។

វេលាព្រះរដ្ឋបាលត្ថេរឆាន់រួចហើយ លោកក្រោកឈរឡើងពោលថា ចូរមើលរូបដ៏វិចិត្រដ៏មានកាយជាដំបៅ លើកឡើងដោយរាងឆ្អឹងដ៏រសាប់រសល់ដែលជាទីប្រាថ្នារបស់ពួកមនុស្សដ៏ច្រើន ដែលឥតឋិតថេរខ្ជាប់ខ្ជួននេះផងចុះ។

ចូរមើលរូបដែលគេធ្វើឲ្យមានលម្អដោយកែវមណី ដោយកុណ្ឌលដែលរួបរឹតដោយឆ្អឹង និងស្បែកលម្អដោយសម្លៀកបំពាក់នេះផងចុះ។ ជើងរបស់ស្ត្រីដែលលាបពណ៌ក្រហម មុខរបស់ស្ត្រីដែលផាត់ដោយម្សៅផង ល្មមធ្វើឲ្យមនុស្សល្ងង់ខ្លៅវង្វេងវង្វាន់បាន តែមិនអាចធ្វើឲ្យអ្នកស្វែងរកនិព្វានវង្វេងបានឡើយ។ សក់របស់ស្ត្រីដែលចងជាខ្នន់ៗដល់៨ខ្នន់ ភ្នែករបស់ស្ត្រី ដែលបន្ទត់ដោយថ្នាំភ្នែក អាចធ្វើឲ្យជនល្ងង់ខ្លៅវង្វេងបាន តែមិនអាចធ្វើឲ្យជនស្វែងរកនិព្វានវង្វេងបានឡើយ។ រាងកាយដ៏ផ្អូមរលួយដែលបានតាក់តែងឲ្យល្អល្អះនេះ ល្មមបោកបញ្ឆោតមនុស្សល្ងង់ៗបាន តែបោកបញ្ឆោតមនុស្សឈ្លាសវៃមិនបានឡើយ។ ព្រានប្រមាញ់ តែងធ្វើអន្ទាក់បម្រុងទុកដាក់ម្រឹគតែម្រឹគដែលឈ្លាសវៃមិនព្រមជាប់អន្ទាក់របស់ព្រានប្រមាញ់ទេ ថែមទាំងស៊ីនុយដែលដាក់បញ្ឆោតឲ្យអស់ផង រួចគេចរត់ទៅធ្វើឲ្យព្រានប្រមាញ់ខូចទឹកចិត្តអស់។ លុះព្រះថេរៈពោលដូច្នេះហើយ ក៏ត្រឡប់និមន្តទៅឯមិគាចីរឧទ្យានតាមផ្លូវអាកាស ហើយលោកគង់សម្រាកនៅទៀបគល់ដើមឈើ១។

គ្រានោះ ព្រះបាទកោរព្យរាជត្រាស់បញ្ជានាយឧទ្យានថា គួរប្រស្តែងទៅរៀបចំ មិគាចីរឧទ្យានឲ្យជាទីគួរទស្សនា ។ នាយឧទ្យានទទួលព្រះរាជឱង្ការក៏ទៅចាត់ចែងមិគាចីរឧទ្យាន ក៏បានជួបព្រះរដ្ឋបាលត្ថេរគង់សម្រាកក្បែរគល់ឈើមួយដើម ក៏បានវិលចូលទៅគាល់ព្រះរាជាក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំរៀបចំមិគាចីរឧទ្យានរួចហើយឯក្នុងឧទ្យាននោះ មានកុលបុត្រឈ្មោះរដ្ឋបាល ដែលជាបុត្ររបស់ត្រកូលដ៏កំពូលក្នុងថុល្លកោដ្ឋិតនិគមនេះ គង់នៅក្បែរគល់ឈើ១ដើមព្រះអង្គ។

ព្រះរាជាត្រាស់បញ្ជាថា បើដូច្នេះយើងនឹងទៅទស្សនាសួរថា ព្រះរដ្ឋបាលត្ថេរ ឥឡូវនេះឯង ត្រាស់ហើយទ្រង់ឡើងគង់លើព្រះរាជយាន មានព្រះរាជបរិវារដ៏ច្រើនហែហមផង លុះស្ដេចដល់ ក៏ទ្រង់យាងចុះអំពីរាជយាន យាងចូលទៅក្នុងឧទ្យាន មិនបានទ្រង់ប្រស្រ័យនឹងព្រះថេរៈទេ រវល់រៀបចំអាសនៈ

ទ្រង់។ លុះទ្រង់រៀបរយហើយ ទ្រង់ត្រាស់ថា លោករដ្ឋបាល សូមនិមន្ត គង់លើអាសនៈដ៏ល្អនេះចុះ។

ព្រះរដ្ឋបាលត្ថេរ ថ្វាយព្រះពរថា កុំបាច់ឡើយមហាបពិត្រ ចូរស្ដេចគង់ប្រថាប់ចុះ អាត្មាភាពបានអង្គុយលើអាសនៈរបស់ខ្លួនហើយ។

ព្រះបាទគោរព្យរាជប្រថាប់គង់លើអាសនៈរបស់ព្រះអង្គហើយ ទ្រង់ត្រាស់ថា លោករដ្ឋបាល ហាយនៈគឺក្ដីសាបសូន្យ៤ប្រការ ដែលធ្វើឲ្យបុគ្គលខ្លះចេញបួស។ ក្ដីសាបសូន្យ៤ប្រការនោះគឺ ជរាភាព១ មានព្យាធិ១ អស់ទ្រព្យសម្បត្តិ១ អស់ញាតិសន្តាន១។

អ្នកខ្លះចាស់ជរាហើយក៏គិតថា អាត្មាអញចាស់ជរាហើយ អាត្មាអញនឹងមិនងាយស្វែងរកទ្រព្យដែលមិនទាន់បាន ឬធ្វើទ្រព្យដែលបានហើយឲ្យលូតលាស់ចម្រើនឡើងនោះបានទេ បើដូច្នេះ អាត្មាអញត្រូវចេញទៅបួស ហើយក៏ចេញបួសទៅ។ ចុះឯលោករដ្ឋបាលនៅក្មេងកំលោះ មានសក់ខ្មៅស្រឹបឋិតនៅក្នុងបឋមវ័យ មិនទាន់ចាស់សោះទេ ចុះលោករដ្ឋបាលដឹងយ៉ាងណា ឃើញយ៉ាងណា បានដឹងឮដូចម្ដេចទើបលោកចេញបួស ?

នៃលោករដ្ឋបាល អ្នកខ្លះមានជំងឺតម្កាត់ប្រចាំកាយក៏ធុញទ្រាន់ក្នុងការស្វែងរកទ្រព្យ ឬមិនអាចធ្វើទ្រព្យឲ្យលូតលាស់ចម្រើនបាន ទើបគេចេញទៅបួស។ ចំណែកឯលោកឈឺថ្កាត់តិច កម្លាំងធាតុនៅបរិបូណ៌ល្អ មានធាតុភ្លើងមិនក្ដៅពេក មិនត្រជាក់ពេក តើលោកដឹងយ៉ាងណា ឃើញយ៉ាងណា បានឮបានស្ដាប់យ៉ាងណា ទើបបានជាលោកចេញបួស ?

នៃលោករដ្ឋបាល អ្នកខ្លះធ្លាប់ជាអ្នកមានស្ដុកស្ដម្ភ តែក្រោយមកទាល់ក្រលំបាកតោកយ៉ាក ទាល់គំនិតនឹងរកទ្រព្យឲ្យមានឡើងវិញបាន ឬធ្វើទ្រព្យដែលមានស្រាប់ឲ្យលូតលាស់ឡើងបាន ទើបគេចេញទៅបួសទៅ។ ចំណែកឯលោកជាបុត្រអ្នកមានត្រកូលខ្ពស់ ក្នុងថុល្លកោដ្ឋិតនិគមនេះ ក្ដីសាបសូន្យចាកទ្រព្យរបស់លោកមិនមានឡើយ ចុះលោកដឹងយ៉ាងណា ឃើញយ៉ាងណា

បានឮបានស្តាប់យ៉ាងណា ទើបលោកចេញទៅបួស?

នៃលោករដ្ឋបាល អ្នកខ្លះធ្លាប់មានមិត្តអាមាត្យញាតិសាលោហិតច្រើន តែលុះអស់មិត្តអាមាត្យញាតិសាលោហិតទៅដោយលំដាប់ ក៏គិតឃើញថា អាត្មាអញមិនអាចស្វែងរកទ្រព្យបានទេ មិនអាចធ្វើទ្រព្យឲ្យលូតលាស់បានទេ ហើយក៏ចេញទៅបួស ចំណែកឯលោកនៅមានមិត្តអាមាត្យញាតិសាលោហិតដ៏ច្រើន គ្មានការសាបសូន្យចាកចេញញាតិឡើយ តើលោកដឹងយ៉ាងណា ឃើញយ៉ាងណា បានឮបានស្តាប់យ៉ាងណា ទើបលោកចេញទៅបួស?

នៃលោករដ្ឋបាល ក្តីសាបសូន្យ៤ប្រការគឺ ជរាភាព ព្យាធិ អស់ទ្រព្យ អស់ញាតិ ធ្វើឲ្យបុគ្គលខ្លះតោងចេញទៅបួស។ ចំណែកឯលោកគ្មានក្តីសាបសូន្យ៤ប្រការនេះឡើយ ចុះហេតុអ្វីក៏លោកចេញទៅបួសដែរ(ហេតុដែលព្រះបាទគោរព្យរាជ លើកយកបញ្ហាស្តីពីហាយនៈ សេចក្តីសាបសូន្យ៤យ៉ាង ចោទសួរព្រះរដ្ឋបាលត្ថេរ នាំឲ្យយើងអ្នកអានអត្ថបទនេះ មានការងឿងឆ្ងល់ខ្លះមិនខាន? ព្រោះក្នុងប្រទេសកម្ពុជាយើង ពួកពុទ្ធបរិស័ទដែលបំពេញផ្នួសក្នុងពុទ្ធសាសនាមិនមែនសុទ្ធតែត្រូវវិបត្តិ៤យ៉ាងឬយ៉ាងណាមួយគ្របសង្កត់ទេ គឺច្រើនតែនិយមទៅតាមប្រពៃណីដែលជាទំនៀមទម្លាប់ពុទ្ធបរិស័ទខ្មែរភាគច្រើន។ ឯរដ្ឋបាលកុលបុត្រ បានសុខចិត្តលះបង់សម្បត្តិមហាសាល បរិវារសម្បត្តិ និងត្រកូលដ៏ខ្ពង់ខ្ពស់ចេញទៅសាងផ្នួស ក្នុងពុទ្ធសាសនា លោកមានឧត្តមគតិខ្ពង់ខ្ពស់ណាស់ គឺឋិតនៅក្នុងលោកកុត្តរនិយម (មគ្គផលនិព្វាន)។

ព្រះរដ្ឋបាលត្ថេរ អង្គព្រះអរហន្ត បានឆ្លើយតបនៅព្រះបាទគោរព្យរាជថា បពិត្រមហារាជ ព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់បានត្រាស់សម្តែងធម្មុទ្ទេស៤ប្រការ ដែលធ្វើឲ្យអាត្មាភាពបានដឹងហើយ បានឃើញហើយ បានស្តាប់ហើយ ត្រេកអរយ៉ាងក្រៃលែង ស្មគ្រចិត្តចេញសាងផ្នួសក្នុងពុទ្ធសាសនានេះ។

ចុះធម្មុទ្ទេស៤ប្រការ គឺអ្វីខ្លះ? គឺខទី១ ថា «**ឧបនីយតិ លោកោ អទ្ធុវោ**»

លោកគ្មានស្ថិរភាពទេ រមែងត្រូវនាំចូលទៅជានិច្ច។ ខទី២ ថា «**អតាណោ លោកោ អនិស្សរោ**» លោកគ្មានអ្វីការពារទេ គ្មានឥស្សរភាពដោយខ្លួនឯងទេ។ ខទី៣ ថា «**អស្សកោ លោកោ សព្វំ បហាយ គមនីយំ**» លោក មិនមានអ្វីជារបស់ខ្លួនទេ ត្រូវតែលះបង់របស់ទាំងអស់ទៅ។ ខទី៤ ថា «**ឩនោ លោកោ អតិត្តោ តណ្ហាទាសោ**» លោកខ្វះជានិច្ច មិនចេះឆ្អែតទេ ជាទាសៈ នៃតណ្ហាដូច្នេះ។

ទាំង៤ខនេះហើយ មហាបពិត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់បានលើក ឡើងសម្តែង ដែលអាត្មាភាពបានដឹងហើយ ឃើញហើយ បានស្តាប់មកហើយ ទើបបានចេញសាងផ្នួស។

ព្រះបាទគោរព្យរាជ ទ្រង់ត្រាស់សួរថា បពិត្រលោករដ្ឋបាល លោក ពោលថា លោកគ្មានស្ថិរភាព គឺថាគ្មានការទៀងទាត់ទេ តែងត្រូវនាំចូលទៅ ជានិច្ច ដូច្នេះ តើពាក្យរបស់លោកគួរយល់ន័យនៃសេចក្តីដូចម្តេច?

ព្រះរដ្ឋបាលត្ថេរឆ្លើយថា សូមថ្វាយព្រះពរ កាលព្រះអង្គមានព្រះជន្ម ២០វស្សាឬ២៥វស្សា ដែលមានកម្លាំងដើមដៃ កម្លាំងជើងគ្រប់គ្រាន់ មានការ ស្ទាត់ជំនាញខាងដំរី ខាងសេះ ខាងរថ ខាងធ្នូ ខាងដាវបានល្អ ទ្រង់បានចូល សង្គ្រាមមកហើយមែនឬ?

ទ្រង់ត្រាស់តបថា ធ្លាប់ចូលសង្គ្រាមមកហើយលោកម្ចាស់ ជួនកាល ខ្ញុំករុណាមិនសម្លឹងឃើញនរណាមួយ មានកម្លាំងស្មើនឹងខ្ញុំករុណាឡើយ ហាក់ដូចខ្ញុំករុណា ជាអ្នកមានឫទ្ធិដ៏វិសេសតែម្តង។

-សូមថ្វាយព្រះពរ វេលានេះ ព្រះអង្គមានកម្លាំងព្រះពាហានិងព្រះបាទា មានសមត្ថភាព មានសេចក្តីក្លាហានក្នុងសង្គ្រាមយ៉ាងដូច្នោះដែរឬ?

-មិនដូចទេ លោករដ្ឋបាល ព្រោះវេលានេះ ខ្ញុំករុណាចាស់ជរា មានអាយុ ដល់៨០ឆ្នាំហើយ ជួនកាលខ្ញុំករុណាចង់ដាក់ជើងត្រង់ទីនេះ ក៏បែរជាដាក់ជើង ត្រង់កន្លែងផ្សេងវិញ។

- នេះហើយមហាបពិត្រ ព្រះដ៏មានព្រះភាគជាម្ចាស់ ជាអ្នកដឹង អ្នកឃើញ ជាព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់បានត្រាស់ថា លោកគ្មានស្ថិរភាពទេ មានតែត្រូវនាំទៅជានិច្ច ដែលអាត្មាភាពបានដឹងហើយ បានឃើញហើយ បានស្តាប់ហើយ ទើបចេញសាងបព្វជ្ជាក្នុងពុទ្ធសាសនា។

«បពិត្រលោករដ្ឋបាល ព្រះដ៏មានព្រះភាគ ជាអ្នកដឹង អ្នកឃើញ ជាព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់បានត្រាស់ថា លោកគ្មានស្ថិរភាព ត្រូវជរានាំចេញទៅរកមរណៈជានិច្ចជាការត្រឹមត្រូវមែនពិតគួរឲ្យអស្ចារ្យ។ក៏ប៉ុន្តែក្នុងរាជត្រកូលនេះមានពលដំរី ពលសេះ ពលរថ ពលថ្មើរជើងការពារជានិច្ច ចុះហេតុអ្វីក៏លោករដ្ឋបាលពោលថា លោកគ្មានអ្វីការពារទេ គ្មានឥស្សរភាពដោយខ្លួនឯងទេ តើខនេះ គេអាចយល់ន័យសេចក្តីដូចម្តេច?

- សូមថ្វាយព្រះពរមហាបពិត្រ ទ្រង់ធ្លាប់ប្រឈួនដោយព្រះរោគអ្វីមួយខ្លះឬទេ?

- ធ្លាប់ឈឺខ្លះដែរ ជួនកាល មានពួកមិត្តអាមាត្យញាតិសាលោហិតមកឈរចោមរោមខ្ញុំករុណា និយាយថា គ្រានេះព្រះរាជាគោរព្យនឹងដល់ពេល (របស់ព្រះអង្គ) ហើយ។

- សូមថ្វាយព្រះពរ ចុះពួកមិត្តអាមាត្យញាតិសាលោហិតរបស់ព្រះអង្គបានជួយរំពឹកទុក្ខវេទនារបស់ព្រះអង្គ ឲ្យបានស្រាកស្រាន្តបានខ្លះ ឬមួយព្រះអង្គត្រូវសោយទុក្ខវេទនាតែមួយព្រះអង្គផង?

- បពិត្រលោករដ្ឋបាល ពួកមិត្តអាមាត្យញាតិសាលោហិតទាំងនោះ មិនបានជួយរំលែកទុក្ខវេទនារបស់ខ្ញុំករុណាឲ្យធូរស្រាលបានទេ គឺខ្ញុំករុណាតែម្នាក់ឯង ទទួលរងទុក្ខវេទនាទាំងនោះ។

- សូមថ្វាយព្រះពរ ព្រះដ៏មានព្រះភាគជាម្ចាស់ ជាអ្នកដឹង អ្នកឃើញ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់បានកត់សម្គាល់សេចក្តីយ៉ាងនេះឯង បានទ្រង់ត្រាស់ទុកថា លោកគ្មានអ្នកការពារទេ គ្មានឥស្សរភាពដោយខ្លួនឯងទេ ដែល

អាត្មាភាពដឹងហើយ បានឃើញហើយ បានស្តាប់ឮហើយ ទើបអាត្មាភាពចេញសាងផ្នួសក្នុងពុទ្ធសាសនានេះ។

- គួរឲ្យអស្ចារ្យដែរ ព្រះពុទ្ធដីកាដែលព្រះពុទ្ធជាម្ចាស់ បានត្រាស់សម្តែងទុកយ៉ាងនេះ ជាពាក្យត្រឹមត្រូវពិតមែន ក៏ប៉ុន្តែរាជត្រកូលនោះ មានមាសប្រាក់ជាច្រើន ចុះហេតុអ្វីក៏លោករដ្ឋបាលបានពោលថា លោកនេះគ្មានអ្វីជារបស់ខ្លួនទេ ត្រូវតែលះបង់ចោលរបស់ទាំងពួងទៅ?

- សូមថ្វាយព្រះពរ ព្រះអង្គទ្រង់សព្វព្រះទ័យនឹងសេចក្តីតទៅនេះយ៉ាងដូចម្តេច គឺក្នុងឥឡូវនេះ ព្រះអង្គពោរពេញដោយកាមគុណទាំង៥ប្រការ ប៉ុន្តែអំណើះតទៅ នៅតែទ្រង់ពោរពេញដោយកាមគុណទាំង៥យ៉ាងនេះ ឬមួយអ្នកដទៃមកគ្រប់គ្រងទ្រព្យសម្បត្តិទាំងនោះជំនួសព្រះអង្គ? ចំណែកខាងព្រះអង្គត្រូវលះបង់ទ្រព្យសម្បត្តិទាំងពួងទៅតែមួយព្រះអង្គឬដូចម្តេច?

- លោករដ្ឋបាល ខ្ញុំករុណាមិនបានពោរពេញដោយកាមគុណទាំង៥ ដូចយ៉ាងនេះរហូតទៅទេ គឺទ្រព្យសម្បត្តិទាំងពួងនោះ ត្រូវធ្លាក់ទៅលើអ្នកដទៃគ្រប់គ្រង ឯខ្ញុំករុណាតែម្នាក់ឯង ត្រូវទៅតាមយថាកម្មរបស់ខ្លួនតែប៉ុណ្ណោះ។

- មហាបពិត្រ ព្រះដ៏មានព្រះភាគជាម្ចាស់ ជាអ្នកដឹង ជាអ្នកឃើញ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់បានកត់សម្គាល់ត្រង់ខនេះយ៉ាងនេះឯង ទើបទ្រង់ត្រាស់ទុកថា លោកគ្មានអ្វីជារបស់ខ្លួនទេ ត្រូវតែលះបង់ចោលរបស់ទាំងពួងទៅ ដែលនាំឲ្យអាត្មាភាពបានដឹង បាន់ឃើញ បានស្តាប់ឮហើយ ទើបចេញសាងផ្នួសក្នុងព្រះពុទ្ធសាសនា។

- គួរឲ្យអស្ចារ្យមែន លោករដ្ឋបាល ព្រះពុទ្ធដីការបស់ព្រះពុទ្ធជាម្ចាស់ ដែលទ្រង់បានត្រាស់សម្តែងទុកមកនេះ ជាពាក្យត្រឹមត្រូវពិតមែន!។ លោករដ្ឋបាលបានពោលទៀតថា លោកខ្វះខាតជានិច្ច មិនចេះឆ្អែតឆ្អន់ទេ ជាទាសៈនៃតណ្ហា ដូច្នេះតើមានន័យសេចក្តីដូចម្តេច?

- សូមថ្វាយព្រះពរ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅដែនកុរុដ៏ធំទូលាយ

មែនឬ?

- ពិតមែន លោករដ្ឋបាល។

- បពិត្រមហារាជ ប្រសិនបើមានបុរសម្នាក់ ដែលគួរជឿទុកចិត្តបាន មកអំពីទិសខាងកើតបានក្រាបទូលថា សូមព្រះតេជះតម្កល់លើត្បូង ទូលបង្គំមកអំពីទិសខាងកើត បានឃើញជនបទមួយដ៏ធំទូលាយ មាននុស្សច្រើនកុះករ មានពលដំរី ពលសេះ ពលរថ ពលថ្មើរជើងច្រើន ភ្លុកនិងស្បែកសត្វក៏ច្រើន ( ទន្តាជិន ប្រែថា ភ្លុកនិងស្បែក សត្វនោះគឺ ទន្ត ភ្លុកដំរី អជិន សំដៅយកស្បែកសត្វដែលគេមិនទាន់សម្លាប់។ ឯស័ព្ទ ចម្មៈ សំដៅស្បែកសត្វដែលគេសម្លាប់ហើយ សម្រាប់ប្រើធ្វើជាប្រដាប់ប្រដាផ្សេងៗ ) មានប្រាក់មាសទាំងសម្រេចរូប ទាំងមិនសម្រេចរូបក៏ច្រើន មានរបស់ដែលគេគប្បីហួងហែង គឺស្ត្រីក៏ច្រើនដែរ។ ព្រះអង្គនឹងអាចយកឈ្នះបានតែដោយកម្លាំងទ័ពប៉ុណ្ណោះ តើមហាបពិត្រទ្រង់ធ្វើយ៉ាងណា?

- លោករដ្ឋបាល ខ្ញុំករុណានឹងត្រូវលើកកងទ័ពទៅវាយយកស្រុកនោះឲ្យបានមកនៅក្នុងការគ្រប់គ្រងរបស់ខ្ញុំករុណា។

- បពិត្រមហារជ បើមានបុរសម្នាក់ទៀត មកពីទិសខាងលិច ម្នាក់ទៀតមកពីទិសខាងជើង ម្នាក់ទៀតមកពីទិសខាងត្បូង ម្នាក់ទៀតមកពីត្រើយសមុទ្រខាងនាយឯណោះ បុរសទាំងនោះមកក្រាបទូលអំពីស្រុកទេសដ៏ធំទូលាយ មានមនុស្សច្រើនកុះករ មានពលដំរី ពលសេះ ពលរថ ពលថ្មើរជើងដ៏ច្រើន មានភ្លុកដំរី និងស្បែកសត្វក៏ច្រើន មានប្រាក់មាសទាំងសម្រេចរូប ទាំងមិនសម្រេចរូបក៏ច្រើន មានរបស់ដែលគួរហួងហែង គឺស្រីក៏ច្រើន ព្រះអង្គអាចយកឈ្នះបាន តែដោយកម្លាំងទ័ពប៉ុណ្ណោះ។ តើព្រះអង្គនឹងទ្រង់ធ្វើដូចម្តេច?

- លោករដ្ឋបាល ខ្ញុំករុណានឹងលើកទ័ពទៅវាយយកស្រុកទាំងនោះ មកទុកក្នុងការគ្រប់គ្រងរបស់ខ្ញុំករុណាទាំងអស់។

- បពិត្រមហារាជ ព្រះដ៏មានព្រះភាគជាម្ចាស់ ជាអ្នកដឹង ជាអ្នកឃើញ

ជាព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់កត់សម្គាល់សេចក្តីនេះឯង ទើបទ្រង់ត្រាស់ថា លោកខ្វះខាតជានិច្ច មិនចេះឆ្អែតឆ្អន់ទេ ជាទាសៈនៃតណ្ហា ដូច្នេះ ដែលនាំឲ្យអាត្មាភាពបានដឹង បានឃើញ បានស្តាប់ឮហើយ ទើបចេញសាងផ្នួសក្នុងព្រះពុទ្ធសាសនានេះ។

- គួរអស្ចារ្យមែន លោករដ្ឋបាល ព្រះពុទ្ធដីកាដែលព្រះពុទ្ធជាម្ចាស់ទ្រង់បានត្រាស់ទុកមកយ៉ាងនេះ ពេញជាត្រឹមត្រូវពិតមែន។

លំដាប់នោះ ព្រះរដ្ឋបាលត្ថេរអង្គអរហន្ត បានពោលសម្តែងតទៅទៀតថា អាត្មាភាពបានឃើញពួកមនុស្សដែលមានទ្រព្យច្រើនក្នុងលោក ដែលជាមនុស្សល្ងង់ខ្លៅ បានទ្រព្យមកហើយមិនធ្វើទាន គិតតែពីខាងសន្សំទ្រព្យទុក គិតខាងចង់បានថែមឡើងទៅទៀត។ ព្រះរាជាបានគ្រប់គ្រងផែនដីដ៏ធំ មានមហាសមុទ្រជាព្រំខណ្ឌរហូតដល់ច្រាំងត្រើយខាងនាយទៀត។ ព្រះរាជានិងពួកមនុស្សដទៃទៀតជាច្រើន មិនចេះអស់តណ្ហាទេរហូតដល់ស្លាប់។

ពួកមនុស្សដ៏ច្រើន មានតែខ្វះខាត មិនចេះឆ្អែតឆ្អន់ ក្នុងកាមារម្មណ៍ឡើយ។ ពួកក្រុមញាតិតែងរំសាយសក់ស្រែកយំកន្ទក់កន្ទេញ។ មនុស្សទាំងឡាយតែងពោលថា សូមកុំឲ្យពួកយើងស្លាប់ឡើយ តែពួកគេក៏នាំយកបុគ្គលដែលគ្របឃុំដោយសំពត់ទៅដុតឯទីប៉ាឆា ពេលដុតត្រូវគេចាក់ដោយលំពែងថែមទៀត សូម្បីសំពត់មួយយកជាប់នឹងខ្លួនមិនបានផង គេត្រូវលះបង់ក្រុមញាតិមិត្តនិងទ្រព្យសម្បត្តិទាំងពួងទៅ ហើយអ្នកដែលស្លាប់គ្មានញាតិមិត្តណាជួយបានឡើយ។ អ្នកដែលត្រូវបានមត៌កក៏ជញ្ជូនយកទ្រព្យអ្នកនោះទៅ។ អ្នកនោះក៏ទៅតាមយថាកម្មរបស់ខ្លួន មិនមានបុត្រភរិយាទ្រព្យសម្បត្តិ ផ្ទះសំបែងអ្វីតាមទៅជាមួយនឹងអ្នកស្លាប់ទៅទេ។ បុគ្គលមិនមែនមានអាយុយឺនយូរ ដោយទ្រព្យសម្បត្តិទេ មិនមែនកម្ចាត់ជរាភាពបានដោយសារទ្រព្យសម្បត្តិដែរ។

អ្នកចេះដឹងទាំងឡាយបានពោលថា ជីវិតនេះជារបស់តិចតួច ជារបស់មិនឋិតថេរខ្ជាប់ខ្ជួន ជារបស់មានការប្រែប្រួលជាធម្មតា។ ទាំងអ្នកមាន ទាំង

អ្នកក្រ ទាំងអ្នកល្ងង់ ទាំងអ្នកឆ្លាតដូចគ្នាទាំងអស់។ ប៉ុន្តែថា មនុស្សល្ងង់បានទទួលទុក្ខហើយតែងដេកកើតទុក្ខក្រៀមក្រម។ ឯមនុស្សឆ្លាត ទោះបីទទួលទុក្ខក៏មិនញាប់ញ័រ។ ព្រោះហេតុដូច្នេះ ទើបថា បញ្ញាដែលធ្វើឲ្យបានសម្រេចនិព្វាន ជាគុណជាតិល្អប្រសើរជាងទ្រព្យ។ អ្នកល្ងង់ខ្លៅ ដែលមិនសម្រេចនិព្វាន តែងធ្វើកម្មមិនល្អទុកក្នុងភពតូចភពធំ គឺភពអាក្រក់និងភពល្អ ក្នុងចំណោមពួកដែលធ្វើកម្មយ៉ាងនេះ មិនថាអ្នកណាមួយទេ ត្រូវតែវិលកើត វិលស្លាប់ជាដរាបរៀងទៅ។

ចោរដែលគេចាប់បានហើយ តែងក្តៅក្រហាយដោយកម្មរបស់ខ្លួនយ៉ាងណាមិញ អ្នកធ្វើកម្មមិនល្អទុក ក៏ក្តៅក្រហាយដោយកម្មរបស់ខ្លួន ក្នុងលោកខាងមុខយ៉ាងនោះដែរ។

អារម្មណ៍ទាំងឡាយដែលខ្លួនស្រឡាញ់ ដែលខ្លួនគាប់ចិត្ត តែងញាំញីចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅផ្សេងៗ។ អ្នកមានបញ្ញាសម្លឹងឃើញទោសក្នុងកាមគុណទាំងឡាយយ៉ាងនេះ ព្រោះហេតុនេះហើយ ទើបអាត្មាភាពចេញទៅសាងផ្នួសក្នុងព្រះពុទ្ធសាសនា។

មនុស្សទាំងឡាយ ទាំងក្មេង ទាំងចាស់ តែងតែស្លាប់ដូចគ្នា ដូចជាផ្លែឈើទាំងទុំ ទាំងខ្ចី តែងតែត្រូវជ្រុះដូចគ្នាទាំងអស់។ អាត្មាភាពបានដឹងយ៉ាងនេះហើយ ទើបចេញទៅសាងផ្នួសក្នុងពុទ្ធសាសនា។

ភាពសមណៈមិនខុសទេ ជាភាពប្រសើរមែន អាត្មាភាពបានពិចារណាឃើញយ៉ាងនេះហើយ ទើបចេញទៅសាងផ្នួសក្នុងពុទ្ធសាសនា។

សូមមហាបពិត្រទ្រង់ជ្រាបចុះថា អាត្មាភាពបានចេញទៅសាងផ្នួសក្នុងពុទ្ធសាសនា ព្រោះបានដឹង បានឃើញ បានស្តាប់ឮមកយ៉ាងនេះឯង សូមថ្វាយព្រះពរ។

អស់សេចក្តីឆ្លើយតបរបស់ព្រះរដ្ឋបាលត្ថេរត្រឹមប៉ុណ្ណោះ។

# ទស្សននិយមប្លែកគ្នា
# រវាងពាហិរសាសនា

អត្ថបទដកស្រង់ចេញពី
ឯសុការីសូត្រ គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ក្នុងសុត្តន្តបិដក
ភាគ១៥
សេចក្តីពន្យល់ពាក្យខ្លះ និងទស្សនៈនៃអ្នកប្រែ-រៀបរៀង

ពាហិរសាសនា (ក្នុងទីនេះ សំដៅយកលទ្ធិសាសនាព្រាហ្មណ៍) មានទស្សនៈនិងគោលការណ៍អនុវត្តប្លែកផ្សេងអំពីពុទ្ធសាសនា។ ប្រសិនបើគេពិនិត្យមើលការវិវត្តនៃលទ្ធិសាសនានេះ តាំងពីបុរាណកាល គឺចាប់ផ្តើមអំពីសម័យវេទនិយម ឆ្លងចូលមកក្នុងសម័យព្រាហ្មណ៍និយម ហើយនៅទីបំផុត មកដល់សម័យហិណ្ឌូនិយម (សព្វថ្ងៃនេះ)។

សម័យវេទ ជាសម័យពហុទេវនិយម (គឺការនិយមរាប់អានអាទិទេពច្រើនអង្គ ឧទាហរណ៍ ព្រះអាទិត្យ ព្រះពាយ ព្រះភិរុណ ព្រះអគ្គី ព្រះធរណី) ។ល។

សម័យព្រាហ្មណ៍ ជាសម័យឯកទេវនិយម (គឺគេបង្កើតឲ្យមានអាទិទេពខ្ពង់ខ្ពស់បំផុតត្រឹមមួយអង្គ គឺព្រះព្រហ្ម ជាអ្នកបង្កើតមនុស្សសត្វ និងធម្មជាតិទូទៅក្នុងលោក)។

សម័យហិណ្ឌូ ពួកព្រាហ្មណ៍បានកែប្រែគោលការណ៍របស់គេអំពីឯកទេវនិយមមកជាត្រីមូរតិ (តាមការពិនិត្យយល់ឃើញរបស់អ្នកប្រាជ្ញខ្លះ បានពោលថាលទ្ធិត្រីមត្រូវនេះ ប្រហែលកើតឡើងក្នុងសម័យពុទ្ធកាលឬក្រោយមកទៀត។ ដូច្នេះនាំឲ្យយើងយល់ថា នេះប្រហែលយកតម្រាប់តាមរតនត្រ័យនៃព្រះពុទ្ធសាសនាទេដឹង?) ប្រកបដោយអាទិទេពខ្ពង់ខ្ពស់ផុតពាអង្គគឺ ព្រះសិវៈ ព្រះវិស្ណុ និង

ព្រះព្រហ្ម (ព្រះអាទិទេពអង្គនេះហាក់ដូចជានិមិត្តរូបនៃធម្មជាតិ៣យ៉ាងគឺ កើត ទ្រទ្រង់ និងវិនាសសាបសូន្យ)។

ចំណែកឯលទ្ធិពុទ្ធនិយម មិនបានពឹងផ្អែកលើព្រះអាទិទេពទេ គឺឲ្យពឹងផ្អែកទៅលើគំនិត ប្រាជ្ញាស្មារតី និងសមត្ថភាពរបស់មនុស្សជាមូលដ្ឋាន ដូចយើងបានឃើញស្រាប់ នូវការដោះស្រាយវិបត្តិផ្សេងៗ ឬបញ្ហាស្មុគស្មាញផ្សេងៗ ក្នុងសង្គមមនុស្ស តាមបែបបទ ឬមធ្យោបាយរបស់មនុស្សស្ទើរតែទាំងអស់។

លទ្ធិព្រាហ្មណ៍បានចាត់រៀបចំសង្គមមនុស្សជាក្រុម ជាពួក ជាជាន់ជាថ្នាក់ ដែលហៅថា វណ្ណៈ តាំងពីសម័យវេទរហូតមកដល់សម័យហិណ្ឌូ។ វណ្ណៈនេះ ដើមឡើយមានត្រឹម៤ថ្នាក់គឺ វណ្ណៈក្សត្រ១ វណ្ណៈព្រាហ្មណ៍១ វណ្ណៈវៃស្យ ឬវេស្សៈ១ វណ្ណៈសូទ្រៈ១។ ទាំង៤ វណ្ណៈនេះ គេតម្រូវឲ្យមានករណីយកិច្ចផ្សេងៗគ្នា ទាំងអស់ សិទ្ធិនិងសេរីភាពរបស់មនុស្ស ក៏មិនស្មើភាពគ្នាដែរ មានតែពួកវណ្ណៈជាន់ខ្ពស់ទេ (ក្សត្រនិងព្រាហ្មណ៍) ទើបមានសិទ្ធិសេរីភាពប្រសើរជាងវណ្ណៈដទៃទៀតទាំងអស់។ដូច្នេះឃើញថាពួកសង្គមមនុស្សក្នុងលទ្ធិព្រាហ្មណ៍ មានការជិះជាន់សង្កត់សង្កិនគ្នា គ្មានសមត្ថភាពនិងសេរីភាពទេ។ ពួកវណ្ណៈថ្នាក់ក្រោមត្រូវទទួលបាបគ្រោះច្រើនជាងគេ ជាពិសេសពួកសូទ្រៈដែលជាវណ្ណៈថ្នាក់ក្រោមបង្អស់នៃក្រុមវណ្ណៈទាំង៤។

ឯលទ្ធិពុទ្ធនិយមវិញ ព្រះពុទ្ធជាម្ចាស់ទ្រង់បានប្រឆាំងជំទាស់នឹងគោលវណ្ណនិយមនេះជាដាច់ខាត គឺថាព្រះពុទ្ធជាម្ចាស់ហាក់ដូចព្រះអង្គទ្រង់ប្រទានសិទ្ធិសេរីភាព និងសមត្ថភាពដល់មនុស្សលោកគ្រប់ជាន់ថ្នាក់ ទោះបីមនុស្សនោះឋិតនៅក្នុងឋានៈណា ក្នុងក្រុមវណ្ណៈណា ឬក្នុងត្រកូលណាក៏ដោយ គឺថាតាមទស្សនៈពុទ្ធនិយម គ្មានការរើសអើងសោះឡើយ។

ហេតុដូច្នេះហើយ បានជាយើងបានឃើញអត្ថបទមួយក្នុងព្រះត្រៃបិដកផ្នែកសុត្តន្តបិដក គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ មានសូត្រមួយហៅថាឯសុការីសូត្រ ខ្ញុំសូមលើកមកដោយសង្ខេបដូចតទៅនេះ ៖

សម័យថ្ងៃមួយ មានព្រាហ្មណ៍ម្នាក់ឈ្មោះ ឯសុការី បានចូលទៅគាល់ព្រះពុទ្ធជាម្ចាស់នៅវត្តជេតពន (ក្រុងសាវត្ថី) បានក្រាបទូលថា បពិត្រព្រះគោតម ពួកព្រាហ្មណ៍ បានបញ្ញត្តបារិចរិយា (ការបម្រុងបម្រើ) មាន៤យ៉ាង គឺការបម្រុងបម្រើព្រាហ្មណ៍១ ការបម្រុងបម្រើក្សត្រ១ ការបម្រុងបម្រើវៃស្យៈ១ ការបម្រុងបម្រើសូទ្រៈ១។ ពួកព្រាហ្មណ៍ ក៏បានបញ្ញត្តទៀតថា ពួកព្រាហ្មណ៍ ត្រូវបម្រុងបម្រើព្រាហ្មណ៍ ពួកក្សត្រ វៃស្យៈ និងសូទ្រៈ ក៏ត្រូវបម្រុងបម្រើពួកព្រាហ្មណ៍ដែរ។ ពួកក្សត្រត្រូវបម្រុងបម្រើក្សត្រ ពួកវៃស្យៈ និង សូទ្រៈ ត្រូវបម្រុងបម្រើក្សត្រដែរ។ ពួកវៃស្យៈ ត្រូវបម្រុង បម្រើវៃស្យៈ ពួកសូទ្រៈត្រូវបម្រុងបម្រើវៃស្យៈដែរ។ ឯពួកសូទ្រៈ ត្រូវបម្រុងបម្រើពួកសូទ្រៈ ឯវណ្ណៈដទៃទៀតមិនត្រូវបម្រុងបម្រើពួកសូទ្រៈទេ (ពួកព្រាហ្មណ៍បានបញ្ញត្តបារិចរិយា៤យ៉ាង តម្រូវទៅលើវណ្ណៈទាំង៤ពួក បែបនេះយើងយល់ថា គ្មានយុត្តិធម៌ទាល់តែសោះ ព្រោះគេតម្រូវវណ្ណៈ៣ពួក ត្រូវទំនុកបម្រុងបម្រើពួកព្រាហ្មណ៍ ឯពួកព្រាហ្មណ៍គ្មានត្រូវបម្រើវណ្ណៈ ក្រៅពីពួកខ្លួនឡើយ)។

ឯសុការីព្រាហ្មណ៍បានទូលសួរថា «ចុះព្រះគោតម ទ្រង់បញ្ញត្តដូចម្តេចទៅវិញ?

(ក្នុងអត្ថបទព្រះពុទ្ធជាម្ចាស់ មិនបានត្រាស់ឆ្លើយតបភ្លាមៗទេ) ព្រះអង្គបានត្រាស់សួរទៅព្រាហ្មណ៍វិញថា «ចុះការបញ្ញត្តបារិចរិយា៤យ៉ាងរបស់ព្រាហ្មណ៍នេះ តើលោកទាំងមូលយល់ព្រមឬទេ សុខចិត្តធ្វើតាមឬទេ?

ព្រាហ្មណ៍ទូលថា «បពិត្រព្រះគោតម មិនបានយល់ព្រមទេ។

ព្រះអង្គត្រាស់ថា «នែព្រាហ្មណ៍មានឧបមាដូច បុរសកម្សត់ម្នាក់មិនត្រូវការសាច់ទេ តែអ្នកលក់សាច់បង្ខំឲ្យបុរសកម្សត់នោះទិញសាច់ ហើយតម្រូវឲ្យបុរសកម្សត់ចេញថ្លៃសាច់ឲ្យគេ នេះយ៉ាងណាមិញ។ ពួកព្រាហ្មណ៍ដែលបញ្ញត្តិបារិចរិយា៤យ៉ាង (សម្រាប់វណ្ណៈទាំង៤) ដោយមិនបានទទួលយល់ព្រមអំពីលោកទាំងមូលក៏ដូច្នោះដែរ។ ម្នាលព្រាហ្មណ៍ តថាគតមិនបាន

ពោលថា អ្វីៗទាំងពួង បុគ្គលត្រូវតែបម្រុងបម្រើទេ ទាំងមិនបានពោលថា អ្វីៗទាំងពួង បុគ្គលមិនត្រូវបម្រុងបម្រើក៏ទេដែរ។ គឺគួរបម្រុងបម្រើតែអ្វីដែលល្អ អ្វីដែលមិនល្អមិនគប្បីបម្រុងបម្រើឡើយ។ ប្រសិនបើអ្នកសួរពួកព្រាហ្មណ៍ ក្សត្រ វៃស្ស និងសូទ្រៈ ចម្លើយរបស់គេក៏គង់ស្របតាមទស្សនៈនេះដែរ។

«ម្នាលព្រាហ្មណ៍ តថាគតមិនពោលថា បុគ្គលល្អប្រសើរជាងគេ ព្រោះមានត្រកូលខ្ពង់ខ្ពស់ជាងគេទេ ទាំងមិនពោលថា បុគ្គលថោកទាបជាងគេ ព្រោះមានត្រកូលខ្ពង់ខ្ពស់ជាងគេក៏ទេដែរ។ តថាគតមិនពោលថា បុគ្គលល្អប្រសើរជាងគេ ព្រោះមានពណ៌ស្បែកល្អជាងគេ ទាំងក៏មិនពោលថា បុគ្គលថោកទាបជាងគេ ព្រោះមានពណ៌សម្បុរស្បែកល្អជាងគេក៏ទេដែរ ។ តថាគតមិនពោលថា បុគ្គលល្អប្រសើរជាងគេ ព្រោះមានទ្រព្យសម្បត្តិច្រើនជាងគេទេ ទាំងមិនពោលថា បុគ្គលថោកទាបជាងគេ ព្រោះមានទ្រព្យសម្បត្តិច្រើនជាងគេ ក៏ទេដែរ។

«ម្នាលព្រាហ្មណ៍ តថាគតមិនបានពោលថា បុគ្គលល្អប្រសើរជាងគេ ព្រោះមានត្រកូលខ្ពង់ខ្ពស់ជាងគេក្តី ព្រោះមានពណ៌សម្បុរល្អជាងគេក្តី ព្រោះមានទ្រព្យសម្បត្តិច្រើនជាងគេក្តី ទាំងមិនបានពោលថា បុគ្គលថោកទាបជាងគេ ព្រោះមានត្រកូលខ្ពង់ជាងគេក្តី ព្រោះមានពណ៌សម្បុរស្បែកល្អជាងគេក្តី ព្រោះមានទ្រព្យសម្បត្តិច្រើនជាងគេក្តី ក៏ទេដែរ។

(អត្ថបទបន្តទៅទៀត ព្រះពុទ្ធជាម្ចាស់ទ្រង់បានបញ្ជាក់តម្លៃរបស់មនុស្សទាំងឡាយ មិនមែនឋិតនៅលើពូជពង្សត្រកូល ទ្រព្យសម្បត្តិ ឬពណ៌សម្បុរស្បែកអ្វីឡើយ)។

«ម្នាលព្រាហ្មណ៍ បុគ្គលខ្លះកើតក្នុងត្រកូលខ្ពង់ខ្ពស់ជាងគេក្តី ខ្លះមានពណ៌សម្បុរល្អជាងគេក្តី ខ្លះមានទ្រព្យសម្បត្តិច្រើនជាងគេក្តី ប៉ុន្តែជាអ្នកប្រព្រឹត្តអំពើជាអកុសលផ្សេងៗ មានបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារជាដើម (សំដៅយកអកុសលកម្មបថទាំង១០ប្រការ មានបាណាតិបាតជាដើម ក្នុងទីនេះខ្ញុំសូមសង្ខេបខ្លី ដើម្បីឲ្យអ្នកអានងាយយល់) តថាគតមិនបានពោល

ថា បុគ្គលនោះៗល្អប្រសើរជាងគេឡើយ ហើយមិនបានពោលថា បុគ្គលពួកនេះ ថោកទាបជាងគេ ព្រោះមានត្រកូលខ្ពង់ជាងគេ ពណ៌សម្បុរល្អជាងគេ សម្បត្តិ ច្រើនជាងគេក៏ទេដែរ។

ម្នាលព្រាហ្មណ៍តថាគតមិនបានពោលថាបុគ្គលគប្បីបម្រុងបម្រើមនុស្សគ្រប់រូបទេ ទាំងមិនបានពោលថា មិនគប្បីបម្រុងបម្រើក៏ទេដែរ។ កាលបើបុគ្គលបានបម្រុងបម្រើជនណាមួយហើយ សទ្ធា សីល សុតៈ ចាគៈ និងបញ្ញា (សទ្ធា ជំនឿសមហេតុសមផល សីលៈ ការប្រព្រឹត្តរៀបរយដោយកាយវាចា សុតៈ ការត្រងត្រាប់ស្តាប់ឱវាទរបស់សម្បុរស ចាគៈ ការលះបង់អ្វីដែលគួរលះបង់ បញ្ញា សំដៅការភ្លឺស្វាងខាងគំនិត ) រមែងកើតចម្រើនឡើង (ដល់ខ្លួន) ទើបគួរបម្រុងបម្រើជននោះ។

លុះព្រះពុទ្ធជាម្ចាស់ទ្រង់បានត្រាស់ឆ្លើយតបយ៉ាងនេះ ទើបឯសុការីព្រាហ្មណ៍ ក្រាបទូលបង្គំអំពីបញ្ញត្តិរបស់ព្រាហ្មណ៍ផ្សេងតទៅទៀតថា «បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍បានបញ្ញត្ត៤ប្រការ សម្រាប់ពួកព្រាហ្មណ៍ក្សត្រៈវៃស្សៈនិសូទ្រៈដោយឡែកៗពីគ្នា។គឺភិក្ខាចារ(ការត្រេចស្វែងបិណ្ឌបាត) ជាទ្រព្យរបស់ពួកព្រាហ្មណ៍។ ធ្នូ សរជាទ្រព្យរបស់ពួកក្សត្រ។ ការធ្វើស្រែ ការឃ្វាលគោ ជាទ្រព្យរបស់ពួកវៃស្សៈ។ ការច្រូតស្មៅនិងរែកស្មៅ ជាទ្រព្យរបស់ពួកសូទ្រៈ។ កាលបើពួកណាមួយមិនធ្វើតាមបញ្ញត្តិ ដូចពោលមកនេះ ឈ្មោះថាពួកនោះមើលងាយទ្រព្យរបស់ខ្លួនៗ ទុកដូចគង្វាលគោ ដែលម្ចាស់គោមិនបានប្រគល់ឲ្យដូច្នោះដែរ។ ពួកព្រាហ្មណ៍បានបញ្ញត្តទ្រព្យ (ពាក្យថា «ទ្រព្យ» ក្នុងលទ្ធិព្រាហ្មណ៍នេះ មិនមែនសំដៅយកធនធានមានមាសប្រាក់ជាដើមទេ គឺគេសំដៅយកមុខការ ជាករណីយកិច្ចដែលវណ្ណៈនីមួយៗ ត្រូវធ្វើត្រូវបំពេញទៅវិញ)៤យ៉ាងសម្រាប់វណ្ណៈទាំង៤យ៉ាងនេះតើព្រះគោតមទ្រង់ត្រាស់សម្តែងទ្រព្យសម្រាប់វណ្ណៈដូចម្តេច? ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សួរទៅវិញថា «ម្នាលព្រាហ្មណ៍ តើលោកទាំងមូលអនុញ្ញាត ឲ្យពួកព្រាហ្មណ៍ បញ្ញត្តទ្រព្យ៤យ៉ាង

នេះទុកមកឬ?

«បពិត្រព្រះគោតម មិនបានអនុញ្ញាតទេ»។

-«បើដូច្នេះ ពួកព្រាហ្មណ៍ដែលបានបញ្ញត្តទ្រព្យ៤យ៉ាងដោយគ្មានការយល់ព្រម អំពីលោកទាំងមូលដូច្នេះ ឧបមាដូចជនកម្សត់ដែលមិនត្រូវការសាច់ឲ្យស៊ីសាច់ហើយ បង្ខំឲ្យចេញថ្លៃសាច់ឲ្យខ្លួនដូច្នោះដែរ។ ឯតថាគត បានបញ្ញត្តលោកុត្តរធម៌ (លោកុត្តរធម៌ សំដៅយកគុណធម៌ជាន់ខ្ពស់បំផុតក្នុងពុទ្ធសាសនា គឺមគ្គ ផល និងនិព្វាន) ដ៏បរិសុទ្ធថា ជាទ្រព្យដ៏ប្រសើរ សម្រាប់បុរសបុគ្គលទូទៅ (គ្មានការរើសអើងអ្វីឡើយ)។

ម្នាលព្រាហ្មណ៍ កាលបើបុគ្គលរឭកនឹកដល់វង្សត្រកូលបុរមបុរាណរបស់មាតាបិតាខ្លួន គេក៏និយមរាប់តាមវង្សត្រកូលនោះៗ គឺកើតក្នុងត្រកូលក្សត្រក៏រាប់ថាជាក្សត្រ។ កើតក្នុងត្រកូលព្រាហ្មណ៍ ក៏រាប់ថាជាព្រាហ្មណ៍។ កើតក្នុងត្រកូលវៃស្យៈ ក៏រាប់ថាជាវៃស្យៈ។ កើតក្នុងត្រកូលសូទ្រៈ ក៏រាប់ថាជាសូទ្រៈដូច្នោះដែរ ។ ប្រៀបដូចភ្លើងដែល ឆេះ ទ្រលោមឡើង ដោយអាស្រ័យអ្វីជាបច្ច័យ ក៏ហៅឈ្មោះភ្លើងតាមបច្ច័យនោះៗ គឺបើ មានឈើជាបច្ច័យ ក៏ហៅថាភ្លើងឈើ បើអាស្រ័យសំបកឈើ ជាបច្ច័យ គឺហៅថា ភ្លើងសំបកឈើ បើអាស្រ័យស្មៅជាបច្ច័យ ក៏ហៅថា ភ្លើងស្មៅ ដូច្នោះដែរ។

ទ្រង់ត្រាស់បន្តទៅទៀតថា «ម្នាលព្រាហ្មណ៍ អ្នកដែលចូលមកបួសក្នុងធម៌វិន័យ (សាសនា) របស់តថាគត ទោះបីមានជាតិកំណើតជាក្សត្រក្តី ជាព្រាហ្មណ៍ក្តី ជាវៃស្យៈក្តី ជាសូទ្រៈក្តី តែវៀរចាកបាណាតិបាត អទិន្នាទាន មុសាវាទ សុរាមេរ័យជាដើមដូចៗគ្នា ក៏នឹងបានសម្រេចនូវធម៌ដែលគួរចេះដឹងដ៏ច្រើន (ដូចគ្នាដែរ)។

តថាគតសុំសួរថា តើមានតែពួកព្រាហ្មណ៍ប៉ុណ្ណោះឬអ្វី ដែលអាច (មានសិទ្ធិ) អប់រំ មានមេត្តាចិត្ត ឥតមានពៀរ ឥតមានព្យាបាទបាន ចំណែកឯពួកក្សត្រ វៃស្យៈ និងសូទ្រៈ មិនអាចអប់រំបានទេឬអ្វី?

- បពិត្រព្រះគោតម មិនមែនដូច្នោះទេ គឺពួកក្សត្រ វៃស្យៈ និងសូទ្រៈអាចអប់រំបានដូចគ្នាព្រះអង្គ។

- ម្នាលព្រាហ្មណ៍ អ្នកដែលចូលមកបួសក្នុងធម្មវិន័យរបស់តថាគត ដោយចេញចាកត្រកូលផ្សេងៗគ្នា មានរាជត្រកូលជាដើម ហើយបានវៀរចាកអំពើអកុសលទាំងឡាយ មានបាណាតិបាត និងអទិន្នាទានជាដើម ក៏អាចនឹងបានសម្រេចនូវកុសលធម៌ ដែលខ្លួនចេះដឹងបានដូចគ្នា។

តថាគតសុំសួរថា ព្រះរាជាជាក្សត្រដែលបានទទួលរាជាភិសេកហើយទ្រង់បានឲ្យប្រកាសហៅជនជាតិផ្សេងៗ ត្រកូលផ្សេងៗឲ្យមកប្រជុំគ្នា ហើយបង្កាត់ភ្លើងឡើង ដោយឈើម៉ៃសាក់ក៏មាន ឈើរាំងក៏មាន ឈើស្រស់ក៏មាន ឈើខ្លឹមចន្ទន៍ក៏មាន កាលបើភ្លើងឆេះឆ្លោឡើងហើយ តើអណ្តាតភ្លើងពណ៌ភ្លើងពន្លឺភ្លើងរបស់ជនដែលមានជាតិកំណើតផ្សេងគ្នា មានត្រកូលផ្សេងគ្នាទាំងនោះមានសភាពដូចគ្នាឬផ្សេងគ្នា? តើភ្លើងទាំងនោះគេអាចយកទៅប្រើជាប្រយោជន៍បានដូចគ្នាឬទេ?

ព្រាហ្មណ៍ក្រាបទូលថា ភ្លើងទាំងអស់នោះ មានអណ្តាតពណ៌និងពន្លឺដូចគ្នា គេអាចធ្វើកិច្ចដែលត្រូវការដោយភ្លើងបានសម្រេចដូចគ្នាព្រះអង្គ។

- ម្នាលព្រាហ្មណ៍ ខនេះក៏ដូច្នេះដែរ គឺថាបុគ្គលដែលចូលបួសក្នុងធម្មវិន័យរបស់តថាគត ចេញមកអំពីត្រកូលផ្សេងៗគ្នា ហើយព្យាយាមវៀរចាកអំពើអកុសលផ្សេងៗ មានបាណាតិបាតជាដើម ក៏នឹងបានសម្រេចនូវកុសល ដែលជាធម៌គួរចេះដឹងបានដូចគ្នាដែរ។

ចំណែកឯសុការីព្រាហ្មណ៍ ក្រោយបានស្តាប់នូវព្រះពុទ្ធទស្សនៈនេះហើយ ក៏កើតសេចក្តីជ្រះថ្លា ក្រាបទូលសរសើរថា ពីរោះណាស់ៗ ហើយប្រកាសថ្វាយខ្លួនជាឧបាសក អ្នកកាន់ព្រះពុទ្ធសាសនាចាប់តាំងអំពីថ្ងៃនោះជាដើមទៅ។

# សង្ខេបអត្ថបទក្នុងឯសុការីសូត្រ

១-តំណាលអំពីព្រាហ្មណ៍ម្នាល់ឈ្មោះឯសុការី ក្រាបទូលស្នើនូវបញ្ញត្តិបារិចរិយា៤ យ៉ាង សម្រាប់វណ្ណៈទាំង៤ តាមលទ្ធិព្រាហ្មណ៍។

២-ព្រាហ្មណ៍បានទូលស្នើសួរអំពីពួកព្រាហ្មណ៍បានបញ្ញត្តទ្រព្យ៤ យ៉ាង សម្រាប់វណ្ណៈទាំង៤ដោយឡែកៗពីគ្នា ហើយបានសួរអំពីទស្សនៈពុទ្ធនិយម ចំពោះបញ្ហាទាំង២ ខាងលើនេះ ( បារិចរិយា៤យ៉ាង និងទ្រព្យ៤ ប្រការសម្រាប់វណ្ណៈទាំង៤ )។

៣-ព្រះពុទ្ធជាម្ចាស់ទ្រង់បានដោះស្រាយ ដោយវិធីត្រាស់សួរឲ្យព្រាហ្មណ៍ទទួលឆ្លើយតបជាមុន រួចទ្រង់ពន្យល់បំភ្លឺឲ្យព្រាហ្មណ៍ យល់កាន់តែជាក់ច្បាស់ឡើងទៀត ដោយប្រើវិធីឧបមាឧបមេយ្យ ដូចមានបញ្ជាក់ក្នុងអត្ថបទខាងដើមស្រាប់។

# ការបកប្រែ និងពន្យល់ពាក្យខ្លះៗ ក្នុងឯសុការីសូត្រ

- **បារិចរិយា** ប្រែថា បម្រុងបម្រើ ឬការទំនុកបម្រុង ចំពោះវណ្ណៈខ្លួនក្តី ចំពោះវណ្ណៈផ្សេងទៀតដែលខ្ពស់ជាងវណ្ណៈខ្លួនក្តី។ ដោយន័យសំដៅយកកាតព្វកិច្ចរបស់វណ្ណៈនីមួយៗតាមលទ្ធិព្រាហ្មណ៍។

- **លោកទាំងមូល** សំដៅយកអ្នកផងទាំងពួងទូទៅ។

- **សទ្ធាៈ** ប្រែថា ជំនឿ មានពីរប្រភេទគឺ សទ្ធាជាញាណសម្បយុត្ត ប្រែថា សទ្ធាប្រកបដោយវិចារណញ្ញា១ សទ្ធាជាញាណវិប្បយុត្ត ប្រែថា សទ្ធាមិនប្រកបដោយវិចារណញ្ញាណ១។ ក្នុងទីនេះសំដៅយក សទ្ធាជាញាណសម្បយុត្ត។

- **សីលៈ** សំដៅយក ការប្រព្រឹត្តរៀបរយ សុភាពរាបសាល្អដោយកាយ វាចា តាមប្រភេទនៃសីល មានច្រើន មានសីល៥ សីល៨ ជាដើម ។

- **សុតៈ** គឺការគ្រប់គ្រងស្ដាប់ឱវាទរបស់លោកសប្បុរសឬអ្នកចេះដឹង គឺការសិក្សាអប់រំខ្លួនឲ្យមានចំណេះវិជ្ជាប្រសើរឡើង។

- **ចាគៈ** ប្រែថា ការលះបង់ គឺការលះបង់វត្ថុផ្សេងៗ ដែលខ្លួនអាចលះបង់ឲ្យបាន ដើម្បីជួយសម្រាលទុក្ខវេទនាដល់អ្នកក្រខ្សត់ជាដើម។

- **បញ្ញា** សំដៅយកការស្គាល់ល្អអាក្រក់ គុណទោស បាបបុណ្យ ហេតុផល និងប្រយោជន៍ឥតប្រយោជន៍ជាដើម របស់ខ្លួនឯងនិងរបស់អ្នកដទៃ។

# ការខ្វែងគំនិតមួយទៀតរវាងទស្សនៈពុទ្ធនិយមនិងព្រាហ្មណ៍និយម

## ទស្សនៈស្តីពី ធម៌ដែលធ្វើឲ្យទៅជាមនុស្សថោកក្នុងសង្គម

អត្ថបទប្រែសម្រួល

អំពីវសលសូត្រ នៃឧរគវគ្គ សុត្តនិបាត សុត្តន្តបិដក

គ្រាមួយនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់គង់ប្រថាប់ក្នុងវត្តជេតវន នាក្រុងសាវត្ថី។ ក្នុងពេលព្រឹកមួយនោះ ព្រះពុទ្ធទ្រង់យាងទៅបិណ្ឌបាត នាក្រុងសាវត្ថី។ គ្រានោះមានព្រាហ្មណ៍ម្នាក់ ឈ្មោះអគ្គិកភារទ្វាជៈ កំពុងធ្វើពិធីបូជាភ្លើងក្នុងលំនៅរបស់ខ្លួន។

អគ្គិកភារទ្វាជព្រាហ្មណ៍នោះ បានឃើញព្រះពុទ្ធជាម្ចាស់ស្តេចយាងមកអំពីចម្ងាយ ក៏ស្រែកប្រាប់ទៅថា ឈប់នៅទីនោះសិន មនុស្សត្រងោល ឈប់នៅទីនោះសិន សមណៈតូច ឈប់នៅទីនោះសិន មនុស្សថោក (អដ្ឋកថាចារ្យបានពោលបញ្ជាក់ថា ពួកព្រាហ្មណ៍យល់ថា មនុស្សត្រងោល ជាមនុស្សមិនបរិសុទ្ធ ទោះបីបានបួសជាសមណៈ ក៏គេទុកជាសមណតូចៗ ជាសមណៈមិនល្អជាសមណៈថោកទាប។គេប្រកាន់ថាមនុស្សត្រងោលមិនគួរគេនៅរួមជាមួយទេ មិនគួរបរិភោគរួមទេ។ អដ្ឋកថាចារ្យបានបញ្ជាក់ទៀតថា ព្រះអង្គឆ្លើយតបនឹងពាក្យប្រមាថមើលងាយរបស់ងាយព្រាហ្មណ៍ ដោយព្រះវាចាទន់ភ្លន់មានព្រះភក្ត្រផូរផង់ ប្រកបដោយព្រះទ័យមេត្តាករុណា) ដូច្នេះ។

កាលព្រាហ្មណ៍ពោលពាក្យយ៉ាងនេះហើយ ទើបព្រះអង្គទ្រង់ត្រាស់សួរទៅវិញថា «ម្នាលព្រាហ្មណ៍ ចុះអ្នកស្គាល់ធម៌ដែលធ្វើឲ្យមនុស្សថោកឬទេ ?

ព្រាហ្មណ៍ពោលថា «មិនស្គាល់ទេ ព្រះគោតម សូមព្រះគោតម សម្តែងឲ្យខ្ញុំព្រះអង្គបានស្គាល់ធម៌ដែលធ្វើឲ្យទៅមនុស្សថោកផងចុះ» ។

-«ម្នាលព្រាហ្មណ៍ បើដូច្នោះ ចូរអ្នកតាំងចិត្តស្តាប់ចុះ តថាគតនឹងសម្តែងឲ្យស្តាប់ក្នុងកាលឥឡូវនេះឯង»។

-«ព្រះករុណា ព្រះអង្គ»។

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្តែងថា «អ្នកណាជាអ្នកហែខឹង ជាអ្នកចងកំហឹង ជាអ្នករមិលគុណ ជាអ្នកយល់ខុស អ្នកមានកលមាយា ចូរអ្នកដឹងចុះថា អ្នកនោះជាមនុស្សថោក»។

«អ្នកណាបៀតបៀនសត្វ ដែលមានកំណើតម្តងក្តី មានកំណើតពីរដងក្តី គ្មានអាណិតមេត្តាដល់សត្វ ចូរអ្នកដឹងចុះថា អ្នកនោះជាមនុស្សថោក»។

«អ្នកណាបៀតបៀនអ្នកស្រុក អ្នកនិគម អ្នកនគរ លើកទ័ពទៅព័ទ្ធឡោមស្រុក និគម នគរ មានគេដឹងឮថា ជាអ្នកសម្លាប់អ្នកស្រុក អ្នកនិគម អ្នកនគរ អ្នកដឹងចុះថា អ្នកនោះជាមនុស្សថោក»។

«អ្នកណាកាន់យកឬរឹបអូសយករបស់ទ្រព្យ ដែលគេមិនបានឲ្យដោយចេតនាជាចោរកម្ម ទោះបីរបស់ទ្រព្យនោះឋិតនៅក្នុងព្រៃឬក្នុងស្រុក ចូរអ្នកដឹងចុះថា អ្នកនោះជាមនុស្សថោក»។

«អ្នកណាខ្ចីបុលទ្រព្យរបស់គេយកមកស៊ីចាយអស់ហើយគេចរត់បាត់ទៅ ដល់ម្ចាស់ទ្រព្យគេមកសួរក៏បដិសេធថា មិនបានជំពាក់គេទៅវិញ ចូរអ្នកដឹងចុះថា អ្នកនោះជាមនុស្សថោក»។

«អ្នកណាឃ្លាំចាំស្ទាក់វាយកាប់អ្នកដំណើរ ហើយប្រមូលទ្រព្យរបស់គេទៅ ចូរដឹងចុះថា អ្នកនោះជាមនុស្សថោក»។

«អ្នកណាធ្វើជាសហាយស្មន់នឹងភរិយារបស់ញាតិមិត្ត ដោយប្រើកម្លាំងបង្ខំគេ ដែលគេមិនយល់ព្រមឬសុខចិត្តយល់ព្រមក៏ដោយ ចូរអ្នកដឹងថា អ្នកនោះជាមនុស្សថោក»។

«អ្នកណាមានមាសប្រាក់ទ្រព្យរបស់ច្រើន តែមិនសុខចិត្តចិញ្ចឹមមាតាបិតា ដែលចាស់ជរាហើយ ចូរអ្នកដឹងចុះថា អ្នកនោះជាមនុស្សថោក»។

“អ្នកណាត្រូវគេសួរអំពីការមានប្រយោជន៍ តែឆ្លើយប្រាប់បង្រៀនអំពីការឥតប្រយោជន៍ទៅវិញ ឬប្រាប់បង្ហាញដោយការលាក់លៀមបិទបាំង ឬមិនព្រមប្រាប់ឲ្យអស់សេចក្តី អ្នកដឹងចុះថា អ្នកនោះជាមនុស្សថោក»។

“អ្នកណាធ្វើអំពើបាបកម្មហើយគិតថា សូមកុំឲ្យអ្នកដទៃដឹងឮឡើយ អ្នកណាបិទបាំងបាបកម្មរបស់ខ្លួនទុកយ៉ាងនេះ ចូរអ្នកដឹងចុះថា អ្នកនោះជាមនុស្សថោក»។

“អ្នកណាទៅកាន់ត្រកូលដទៃហើយ បានបរិភោគអាហារល្អៗរបស់គេ ហើយដល់ពេលគេត្រឡប់មកផ្ទះខ្លួនវិញ មិនព្រមទទួលគេដោយរាក់ទាក់ ឬមិនព្រមជប់លៀងគេវិញ ចូរអ្នកដឹងចុះថា អ្នកនោះជាមនុស្សថោក» ។

“អ្នកណាកុហកបោកបញ្ឆោតសមណព្រាហ្មណ៍ ឬស្មូមយាចក ចូរអ្នកដឹងចុះថា អ្នកនោះជាមនុស្សថោក»។

“អ្នកណាស្តីជេរប្រទេចសមណព្រាហ្មណ៍ ក្នុងពេលបានឃើញសមណព្រាហ្មណ៍ ឬពេលឃើញសមណព្រាហ្មណ៍កំពុងបិណ្ឌបាត ក៏មិនចង់ឲ្យជួបមុខ ចូរអ្នកដឹងចុះថា អ្នកនោះជាមនុស្សថោក»។

“អ្នកណាត្រូវមោហៈ ( ស្នេហា ) គ្របដណ្តប់ហើយ គិតរកឧបាយប្រវ័ញ្ចចង់បានអ្វីជារបស់អ្នកដទៃ ដោយពោលប្រាប់អំពីអ្វីដែលមិនមានដូចពោលថា នៅស្រុកភូមិឯណោះ សេចក្តីចម្រើននឹងកើតឡើងដល់យើង មកយើងនាំគ្នាទៅនៅឯស្រុកភូមិឯណោះចុះ អ្នកនាងនឹងបានធ្វើជាមេផ្ទះរបស់ខ្ញុំ ខ្ញុំនឹងឲ្យវត្ថុនោះៗដល់នាង ហើយជម្រត់យកភរិយាអ្នកដទៃទៅ ចូរអ្នកដឹងចុះថា អ្នកនោះជាមនុស្សថោក»។

“អ្នកណាលើកតម្កើងខ្លួនសង្កត់សង្កិនអ្នកដទៃ ជាមនុស្សលាមកដោយអស្មិមានះ ចូរអ្នកដឹងចុះថា អ្នកនោះជាមនុស្សថោក»។

“អ្នកណាហៃស្តីជេរគេ ជាអ្នករឹងរូសមានសេចក្តីត្រូវការលាមក ជាអ្នកកំណាញ់ស្វិត ហៃអួតខ្លួន មិនខ្មាសបាប មិនខ្លាចបាប ចូរអ្នកដឹងចុះថា អ្នក

នោះជាមនុស្សថោក»។

«អ្នកណាត្មះតិះដៀលព្រះពុទ្ធឬសាវ័កព្រះពុទ្ធ បរិព្វាជកឬគ្រហស្ថជាសាវ័កបរិព្វាជក ដោយរឿងមិនពិត ចូរអ្នកដឹងចុះថា អ្នកនោះជាមនុស្សថោក»។

«អ្នកណាមិនមែនអរហន្ត ប្តេជ្ញាថាខ្លួនជាអរហន្ត ពួកនេះជាចោរ(អដ្ឋកថាចារ្យបានពន្យល់ថា ពួកចោរក្នុងលោកិយនេះ តែងលួចប្លន់ទ្រព្យគេតាមផ្លូវលោកិយ។ ឯពួកចោរក្នុងផ្លូវសាសនា ក៏មានការលួចតាមផ្លូវធម៌ដែរ មាន៥ជំពូក គឺជំពូកទី១ លួចបច្ច័យមានចីវរជាដើម។ ជំពូកទី២ លួចបរិយត្តិធម៌ គឺសិក្សាបរិយត្តិដើម្បីលាភសក្ការៈ។ ជំពូកទី៣ លួចព្រហ្មចរិយៈ គឺចោទភិក្ខុដទៃដែលបរិសុទ្ធ ដោយអាបត្តិគ្មានមូលហេតុ។ ជំពូកទី៤ លួចគរុភណ្ឌរបស់ព្រះសង្ឃ។ ជំពូកទី៥ គឺលួចឈានសមាបត្តិ សមាធិ មគ្គផល ដែលទ្រង់ត្រាស់ថាជាមហាចោររហូតដល់ព្រហ្មលោក គឺសំដៅពួកចោរ ជំពូកទី៥នេះឯង ព្រោះព្រះអង្គត្រាស់ថា (ភិក្ខុណាអួតឧត្តរិមនុស្សធម៌ដែលគ្មានក្នុងខ្លួន ភិក្ខុនោះជាមហាចោរដ៏ឧក្រិដ្ឋក្នុងលោកនេះ) ក្នុងលោកនេះរហូតដល់ព្រហ្មលោក អ្នកនោះឯងជាមនុស្សអធម៌»។

«ជនទាំងឡាយណា ដែលតថាគតបានលើកឡើងសម្តែងមកហើយនោះ ជនទាំងឡាយនោះជាពួកមនុស្សថោកទាំងអស់»។

«ជាតិត្រកូលមិនបានធ្វើឲ្យថោកទេ មិនបានធ្វើឲ្យទៅជាព្រាហ្មណ៍ទេ។ មនុស្សទៅជាថោកដោយសារអំពើ (របស់ខ្លួន) ទេតើ បានទៅជាព្រាហ្មណ៍ក៏ដោយសារអំពើ (របស់ខ្លួន) ដែរ។

«ពាក្យណាដែលតថាគតបានពោលថាមនុស្សជម៌មិនមែនថោកដោយសារតែជាតិត្រកូលជាដើមនោះ ចូរអ្នកដឹងនូវពាក្យនេះដូច្នេះចុះ ហើយត្រូវដឹងតាមនិទស្សនៈនេះផងចុះ គឺបុត្ររបស់មនុស្សចណ្ឌាលឈ្មោះមាតង្គៈ (មនុស្សចណ្ឌាលឈ្មោះមាតង្គៈនេះ អដ្ឋកថាចារ្យបានតំណាលជីវប្រវត្តិរបស់គេពិស្តារគួរឲ្យចាប់អារម្មណ៍ដែរ។ដូច្នេះខ្ញុំសូមលើកយកជីវប្រវត្តិមាតង្គៈទៅដាក់ខាងចុង

នៃវសលសូត្រនេះចុះ ព្រោះប្រវត្តិនេះវែងបន្តិច ដើម្បីបង្ហាញទស្សនៈពុទ្ធនិយម ដែលបដិសេធការប្រកាន់ពូជសាសន៍របស់លទ្ធិព្រាហ្មណ៍) បានសម្រេចនូវភាពជាកំពូល ដោយយសុសក្តិ មានពួកក្សត្រនិងពួកព្រាហ្មណ៍ នាំគ្នាចូលទៅគោរពប្រណិប័តន៍មាតង្គៈយ៉ាងច្រើន។ មាតង្គៈបានឡើងកាន់ទេវយាន ដែលប្រាសចាកធូលី(សៅហ្មង) ជាផ្លូវធំ បន្សាត់បង់នូវតម្រេកត្រេកត្រអាលក្នុងកាមារម្មណ៍ ហើយបានឡើងទៅកើតក្នុងព្រហ្មលោក។

ឯពួកព្រាហ្មណ៍ដែលកើតក្នុងត្រកូលព្រាហ្មណ៍ហើយ ធ្វើតែអំពើបាបកម្ម តែងមានការរិះគន់ត្មះតិដៀលអំពីវិញ្ញូជន ក្នុងវេលាមានជីវិតរស់នៅ ដល់ពេលស្លាប់ទៅរមែងទៅកើតក្នុងទុគ្គតិភពទៀត។ ជាតិត្រកូលមិនអាចជួយការពារខ្លួនគេឲ្យចេញផុតអំពីទុគ្គតិភពបានឡើយ។ ទើបតថាគតពោលថា មនុស្សមិនមែនថោកដោយសារជាតិត្រកូលទេ មិនមែនជាព្រាហ្មណ៍ដោយសារជាតិត្រកូលក៏ទេដែរមនុស្សទៅជាថោកដោយសារអំពើ(របស់ខ្លួន)ទេតើទៅជាព្រាហ្មណ៍ក៏ដោយសារអំពើ(របស់ខ្លួន)ដែរ។

កាលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្តែងយ៉ាងនេះហើយ អគ្គិកភារទ្វាជព្រាហ្មណ៍ បានក្រាបបង្គំទូលថា «បពិត្រព្រះគោតម ពីរោះមែន បពិត្រព្រះគោតមល្អមែន ព្រះគោតមទ្រង់ត្រាស់សម្តែងធម៌ដោយបរិយាយច្រើនអនេកហាក់ដូចជាផ្ងាររបស់ដែលផ្កាប់ បើកគម្របរបស់ដែលគេបិទ ប្រាប់បង្ហាញផ្លូវដល់មនុស្សវង្វេងផ្លូវ បំភ្លឺភ្លើងក្នុងទីងងឹតដូច្នោះ។

ខ្ញុំព្រះអង្គសូមរាប់អានព្រះគោតម ព្រមទាំងព្រះធម៌ និងព្រះសង្ឃ សូមព្រះគោតមចាំទុកនូវខ្ញុំព្រះអង្គថា ជាអ្នកគោរពរាប់អានព្រះរតនត្រ័យតាំងអំពីថ្ងៃនេះជាដើមទៅ»។

**ចប់អត្ថបទក្នុងវសលសូត្រត្រឹមប៉ុណ្ណោះ។**

# ជីវប្រវត្តិមាតង្គៈ ជាកូនជនចណ្ឌាល

កាលពីអតីតកាលកន្លងមកយូរអង្វែងហើយ ព្រះពុទ្ធជាម្ចាស់កាលព្រះអង្គបានសរជាតិទៅកើតក្នុងត្រកូលចណ្ឌាលឈ្មោះ មាតង្គៈ មានរូបឆោមអាក្រក់គួរឲ្យគេខ្ពើម អាស្រ័យនៅក្នុងខ្ទមតូចមួយ ខាងក្រៅទីក្រុង ចិញ្ចឹមពោះរស់ជីវិត ដោយធ្វើជាស្មូម។

ថ្ងៃមួយក្នុងនគរនោះ គេបានប្រកាសឃោសនានក្ខត្តឫក្សសុរា។ ពួកអ្នកលេង នាំគ្នាដើរលេងកម្សាន្តតាមវិថីនានាជាមួយនឹងបរិវារ។ គ្រានោះ មានធីតាក្រមុំរបស់ព្រាហ្មណ៍មហាសាលម្នាក់ មានអាយុ១៦ឆ្នាំ មានរូបឆោមស្រស់ប្រិមប្រិយ ដូចស្រីអប្សរ មានបំណងទៅលេងនក្ខត្តឫក្សនឹងគេដែរ ទើបបញ្ជាឲ្យបរិវារចាត់ចែងគ្រឿងល្បែង គ្រឿងស៊ី គ្រឿងផឹកផ្ទុកក្នុងរទេះ ទឹមដោយលាស ហើយឡើងជិះបរចេញទៅព្រមដោយបរិវារដ៏ច្រើន បរសំដៅទៅទីឧទ្យាន។ ឯធីតារបស់ព្រាហ្មណ៍នោះឈ្មោះនាងទិដ្ឋមង្គលិកា (ព្រោះចង់ឃើញចង់មើលតែអ្វីដែលល្អចម្រើនរុងរឿង)។

ជួនជាគ្រានោះ មាតង្គៈក្រោកអំពីព្រលឹមស្លៀកសំពត់កញ្ចាស់កាន់អំបែងដើរចូលទៅក្នុងស្រុកដើម្បីសុំទានគេ បានឃើញមនុស្សទាំងឡាយ (ដង្ហែនាងទិដ្ឋមង្គលិកា) វាយឃ្មោះគោះគងមកអំពីចម្ងាយ។

នាងទិដ្ឋមង្គលិកាក្រឡេកឃើញក៏សួរទៅថា នុ៎ះគឺអ្នកណា។ មាតង្គៈឆ្លើយមកវិញថា ខ្ញុំឈ្មោះមាតង្គៈ ជាចណ្ឌាល។ នាងទេវីប្រាប់ទៅបរិវារថា កាលបើយើងបានឃើញមនុស្សមានសភាពដូច្នេះនឹងមានសិរីសួស្តីពីណា ហើយបង្គាប់បរិវារឲ្យត្រឡប់យានជំនិះបរត្រឡប់មកផ្ទះវិញ។ ពួកបរិវារនាំគ្នាខឹងឃោរជាខ្លាំងដោយយល់ថា ពួកយើងនឹងបានទៅលេងស៊ីផឹកសប្បាយទាំងអស់គ្នា ស្រាប់តែមាតង្គៈមកធ្វើឲ្យអន្តរាយអស់ ហើយនាំគ្នាវាយដំមាតង្គៈ ដោយដំបងនិងដុំដី ហើយនាំគ្នាសែងយកទៅចោលក្នុងគំនរសម្រាម ដោយស្មានថា

ស្លាប់ហើយ ទើបគេនាំគ្នាត្រឡប់ទៅវិញ។

ក្រោយមក មាតង្គៈដឹងខ្លួនមានស្មារតីឡើងវិញ ក៏សួរទៅមនុស្សទាំងឡាយថា «អ្នកទាំងឡាយចុះទ្វារនគរនេះជារបស់សម្រាប់មនុស្សទាំងឡាយទូទៅ ឬសម្រាប់តែពួកព្រាហ្មណ៍ប៉ុណ្ណោះ។ គេប្រាប់ថា សម្រាប់មនុស្សទូទៅ។ មាតង្គៈពោលថា ចុះហេតុអ្វីពួកមនុស្សបម្រើរបស់នាងទិដ្ឋ-មង្គលិកាមកប្រទូសរ៉ាយនឹងខ្ញុំ គ្រាន់តែដើរចូលមកសុំទានគេតាមទ្វារនេះ។ មាតង្គៈពោលដូច្នេះហើយក៏ដើរស្រែកប្រកាសតាមផ្លូវថ្នល់និងតាមផ្លូវច្រកតូចធំទាំងឡាយថា «អ្នកទាំងឡាយចូរដឹងចុះថា ខ្ញុំគ្រាន់តែដើរចូលមកសុំទានតាមទ្វារនគរនេះ ក៏ត្រូវពួកបរិវារនាងទិដ្ឋមង្គលិកាវាយដុំទាល់តែសន្លប់ទៅ»។ លុះដើរប្រកាសប្រាប់មហាជនដូច្នេះហើយ មាតង្គៈក៏ដើរចូលទៅដេកនៅមុខទ្វារផ្ទះរបស់ព្រាហ្មណ៍ ជាមាតាបិតារបស់នាងទិដ្ឋមង្គលិកា ដោយតាំងចិត្តថា បើអាត្មាអញមិនបាននាងទិដ្ឋមង្គលិកាទេ នឹងមិនក្រោកចេញជាដាច់ខាត។

ឯព្រាហ្មណ៍ជាបិតាបានដឹង ក៏បង្គាប់បរិវារថា ចូរឯងយកប្រាក់១កាកឲ្យវាទៅ ហើយលាបប្រេងខ្លួនវាផង ឲ្យវាចេញទៅ។ មាតង្គៈ មិនត្រូវការប្រាក់ក៏បានប្រាប់ទៅវិញថា បើយើងមិនបាននាងទិដ្ឋមង្គលិកាទេ នឹងមិនក្រោកចេញទេ។ ទើបព្រាហ្មណ៍បង្គាប់ថា ចូរឯងឲ្យវា២ កាកនឹក ហើយប្រាប់ឲ្យបន្ថែមឡើងរហូតដល់សែនកហាបណៈ ឯមាតង្គៈ ក៏មិនព្រមទទួលដែរ។

តមកមនុស្សទាំងឡាយ មានខត្តិយកុមារជាដើម ដែលធ្លាប់បានបញ្ជូនគ្រឿងបណ្ណាការទៅជូនព្រាហ្មណ៍បិតា (ស្ដីដណ្ដឹង) តែមិនបាននាងទិដ្ឋមង្គលិកា ក៏ខ្សឹបប្រាប់មាតង្គៈថា ធម្មតាបុរសត្រូវធ្វើសេចក្ដីព្យាយាមច្រើនឆ្នាំទើបសម្រេចដូចបំណងបាន ចូរឯងកុំបោះបង់ចោលបំណង ហើយប្រហែល ២-៣ ថ្ងៃទៀត ឯងមុខជាបាននាងទិដ្ឋមង្គលិកា។

លុះដល់គម្រប់៧ថ្ងៃ ពួកអ្នកផ្ទះជិតខាងនៃព្រាហ្មណ៍នោះ នាំគ្នាប្រាប់

ព្រាហ្មណ៍ថា សូមលោកប្រាប់ឲ្យមាតង្គៈក្រោកចេញទៅ កុំធ្វើឲ្យយើងវិនាស ហិនហោចដោយសារ ព្រឹត្តិការណ៍នេះឡើយ (ពួកគេដែលនាំគ្នានិយាយយ៉ាង នេះ ព្រោះគេជឿប្រកាន់ថា ប្រសិនបើមានមនុស្សចណ្ឌាលដេកស្លាប់នៅមុខផ្ទះ របស់ជនណាមួយពួកដែលមានផ្ទះជិតខាងគ្នាម្ខាងៗ៧ខ្នងនឹងត្រូវប្រែក្លាយទៅ ជាចណ្ឌាលទាំងអស់)។

គ្រានោះ មនុស្សទាំងឡាយបង្ខំឲ្យនាងទិដ្ឋមង្គលិកាស្លៀកពាក់សំពត់ ចាស់ៗពណ៌ខៀវ រួចប្រគល់ប្រដាប់សម្រាប់ស្នូមឲ្យនាងហើយ ក៏នាំខ្លួននាង ប្រគល់ឲ្យមាតង្គៈ ដោយពាក្យថា «ចូរប្រស្តែងទទួលយកនាងទិដ្ឋមង្គលិកា ហើយក្រោកចេញទៅចុះ»។ នាងទិដ្ឋមង្គលិកា ក៏បានទៅឈរជិតៗ ហើយប្រាប់ ថា «ក្រោកឡើង»។ មាតង្គៈ ពោលថា «ចូរនាងចាប់ដៃខ្ញុំលើកឡើង ហើយ ប្រាប់ថា យើងមិនអាចរស់នៅក្នុងក្រុងបានទេ ចូរនាងនាំខ្ញុំទៅនៅខ្លមងក្រៅ ចុះ»។ នាងទិដ្ឋមង្គលិកា ក៏ដឹកដៃមាតង្គៈដើរចេញទៅ។

ឯមាតង្គៈ លុះបានទៅដល់ទីលំនៅរបស់ខ្លួនហើយក៏គិតថា មិនត្រូវធ្វើ ឲ្យនាងព្រាហ្មណ៍នេះខូចបង់ព្រហ្មចារីឡើយ ហើយមាតង្គៈឥតបានរួមសង្វាស ជាមួយនឹងនាងឡើយ លុះបានឈប់សម្រាកប្រមាណកន្លះខែល្មមមានកម្លាំង ស្រួលបួលហើយ ទើបនិយាយប្រាប់នាងថា «យើងនឹងចេញទៅនៅព្រៃ សូម នាងកុំព្រួយចិត្តដោយសារការយឺតយូរនៃយើងឡើយ និយាយផ្តាំផ្ញើនឹងអ្នកផ្ទះ ឲ្យជួយមើលថែរក្សានាងផង ហើយក៏ចេញទៅបួសជាតាបស ខិតខំចម្រើន កសិណបរិកម្ម ហើយបានសម្រេចសមាបត្តិ៨និងអភិញ្ញា៥ ក្នុងពេលមិន យូរប៉ុន្មាន ហើយធ្វើដំណើរទៅតាមអាកាសដោយតាំងចិត្តថា នឹងជួយសង្គ្រោះ នាងទិដ្ឋមង្គលិកា រួចទៅត្រង់ទ្វារនគរបានបង្គាប់ឲ្យគេទៅប្រាប់នាងទិដ្ឋមង្គលិកា ហើយនាងគិតថា ប្រហែលជាមានបព្វជិតជាញាតិណាមួយដឹងថា អញតោក យ៉ាកហើយមកជួយសង្គ្រោះទេដឹង។ទើបនាងសំពះសួរថា«ហេតុអ្វីលោកធ្វើឲ្យ ខ្ញុំករុណា អនាថាដូច្នេះ»។ តាបសពោលថា «ម្នាលនាងទិដ្ឋមង្គលិកា នាងកុំ

ព្រួយបារម្ភពេកឡើយ អាត្មានឹងធ្វើឲ្យមនុស្សក្នុងជម្ពូទ្វីបនេះ នាំគ្នាធ្វើសក្ការបូជានាង ចូរនាងទៅប្រាប់ពួកអ្នកនគរថា មហាព្រហ្មជាព្រះស្វាមីយើង មិនមែនឈ្មោះមាតង្គៈជាស្វាមីយើងទេ មហាព្រហ្មនោះនឹង ចេញអំពីដួងចន្ទ ចុះមករកយើងក្នុងថ្ងៃគម្រប់៧ខាងមុខនេះ»។

នាងទិដ្ឋមង្គលិកាឆ្លើយថា «ខ្ញុំករុណាជាធីតារបស់ព្រាហ្មណ៍មហាសាលបានធ្លាក់ខ្លួនមកជាមនុស្សចណ្ឌាលដូច្នេះ ព្រោះបាបកម្មរបស់ខ្ញុំករុណាៗ មិនអាចនិយាយពាក្យយ៉ាងនេះបានទេ»។

តាបសពោលឡើងថា «នាងមិនជឿអានុភាពរបស់មាតង្គៈទេឬ ពោលហើយក៏សម្តែងបាដិហារ្យច្រើនឲ្យនាងបានឃើញជាក់ស្តែង ញុំាងនាងទិដ្ឋមង្គលិកាឲ្យជឿស៊ប់ហើយ ទើបតាបសវិលត្រឡប់ទៅកាន់អាស្រមក្នុងព្រៃវិញទៅ។ ទិដ្ឋមង្គលិកា ក៏ចេញដើរប្រកាសឃោសនាតាមបណ្តាំតាបស។

មនុស្សទាំងឡាយនាំគ្នាសើចចំអកឡកឡឺយថា ស្រ្តីនេះធ្លាក់ខ្លួនទៅជាចណ្ឌាល ដោយបាបកម្មរបស់ខ្លួន ហេតុម្តេចក៏មកនិយាយឃោសនាយ៉ាងនេះ។ ឯនាងទិដ្ឋមង្គលិកានៅតែដើរប្រកាសឃោសនាយ៉ាងនេះរាល់ៗថ្ងៃ ជនទាំងឡាយក៏យល់ថា ប្រហែលជាពិតដូចសម្តីនាងនិយាយមែនទេដឹង ទើបពួកគេនាំគ្នាតាក់តែងជាបារាំនៅមុខផ្ទះរៀងៗខ្លួន ហើយគេនាំគ្នាជញ្ជូនកូនចៅទៅអង្គុយរង់ចាំមើលរាល់ៗគ្នា។

លុះថ្ងៃគម្រប់៧ ជាថ្ងៃពេញបូណ៌មី លោកតាបសក៏ហោះឡើងកាន់ផ្ទៃអាកាស ហាក់ដូចចូលទៅក្នុងមណ្ឌលដួងចន្ទ ហើយលឿនលយអណ្តែតចុះមកកាន់ផ្ទៃពិភព ដោយរូបមហាព្រហ្មប្រាកដជាក់ស្តែងដល់ភ្នែកមហាជនទូទៅ។ មហាជននាំគ្នាគយគន់មើលយល់ថា មានព្រះចន្ទពីរដួងក្នុងគ្រានោះ ប៉ុន្តែលុះជិតមកៗ គេបានឃើញជារូបមហាព្រហ្មទៅវិញ ទើបគេនាំគ្នាជឿនិងយល់ថា មហាព្រហ្មនោះប្រាកដជានិម្មិតជារូបមាតង្គៈ ដើម្បីដាក់ទណ្ឌកម្មដល់នាងទិដ្ឋមង្គលិកា។ កាលណាមហាជនកំពុងនាំគ្នាក្រឡេកមើលនោះ មហាព្រហ្មក៏លឿន

លយចុះទៅកាន់ទីលំនៅរបស់នាងទិដ្ឋមង្គលិកា។

វេលានោះ នាងទិដ្ឋមង្គលិកាកំពុងមានរដូវ មហាព្រហ្មនិម្មិតនោះក៏យកម្រាមដៃប៉ះពាល់ផ្ចិតរបស់នាងទិដ្ឋមង្គលិកា ហើយនាងក៏ចាប់ផ្ដើមតាំងគភ៌ឡើង។ លុះដឹងថា នាងតាំងគភ៌ឡើងហើយ មហាព្រហ្មក៏ប្រាប់នាងថា នាងមានគភ៌ហើយ កាលបើប្រសូតបុត្រហើយ ចូរនាងអាស្រ័យបុត្រចិញ្ចឹមជីវិតចុះ។

លុះពោលដូច្នេះហើយ មហាព្រហ្មនិម្មិត ក៏លឿនលយអណ្ដែតត្រសែតឡើងទៅកាន់មណ្ឌលដួងចន្ទវិញ មហាជនទាំងឡាយក៏បានមើលឃើញជាក់ច្បាស់ទាំងអស់គ្នា។ ពួកព្រាហ្មណ៍នាំគ្នានិយាយថា នាងទិដ្ឋមង្គលិកាជាបជាបតី (មហេសី) របស់មហាព្រហ្ម ក៏ទុកដូចជាមាតារបស់យើងទាំងអស់គ្នាដែរ ហើយក៏នាំគ្នាលើកសែងនាងទៅកាន់លំនៅរបស់នាង។ ទ្វារនៃក្រុងចង្អៀតណែនដោយពួកមនុស្សដែលមានបំណងចង់ទៅធ្វើសក្ការបូជាដល់នាងទិដ្ឋមង្គលិកា។

គ្រានោះ មនុស្សទាំងឡាយក៏បានលើកនាងឲ្យឡើងអង្គុយលើគំនរមាសគំនរប្រាក់ និងគំនររតនៈផ្សេងៗ ហើយឲ្យនាងកក់ស្រង់ដោយទឹកអប់ រួចនាំគ្នាប្រដាប់ប្រដាដោយគ្រឿងអលង្ការផ្សេងៗ បន្ទាប់មកឲ្យឡើងជិះលើរថដង្ហែចូលទៅក្នុងក្រុង ទើបគេនាំគ្នាសាងបារាំមួយចំកណ្ដាលទីក្រុងនោះ ហើយឲ្យនាងទិដ្ឋមង្គលិកាឋិតនៅក្នុងទីនោះដរាបដល់នាងប្រសូតបុត្រ លុះប្រសូតបុត្រហើយក៏តាំងឈ្មោះបុត្រនោះថា មណ្ឌព្យកុមារ (ព្រោះកើតក្នុងបារាំ ? )។

ចាប់តាំងអំពីកាលនោះមក ពួកព្រាហ្មណ៍នាំគ្នាចោមរោមអភិបាលកុមារដោយម៉ឺងម៉ាត់ ដោយពួកគេយល់ថា កុមារជាបុត្ររបស់មហាព្រហ្ម ហើយបាននាំយកគ្រឿងសក្ការៈផ្សេងៗច្រើនអនេក ជូននាងទិដ្ឋមង្គលិកាជាមាតា។ ពួកព្រាហ្មណ៍បានធ្វើអារក្ខារក្សាការពារកុមារយ៉ាងហ្មត់ចត់ណាស់។ លុះកុមារធាត់ធំចម្រើនវ័យឡើង ក៏បានធ្វើទានចំពោះតែពួកព្រាហ្មណ៍។

ឯតាបស (ជាបិតា) ក៏បានទៅទូន្មានណែនាំកុមារដោយឱវាទផ្សេងៗ

តមកទៀត តាបសនោះក៏បានធ្វើមរណកាលទៅ ហើយបានឡើងទៅកើតក្នុងឋានព្រហ្មលោកទៅ។

ដោយហេតុនេះ ទើបព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្ដែងថា «មនុស្សមិនមែនថោកដោយសារជាតិត្រកូលទេ មិនមែនបានជាព្រាហ្មណ៍ដោយសារជាតិត្រកូលដែរ។ មនុស្សដែលទៅជាថោក ដោយសារតែអំពើ(របស់ខ្លួន) ទេតើបានទៅជាព្រាហ្មណ៍ ដោយសារតែអំពើ(របស់ខ្លួន)ដែរ។

ចប់អត្ថបទពង្រីកសេចក្ដីស្ដីពីប្រវត្តិមាតង្គៈ ដោយអដ្ឋកថាចារ្យត្រឹមប៉ុណ្ណោះ។

# ព្រះពុទ្ធបដិភាណ

(បដិភាណ: គឺការឈ្លាសវៃ មានប្រាជ្ញាភ្លឺថ្លា ចាក់ធ្លុះយល់ច្បាស់
នូវព្រឹត្តិការណ៍ផ្សេងៗ អាចឆ្លើយឆ្លងដោះស្រាយបញ្ហា
ឬឧបសគ្គនានាបានរួសរាន់ទាន់ចិត្ត )

## សេចក្តីប្រែសម្រួល អំពីមាគណ្ឌិយសូត្រ
## ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក: ភាគទី២៤ ទំព័រ៦១-៩១
## ផ្នែកសុត្តន្តបិដក

**អត្ថបទសង្ខេប:** កាលនោះព្រះពុទ្ធជាម្ចាស់ ទ្រង់គង់ប្រថាប់ក្នុងរោងបូជាភ្លើងរបស់ព្រាហ្មណ៍១រូប ឈ្មោះភារទ្វាជគោត្រ ក្នុងកម្មាសធម្មនិគម ដែនកុរុ។

មានបរិព្វាជក១រូបឈ្មោះ មាគណ្ឌិយ: ជាអ្នកពោលចោទព្រះពុទ្ធថាជាអ្នកកម្ចាត់សេចក្តីចម្រើន។ ជាដំបូងទ្រង់ត្រាស់សួរអ្នកចោទ ដែលពោលថាព្រះអង្គជាអ្នកកម្ចាត់សេចក្តីចម្រើននោះ តើសំដៅយកអ្វី? ក្រោយទ្រង់បានជ្រាបគោលដៅរបស់គេហើយ ទើបទ្រង់សម្តែងគុណនិងទោសនៃកាមគុណទាំង៥គឺ រូប សំឡេង ក្លិន រស សម្ផស្ស ដែលជាទីចាប់អារម្មណ៍ តែភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត ដោយទ្រង់លើកយកឧទាហរណ៍ផ្សេងៗមកបញ្ជាក់ ព្រមទាំងឧបមាឧបមេយ្យជាអនេកបរិយាយ ដូចមានសេចក្តីពិស្តារក្នុងអត្ថបទនៃសូត្រ:នេះស្រាប់។

ក្រោយបរិព្វាជកនោះបានយល់ភ្លឺច្បាស់ស្របតាមទស្សនៈពុទ្ធនិយមហើយ ទើបព្រះអង្គទ្រង់បន្លឺព្រះឧទានវាចាក្នុងទីនោះថា «**អារោគ្យា បរមាលាភា**» ភាវៈឥតរោគ ជាលាភយ៉ាងក្រៃលែង។ «**និព្វានំ បរមំ សុខំ**» និព្វានជាសុខយ៉ាងក្រៃលែង។

ឯបរិព្វាជកនោះ កាលបានស្តាប់ព្រះឧទានវាចានេះ បានក្រាបទូលសរសើរថា «បពិត្រព្រះគោតម គួរឲ្យអស្ចារ្យពិតមែន ល្អប្រសើរមែនពិត»។ ទ្រង់ត្រាស់សួរទៅគេវិញថា ចុះភាវៈគ្មានរោគគឺអ្វី? និព្វានគឺអ្វី?

គេបានស្ទាបខ្លួនគេហើយឆ្លើយថា «ភាវៈគ្មានរោគគឺត្រង់នេះ និព្វានគឺត្រង់នេះ»។

ពាក្យ២ឃ្លានេះ បង្កើតបានបញ្ហាដែលត្រូវដោះស្រាយវែងឆ្ងាយតទៅទៀត ដោយហេតុគេយល់ខុសចំពោះអត្ថន័យនៃពាក្យ២នេះ។ ព្រះអង្គទ្រង់នាំយកឧទាហរណ៍ មនុស្សខ្វាក់ភ្នែកពីកំណើតមកបញ្ជាក់។ ទ្រង់បានពន្យល់បំភ្លឺពាក្យ២ឃ្លានេះយ៉ាងពិស្តារ ព្រមទាំងឧបមាឧបមេយ្យផង។

នៅពេលចប់សេចក្តីពន្យល់ម្តងៗ គេក្រាបទូលសរសើរព្រះធម៌ទេសនាព្រះអង្គដល់៣លើក។

ទីបំផុត មាគណ្ឌិយបរិព្វាជក កើតសទ្ធាជ្រះថ្លាយ៉ាងមុតមាំចំពោះព្រះអង្គ ហើយក្រាបបង្គំទូលសូមបព្វជ្ជា ឧបសម្បទជាភិក្ខុភាវៈក្នុងពុទ្ធសាសនា ចម្រើនសមណធម៌មិនយូរប៉ុន្មានក៏បានសម្រេចអរហត្តជាព្រះអរហន្ត១អង្គក្នុងសាសនានេះ។

ប្រធានសំខាន់ៗ នៃអត្ថបទមានពីរគឺ

១-ពាក្យចោទរបស់មាគណ្ឌិយបរិព្វាជក ដែលពោលថា ព្រះគោតមជាអ្នកកម្ចាត់សេចក្តីចម្រើន ។

២-ពុទ្ធភាសិតដែលពោលថា «ភាវៈគ្មានរោគគឺអ្វី? និព្វានគឺអ្វី?

# មាគណ្ឌិយសូត្រ
## ( សេចក្តីប្រែសម្រួល )

គ្រាមួយនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់គង់ប្រថាប់លើកម្រាលស្មៅ ក្នុងរោងបូជាភ្លើងរបស់ព្រាហ្មណ៍១រូប ឈ្មោះភារទ្វាជគោត្រ នៅជិតកម្មាសធម្មនិគមដែនកុរុ។

ព្រឹកថ្ងៃមួយនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់យាងចូលទៅបិណ្ឌបាតក្នុងកម្មាសធម្មនិគម ស្តេចយាងត្រឡប់មកពីបិណ្ឌបាតវិញ ដល់វេលាក្រោយភត្តាហារហើយ ស្តេចយាងចូលទៅសម្រាកពេលថ្ងៃនៅក្បែរគល់ឈើមួយដើម ក្នុងដងព្រៃមួយ។

គ្រានោះ មាគណ្ឌិយបរិព្វាជក ចូលទៅបានប្រទះឃើញកម្រាលស្មៅក្នុងរោងបូជាភ្លើងរបស់ព្រាហ្មណ៍ភារទ្វាជគោត្រ ក៏សួរថា «កម្រាលស្មៅក្នុងរោងបូជាភ្លើងរបស់លោកភារទ្វាជគោត្រនេះ ជាអាសនៈរបស់អ្នកណា សមជាទីដំណេករបស់សមណៈ?

ព្រាហ្មណ៍ភារទ្វាជគោត្រឆ្លើយថា «ព្រះសមណគោតម ជាសាក្យបុត្រទ្រង់បានយាងចេញបព្វជ្ជា អំពីសាក្យត្រកូល ដែលមានព្រះកិត្តិសព្ទខ្ចរខ្ចាយទូទៅថា «**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវា**( មានពាក្យប្រែក្នុងបទនមស្ការ ថ្វាយបង្គំព្រះព្រឹកល្ងាច ដែលពុទ្ធបរិស័ទតែងសូត្ររាល់ពេលព្រឹក )» ដូច្នេះទីដំណេកនេះយើងបានរៀបចំទុកថ្វាយព្រះសមណគោតមនោះ។

មាគណ្ឌិយបរិព្វាជកពោលឡើងថា «យើងមិនគប្បីក្រឡេកមើលទីដំណេករបស់ព្រះគោតម ជាអ្នកកម្ចាត់សេចក្តីចម្រើននោះទេ»។

ព្រាហ្មណ៍ភារទ្វារជគោត្រពោលថា «នែមាគណ្ឌិយ ចូរអ្នករក្សាវាចានេះ

ទុកសិន ដ្បិតមានពួកក្សត្រ ពួកព្រាហ្មណ៍ ពួកគហបតី និងពួកសមណៈ ដែលជាអ្នកប្រាជ្ញជ្រះថ្លាយ៉ាងក្រៃលែងចំពោះព្រះគោតម ដែលបានទទួលកុសលធម៌ចេះដឹងពីព្រះអរិយៈក៏មានជាចំនួនច្រើន។

ទើបមាគណ្ឌិយបរិព្វាជក ពោលឡើងថា «នែភារទ្វាជៈ! ប្រសិនបើយើងបានប្រឈមមុខនឹងព្រះគោតម យើងនឹងពោលនៅចំពោះមុខព្រះគោតមថា «ព្រះសមណគោតម ជាអ្នកកម្ចាត់បង់នូវសេចក្តីចម្រើន ព្រោះហេតុអ្វីទើបយើងពោលយ៉ាងនេះ ព្រោះហេតុថា ពាក្យយ៉ាងនេះ មានចែងក្នុងសូត្ររបស់ពួកយើង មិនមែនយើងចេះតែថាតាមស្រួលមាត់នោះទេ ព្រោះហេតុនេះ យើងត្រូវនិយាយពាក្យនេះចំពោះមុខព្រះគោតមឲ្យបាន។

ឯព្រាហ្មណ៍ភារទ្វាជគោត្រ ក៏សួរបញ្ជាក់ទៀតថា «បើយើងប្រាប់ពាក្យនេះចំពោះព្រះសមណគោតម មិនជាការធ្ងន់ធ្ងរដល់លោកមាគណ្ឌិយៈ ទើបយើងហ៊ាននិយាយប្រាប់។

មាគណ្ឌិយបរិព្វាជក ឆ្លើយថា «មិនជាការធ្ងន់ធ្ងរអ្វីទេ។

ព្រះពុទ្ធជាម្ចាស់ទ្រង់បានជ្រាបពាក្យសន្ទនានៃជនទាំងពីររូប ដោយព្រះទិព្វសោត។ លុះដល់ថ្ងៃរសៀលល្ងាច ស្តេចយាងចេញអំពីទីស្ងប់ស្ងាត់ចូលទៅប្រថាប់លើកម្រាលស្មៅក្នុងរោងបូជាភ្លើងរបស់ព្រាហ្មណ៍ភារទ្វាជគោត្រក៏ចូលទៅគាល់ ទើបព្រះអង្គទ្រង់ត្រាស់សួរថា «ម្នាលភារទ្វាជៈ មានការសន្ទនាគ្នាដូចម្តេចខ្លះជាមួយនឹងមាគណ្ឌិយបរិព្វាជកជាប់ទាក់ទងនឹងកម្រាលស្មៅនេះ ?

ព្រាហ្មណ៍បានឮព្រះពុទ្ធដីកាត្រាស់សួរដូច្នេះ ក៏ព្រឺព្រួចឡើង ទើបក្រាបទូលថា ទូលបង្គំប្រុងនឹងក្រាបទូលរឿងនេះដល់ព្រះអង្គ (ឥឡូវ)ស្រាប់តែព្រះគោតមត្រាស់សួរមកមុន។

ក្នុងខណៈដែលព្រះពុទ្ធជាម្ចាស់ កំពុងត្រាស់សន្ទនាជាមួយនឹងព្រាហ្មណ៍ភារទ្វាជគោត្រនោះ ស្រាប់តែមាគណ្ឌិយបរិព្វាជក ក៏បានចូលទៅដល់ដែរ ហើយបានពោលសន្ទនាប្រាស្រ័យ ហើយក៏អង្គុយក្នុងទីដ៏សមគួរមួយ។

( សូមអ្នកអានគិតមើល តើព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់នឹងមាគណ្ឌិយបរិព្វាជក ដូចម្តេចក្នុងពេលនោះ ? )

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់នឹងមាគណ្ឌិយបរិព្វាជកថា«ម្នាលមាគណ្ឌិយៈ ចក្ខុជាអវយវៈត្រេកអររីករាយនឹងរូបនេះ តថាគតបានទូន្មានហ្វឹកហ្វឺនហើយ បានគ្រប់គ្រងហើយ បានថែរក្សាហើយ បានសង្រួមហើយ ទើបតថាគតសម្តែងធម៌ដើម្បីសង្រួម (ប្រុងប្រយ័ត្ន) ចក្ខុនេះ។ ម្នាលមាគណ្ឌិយៈ អ្នកបានពោលថា ព្រះសមណគោតម ជាអ្នកកម្ចាត់បង់នូវសេចក្តីចម្រើន តើអ្នកសំដៅយកចក្ខុនេះមែនឬ ?

មាគណ្ឌិយបរិព្វាជកក្រាបទូលថា«ពិតមែនព្រះអង្គ ដែលទូលបង្គំពោលថា ព្រះសមណគោតម ជាអ្នកកម្ចាត់បង់នូវសេចក្តីចម្រើន គឺសំដៅយកចក្ខុនេះឯង ព្រោះហេតុអ្វី ព្រោះពាក្យយ៉ាងនេះមានក្នុងសូត្ររបស់ទូលបង្គំ»។

ព្រះអង្គទ្រង់ត្រាស់សួរតទៅទៀត ដោយទ្រង់លើកយត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ហើយទ្រង់បានបញ្ជាក់សួរម្តងមួយៗ (ដូចកាលត្រាស់សួរចក្ខុដែរ) គឺថាត្រចៀក ជាអវយវៈត្រេកអរនឹងសំឡេង ច្រមុះជាអវយវៈត្រេកអរនឹងក្លិន អណ្តាតជាអវយវៈត្រេកអរនឹងរស កាយជាអវយវៈត្រេកអរនឹងសម្ផស្ស ចិត្តជាធម្មជាតិត្រេកអរនឹងអារម្មណ៍ផ្សេងៗ ទាំងនេះដែលតថាគតបានអប់រំហើយ បានគ្រប់គ្រងហើយ បានថែរក្សាហើយ បានសង្រួមហើយ ទើបតថាគតតែងសម្តែងធម៌ដើម្បីសង្រួមត្រចៀក ច្រមុះ អណ្តាត កាយ ចិត្តទាំងនេះ។ តើសម្តីដែលអ្នកពោលថា សមណគោតម ជាអ្នកកម្ចាត់សេចក្តីចម្រើននោះ គឺសំដៅយកត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ទាំងនេះមែនឬ ? «ពិតមែនព្រះអង្គ ព្រោះពាក្យយ៉ាងនេះ មានមកក្នុងសូត្ររបស់ពួកទូលបង្គំ»។

ទ្រង់ត្រាស់សួរបរិព្វាជក តទៅទៀតថា «ម្នាល មាគណ្ឌិយ អ្នកខ្លះដែលធ្លាប់បានទទួលការបម្រុងបម្រើ ដោយរូប សំឡេង ក្លិន រស សម្ផស្ស ដែលជាទីស្រឡាញ់ពេញចិត្តរួចមកហើយ។ លុះដល់ក្រោយមក គេបានដឹងស្គាល់នូវ

កំណើតនិងការរលត់រលាយ ស្គាល់នូវគុណនិងទោសនៃរូប សំឡេង ក្លិន រស សម្ផស្ស ហើយស្គាល់វិធីលះបង់ ហើយក៏លះបង់តណ្ហា កម្ចាត់បង់សេចក្តីក្រវល់ក្រវាយ លែងស្រេកឃ្លានក្នុងរូប សំឡេង ក្លិន រស សម្ផស្ស ទាំងនោះ ហើយមានចិត្តស្ងប់ស្ងៀមនៅ តើអ្នកគួរពោលដូចម្តេច ចំពោះជនប្រភេទនេះ?

«មិនគួរពោលថាអ្វីឡើយ ព្រះគោតម»។

-«ម្នាល មាគណ្ឌិយៈ កាលពីមុននេះ គឺកាលយើងនៅជាគ្រហស្ថសម្បូរដោយកាមគុណទាំង៥គឺ រូប សំឡេង ក្លិន រស និងសម្ផស្ស មុខគួរត្រូវការ មុខគួរប្រាថ្នា មុខគួរគាប់ចិត្ត មុខគួរស្រឡាញ់ មុខគួរត្រេកត្រអាលទាំងនោះណាស់។ យើងមានប្រាសាទ៣ខ្នង សម្រាប់នៅក្នុងរដូវទាំង៣ គឺរដូវភ្លៀង រដូវរងា និងរដូវក្តៅ យើងបានទទួលការបម្រុងបម្រើដោយពួកតន្ត្រី (នារី) ឥតមានបុរសលាយនៅក្នុងប្រាសាទទាំង៣ខ្នងនោះ ក្នុង១ខ្នង ៤ខែ ក្នុងចិរវេលានោះយើងមិនដែលចុះមកខាងក្រោមប្រាសាទឡើយ។

អំណឹះកាលតមក យើងបានស្គាល់នូវកំណើតនិងការរលត់រលាយនូវគុណនិងទោសនៃកាមារម្មណ៍ទាំងនោះ ព្រមទាំងវិធីលះបង់ចោល ទើបយើងលះបង់តម្រេកស្រេកឃ្លានក្នុងកាមគុណ ហើយមានចិត្តស្ងប់ស្ងៀមនៅ។ យើងបានឃើញអ្នកដទៃ ដែលមិនទាន់ប្រាសចាកតម្រេកក្នុងកាមារម្មណ៍ ត្រូវតណ្ហាចាំទំពាស៊ី ក្រហល់ក្រហាយក្នុងកាមារម្មណ៍ជំពាក់ជាប់នឹងកាមារម្មណ៍ ទើបយើងគ្មានការត្រេកត្រអាលចំពោះជនពួកនោះ គ្មានរីករាយចំពោះជនពួកនោះ ព្រោះយើងបានលះបង់តម្រេកក្នុងកាមារម្មណ៍ លះបង់ការរីករាយចំពោះអ្វីដែលជាអកុសលអស់រលីងហើយ»។

-«ម្នាល មាគណ្ឌិយៈ គហបតីឬបុត្រគហបតី ជាអ្នកស្តុកស្តម្ភមានទ្រព្យសម្បត្តិច្រើន មានគ្រឿងឧបភោគបរិភោគច្រើន ពោរពេញដោយកាមគុណទាំង៥ (ដែលពោលហើយ) ដែលមុខគួរត្រូវការ មុខគួរប្រាថ្នា មុខគួរគាប់ចិត្ត មុខគួរត្រេកត្រអាល មុខគួរស្រឡាញ់។ គេប្រព្រឹត្តតែអំពើសុចរិត ដោយកាយវាចា

ចិត្ត ដល់ពេលបែកធ្លាយទម្លាយខន្ធហើយ ក៏បានទៅកើតជាពួកទេវតាជាន់តាវត្តិង្ស ពោរពេញដោយកាមគុណដ៏ជាទិព្វ ចោមរោមដោយពពួកអប្សរ ជាឧទ្យាននន្ទវ័ន។ កាលនោះ ទេវបុត្រនោះបានឃើញគហបតី ឬបុត្រគហបតី ដែលពោរពេញទៅដោយកាមគុណទាំង៥ដែរ តើទេវបុត្រនោះ អួះអន្វែងចង់បានដូចគហបតីនោះឬទេ? នឹងវិលត្រឡប់នឹករឭកដល់អារម្មណ៍ដែលមុខគួរស្រឡាញ់ មុខគួរគាប់ចិត្តរបស់មនុស្សលោកឬទេ?

«គ្មានសោះឡើយ ព្រះគោតម» ។

-«ម្នាលមាគណ្ឌិយៈ ឯយើងក៏ដូច្នោះដែរ គឺកាលមុននោះ យើងនៅជាគ្រហស្ថ ពោរពេញទៅដោយកាមគុណទាំង៥ មុខគួរត្រូវការ មុខគួរប្រាថ្នា មុខគួរគាប់ចិត្តមុខគួរស្រឡាញ់មុខគួរត្រេកត្រអាលមកហើយ។តមកក្រោយទៀត យើងបានស្គាល់ពិតៗនូវកំណើតនិងការរលត់រលាយ នូវគុណធម៌នៃកាមារម្មណ៍ទាំងនោះ ហើយស្គាល់ច្បាស់នូវវិធីលះបង់ចោល ទើបយើងលះបង់ចោលនូវតណ្ហាក្នុងកាមារម្មណ៍ កម្ចាត់ចោលការក្រហល់ក្រហាយក្នុងកាមារម្មណ៍ ហើយមានចិត្តស្ងប់ស្ងៀមនៅ។ យើងបានឃើញអ្នកដទៃៗ ដែលនៅត្រេកត្រអាលក្នុងកាមារម្មណ៍ ត្រូវតណ្ហាក្នុងកាមារម្មណ៍ខំទំពាស៊ី ក្រហល់ក្រហាយដោយកាមារម្មណ៍ ជាប់ជំពាក់នឹងកាមារម្មណ៍ យើងគ្មាននឹកត្រេកត្រអាលរីករាយនឹងគេឡើយព្រោះយើងបានលះបង់តម្រេកត្រេកត្រអាលក្នុងកាមារម្មណ៍ទាំងនោះ នឹងអ្វីដែលជាអកុសលអស់រលីង ហើយទើបយើងត្រេកអរសប្បាយដោយក្តីសុខដ៏ជាទិព្វប៉ុណ្ណោះ»។

ម្នាលមាគណ្ឌិយៈ មនុស្សកើតរោគឃ្លង់ មានដំបៅពាសពេញខ្លួន ក្រហមឆ្អៅដោយជំងឺឃ្លង់ មានហ្វូងដង្កូវក្នុងដំបៅ អេះដំបៅដោយក្រចក តោងដែកឆ្អើរភ្លើង។ ពួកមិត្តអាមាត្យញាតិសាលោហិត ទៅរកគ្រូពេទ្យមកថែរក្សាគេ ត្រាតែបានសះជាពីរោគឃ្លង់នោះ គេបានទៅជាមនុស្សមានសេចក្តីសុខ មានសេរីភាពអាចទៅកាន់ទីណាក៏បានតាមចិត្ត នៅពេលដែលគេបានឃើញអ្នក

ដទៃកើតរោគឃ្លង់ដូចគេ ( កាលមុន )ដែរតើគេត្រេកអររីករាយនឹងមនុស្សគម្លង់ សប្បាយចិត្តនឹងមនុស្សគម្លង់ដែលដេកឆ្អើរភ្លើង ខំផឹកថ្នាំ រក្សារោគឃ្លង់ដែរឬទេ ?

«គេគ្មានត្រេកអរសោះឡើយព្រះគោតមព្រោះថាកាលបើកើតរោគនោះទើបគេខំថែរក្សាខ្លួនដោយថ្នាំ កាលបើគ្មានរោគទេ គេក៏គ្មានការចាំបាច់ដោយថ្នាំទេ ព្រះអង្គ» ។

«ម្នាលមាគណ្ឌិយៈ ឯយើងក៏ដូច្នោះដែរ គឺកាលពីមុននេះយើងនៅជាគ្រហស្ថ គ្រប់គ្រងឃរាវាស ពោរពេញដោយកាមគុណទាំង៥ មុខគួរត្រូវការមុខគួរប្រាថ្នា។ ក្រោយមកយើងបានស្គាល់កំណើតនិងការរលត់រលាយ គុណនិងទោសព្រមទាំងវិធីលះបង់ចោលនូវកាមគុណទាំងនោះយើងបានលះបង់នូវតណ្ហាក្នុងកាមារម្មណ៍ កម្ចាត់ការក្រហល់ក្រហាយក្នុងកាមបាន លែងមានការអន្ទះអន្ទែងក្នុងកាមារម្មណ៍ ទើបយើងមានចិត្តស្ងប់ស្ងៀមនៅ។ នៅពេលដែលយើងបានឃើញអ្នកដទៃ ត្រេកត្រអាលរីករាយក្នុងកាមារម្មណ៍ ត្រូវតណ្ហាចាំទំពាស៊ី ក្តៅក្រហល់ក្រហាយដោយកាមារម្មណ៍នោះ យើងមិនដែលត្រេកអរសប្បាយនឹងគេទេ ព្រោះយើងមានការត្រេកអរសប្បាយដ៏ជាទិព្វ ក្រៅអំពីកាមារម្មណ៍ ក្រៅអំពីអំពើជាអកុសលទាំងឡាយ។

«ម្នាលមាគណ្ឌិយៈ បុរសកើតរោគឃ្លង់ មានខ្លួនដំបៅដេកឆ្អើរភ្លើង។ មិត្តអាមាត្យញាតិសាលោហិត ត្រូវទៅរកគ្រូពេទ្យមកថែរក្សាគេ លុះគេបានសះជារោគហើយ ក៏មានក្តីសុខកាយសប្បាយចិត្ត មានសេរីភាពអាចចេញទៅណាបានតាមចិត្ត។ ប្រសិនបើមានបុរសដែលមានកម្លាំង២ នាក់ មកចាប់ដៃគេម្ខាងម្នាក់ អូសទាញទៅកាន់រណ្តៅរងើកភ្លើង ដែលគេធ្លាប់ឆ្អើរខ្លួនកាលពីមុន អ្នកឯងគិតមើល តើបុរសនោះ សុខចិត្តដេកឆ្អើរខ្លួនដូចមុនទៀតឬទេ ?

-«គេមិនសុខចិត្តដេកឆ្អើរទេ ព្រះគោតម ព្រោះធម្មតាភ្លើងជារបស់ក្តៅ មានសម្ផស្សជាទុក្ខ គ្មានស្រួលសប្បាយទេ»។

-«ម្នាលមាគណ្ឌិយៈ ភ្លើងនោះទើបតែនឹងក្តៅ ក្នុងកាលឥឡូវនេះ ឬកាលពីមុនក៏ក្តៅដូចគ្នាដែរ»។

-«បពិត្រព្រះគោតម ក្នុងកាលមុនក៏ដូចជាក្នុងកាលឥឡូវដែរ ភ្លើងតែងតែក្តៅដូចគ្នាទេ។ ប៉ុន្តែកាលមុនបុរសនោះកំពុងកើតរោគឃ្លង់ ក៏គេយល់ខុសថា សេចក្តីសុខស្រួលនៅត្រង់ភ្លើង»។

-«ម្នាលមាគណ្ឌិយៈ ខនេះក៏ដូច្នោះដែរ គឺថាធម្មតាកាមារម្មណ៍ទាំងឡាយ តែងនាំឲ្យកើតទុក្ខព្រួយ ទាំងក្នុងអតីតកាល ទាំងក្នុងអនាគតកាល ទាំងក្នុងបច្ចុប្បន្នកាលនេះដែរ ក៏ប៉ុន្តែពួកដែលនៅត្រេកត្រអាលក្នុងកាមារម្មណ៍ ពួកដែលត្រូវតណ្ហាចាំទំពាស៊ី ពួកដែលក្រហល់ក្រហាយដោយកាមារម្មណ៍ ពួកដែលមានឥន្ទ្រិយក្តៅរោលនៅឡើយ ក៏យល់ខុសថា សេចក្តីសុខនៅក្នុងកាមារម្មណ៍ ដែលមានសម្ផស្សប្រកបដោយទុក្ខព្រួយនោះ»។

-«ម្នាលមាគណ្ឌិយៈ បុរសកើតរោគឃ្លង់ ដែលមានខ្លួនកើតដំបៅរាងកាយក្រហមឆ្អិន ដេកផ្អើរខ្លួនលើរណ្តៅរងើកភ្លើង ដំបៅឃ្លង់កាន់តែស្មោកគ្រោកឡើង មានក្លិនធុំស្អុយខ្លាំងឡើងកាន់តែរលួយច្រើនឡើង ប៉ុន្តែបុរសដែលកើតរោគឃ្លង់នោះ ត្រឡប់ជាយល់ថា ជាការសុខស្រួលទៅវិញ ដោយគ្រាន់តែបានអេះដំបៅឃ្លង់នោះ យ៉ាងណាមិញ ពួកដែលនៅត្រេកត្រអាលក្នុងកាមារម្មណ៍ ត្រូវតណ្ហាក្នុងមាមារម្មណ៍ចាំទំពាស៊ី ក៏យល់ខុសថា អារម្មណ៍ទាំងឡាយជាសេចក្តីសុខស្រួល ក៏យ៉ាងដូច្នោះដែរ»។

-«ម្នាលមាគណ្ឌិយៈ អ្នកធ្លាប់បានឃើញ បានឮខ្លះឬទេថា ព្រះរាជា ឬមហាមាត្យរបស់ព្រះរាជា ដែលសម្បូណ៌ដោយកាមគុណទាំង៥ មិនទាន់លះបង់តម្រេកក្នុងកាមគុណទាំង៥ មិនទាន់អស់ក្តីស្រេកឃ្លានក្នុងកាមគុណទាំង៥ ហើយបានទៅជាអ្នកមានចិត្តស្ងប់ស្ងៀមនៅ ឬមុខជានឹងបានស្ងប់តទៅមុខដែរឬទេ» ។

-«បពិត្រព្រះគោតម មិនធ្លាប់បានឃើញ មិនធ្លាប់បានឮសោះឡើយ»។

-«ម្នាលមាគណ្ឌិយៈ សូម្បីយើងក៏មិនធ្លាប់ឃើញ ឬធ្លាប់ឮដែរ។ នែ មាគណ្ឌិយៈ ពួកសមណៈឬព្រាហ្មណ៍ដែលលែងមានការក្រហល់ក្រហាយក្នុងកាមគុណទាំង៥ ហើយស្គាល់ពិតនូវកំណើតនិងការរលត់រលាយ ស្គាល់ពិតនូវគុណនិងទោស ព្រមទាំងរលាស់ចោលនូវកាមគុណទាំង៥ លះបង់តណ្ហាក្នុងកាមគុណទាំង៥ ហើយមានចិត្តស្ងប់ស្ងៀមនៅយ៉ាងនេះ ទាំងក្នុងអតីត អនាគត និងបច្ចុប្បន្ន» ។

លុះព្រះសម្ពុទ្ធ ទ្រង់បានត្រាស់សម្តែងយ៉ាងនេះហើយ ទ្រង់បានបន្លឺព្រះឱទានវាចាថា «**អរោគ្យា បរមា លោភា, និព្វានំ បមរំ សុខំ, អដ្ឋង្គិកោ មគ្គានំ ខេមំ អមត គាមិនំ**»។ ប្រែថា ភាវៈគ្មានរោគជាលាភយ៉ាងក្រៃលេង, និព្វានជាសេចក្តីសុខយ៉ាងក្រៃលែង បណ្តាផ្លូវទាំងឡាយផ្លូវប្រកបដោយអង្គ៨ ជាផ្លូវក្សេមក្សាន្ត ជាផ្លូវទៅកាន់អមតៈ (ការមិនស្លាប់)។

កាលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់យ៉ាងនេះហើយ មាគណ្ឌិយៈបរិព្វាជកក្រាបទូលទទួលយល់ស្របតាមថា «ព្រះវាចាព្រះគោតមដែលត្រាស់សម្តែងនេះ គួរឲ្យអស្ចារ្យមែន ជាវាចាល្អមែនពិត ព្រោះថាភាវៈគ្មានរោគជាលាភយ៉ាងក្រៃលែង និព្វានជាសុខយ៉ាងក្រៃលែងមែន ទូលបង្គំធ្លាប់បានឮអំពីពួក បរិព្វាជកមុនៗ ដែលជាគ្រូអាចារ្យតូចធំទាំងឡាយ ធ្លាប់បានពោលតៗគ្នាមកយ៉ាងនេះឯង។

-«ម្នាលមាគណ្ឌិយៈ ពាក្យដែលអ្នកពោលថា ពួកបរិព្វាជកមុនៗ ដែលជាគ្រូអាចារ្យតូចធំទាំងឡាយបានពោលទុកថា ភាវៈគ្មានរោគ ជាលាភយ៉ាងក្រៃលែង និព្វានសុខយ៉ាងក្រៃលែងនេះ យើងសូមសួរអ្នកថា «ភាវៈគ្មានរោគគឺអ្វី? និព្វានគឺអ្វី?»

មាគណ្ឌិយបរិព្វាជក ស្ទាបខ្លួនឯងហើយក្រាបទូលថា «បពិត្រព្រះគោតម ភាវៈគ្មានរោគគឺត្រង់នេះ និព្វានគឺត្រង់នេះ ឥឡូវទូលបង្គំ (សម្តីដែលបរិព្វានជនឆ្លើយតបនេះ មិនស្របតាមប្រធាន ដែលព្រះអង្គបានត្រាស់សួរគេ

គឺភាវៈគ្មានភេទនិងនិព្វាន គេសំដៅយកខ្លួនគេ ដែលគ្មានរោគ មានសុខភាពស្រួលបួលនោះទេ )។

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្តែងជាសេចក្តីឧបមា ដើម្បីឲ្យគូសន្ទនាយល់ន័យនៃពាក្យទាំងពីរឃ្លា យ៉ាងជាក់ច្បាស់ដោយខ្លួនឯង។

«ម្នាលមាគណ្ឌិយៈ បុរសភ្នែកខ្វាក់ពីកំណើត មិនធ្លាប់ឃើញពណ៌ខ្មៅ ស ខៀវ លឿង ក្រហមទេ មិនធ្លាប់ឃើញទីករាបស្មើមិនរាបស្មើទេ មិនធ្លាប់ដែលឃើញដួងព្រះអាទិត្យ ដួងព្រះចន្ទ ដួងតារាទាំងឡាយឡើយ។ ប្រសិនបើគេបានឮអ្នកមានភ្នែកភ្លឺនិយាយថា សំពត់នេះសស្អាតល្អ សាច់ស្រស់ល្អ។ បុរសភ្នែកខ្វាក់នោះ ចង់បានសំពត់សស្អាតនោះ មានបុរសម្នាក់ទៀត បោកបញ្ឆោតគេដោយយកសំពត់សាច់គគ្រាតត្បាញដោយរោមកែះខ្មៅ ប្រឡាក់ធ្យូងខ្មៅ ហើយប្រាប់គេថា នេះជាសំពត់សស្អាតសាច់ស្រស់ល្អ។ បុរសខ្វាក់ទទួលយកសំពត់សាច់គគ្រាតនោះមកដណ្តប់ ហើយនិយាយដោយរីករាយថា សំពត់សស្អាត សាច់ស្រស់ល្អ។

«តើអ្នកយល់ដូចម្តេច អ្នកគិតថា បុរសភ្នែកខ្វាក់ពីកំណើតនោះមើលឃើញឬ បានជាទទួលយកសំពត់សាច់គគ្រាតត្បាញរោមកែះខ្មៅប្រឡាក់ខ្មៅដណ្តប់ហើយ សប្បាយចិត្តបញ្ចេញវាចាថា សំពត់នេះសស្អាត ពណ៌ស្រស់ល្អ ឬមួយជឿតាមសម្តីរបស់បុរសមានភ្នែកភ្លឺ។

-«បពិត្រព្រះគោតម បុរសភ្នែកខ្វាក់ដែលបានពោលមកនេះ ព្រោះជឿតាមសម្តីរបស់បុរសភ្នែកភ្លឺនោះឯង។

-«ម្នាលមាគណ្ឌិយៈ ឧបមានេះយ៉ាងណាមិញ សេចក្តីឧបមេយ្យក៏ដូច្នោះដែរ គឺពួកបរិព្វាជក អ្នកបួសក្រៅសាសនាយើងជាពួកភ្នែកខ្វាក់ ឥតមានភ្នែក មិនស្គាល់ភាវៈឥតរោគ មិនដែលឃើញនិព្វានឡើយ គ្រាន់តែបានឮពាក្យដែលគេបានពោលទុកមកថា «គ្មានរោគជាលាភយ៉ាងក្រៃលែង និព្វានជាសុខយ៉ាងក្រៃលែង»។

ឯពាក្យថា «ភាវៈគ្មានរោគជាលាភយ៉ាងក្រៃលែង និព្វានជាសុខយ៉ាងក្រៃលែង ផ្លូវមានអង្គ៨ ជាផ្លូវក្សេមក្សាន្ត ជាផ្លូវទៅកាន់ព្រះនិព្វាន នេះជាពាក្យដែលព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយបានត្រាស់សម្តែងទុកមក បុថុជ្ជនទាំងឡាយក៏បានពោលតៗគ្នា ដរាបដល់ឥឡូវនេះ។ ម្នាលមាគណ្ឌិយៈ រាងកាយនេះដូចក្បាលបូស ដូចកូនសរជាឫសគល់នៃទុក្ខព្រួយ ធ្វើឲ្យលំបាក អ្នកឯងបានពោលថា ភាវៈឥតរោគ ជានិព្វានទៅវិញ ភ្នែករបស់អ្នកដែលធ្វើឲ្យអ្នកស្គាល់នូវភាវៈឥតរោគ ឃើញថាគ្មាននិព្វានមែនទេ ?

មាគណ្ឌិយៈ បានក្រាបបង្គំទូលថា «ទូលព្រះបង្គំមានចិត្តជ្រះថ្លាចំពោះព្រះគោតម ព្រះអង្គអាចសម្តែងធម៌ ដើម្បីឲ្យទូលព្រះបង្គំស្គាល់ភាវៈឥតរោគ ឃើញនិព្វាន( មែន )។

«ម្នាលមាគណ្ឌិយៈ បុរសខ្វាក់ភ្នែកពីកំណើត មិនដែលឃើញពណ៌ខ្មៅ ស ខៀវ លឿង ក្រហមសោះឡើយ មិនធ្លាប់ឃើញទីរាបស្មើ មិនរាបស្មើទេ មិនធ្លាប់ឃើញដួងព្រះអាទិត្យ ដួងព្រះចន្ទ ដួងតារាទាំងឡាយទេ។ ពួកមិត្តអាមាត្យ ញាតិសាលោហិតរបស់បុរសខ្វាក់នោះ រកគ្រូពេទ្យមកថែរក្សា តែមិនអាចធ្វើភ្នែកខ្វាក់ឲ្យសះជា (ភ្លឺ) ឡើងវិញទេ គ្រូពេទ្យនោះត្រូវព្រួយលំបាកទទេនឹងការថែរក្សាមែនទេ ?

-«ពិតមែន ព្រះគោតម ។

-«ម្នាលមាគណ្ឌិយៈ នេះក៏ដូច្នោះដែរ ប្រសិនបើយើងសម្តែងធម៌ឲ្យអ្នកស្តាប់ ជាភាវៈគ្មានរោគនៅត្រង់នេះ និព្វាននៅត្រង់នោះ ដូច្នេះ អ្នកក៏មិនស្គាល់ភាវៈគ្មានរោគ មិនឃើញនិព្វាន (ពិតៗ)ទេ ក៏ជាការនាំឲ្យយើងព្រួយលំបាកទទេៗដែរ។

ទើបមាគណ្ឌិយបរិព្វាជក ក្រាបបង្គំទូលម្តងទៀតថា

«ទូលព្រះបង្គំមានចិត្តជ្រះថ្លាចំពោះព្រះគោតម ព្រះអង្គអាចសម្តែងធម៌ ដើម្បីឲ្យទូលព្រះបង្គំឃើញភាវៈឥតរោគ ឃើញនិព្វាន( មែន )។

-«ម្នាលមាគណ្ឌិយៈ ឧបមាថា បុរសភ្នែកខ្វាក់ពីកំណើត មិនដែលឃើញរបស់ខ្មៅ ស ខៀវ មិនដែលឃើញដួងព្រះអាទិត្យ ព្រះចន្ទ និងដួងតារាទាំងឡាយទេ។ នៅពេលដែលគេបានឮអ្នកមានភ្នែកភ្លឺនិយាយថា សំពត់នេះសស្អាត សាច់ស្រស់ល្អ។ គេក៏ចង់បានសំពត់សនោះ មានបុរសម្នាក់បោកបញ្ឆោតគេ យកសំពត់សាច់ក្រាស់ត្បាញដោយរោមកែះខ្មៅ ប្រឡាក់ធ្យូងខ្មៅ ថានេះជាសំពត់សស្អាត ស្រស់ល្អ។ គេក៏ទទួលយកមកដណ្ដប់ខ្លួនគេ ដោយសប្បាយរីករាយ។ (ក្រោយមក) ពួកញាតិមិត្តសាលោហិតរបស់គេ រកគ្រូពេទ្យមកថែរក្សា គ្រូពេទ្យឲ្យគេផឹកថ្នាំបញ្ចុះរោគខាងលើខាងក្រោមចេញហើយ ទើបឲ្យគេដាក់ថ្នាំភ្នែក ឲ្យថ្នាំលាងភ្នែក ថ្នាំដាក់ច្រមុះ។ លុះរកបានទទួលការព្យាបាលថែរក្សាយ៉ាងនេះហើយ ភ្នែករបស់គេក៏បានសះជាឡើងវិញ លុះភ្នែកបានសះជាហើយ គេលះបង់សំពត់ត្បាញដោយរោមកែះខ្មៅ ដែលប្រឡាក់ធ្យូងខ្មៅនោះចោលទៅ។ គេគិតថា បុរសដែលបោកបញ្ឆោតគេនោះមិនមែនមិត្តគឺជាសត្រូវក៏គិតចង់សម្លាប់បុរសនោះចោលដោយគិតឃើញថា បុរសនោះបោកបញ្ឆោតខ្លួនមកយូរយារហើយ។ បើយើងសម្ដែងធម៌ឲ្យស្ដាប់ (អំពីភាវៈឥតរោគនិងនិព្វាន) អ្នកក៏អាចដឹងស្គាល់ភាវៈឥតរោគនិងនិព្វានបានពិតប្រាកដ។ ព្រមគ្នានឹងពេលដែលបានដឹងស្គាល់ បានឃើញពិតនេះ អ្នកក៏លះបង់សេចក្ដីស្រឡាញ់ពេញចិត្តក្នុងខន្ធទាំង៥ ចោលទៅហើយថា អាត្មាអញត្រូវខន្ធទាំង៥នេះបោកបញ្ឆោតមកយូរហើយ អញបានប្រកាន់ខ្ជាប់នូវខន្ធទាំង៥នេះ ដែលជាប្រភពបង្កើតភព ជាតិ ជរា ព្យាធិ មរណៈ សោក បរិទេវៈ (ការខ្សឹកខ្សួល) ទុក្ខ ទោមនស្ស ឧបាយាស (ការតានតឹងចង្អៀតចង្អល់)។

មាគណ្ឌិយបរិព្វាជក ក្រាបបង្គំទូលម្ដងទៀតថា «ទូលព្រះបង្គំមានចិត្តជ្រះថ្លាចំពោះព្រះគោតម ទ្រង់អាចសម្ដែងធម៌ឲ្យទូលព្រះបង្គំចេញចាកភាវៈ(ល្ងិត) នេះបាន ឲ្យបានជាមនុស្សមានភ្នែកមិនខ្វាក់។

ទ្រង់ត្រាស់តទៅទៀតថា «បើដូច្នេះត្រូវអ្នកសេពគប់នឹងសប្បុរសទាំង

ឡាយ ត្រូវស្តាប់ធម៌របស់សប្បុរស ត្រូវប្រតិបត្តិតាមធម៌របស់សប្បុរស ទើបអ្នកចេះដឹងខ្លួនឯង ឃើញដោយខ្លួនឯងថា សភាវៈអស់នោះ ជារោគក្បាលបូសកូនសរ ហើយរោគក្បាល បូស កូនសរ នឹងរលត់ទៅបានក្នុងទីនេះ។ កាលបើការប្រកាន់ខ្ជាប់រលត់រលាយទៅ ភព ជាតិ ជរា ព្យាធិ មរណៈ សោកបរិទេវៈ ទុក្ខទោមនស្ស ឧបាយាស ក៏នឹងរលត់រលាយទៅជាមួយដែរ ឈ្មោះថាកងទុក្ខទាំងអស់ រមែងរលត់រលីងអស់ទៅ ដោយប្រការយ៉ាងនេះឯង។

កាលព្រះសម្មាសម្ពុទ្ធត្រាស់សម្តែងយ៉ាងនេះហើយមាគណ្ឌិយបរិព្វាជកក្រាបបង្គំទូលសរសើរព្រះធម្មទេសនា ដោយចិត្តសទ្ធាជ្រះថ្លាពិតមែន ហើយក្រាបបង្គំទូលសូមបព្វជ្ជាឧបសម្បទ លុះបានបព្វជ្ជាឧបសម្បទហើយ ក៏បានតាំងចិត្តខិតខំចម្រើនសមណធម៌ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ជាព្រះអរហន្ត១ អង្គ ក្នុងពុទ្ធសាសនានេះ។

**ចប់មាគណ្ឌិយសូត្រ**

# ធម្មសាកច្ឆាអំពីមាគណ្ឌិយសូត្រ
# រវាងលោកធម្មកថិក និងឧបាសក

ក្រោយពីចប់ធម្មទេសនា ដែលលោកធម្មកថិកបានសម្តែង អំពីមាគណ្ឌិយសូត្រ នេះមានឧបាសកម្នាក់បានចូលទៅរកលោកគ្រូធម្មកថិក ហើយបានពោលថា «លោកគ្រូម្ចាស់ ខ្ញុំករុណាមានសេចក្តីងឿងឆ្ងល់បន្តិចត្រង់ឃ្លាដែលបរិព្វាជក (អ្នកបួសក្រៅសាសនា) បានពោលចោទព្រះពុទ្ធថា «ព្រះសមណគោតម ជាអ្នកកម្ចាត់សេចក្តីចម្រើន»។

ត្រង់ឃ្លានេះ ព្រះអង្គត្រាស់សួរបញ្ជាក់ទៅវិញថា «អ្នកពោលដូច្នេះ គឺអ្នកពោលសំដៅយកភ្នែក ត្រចៀក ច្រមុះ កាយ ចិត្ត មែនឬ?

បរិព្វាជក ទូលតបថា «ពិតមែនព្រះអង្គ។

ត្រង់កន្លែងនេះ នាំឲ្យខ្ញុំករុណាយល់ថា មានការខ្វែងគំនិតរវាងទស្សនៈទាំងពីរពិតមែន ប៉ុន្តែខ្ញុំករុណាមិនទាន់យល់ឲ្យបានច្បាស់អំពីទស្សនៈទាំងពីរនេះ សូមលោកគ្រូម្ចាស់ មេត្តាពន្យល់អំពីការខ្វែងគំនិតឲ្យទានបន្តិចមើល។

**លោកធម្មកថិក** ទស្សនៈទាំងពីរពិតជាមានការខ្វែងគំនិតគ្នាមែន គឺគេចោទព្រះអង្គថា «ព្រះសមណគោតម ជាអ្នកកម្ចាត់បង់នូវសេចក្តីចម្រើន» ត្រង់ពាក្យមួយឃ្លានេះ គ្មាននរណាអាចយល់បានដូចម្តេចទេ ព្រោះព្រះអង្គមិនដែលធ្វើឲ្យខូចផលប្រយោជន៍របស់អ្នកឯណាមួយឡើយ ពាក្យចោទយ៉ាងខ្លីនេះ ហាក់ដូចជាចង់ឲ្យអ្នកផងយល់ថា ព្រះអង្គគិតតែធ្វើឲ្យខូចសេចក្តីសុខចម្រើនរបស់អ្នកដទៃ?

ហេតុដូច្នេះហើយ ទើបព្រះអង្គត្រាស់សួរបញ្ជាក់ទៅគេវិញថា «តើអ្នកពោលដូច្នេះ សំដៅយកភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្តទាំងនេះមែនឬទេ?

មាគណ្ឌិយបរិព្វាជក ទូលតបថា «ពិតមែន ព្រះគោតម» ។

ដល់មកកន្លែងនេះនាំឲ្យយើងយល់បានខ្លះ តែមិនទាន់ច្បាស់លាស់ទេ។ ចុះក្នុងទស្សនៈនេះ តាមលទ្ធិរបស់គេពន្យល់ដូចម្តេច? គឺគេពន្យល់ថា «អ្វីដែលមិនបានឃើញដោយភ្នែក (ចក្ខុទ្វារ) គួរមើលឲ្យឃើញ ដែលធ្លាប់បានឃើញគួរកន្លងហួសទៅ។ សូរសព្ទដែលមិនទាន់បានឮដោយត្រចៀក (សោតទ្វារ) គួរតែឮគួរតែស្តាប់ ដែលធ្លាប់បានឮហើយ គួរកន្លងហួសទៅ។ ឯក្លិនដែលមិនធ្លាប់បានហិតដោយច្រមុះ (ឃានទ្វារ) គួរតែហិតដែលធ្លាប់ហិតហើយគួរកន្លងហួសទៅ។ រសជាតិដែលមិនធ្លាប់លិទ្ធភ្លក់ដោយអណ្តាត (ជិវ្ហាទ្វារ) គួរតែលិទ្ធភ្លក់ ដែលបានលិទ្ធភ្លក់ហើយ គួរកន្លងហួសទៅ។ សម្ផស្សអ្វីដែលមិនធ្លាប់ប៉ះពាល់ ដោយកាយ (កាយទ្វារ) គួរតែប៉ះពាល់ ដែលបានប៉ះ ពាល់ហើយគួរកន្លងហួសទៅ។ អារម្មណ៍អ្វីដែលមិនធ្លាប់គិតនឹកដោយចិត្ត (មនោទ្វារ) គួរគិតនឹក ដែលបានធ្លាប់គិតនឹកហើយ គួរកន្លងហួសទៅ។

ការធ្វើដូច្នេះគេយល់ថា ជាមធ្យោបាយធ្វើឲ្យកើតសេចក្តីចម្រើនពិតប្រាកដ។ ព្រោះហេតុនេះ បានជាគេចោទថា «ព្រះសមណគោតម ជាអ្នកកម្ចាត់សេចក្តីចម្រើន»។ ទស្សននិយមបែបនេះ គេអាចយល់ស្របបានខ្លះដែរ តាមទស្សនៈលោកិយនិយម ប៉ុន្តែផ្ទុយគ្នាស្រឡះអំពីទស្សនៈលោកុត្តរនិយម ដែលជាឧត្តមគតិខ្ពង់ខ្ពស់បំផុតក្នុងពុទ្ធសាសនានេះ។

-ខ្ញុំករុណាបានស្តាប់សេចក្តីពន្យល់របស់លោកគ្រូម្ចាស់ ខ្ញុំករុណាបានទទួលពន្លឺខ្លះហើយ ក្នុងទស្សននិយម នៃលទ្ធិបរិព្វានជកនោះ។

ចុះចំណែកខាងទស្សនៈពុទ្ធនិយមវិញ តើព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ប្រឆាំងជំទាស់ដូចម្តេចខ្លះ? សូមលោកគ្រូម្ចាស់សង្ខេបខ្លីៗ ដើម្បីប្រៀបធៀប»។

-ញោមបានស្តាប់ មាគណ្ឌិយសូត្រ ដែលទ្រង់បានសម្តែងដល់បរិព្វាជកនោះ យ៉ាងពិស្តារួចមកហើយ ប៉ុន្តែអាត្មាភាពមិនបានឃើញត្រង់ឃ្លាណា ឬប្រយោគណា ដែលព្រះអង្គរិះគន់តិះដៀលទស្សននិយមរបស់គេទេ គ្រាន់តែ

ទ្រង់បានសម្តែងពន្យល់ទស្សនៈរបស់ព្រះអង្គ ដើម្បីបំភ្លឺឲ្យគេបានឃើញយល់សេចក្តីពិត និងទស្សនៈដ៏សម សហាតុសមផលរបស់ព្រះអង្គប៉ុណ្ណោះ ដូចជាគ្រាទ្រង់បានបញ្ជាក់សួរគេ រាល់ៗលើក ក្នុងខណៈចប់សេចក្តីពន្យល់ម្តងៗថា តើគេយល់ឬមិនយល់? ថាតើទស្សនៈរបស់ព្រះអង្គពិតឬមិនពិត?

ក្នុងអត្ថបទបានបង្ហាញឲ្យយើងឃើញថា គេបានឆ្លើយទទួលយល់ស្រប តាមទស្សនៈរបស់ព្រះអង្គរាល់ៗលើក។

ឯប្រធានបទដែលត្រូវលើកឡើងយកមកចោទ ដើម្បីដោះស្រាយនៅតែដដែល គឺសំដៅយកភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត ហើយនឹងកាមគុណទាំង៥ ដែលជាប្រធានសំខាន់ ក្នុងអត្ថបទពុទ្ធនិយមនេះ។

អាត្មាសូមស្រង់យកអន្លើខ្លះ នៃអត្ថបទមកជូនញោមស្តាប់ឡើងវិញ។

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្តែងថា «ម្នាល មាគណ្ឌិយៈ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្តទាំងនេះហើយ ដែលតថាគតបានអប់រំហ្វឹកហ្វឺនហើយ បានគ្រប់គ្រងរក្សាហើយ បានសង្រួមហើយ ទើបតថាគតតែងសម្តែងធម៌ដើម្បីសង្រួមនូវអាយតនៈទាំង៦នេះឯង»។

«ម្នាលមាគណ្ឌិយៈ មានអ្នកខ្លះដែលគេធ្លាប់បានទទួលការទំនុកបម្រុង (យ៉ាងពេញលេញ) ដោយកាមគុណទាំង៥គឺ រូប សំឡេង ក្លិន រស សម្ផស្ស ដែលជាទីស្រឡាញ់ ជាទីគាប់ចិត្តរួចមកហើយ។ លុះដល់ក្រោយមក គេបានដឹងស្គាល់ច្បាស់នូវកំណើតនិងការរលត់រលាយ ស្គាល់ច្បាស់នូវគុណនិងគោលនៃកាមគុណទាំង៥ ហើយ គេបានដឹងវិធីលះបង់ចោលផង គេក៏បានលះបង់នូវតណ្ហា ដែលក្រវល់ក្រវាយ លែងស្រេកឃ្លាន លែងជាប់ជំពាក់ក្នុងកាមគុណទាំង៥ នោះទៀត ហើយមានចិត្តស្ងប់ស្ងៀមនៅ។ល។

ទ្រង់ត្រាស់សួរបរិព្វាជកនោះថា «តើអ្នកគួរពោលបន្ទោសជនប្រភេទនេះឬទេ?

គេក្រាបទូលថា «បពិត្រព្រះគោតម មិនគួរស្តីបន្ទោសអ្វីឡើយ»។

អត្ថបទបន្តទៅទៀត ព្រះអង្គទ្រង់បានលើកឧទាហរណ៍ផ្ទាល់ព្រះអង្គ ផងអ្នកដទៃខ្លះទៀតផង ដើម្បីបញ្ជាក់បំភ្លឺបរិញ្ញាជកនោះឲ្យបានយល់ច្បាស់-លាស់ឡើងទៀត។

ចំពោះអត្ថបទយ៉ាងខ្លី ដែលអាត្មាដកស្រង់យកមកជូនជាទីសណ្ដាប់នេះ ល្មមនាំឲ្យយើងត្រិះរិះពិចារណាទៅ ក៏អាចយល់ឃើញថា ព្រះអង្គមិនមែនបិទសិទ្ធិសេរីភាពរបស់យើង ក្នុងការប្រើប្រាស់អាយតនៈទាំង៦នេះទេ គឺគ្រាន់តែទ្រង់ណែនាំទូន្មានឲ្យយើងចេះអប់រំ ហ្វឹកហ្វឺន ថែរក្សា សង្រួមឲ្យកាន់តែបានល្អប្រសើរឡើងទៀតប៉ុណ្ណោះ។

ឯគោលការណ៍ខាងលើនេះ ប្រសិនបើគេយកមកអនុវត្តក្នុងគតិលោកវិញ ក៏មិនជាការខុសអ្វីដែរ (តាមទស្សនៈអាត្មា)។

ដូចបុរសស្ត្រីខ្លះ ដែលងប់ងុលជ្រុលជ្រប់នឹងកុន ល្ខោន រាំច្រៀងតាមរង្គសាល ឬប្រព្រឹត្តអបាយមុខដទៃទៀត មានស្រា ស្រី ល្បែង បៀរប៉ោជាដើម ជនជំពូកនេះ ឈ្មោះថា លុះក្នុងអំណាចនៃចំណង(តណ្ហា) រកទីបំផុតគ្មាន ជនជំពូកនេះ មិនគ្រាន់តែធ្វើខ្លួនឯងឲ្យបាត់បង់ធនធាននិងកេរ្តិ៍ឈ្មោះប៉ុណ្ណោះទេ ថែមទាំងធ្វើខ្លួនឲ្យខូចសុខភាពកើតជំងឺចម្កាត់ផ្សេងៗជាពុំខាន។ ប្រសិនបើគេទប់ទល់ចំណង់ហួសប្រមាណរបស់គេបានខ្លះ ចេះអប់រំហ្វឹកហ្វឺនចិត្តគំនិតមិនឲ្យលុះទៅនៅក្រោមឥទ្ធិពលនៃកាមគុណខ្លាំងជ្រុលពេកទេ សុភមង្គលក៏អាចកើតចម្រើនឡើងដល់ខ្លួនគេខ្លះៗជាពុំខាន។ (នេះពោលតាមទស្សនៈផ្ទាល់របស់អាត្មា)។

ចំណែកសេចក្ដីពន្យល់តាមទស្សនៈពុទ្ធិយមវិញ ដូចព្រះអង្គបានត្រាស់សម្ដែងយ៉ាងពិស្ដារ ព្រមទាំងឧបមាឧបមេយ្យក្នុងមាគណ្ឌិយសូត្រស្រាប់។ ម្យ៉ាងទៀត ទ្រង់ប្រហែលជាបានជ្រាបឧបនិស្ស័យវាសនារបស់មាគណ្ឌិយបរិញ្វាជកជាមុនថា ដល់ទៅថ្ងៃក្រោយ គេមុខជានឹងបានសម្រេចមគ្គផលដល់ថ្នាក់លោកុត្តរៈក្នុងធម្មវិន័យនេះ។

ហេតុដូច្នេះហើយ បានជាព្រះអង្គទ្រង់ណែនាំគេឆ្ពោះសំដៅទៅរកឧត្តមគតិដ៏ខ្ពង់ខ្ពស់បំផុត គឺលោកុត្តរធម៌ (មគ្គផលនិព្វាន) ដែលជាគោលដៅចុងក្រោយបំផុត ក្នុងសាសនារបស់ព្រះអង្គ។

-លោកគ្រូម្ចាស់ បានអធិប្បាយពន្យល់មកនេះ ខ្ញុំករុណាអាចបានយល់គុណប្រយោជន៍នៃពុទ្ធភាសិតនេះ ទាំងខាងគតិលោក ទាំងខាងគតិធម៌ល្មមគួរសមដែរហើយ។ ចុះចំណែកខាងពុទ្ធភាសិតដែលត្រាស់សួរបរិព្វាជកនោះថា ភាវៈគ្មានរោគគឺអ្វី ? និព្វានគឺអ្វី ?

បរិព្វាជកនោះឆ្លើយតបដោយគេបានស្ទាបអង្អែលខ្លួនគេ ហើយទូលថា «បពិត្រព្រះគោតម ភាវៈគ្មានរោគគឺត្រង់នេះ និព្វានគឺត្រង់នេះ។ ឥឡូវនេះទូលបង្គំនៅជាសុខ ឥតមាន (ជំងឺ) អ្វីបៀតបៀនទូលបង្គំទេ»។

ត្រង់ពាក្យឆ្លើយតបនេះ គ្មានបញ្ជាក់ថា ទ្រង់ប្រឆាំងជំទាស់អ្វីទេ គ្រាន់តែទ្រង់លើកឧបមាដូចមនុស្សខ្វាក់ពីកំណើត ឥតដែលធ្លាប់ឃើញពណ៌អ្វី ឥតដែលឃើញដួងព្រះអាទិត្យ ដួងព្រះចន្ទជាដើមនោះ។ ត្រង់អត្ថន័យនៃពាក្យពីរឃ្លានេះ ព្រះអង្គឥតបានពន្យល់សោះ តើខនេះព្រោះហេតុអ្វី ?

-សូមញោមជ្រាបថា «ភាវៈគ្មានរោគនិងនិព្វាន» គឺជាលទ្ធផលនៃធម៌ជាន់ខ្ពស់ ដែលហៅថា លោកុត្តរធម៌ ដែលនឹងសម្រេចទៅដល់បាន ដោយសារការប្រតិបត្តិដ៏ត្រឹមត្រូវ តាមឱវាទរបស់លោកសប្បុរស មានព្រះពុទ្ធជាម្ចាស់និងសាវ័ករបស់ព្រះអង្គជាអាទិ៍។

ឯមធ្យោបាយដែលនឹងដើរទៅដល់គោលដៅដ៏ខ្ពង់ខ្ពស់នេះបាន ព្រះអង្គទ្រង់បានចង្អុលបង្ហាញផ្លូវ សម្រាប់ប្រើជាមធ្យោបាយសម្រាប់ឈោងឲ្យដល់លទ្ធផលដ៏ខ្ពង់ខ្ពស់នេះដែរ គឺអដ្ឋង្គិកមគ្គ (ផ្លូវមានអង្គ៨) ដែលព្រះអង្គត្រាស់ថា ជាមាគ៌ា មជ្ឈិមា បដិបទា (ផ្លូវប្រតិបត្តិជាកណ្តាលមិនតឹងពេក មិនធូរពេក) ដូចព្រះឧទានវាចាថា «អដ្ឋង្គិកោ មគ្គានំ ខេមំ អមតគាមិនី» បណ្តាផ្លូវទាំងឡាយ ផ្លូវប្រកបដោយអង្គ៨ ជាផ្លូវក្សេមក្សាន្ត ជាផ្លូវទៅដល់គោលដៅ

គឺអមតៈ (ការមិនស្លាប់)។

ហេតុអ្វីក៏ព្រះអង្គមិនទ្រង់ពន្យល់ន័យចំៗនៃពាក្យពីរឃ្លានេះ? ព្រោះពាក្យពីរឃ្លានេះ សំដៅយកធម្មជាតិតែមួយដូចគ្នា ដែលគេមិនអាចដឹងបានយល់ឃើញបាន ដោយគ្រាន់តែស្តាប់សេចក្តីពន្យល់ប៉ុណ្ណោះទេ។

ហេតុដូច្នេះហើយ នៅខាងចុងនៃព្រះសូត្រនេះ ព្រះអង្គត្រាស់ថា «ត្រូវអ្នកសេពគប់នឹងសប្បុរស ត្រូវស្តាប់ធម៌របស់សប្បុរស ត្រូវប្រតិបត្តិតាមធម៌របស់សប្បុរស ទើបអ្នកនឹងចេះដឹងដោយខ្លួនឯង ឃើញច្បាស់ដោយខ្លួនឯង កាលបើអ្នកលះបង់ឧបាទាន (ការប្រកាន់ខ្ជាប់) បានហើយ ភព ជាតិ ជរា ព្យាធិ មរណ សោក ទុក្ខ ទោមនស្ស ឧបាយាស ក៏នឹងរលត់រលាយអស់ទៅ ឈ្មោះថា កងទុក្ខទាំងអស់ក៏រលត់រលីងអស់ទៅដោយប្រការយ៉ាងនេះឯង»។

## មនុស្សលោកទាំងអស់ក្នុងលោកនេះ គ្មានអ្នកណាម្នាក់ដែលគេមិនតិះដៀល មិនរិះគន់សោះនោះទេ

មនុស្សគ្រប់រូបក្នុងលោកនេះ ទោះអ្នកមានក្តី អ្នកក្រក្តី អ្នកមានយសស័ក្តិ អ្នកឥតយសស័ក្តិក្តី អ្នកចេះដឹងក្តី អ្នកល្ងង់ខ្លៅក្តី សុទ្ធតែត្រូវគេតិះដៀល គេរិះគន់គ្រប់រូបឥតសល់ខានម្នាក់ឡើយ ប្លែកតែតិចនិងច្រើនជាងគ្នាប៉ុណ្ណោះ។ មិនតែមនុស្សសាមញ្ញទេ សូម្បីព្រះសម្មាសម្ពុទ្ធជាម្ចាស់ដែលជាអគ្គបុគ្គលកំពូលមនុស្សនិងទេវតា ក៏នៅតែមានអ្នកខ្លះតិះដៀលរិះគន់មិនខានដែរ។ សូមលើកយករឿងនិគ្រោធបរិព្វាជកមកបញ្ជាក់ក្នុងទីនេះ ដើម្បីឲ្យបានយល់ច្បាស់លាស់នូវអត្ថបទខាងដើម ដូចមានសេចក្តីសង្ខេបដូចតទៅនេះ ៖

# រឿងនិគ្រោធបរិព្វាជក

(ស្រង់ខ្លីៗ ពីឧទុម្ពរិកសូត្រ សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ
ព្រះត្រៃបិដកបាលីខ្មែរលេខទី១៦)

សម័យមួយ សន្ធានគហបតីទៅគាល់ព្រះដ៏មានបុណ្យ ប៉ុន្តែជួនជាពេលនោះ ព្រះពុទ្ធអង្គកំពុងតែសំងំនៅលើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ទើបសន្ធានគហបតីចូលទៅជួបនឹងនិគ្រោធបរិព្វាជក ក្នុងបរិព្វាជការាម នៅវេលាថ្ងៃរសៀលជាមុនសិន។ និគ្រោធបរិព្វាចកក្រឡេកទៅឃើញសន្ធានគហបតីដើរមកពីចម្ងាយលឹមៗ ក៏ប្រាប់កូនសិស្សទាំងបីពាន់នាក់ ដែលកំពុងតែស្រែកហ៊ោកញ្ជ្រៀវជជែកគ្នាពីតិរច្ឆានកថាជាច្រើនប្រការ (តិរច្ឆានកថានោះគឺ និយាយពីស្តេច ពីចោរ ពីមហាមាត្យ ពីសេនា ពីភ័យ ពីចម្បាំង ពីបាយ ពីទឹក ពីសំពត់ ពីទីដេក ពីកម្រងផ្កា ពីគ្រឿងក្រអូប ពីញាតិ ពីយាន ពីស្រុក ពីនិគម ពីជនបទ ពីក្រុង ពីស្ត្រី ពីបុរស ពីការផឹកសុរា ពីច្រកល្ហក ពីកំពង់ទឹក ពីរឿងផ្សេងៗ ដែលឥតប្រយោជន៍ ពីរឿងលោក (និយាយរឿងក្អែកស កុកក្រហមជាដើម) ពីសមុទ្រ ពីសេចក្តីចម្រើននិងសេចក្តីសាបសូន្យ ដែលជាហេតុឥតប្រយោជន៍ ថាដូច្នេះខ្លះ ដូច្នោះខ្លះ) គាត់ឃាត់សិស្សទាំងនោះថា ពួកអ្នកកុំស្រែកហ៊ោកញ្ជ្រៀវ កុំជជែកគ្នាឮខ្លាំងពេក ចូរនិយាយគ្នាឲ្យតិចៗ ដ្បិតសាវ័ករបស់ព្រះសមណគោតម ឈ្មោះសន្ធានគហបតីកំពុងដើរមករកយើងជិតដល់វត្តយើងហើយ មួយទៀត ពួកគ្រហស្ថជាសាវ័ករបស់ព្រះសមណគោតម ជាអ្នកមានសម្លៀកបំពាក់ស នៅអាស្រ័យក្នុងក្រុងរាជគ្រឹះ ពួកគេសុទ្ធតែត្រូវការមនុស្សមានសំឡេងតិច សរសើរតែមនុស្សមានសំឡេងតិច។

សន្ធានគហបតីដើរចូលទៅដល់ក្នុងវត្តនោះហើយ ក៏សំណេះសំណាលរាក់ទាក់ជាមួយនឹងនិគ្រោធបរិព្វាជក អង្គុយក្នុងទីដ៏សមគួរហើយនិយាយថា

ពួកបរិព្វាជកជាអន្យតិត្ថិយនេះជួបជុំគ្នាហើយ ស្រែកហៅឮខ្លាំងនិយាយតិរច្ឆានកថាជាច្រើនប្រការ។ ដោយឡែកព្រះដ៏មានព្រះភាគវិញ ព្រះអង្គទ្រង់គង់ក្នុងសេនាសនៈដ៏ស្ងាត់ ជាទីតាំងនៅក្នុងព្រៃស្រោង ជាសេនាសនៈមានសំឡេងសន្ធឹកគឹកកងតិច ប្រាសចាកពាក្យសម្ដីរបស់អ្នកផង សមគួរដល់ភាវៈស្ងប់ស្ងាត់របស់មនុស្ស គួរដល់ការលាក់ខ្លួនពួនអាត្មាបាន។

កាលបើសន្ធានគហបតីនិយាយយ៉ាងនេះហើយ និគ្រោធបរិព្វាជកឆ្លើយឡើងថា នែគហបតី ដូចជាយើងរិះគន់ព្រះសមណគោតម ចរចាជាមួយនឹងអ្នកណាបាន ធ្វើសាកច្ឆាជាមួយនឹងអ្នកណាកើត ល្បងភាពវាងវៃដោយប្រាជ្ញាជាមួយនឹងអ្នកណាដូចម្ដេចបាន ព្រោះប្រាជ្ញារបស់ព្រះសមណគោតមវិនាសបាត់ក្នុងផ្ទះស្ងាត់អស់ទៅហើយ ព្រះសមណគោតមជាបុគ្គលមិនហ៊ានចូលក្នុងជំនុំចំណោមបរិស័ទទេ មិនអាចចរចានឹងអ្នកដទៃបានទេ បានជាលោកចេះតែពួនសំងំនៅក្នុងសេនាសនៈដ៏ស្ងាត់ដូច្នោះ ប្រៀបដូចជាមេគោខ្វាក់ភ្នែកម្ខាង តែងត្រេចទៅតែក្នុងទីជុំវិញ ស្វែងរកតែទីស្ងាត់ម៉្យាងប៉ុណ្ណោះ (អដ្ឋកថាថា មេគោខ្វាក់ភ្នែកម្ខាងចូលចិត្តរកស៊ីខាងៗព្រៃ ព្រោះខ្លាចស្លឹកឈើ មែកឈើ ឬបន្លាប៉ះលើ មិនហ៊ាននៅក្នុងហ្វូង ព្រោះខ្លាចក្រែងប៉ះស្នែង ប៉ះត្រចៀក ឬកន្ទុយពួកគោដូចគ្នា) ដូចម្ដេចមិញ ប្រាជ្ញារបស់ព្រះសមណគោតម ក៏វិនាសបាត់អស់ទៅក្នុងផ្ទះស្ងាត់នោះហើយ ព្រះសមណគោតមមិនចូលមករកបរិស័ទនេះទេ មិនគួរនឹងសំណេះសំណាលបានទេ លោកចូលចិត្តអាស្រ័យនៅតែក្នុងសេនាសនដ៏ស្ងាត់ដូច្នោះឯង។ នែគហបតី ល្បងមើលចុះ ប្រសិនបើព្រះសមណគោតមហ៊ានចូលមករកបរិស័ទនេះ ពួកយើងនឹងសាកសួរលោកមួយប្រស្នា ល្បងមើលដែរ ពួកយើងនឹងចាប់បង្វិលព្រះសមណគោតមនោះឲ្យវិលខ្វាល់ ដូចជាគេចាប់បង្វិលឆ្នាំងទទេមិនខាន។

គ្រានោះ ព្រះដ៏មានបុណ្យទ្រង់ជ្រាបពាក្យឆ្លើយឆ្លងរបស់សន្ធានគហបតី និងនិគ្រោធបរិព្វាជក ដោយសោតធាតុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវសោត

ធាតុរបស់មនុស្សសាមញ្ញ ទើបព្រះអង្គស្តេចចុះអំពីភ្នំគិជ្ឈកូដ ហើយយាងទៅឯមោរនិវាបស្ថាន គឺកន្លែងសម្រាប់ឲ្យចំណីដល់សត្វក្ងោកក្បែរឆ្នេរស្រះឈ្មោះសុមាគធា លុះចូលទៅជិតហើយ ក៏ទ្រង់ចង្ក្រមក្នុងទីវាលក្បែរឆ្នេរស្រះនោះ។

ឯនិគ្រោធបរិព្វាជកបានឃើញព្រះពុទ្ធអង្គទ្រង់ចង្ក្រមក្នុងទីជិតនោះហើយ ក៏ហាមប្រាមពួកបរិស័ទរបស់ខ្លួនថា សូមអ្នកទាំងអស់មានសំឡេងតិចៗ កុំជជែកគ្នាឲ្យឮសូរខ្លាំងពេក នេះព្រះសមណគោតមកំពុងតែចង្ក្រមក្នុងទីវាលនោះ ដ្បិតលោកដ៏មានអាយុនោះ ត្រូវការតែអ្នកមានសំឡេងតិចៗ សរសើរតែអ្នកមានសំឡេងតិចៗ យើងធ្វើដូចម្តេចឲ្យលោកជ្រាបថា បរិស័ទនេះមានសំឡេងតិច ហើយលោកគួរចូលមករកពួកយើង ប្រសិនបើ ព្រះសមណគោតមហ៊ានចូលមករកបរិស័ទនេះមែន ពួកយើងត្រូវសួរប្រស្នានឹងលោកថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ទូន្មានសាវ័កដោយធម៌ឯណា ពួកសាវ័កដែលព្រះអង្គទ្រង់ទូន្មានដោយធម៌ឯណា ហើយដល់នូវសេចក្តីត្រេកអរ បានបំពេញអរិយមគ្គជាព្រហ្មចរិយធម៌ដើម ជាធម៌ឲ្យកើតនិស្ស័យដ៏ឧត្តម ធម៌របស់ព្រះអង្គនោះ តើឈ្មោះដូចម្តេច។

លំដាប់នោះ ព្រះដ៏មានបុណ្យទ្រង់ស្តេចចូលទៅត្រង់កន្លែង ដែលនិគ្រោធបរិព្វាជកនៅ។ និគ្រោធបរិព្វាជកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គស្តេចចូលមក ព្រះអង្គស្តេចមកប្រពៃហើយ សូមព្រះអង្គស្តេចគង់ចុះ នេះជាអាសនៈដែលខ្ញុំព្រះអង្គបានក្រាលបម្រុងទុកស្រេចហើយ។ ព្រះសម្ពុទ្ធទ្រង់គង់លើអាសនៈនោះ ចំណែកនិគ្រោធបរិព្វាជកក៏ប្រកាន់យកអាសនៈទាបមួយ ហើយអង្គុយតាមទីដ៏សមគួរ។

ព្រះមហាមុនីទ្រង់ត្រាស់សួរនិគ្រោធបរិព្វាជកថា ម្នាលនិគ្រោធអំបាញមិញនេះ អ្នកអង្គុយប្រជុំគ្នានិយាយពីរឿងអ្វី សម្តីដូចម្តេចដែលពួកអ្នកឈប់បង្អង់ពាក់កណ្តាល។

និគ្រោធបរិព្វាជកក្រាបទូលរៀបរាប់តាំងពីកាលខ្លួនហាមប្រាមពួកបរិស័ទ

រហូតដល់ប្រស្នាដែលខ្លួនប្រុងនឹងទូលសួរ តាមសម្ដីខ្លួននិយាយខាងដើមគ្រប់ម៉ាត់ ឥតកាត់រំលងចោលមួយម៉ាត់ឡើយ។

ព្រះភគវន្តទ្រង់ត្រាស់ថា ម្នាលនិគ្រោធ តថាគតទូន្មានសាវ័កដោយធម៌ឯណា ពួកសាវ័កពេញចិត្តបំពេញអរិយមគ្គ ជាព្រហ្មចរិយធម៌ដើម ដែលឲ្យកើតនិស្ស័យដ៏ឧត្ដម អ្នកឯងមានទិដ្ឋិដោយឡែក មានសេចក្ដីពេញចិត្តដោយឡែក មិនងាយនឹងដឹងធម៌នោះបានទេ វៀរលែងតែអ្នកព្យាយាមខ្លាំងក្លា វៀរលែងតែអ្នកបានរៀនក្នុងសំណាក់អាចារ្យនោះទើបដឹងបាន ម្នាលនិគ្រោធ អញើញអ្នកសួរប្រស្នាក្នុងការខ្ពើមបាប ជាអាចរិយវាទរបស់ខ្លួននឹងតថាគតថា ការខ្ពើមបាបដោយសេចក្ដីព្យាយាម ជាគ្រឿងដុតកិលេសដូចម្ដេចឈ្មោះថា បរិបូណ៌ ដូចម្ដេចឈ្មោះថា មិនបរិបូណ៌។

កាលព្រះសុគតទ្រង់ត្រាស់យ៉ាងនេះហើយ ពួកបរិព្វាជកទាំងនោះក៏នាំគ្នាស្រែកហ៊ោឰខ្លាំងថា នែអ្នកដ៏ចម្រើន គួរអស្ចារ្យណាស់តើ ហេតុអ្វីមិនដែលមានសោះ ព្រះសមណគោតមព្រះអង្គមានឫទ្ធិច្រើន មានអានុភាពខ្លាំង ព្រោះទ្រង់បញ្ឈប់វាទៈរបស់ព្រះអង្គ ទ្រង់បណ្ដោយឲ្យអ្នកដទៃនិយាយវិញ។

និគ្រោធបរិព្វាជកបានទូលស្នើព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គ ជាតបោជិគុច្ឆវាទ គឺអ្នកពោលប្រកាន់ការខ្ពើមបាបដោយព្យាយាមជាគ្រឿងដុតកិលេស ជាអ្នកមិនរុញរានឹងតបោជិគុច្ឆវត្ត បពិត្រព្រះអង្គដ៏ចម្រើន ការខ្ពើមបានដោយព្យាយាម ជាគ្រឿងដុតកិលេស ដូចម្ដេចទើបឈ្មោះថា បរិបូណ៌ ដូចម្ដេចទើបថា មិនបរិបូណ៌។

ព្រះសាស្ដាទ្រង់ត្រាស់ថា ម្នាលនិគ្រោធ មនុស្សបំពេញព្យាយាមជាគ្រឿងដុតកិលេសក្នុងលោកនេះជាអ្នកអាក្រាតកាយលះបង់ចោលមារយាទល្អ ប្រកាន់ហត្ថាវលេខនបដិបត្តិ(អដ្ឋកថាថា សំដៅយកការបរិភោគលិទ្ធដៃ ឬថាវេលាបន្ទោបង់ឧច្ចារៈរួចហើយ ជូតជម្រះផ្ទាល់នឹងដៃ។ មហាសីហនាទសូត្រ) ជាអ្នកប្រកាន់វត្តដែលគេនិមន្តថា លោកដ៏ចម្រើន សូមចូលមកទទួលភត្ត ហើយមិន

ចូលមក។បេ។ កាលព្រះសព្វញ្ញូទ្រង់សម្តែងតបោជិគុច្ឆវត្ត ដោយអនេក បរិយាយហើយ ពួកបរិព្វាជកទាំងនោះក៏នាំគ្នាស្រែកហ៊ោកងរំពងឡើងថា ពួកយើងដែលជាអ្នករួមអាចារ្យផងគ្នា មិនដែលឃើញដំណើរនេះសោះឡើយ ពួកយើងមិនធ្លាប់ដឹងឲ្យលើសជាងនេះទៅទៀតទេ។

ពេលនោះ សន្ធានគហបតីបានដឹងថា ឥឡូវនេះពួកបរិព្វាជក ជាអន្យតិត្ថិយទាំងនេះ កំពុងប្រុងស្តាប់ភាសិតព្រះពុទ្ធអង្គ ត្រងត្រាប់សោតប្បសាទតម្កល់ចិត្តមិនឲ្យរាយមាយដោយពិតប្រាកដ ដូច្នោះហើយទើបនិយាយនឹងនិគ្រោធបរិព្វាជក បពិត្រនិគ្រោធ លោកបាននិយាយនឹងខ្ញុំពីមុនរួចមកហើយថា នែគហបតី ដូចជាយើងរិះគន់ អ្នកត្រូវដឹងថា ព្រះសមណគោតមចរចាជាមួយនឹងអ្នកណាបាន។បេ។ ពួកយើងនឹងចាប់បង្វិលព្រះសមណគោតមឲ្យវិលខ្វាល់ ដូចជាគេចាប់បង្វិលឆ្នាំងទទេមិនខាន បពិត្រលោកដ៏ចម្រើន ស្រាប់តែព្រះអង្គស្តេចមកដល់ទីនេះតែម្តងតើឥឡូវនេះដល់ហើយចូរលោកធ្វើព្រះអង្គឲ្យជាអ្នកមិនហ៊ានចូលមករកបរិស័ទចុះ ឲ្យដូចជាមេគោខ្វាក់ភ្នែកម្ខាងចុះ ចូរលោកសាកសួរព្រះអង្គមួយប្រស្នាចុ ចូរលោកបង្វិលព្រះអង្គឲ្យដូចជាគេចាប់បង្វិលឆ្នាំងទទេចុះ។ កាលសន្ធានគហបតីនិយាយយ៉ាងនេះហើយ និគ្រោធបរិព្វាជកអង្គុយតែនៅស្ងៀមឈឹង ឥតឆ្លើយមួយម៉ាត់សោះ អៀនខ្មាសឱនមុខជ្រប់ស្រពោនទាល់ប្រាជ្ញា។

សម្តេចព្រះលោកុត្តមាចារ្យ ទ្រង់ជ្រាបអាការៈរបស់និគ្រោធបរិព្វាជកដូច្នោះហើយ ក៏ត្រាស់សួរថា ម្នាលនិគ្រោធ សម្តីនេះអ្នកបាននិយាយមែនឬទេ? ខ្ញុំព្រះអង្គបាននិយាយសម្តីនេះពិតមែនហើយ តាមដែលខ្ញុំព្រះអង្គជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស។

ម្នាលនិគ្រោធ អ្នកធ្លាប់បានឮពួកបរិព្វាជកព្រឹទ្ធាចារ្យ មានអាយុច្រើនជាអាចារ្យប្រធានលើអាចារ្យនិយាយថា ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយឯណា ក្នុងកាលកន្លងទៅហើយ ព្រះសម្មាសម្ពុទ្ធទាំងនោះ ទ្រង់ជួបជុំសមាគម

ហើយបន្លឺសំឡេងស្រែកហ៊ោព្ទខ្លាំង និយាយតិរច្ឆានកថាច្រើនយ៉ាង ដូចជាអ្នករួមអាចារ្យផងគ្នាក្នុងកាលឥឡូវនេះ យ៉ាងនេះដែរឬទេ ?

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនធ្លាប់ឮសម្ដីយ៉ាងនេះទេ ខ្ញុំព្រះអង្គធ្លាប់តែឮថា ព្រះសម្មាសម្ពុទ្ធទាំងឡាយក្នុងកាលកន្លងទៅហើយ ព្រះអង្គទាំងនោះ តែងអាស្រ័យតែសេនាសនៈដ៏ស្ងាត់ក្នុងព្រៃស្រោង មានសំឡេងសន្ធឹកគឹកកងតិច ប្រាសចាកសម្ដីអ្នកផង សមគួរដល់ការស្ងប់ស្ងាត់របស់មនុស្ស គួរដល់ការលាក់ខ្លួនពួនអាត្មាបាន ដូចជាព្រះអង្គក្នុងកាលឥឡូវនេះដែរ។

គ្រានោះ និគ្រោធបរិព្វាជកដឹងកំហុសរបស់ខ្លួនហើយ ក៏ក្រាបទូលសូមខមាទោសចំពោះព្រះបរមគ្រូ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា អើនិគ្រោធ ពាក្យសម្ដីដែលអ្នកតិះដៀលរិះគន់តថាគតទាំងប៉ុន្មាននោះ ជាកំហុសរបស់អ្នកពិតមែនហើយ តថាគតអត់ទោសឲ្យអ្នកហើយ។

ជីវិតនៃមនុស្សណាសូម្បីតាំងនៅតែមួយខណៈតែមិនប្រាសចាកការចេះដឹង សេចក្ដីព្យាយាមអង់អាច និងកេរ្តិ៍ឈ្មោះយសស័ក្តិ អ្នកប្រាជ្ញពោលថា ជីវិតនៃមនុស្សនោះពេញជាជីវិតដ៏ប្រសើរនៅនាលោកនេះ។ ( ស្រីហិតោបទេស )

# គោលការណ៍នៃជីវិត

## មហាមង្គលសូត្រ

(សុត្តន្តបិដក សុត្តនិបាត តតិយភាគ គម្ពីរលេខ៥៤)

មហាមង្គលសូត្រ គឺជាគោលការណ៍នៃជីវិត ដើម្បីសម្រេចឲ្យបានជ័យមង្គល ក្នុងការរស់នៅប្រកបដោយសេចក្ដីសុខ សុភមង្គល និងជោគជ័យទាំងសម្រាប់ខ្លួនឯង ទាំងសម្រាប់មនុស្សដទៃឯទៀត ដែលកំពុងរស់នៅជាមួយគ្នានៅក្នុងលោកយើងនេះ។

គេអាចយកគោលធម៌ទាំង៣៨ប្រការនេះ មកអនុវត្តមួយជំហានម្ដងមួយជំហាន ពីងាយទៅលំបាក។ ប្រការនីមួយៗនាំមកនូវការចម្រើនខាងអភិសមាចារ និងខាងសីលធម៌កាន់តែខ្ពស់ឡើងៗជាលំដាប់។

ប្រការទាំង៣៨ នេះមានលក្ខណៈជាសាកល ដែលនរណាក៏អាចទទួលយកបានយ៉ាងងាយ និងអាចអនុវត្តបានក្នុងពេលដែលគេម្នាក់ៗកំពុងជាប់រវល់ក្នុងការងារប្រចាំថ្ងៃរបស់គេ ព្រមទាំងអាចមើលឃើញនូវការរីកចម្រើននៃសេចក្ដីសុខពិតប្រាកដនៅក្នុងចិត្តគំនិតរបស់ខ្លួន ដោយមិនប្រកាន់ជាតិសាសន៍ណា ភាសាណា និងជំនឿសាសនាឡើយ។

មង្គលទាំង៣៨ប្រការនេះ ចែកចេញជា១០ក្រុមយ៉ាងដូច្នេះគឺ ៥ក្រុមខាងដើម មាន១៨ប្រការដែលជាជំហានដំបូង ដើម្បីអប់រំខ្លួនឲ្យក្លាយទៅជាមនុស្សល្អក្នុងសង្គម។ ក្នុងនេះដែរ ក៏មានការរីកចម្រើនខាងការទទួលខុសត្រូវក្នុងសង្គម និងការទទួលខុសត្រូវផ្ទាល់ខ្លួនម្នាក់ៗ។

ឯ ៥ក្រុមខាងក្រោយមាន២០ប្រការគឺ ចាប់ពីមង្គលទី១៩ ដល់ ៣៨ គឺជាកម្រិតថ្នាក់ខ្ពស់នៃការអនុវត្តខាងសីលធម៌ សម្រាប់ជនទាំងឡាយណាដែលមានបំណង សម្រេចថ្នាក់ខ្ពស់បំផុតខាងជំនឿនិងសាសនារបស់ខ្លួន។

# គោលការណ៍នៃជីវិត

## មហាមង្គលសូត្រ

(សុត្តន្តបិដក សុត្តនិបាត តតិយភាគ គម្ពីរលេខ៥៤)

មហាមង្គលសូត្រ គឺជាគោលការណ៍នៃជីវិត ដើម្បីសម្រេចឲ្យបានជ័យមង្គល ក្នុងការរស់នៅប្រកបដោយសេចក្ដីសុខ សុភមង្គល និងជោគជ័យទាំងសម្រាប់ខ្លួនឯង ទាំងសម្រាប់មនុស្សដទៃឯទៀត ដែលកំពុងរស់នៅជាមួយគ្នានៅក្នុងលោកយើងនេះ។

គេអាចយកគោលធម៌ទាំង៣៨ប្រការនេះ មកអនុវត្តមួយជំហានម្ដងមួយជំហាន ពីងាយទៅលំបាក។ ប្រការនីមួយៗនាំមកនូវការចម្រើនខាងអភិសមាចារ និងខាងសីលធម៌កាន់តែខ្ពស់ឡើងៗជាលំដាប់។

ប្រការទាំង៣៨ នេះមានលក្ខណៈជាសាកល ដែលនរណាក៏អាចទទួលយកបានយ៉ាងងាយ និងអាចអនុវត្តបានក្នុងពេលដែលគេម្នាក់ៗកំពុងជាប់រវល់ក្នុងការងារប្រចាំថ្ងៃរបស់គេ ព្រមទាំងអាចមើលឃើញនូវការរីកចម្រើននៃសេចក្ដីសុខពិតប្រាកដនៅក្នុងចិត្តគំនិតរបស់ខ្លួន ដោយមិនប្រកាន់ជាតិសាសន៍ណា ភាសាណា និងជំនឿសាសនាឡើយ។

មង្គលទាំង៣៨ប្រការនេះ ចែកចេញជា១០ក្រុមយ៉ាងដូច្នេះគឺ ៥ក្រុមខាងដើម មាន១៨ប្រការដែលជាជំហានដំបូង ដើម្បីអប់រំខ្លួនឲ្យក្លាយទៅជាមនុស្សល្អក្នុងសង្គម។ ក្នុងនេះដែរ ក៏មានការរីកចម្រើនខាងការទទួលខុសត្រូវក្នុងសង្គម និងការទទួលខុសត្រូវផ្ទាល់ខ្លួនម្នាក់ៗ។

ឯ ៥ក្រុមខាងក្រោយមាន២០ប្រការគឺ ចាប់ពីមង្គលទី១៩ ដល់ ៣៨ គឺជាកម្រិតថ្នាក់ខ្ពស់នៃការអនុវត្តខាងសីលធម៌ សម្រាប់ជនទាំងឡាយណាដែលមានបំណង សម្រេចថ្នាក់ខ្ពស់បំផុតខាងជំនឿនិងសាសនារបស់ខ្លួន។

## ក្រុមទី១ ការមិនប្រព្រឹត្តអំពើបាប

១- កិរិយាមិនសេពគប់នឹងបុគ្គលពាលទាំងឡាយ (ការចម្រើនការប្រុងប្រយ័ត្ន) តើគួរឬពុំគួរ ? (តើត្រូវជ្រើសរើសមិត្តសម្លាញ់យ៉ាងណា ? ដូចម្ដេចហៅថាមនុស្សឃោរឃៅ ? តើត្រូវដកខ្លួនឲ្យឆ្ងាយពីមនុស្សឃោរឃៅរបៀបណា ? )។

២- កិរិយាសេពគប់តែនឹងបណ្ឌិតទាំងឡាយ គឺធ្វើខ្លួនឲ្យក្លាយជាមនុស្សល្អ (តើយ៉ាងដូចម្ដេចដែលហៅថាបណ្ឌិត ? តើការសេពគប់នឹងមនុស្សល្អបានប្រយោជន៍ដូចម្ដេចខ្លះ ? )។

៣- កិរិយាគោរពបូជាដល់បុគ្គល ដែលគួរគោរពបូជាទាំងឡាយ។ ក្រុមទីមួយនេះ ទាក់ទងទៅនឹងការព្យាយាមប្រុងប្រយ័ត្នចំពោះអ្វីដែលគួរ អ្វីដែលមិនគួរ ទាក់ទងនឹងការយល់ដឹងច្បាស់ដោយខ្លួនឯងថា អ្វីត្រូវ អ្វីខុស។ ទោះបីមានកម្រិតចំណេះដឹងខ្ពស់ហើយក្ដី ប៉ុន្តែបើការជ្រើសរើសរបស់ខ្លួនមិនត្រឹមត្រូវនោះ ក៏អនាគតរបស់ខ្លួនមិនបានទទួលផលល្អដែរ។ ផ្ទុយទៅវិញ អ្នកដែលចេះបែងចែកល្អ និងអាក្រក់ច្បាស់លាស់ ទោះបីមានចំណេះដឹងទាបក្ដី ក៏យ៉ាងហោចណាស់ អ្នកទាំងនោះមិនបានធ្វើអ្វីនាំអំពល់ដល់សង្គមដែរ។ នេះគឺជាសម្មាទិដ្ឋិ គឺការយល់ដឹងត្រូវ។

## ក្រុមទី២ ការស្វែងរកសេចក្ដីល្អ (បុណ្យ)

៤- កិរិយារស់នៅក្នុងទីដ៏សមគួរ រស់នៅដោយគ្មានអាថ៌កំបាំង។

៥- ភាវៈជាអ្នកបានធ្វើបុណ្យទុកហើយក្នុងអតីតកាល។ បុណ្យដែលបុគ្គលធ្វើឲ្យក្នុងបច្ចុប្បន្នកាលនាំឲ្យបានផលល្អក្នុងជីវិតទៅអនាគត។ បុណ្យ គឺអំពើល្អនេះកើតឡើងដោយវិធី៣យ៉ាងគឺ ការបំផ្លាញចោលឲ្យអស់នូវសេចក្ដីកំណាញ់ បង្ការកុំឲ្យអំពើបាបកើតឡើង និងការអប់រំខ្លួនឯងឲ្យកើតសេចក្ដីនឹងនក្នុងចិត្ត គឺធ្វើសមាធិ។

៦- កិរិយាតម្កល់ខ្លួនដោយប្រពៃ នៅក្នុងជីវិតរស់នៅរបស់ខ្លួន។

ក្រុមទីពីរនេះ ទាក់ទងទៅនឹងការពង្រីងបុណ្យកុសល ដែលម្នាក់ៗបានសម្រេចជ្រើសរើសយក ឲ្យទៅតាមបរិដ្ឋានសង្គមដែលអ្នកទាំងនោះរស់នៅដោយទម្លាប់ ដែលម្នាក់ៗធ្លាប់បានធ្វើល្អចំពោះខ្លួនយើងក្នុងអតីតកាល និងដោយតម្កល់ខ្លួនឲ្យប្រពៃចំពោះគោលបំណងនៃជីវិតទៅអនាគត។

## ក្រុមទី៣ ការរស់នៅឲ្យមានប្រយោជន៍ (ដល់សង្គម)

៧- ភាវៈជាបុគ្គលដែលបានស្តាប់ បានរៀនសូត្រច្រើនហើយ។

៨- ភាវៈជាបុគ្គលមានសិល្បសាស្ត្រ គឺសេចក្តីឆ្លៀវឆ្លាសក្នុងការងារសព្វសារពើក្នុងការទាក់ទងគ្នា ក្នុងការត្រិះរិះពិចារណា។

៩- ភាវៈជាបុគ្គលបានសិក្សាអំពីវិន័យ និងមានសណ្តាប់ធ្នាប់ដោយខ្លួនឯងព្រមទាំងដឹងច្បាស់ដោយខ្លួនឯងថា ត្រូវរស់នៅយ៉ាងណាឲ្យសមស្របនឹងសង្គមរបស់ខ្លួន ពោលគឺត្រូវមានវិន័យផ្ទាល់ខ្លួន។

១០- ភាវៈជាបុគ្គលដែលមានវាចាពីរោះថ្លៃថ្នូរ និងពោលតែពាក្យត្រឹមត្រូវ សមទៅតាមកាលវេលា។ ក្រុមទីបីនេះទាក់ទងនឹងប្រការដែលថា តើយើងម្នាក់ៗគប្បីរួមវិភាគទានអ្វីខ្លះដល់សង្គម តាមរយៈការប៉ិនប្រសប់របស់យើងដើម្បីកុំឲ្យយើងនេះក្លាយទៅជាបន្ទុកដ៏ធ្ងន់របស់សង្គម ហើយទន្ទឹមនឹងនេះដែរ គឺធ្វើខ្លួនយើងក្លាយជាទីពំនាក់របស់យើងផ្ទាល់នៅក្នុងការប្រកបរបស់ចិញ្ចឹមជីវិត។

## ក្រុមទី៤ សុខដុមភាពក្នុងគ្រួសារ

១១- កិរិយាទំនុកបម្រុងមាតាបិតារបស់ខ្លួន។

១២- សេចក្តីសង្គ្រោះដលបុត្រធីតា។

១៣- សេចក្តីសង្គ្រោះដល់ស្វាមីភរិយា។

១៤- មិនទុកការងារឲ្យប្រប្រូកប្រួចប្រួល ឬពុំបានធ្វើឲ្យហើយរួចរាល់។

ក្រុមទី៤នេះ ឈានពីសមត្ថភាពក្នុងការជួយខ្លួនឯង ឆ្ពោះទៅជួយអ្នកដទៃថែមទៀត។ ក្រុមជនដែលយើងត្រូវជួយទំនុកបម្រុងមុនគេនោះ គឺជនដែលជាមាតាបិតារបស់យើង។ ក្រុមជនទី២ដែលយើងមានភារកិច្ចត្រូវតែជួយទំនុកបម្រុងនោះ មានបុត្រភរិយារបស់យើង។ លើសពីនេះទៀត យើងត្រូវតែបែងចែកពេលវេលារបស់យើងឲ្យបានច្បាស់លាស់ ដើម្បីកុំឲ្យភ្លេចការទទួលខុសត្រូវរបស់យើង នៅកន្លែងប្រកបការងាររបស់យើង និងនៅក្នុងគ្រួសាររបស់យើងផង។

## ក្រុមទី៥ ធ្វើខ្លួនឲ្យក្លាយជាសសរទ្រូងរបស់សង្គម

១៥- កិរិយាបរិច្ចាគទាន។

១៦- កិរិយាប្រព្រឹត្តនូវធម៌ ( សីលធម៌ ) គឺធ្វើតែអំពើល្អ។

១៧- សេចក្តីសង្គ្រោះដល់ញាតិទាំងឡាយ តើនរណាខ្លះដែលយើងគប្បីជួយ? តើគប្បីជួយតាមរបៀបណា? តើគប្បីជួយនៅពេលណា?

១៨- ប្រកបការងារទាំងឡាយដែលមិនមានទោស។ ចំណុចសំខាន់ដែលត្រូវយកចិត្តទុកដាក់នោះគឺ អ្វីដែលខុស អ្វីដែលត្រូវ។

ក្រុមទី៥នេះ ទាក់ទងនឹងការពង្រឹងគុណធម៌ដែលយើងបានកសាងរួចហើយសម្រាប់ខ្លួនយើងនៅក្នុងផ្ទះ រួចពង្រាយគុណធម៌របស់ខ្លួនឲ្យជំឡើងគ្រប់ទៅលើសង្គម ដោយបរិច្ចាគទាននិងកិច្ចការសាធារណៈ។ ប្រសិនបើយើងរស់នៅក្នុងជីវិតប្រកបដោយវិន័យ សណ្តាប់ធ្នាប់ហើយ នោះយើងប្រាកដជាអាចធ្វើអ្វីមួយ ដែលមានប្រយោជន៍ដល់សង្គមមិនខានឡើយ។ ជនណាដែលសាកល្បងជួយកិច្ចការសង្គម នៅពេលដែលខ្លួនពុំបានរៀបចំខ្លួនឲ្យមានបុគ្គលិកលក្ខណៈល្អ និងវិន័យច្បាស់លាស់ ជននោះអាចនឹងបង្កើតឲ្យមានមហន្តរាយដល់អ្នកដទៃច្រើនជាងជួយអ្នកដទៃ។ ជនដែល

ចង់ឲ្យដំបូន្មានគេ តែមិនអាចនិយាយពាក្យគួរសមបាន ជននោះនឹងបង្កើត សត្រូវ ជាជាងការពង្រឹងគុណភាពសង្គម។ ដូច្នេះ ចូរកុំអាលបំភ្លេចពរសព្វ សាធុការពីមុនៗមក មុនពេលដែលយើងមិនទាន់ទទួលបានផលសម្រេច កម្រិតណាមួយ ពីអ្វីដែលយើងខំប្រឹងហ្វឹកហាត់ឲ្យសោះ។

## ក្រុមទី៦ ការត្រៀមខ្លួនដើម្បីសុក្រឹត្យភាព

១៩- កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប។

២០- សេចក្តីសង្រួមចាកកិរិយាសេពនូវគ្រឿងញៀននិងទឹកស្រវឹង។

២១- សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ គឺសេចក្តីភ្ញាក់រឭកក្នុងការធ្វើតែអំពើល្អដើម្បីឲ្យបានផលល្អ។

ក្រុមទី៧ អនុវត្តន៍ខាងអភិសមាចារ ជាមូលដ្ឋាន

២២- សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព។

២៣- កិរិយាប្រព្រឹត្តបន្ទាបខ្លួន។

២៤- សេចក្តីត្រេកអរចំពោះរបស់ដែលខ្លួនមាន។

២៥- ភាវៈនៃបុគ្គល អ្នកដឹងនូវឧបការៈដែលអ្នកដទៃបានធ្វើដល់ខ្លួន។

២៦- កិរិយាស្តាប់នូវធម៌ ( ការទទួលយកពាក្យប្រដៅរបស់ព្រះពុទ្ធ ) តាមកាលឲ្យបានទៀងទាត់។

## ក្រុមទី៨ ការប្រព្រឹត្តដើម្បីឲ្យកាន់តែល្អប្រសើរឡើងថែមទៀត

២៧- សេចក្តីអត់ធន់ ( ខន្តិ )។

២៨- ភាវៈជាបុគ្គលដែលគេប្រដៅបានដោយងាយ គឺការភ្ញាក់រឭកកែលម្អដើម្បីការរីកចម្រើនដោយខ្លួនឯង។

២៩- កិរិយាបានឃើញ បានជួប និងបានរៀនសូត្រពីសមណៈទាំងឡាយ ពោលគឺបុគ្គលដែលបានសម្រេចហើយនូវសុក្រឹត្យភាព ( បារមី )។

៣០- ធម្មសាកច្ឆា គឺកិរិយាសន្ទនាទៅវិញទៅមក នូវធម៌តាមកាលឲ្យបានទៀងទាត់។

## ក្រុមទី៩ កម្ចាត់បង់នូវហេតុដែលនាំទុក្ខសោក ចេញពីចិត្តគំនិតរបស់ខ្លួន

៣១- សេចក្តីព្យាយាមដុតកម្ទេចនូវបាបធម៌ចោលឲ្យអស់ ការដឹងច្បាស់នូវអ្វីដែលនាំឲ្យសៅហ្មងដល់ចិត្តគំនិត។

៣២- កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ។

៣៣- កិរិយាឃើញនូវអរិយសច្ចៈទាំងឡាយ គឺឃើញនូវទុក្ខ ហេតុដែលនាំឲ្យមានទុក្ខ ការរំលត់ទុក្ខ និងមាគ៌ាប្រតិបត្តិដើម្បីរំលត់ទុក្ខ។

៣៤- កិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺការឈានឆ្ពោះទៅសម្រេចព្រះនិព្វាន។

## ក្រុមទី១០ លទ្ធផលទទួលបានពីការបន្សុទ្ធចិត្តគំនិត

៣៥- ចិត្តមិនរំភើបញាប់ញ័រនឹងលោកធម៌ទាំងឡាយ។

៣៦- មិនមានសេចក្តីសោក។

៣៧- ការរួចរំដោះពីការប្រឡាក់ទៅដោយធូលី គឺរាគៈ។

៣៨- មានចិត្តក្សេមក្សាន្ត។

# ពាលសូត្រ

«បុរសស្ត្រីនឹងបាត់បង់ភាពជាមនុស្ស
កាលណាបើរស់ប្រាសចាកសីលធម៌»

## សេចក្តីថា

ខ្ញុំអានន្ទបានស្តាប់មកហើយយ៉ាងនេះ។ សម័យមួយព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ កាលព្រះអង្គគង់នៅវត្តនោះ បានត្រាស់ហៅភិក្ខុទាំងឡាយ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាថា ព្រះករុណាព្រះអង្គ។

ព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមានហេតុជាគ្រឿងចំណាំថា «ពាល» មានចរិតជា «ពាល» ៣យ៉ាងគឺ បុគ្គលពាលក្នុងលោកនេះ ជាអ្នកគិតគំនិតអាក្រក់១ និយាយសម្តីអាក្រក់១ ធ្វើអំពើអាក្រក់១ (កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត)។ ប្រសិនបើបុគ្គលពាលជាអ្នកមិនគិតគំនិតអាក្រក់ផង មិននិយាយអាក្រក់ផង មិនធ្វើអំពើអាក្រក់ផងទេ តើពួកបណ្ឌិតណានឹងស្គាល់គេថា អ្នកដ៏ចម្រើននេះជាមនុស្សពាល ជាអសប្បុរសដូច្នេះបាន។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលតែងជាអ្នកគិតអាក្រក់ផង និយាយអាក្រក់ផង ធ្វើអាក្រក់ផង ព្រោះហេតុណា ព្រោះហេតុនោះបានជាបណ្ឌិតទាំងឡាយស្គាល់គេថា អ្នកនេះជាពាល ជាអសប្បុរសបាន។ បុគ្គលពាលនោះឯង តែងទទួលទុក្ខទោមនស្ស៣យ៉ាងក្នុងបច្ចុប្បន្ននេះ។

ម្នាលភិក្ខុទាំងឡាយ បើបុគ្គលពាលអង្គុយក្នុងសាលាក្តី ក្នុងចក្រក្តី ក្នុងផ្លូវបែកជា៤ក្តី ចំណែកអ្នកផងអង្គុយក្នុងបរិស័ទនោះតែងប្រឹក្សាពាក្យ (ថ្លែងអំពីទោស) ដែលកើតអំពីអំពើនោះ សមគួរដលអំពើនោះ (ប្រឹក្សាអំពីទោសរបស់បញ្ចវេរា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននិងបរលោក។ អដ្ឋកថា។)។

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលពាលជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម និយាយកុហក មានសេចក្តីប្រមាទ។ បុគ្គលពាលតែងគិតក្នុងពាក្យដែលអ្នកផងតែងប្រឹក្សានោះថា «ធម៌ទាំងឡាយនោះក៏មាននៅក្នុងអញផង ខ្លួនអញសោត ក៏ប្រាកដក្នុងធម៌ទាំងនោះផង»។ បុគ្គលពាលតែងទទួលទុក្ខតូចចិត្តទី១នេះក្នុងបច្ចុប្បន្ន។

ម្យ៉ាងទៀត បុគ្គលពាល ឃើញព្រះរាជាទាំងឡាយ កាលចាប់ចោរបានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មផ្សេងៗគឺ ឲ្យវាយដោយរំពាត់ខ្លះ ដោយដំបងខ្លះ ឲ្យកាត់ដៃខ្លះ ជើងខ្លះ ស្លឹកត្រចៀកខ្លះ ច្រមុះខ្លះ ឲ្យស្រោចដោយប្រេងដ៏ក្តៅខ្លះ, ឲ្យឆ្កែខាំខ្លះ ឲ្យដេកលើឈើអាររអណ្តាតទាំងរស់ខ្លះ ឲ្យកាត់ក្បាលដោយដាវខ្លះ។ល។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលតែងត្រិះរិះក្នុងអំពើនោះថា ព្រះរាជាទាំងឡាយ ចាប់ចោរបានហើយ ត្រាស់បង្គាប់ឲ្យធ្វើទារុណកម្មផ្សេងៗយ៉ាងនេះ ព្រោះហេតុតែបាបកម្មមានសភាពយ៉ាងណាៗ ក្នុងសភាពបែបនោះឯង ក៏មាននៅក្នុងអញផង ខ្លួនអញសោតក៏ប្រាកដក្នុងធម៌ទាំងនោះឯង។ បុគ្គលពាលតែងទទួលទុក្ខទោមនស្សទី២នេះឯងក្នុងបច្ចុប្បន្ន។

ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពាលកាលឡើងកាន់តាំង (ក្តារងឿ)ក្តី ឡើងកាន់គ្រែក្តី ដេកលើផែនដីក្តី អំពើអាក្រក់ទាំងឡាយ គឺការប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្តណា ដែលគេធ្វើទុកក្នុងកាលមុន អំពើអាក្រក់ទាំងនោះឯង តែងគ្របដណ្តប់សង្កត់សង្កិនគេក្នុងសម័យនោះ។ ដូចជាស្រមោលនៃកំពូលភ្នំដ៏ធំ រែងក្រាល គ្របលើផែនដីក្នុងវេលាថ្ងៃរសៀលដូច្នេះដែរ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលតែងគិតក្នុងអារម្មណ៍ដែលប្រាកដក្នុងចក្ខុទ្វារយ៉ាងនេះថា អើហ្ន៎! អាត្មាអញមិនបានធ្វើអំពើល្អ ជាបុណ្យកុសលសម្រាប់ការពារភ័យទុក្ខសោក អាត្មាអញធ្វើតែអំពើបាបអាក្រក់ក្តៅ ក្រហាយទុក រមែងមានគតិណា អាត្មាអញនឹងទៅកាន់គតិនោះក្នុងបរលោក។ បុគ្គល

ពាលនោះតែងក្រៀមក្រំចិត្ត លំបាក ខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំ ដល់នូវសេចក្ដីវង្វេង។ បុគ្គលពាលតែងទទួលទុក្ខតូចចិត្តទី៣នេះឯងក្នុងបច្ចុប្បន្ន។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះប្រព្រឹត្តទុច្ចរិតដោយកាយ វាចា ចិត្ត លុះស្លាប់ទៅរមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក។ ម្នាលភិក្ខុទាំងឡាយ អ្នកដែលនិយាយតាមហេតុ (តែងនិយាយចំពោះ) ទីមិនគួរប្រាថ្នា មិនគួរត្រេកអរ មិនគួរពេញចិត្ត តែមួយយ៉ាងៗដូច្នេះ ទីនោះគឺ «នរក» នុ៎ះឯង។ សេចក្ដីនេះមិនងាយនឹងធ្វើឧបមាឲ្យដល់កម្រិតនរក ដែលមាទុក្ខបានឡើយ។

កាលបើព្រះអង្គត្រាស់យ៉ាងនេះហើយ មានភិក្ខុមួយអង្គសួរថា ចុះព្រះអង្គអាចនឹងធ្វើសេចក្ដីឧបមាបានទេក្រាបទូល? តថាគតអាចនឹងធ្វើបានរួចទ្រង់សម្ដែងថា ដូចពួករាជបុរស ចាប់ចោរប្រព្រឹត្តអាក្រក់បានហើយ នាំមកថ្វាយព្រះរាជាទូលថា អ្នកនេះជាចោរ ប្រព្រឹត្តអាក្រក់នឹងព្រះអង្គ បើទ្រង់សព្វព្រះទ័យនឹងដាក់អាជ្ញាណាដល់ចោរនេះ សូមទ្រង់ដាក់អាជ្ញានោះចុះ។ ព្រះរាជាមានព្រះរាជឱង្ការយ៉ាងនេះ នែ! ប្រស្ដែង ចូរអ្នករាល់គ្នាទៅយកលំពែងមួយរយចាក់បុរសនេះ ក្នុងវេលាព្រឹកព្រហាមមួយរយលំពែង ក្នុងវេលាថ្ងៃត្រង់មួយរយលំពែង ក្នុងវេលាថ្ងៃរសៀលមួយរយលំពែងទៀតចុះ។ ពួករាជបុរសក៏យកលំពែងមួយរយ ចាក់បុរសនោះក្នុងវេលាព្រឹក ថ្ងៃត្រង់ ថ្ងៃរសៀល។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្ដីនោះដូចម្ដេច? កាលបើគេចាក់ដោយលំពែងបីរយ តើនឹងទទួលទុក្ខទោមនស្ស ព្រោះលំពែងនោះជាហេតុដែរឬទេ? ពួកភិក្ខុក្រាបទូលថា បុរសនោះ សូម្បីគេចាក់ដោយលំពែងតែមួយ ក៏ទទួលទុក្ខទោមនស្ស ព្រោះលំពែងនោះទៅហើយ ចាំបាច់និយាយថ្វីដល់ទៅចាក់ដោយលំពែងបីរយ។

គ្រានោះឯង ព្រះអង្គទ្រង់ចាប់ថ្មតូចប្រមាណប៉ុនបាតដៃ ហើយសួរពួកភិក្ខុថា «ដុំថ្មប៉ុនបាតដៃដែលតថាគតកំពុងកាន់នេះ និងស្ដេចភ្នំហិមពាន្ត តើមួយណាធំជាង?។ ភិក្ខុទូលថា ដុំថ្មតូចប្រមាណប៉ុនបាតដៃ ដែលព្រះអង្គកាន់

នោះ តូចពេកណាស់ ប្រៀបផ្ទឹមនឹងស្ដេចភ្នំហិមពាន្តនោះ មិនប៉ុន្មានផង មិនដល់មួយចំណិតផង មិនដល់នូវការប្រៀបធៀបផង។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីនេះមានឧបមេយ្យដូចជាបុរស ដែលគេចាក់ដោយលំពែងបីរយ រមែងរងទុក្ខ ព្រោះលំពែងនោះជាហេតុ។ ទុក្ខនោះឯង ប្រៀបផ្ទឹមនឹងទុក្ខរបស់នរក ក៏មិនប៉ុន្មានផង។ល។ មិនដល់នូវការប្រៀបធៀបផង។

ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាលធ្វើទារុណកម្ម ឈ្មោះបញ្ចពិធពន្ធន៍ (ចំណង៥ប្រការ) ចំពោះសត្វនរកនោះគឺ ផ្ដេក (សត្វនរកនោះ) ហើយបោះដុំដែកគោលដ៏ក្ដៅ ត្រង់ដៃខាងស្ដាំ១ ត្រង់ដៃខាងឆ្វេង១ ត្រង់ជើងខាងស្ដាំ១ ត្រង់ជើងខាងឆ្វេង១ បោះដែកគោលដ៏ក្ដៅចំកណ្ដាលទ្រូង១។ សត្វនោះរងទុក្ខវេទនាក្លាខ្លាំងខ្លោចផ្សាក្នុងទីនោះ បើបាបកម្មនោះ មិនទាន់អស់ដរាបណា ក៏មិនធ្វើមរណកាលដរាបនោះ។ ម្នាលភិក្ខុទាំងឡាយ លុះពួកនិរយបាលផ្ដេកសត្វនរកនោះរួចហើយ ទើបយកដឹងចាំងសត្វនោះ ក៏រងទុក្ខវេទនាក្លាខ្លាំងក្នុងទីនោះ។ល។ម្នាលភិក្ខុទាំងឡាយពួកនិរយបាលចាប់សត្វនោះយកជើងព្យួរឡើងលើ ក្បាលចុះក្រោម ហើយច្រាសដោយកំបិតព្រា។ ពួកនិរយបាល ទឹមសត្វនោះនឹងរថ ហើយបរទៅបរមកលើប្រថពី ដែលភ្លើងកំពុងឆេះសព្វ ភ្លឺសន្ធោសន្ធៅប្រាលឆ្អៅ ពួកនិរយបាល ប្រើសត្វនោះឲ្យឡើងភ្នំ ឲ្យចុះអំពីភ្នំភ្លើងដ៏ធំដែលកំពុងឆេះសព្វ ភ្លឺសន្ធោសន្ធៅប្រាលឆ្អៅ។ សត្វនោះរងទុក្ខវេទនាក្លាខ្លាំងក្នុងទីនោះ បើបាបកម្មមិនទាន់អស់ដរាបណាក៏មិនស្លាប់ដរាបនោះ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាលចាប់សត្វនោះ យកជើងឡើងលើសំយុងក្បាលចុះក្រោម ទម្លាក់ទៅក្នុងខ្ទះទង់ដែងដ៏ក្ដៅ ដែលភ្លើងកំពុងឆេះសព្វ។ សត្វនោះឆេះនឹងកំសួលពពុះក្នុងខ្ទះទង់ដែងនោះ។ ជួនកាលអណ្ដែតឡើងលើម្ដង ចុះក្រោមម្ដង។ សត្វនោះរងទុក្ខវេទនាក្លាខ្លាំងក្នុងខ្ទះទង់ដែងនោះ បើបាបកម្មមិនទាន់អស់ សត្វនោះក៏មិនស្លាប់ដរាបនោះ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ក៏ចាប់បោះសត្វនោះ ទៅក្នុងមហានរក។ មហានរកសោត មាន

ជ្រុងបួន មានទ្វារបួន បែងចែកដោយចំណែកៗ មានរបងដែកព័ទ្ធជុំវិញ គ្រប ដោយគម្របដែក។ ផ្ទៃក្រោមនៃមហានរកនោះសុទ្ធតែមានភ្លើងឆេះភ្លឺប្រាល រន្ទាល ផ្សាយទៅបានមួយរយយោជន៍ជុំវិញតាំងនៅសព្វៗកាល។ តថាគតនឹង សម្តែងរៀបរាប់អំពីនរកដោយអនេកបរិយាយទៅក៏បាន។ តែដំណើរដែលតថាគត ពោលទៅមិនងាយនឹងដល់កម្រិតនរក ដែលមានទុក្ខបានឡើយ។

ម្នាលភិក្ខុទាំងឡាយ មានពួកសត្វតិរច្ឆាន(ខ្លះ) មានស្មៅជាអាហារ។ គឺ សេះ គោ លា ពពែ ម្រឹគ ឬសត្វតិរច្ឆានណាមួយ ដទៃទៀតដែលមានស្មៅជា អាហារដូចគ្នា។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពោលនោះឯងជាអ្នកជាប់នឹងរស អាហារក្នុងកាលពីមុន លុះស្លាប់ទៅ ក៏ទៅកើតជាពួកសត្វដែលមានស្មៅ ជាអាហារនោះ។

ម្នាលភិក្ខុទាំងឡាយ មានពួកសត្វតិរច្ឆាន (ខ្លះ) មានលាមកជាអាហារ។ ពួកសត្វនោះគ្រាន់តែធុំក្លិនលាមកពីចម្ងាយ ក៏ស្ទុះទៅគិតថា យើងនឹងស៊ីក្នុង ទីនោះៗ។ ដូចគ្នានឹងពួកព្រាហ្មណ៍ ដែលស្ទុះទៅតាមក្លិននៃគ្រឿងបូជា ដោយ គិតថា យើងនឹងបរិភោគក្នុងទីនុ៎ះៗ។ ឯបុគ្គលពាលនោះលុះស្លាប់ទៅ ក៏ទៅ កើតជាពួកសត្វដែលមានលាមកជាអាហារនោះ។

ម្នាលភិក្ខុទាំងឡាយ មានពួកសត្វតិរច្ឆាន កើតក្នុងទីងងឹត ចាស់ក្នុង ទីងងឹត ស្លាប់ក្នុងទីងងឹត ចាស់... ស្លាប់ក្នុងទីងងឹត គឺកន្លាត ទាក ជន្លេន... ។ បុគ្គលពាលក៏ទៅកើតក្នុងទីងងឹត ចាស់... ស្លាប់ក្នុងទីងងឹត ដូចសត្វទាំងនោះ ដែរ។

ម្នាលភិក្ខុទាំងឡាយ មានពួកសត្វតិរច្ឆាន កើតក្នុងទីមិនស្អាត...ចាស់... ស្លាប់ក្នុងទីមិនស្អាត គឺកើតក្នុងត្រីស្អុយ ក្នុងសាកសពស្អុយ នំស្អុយ រណ្តៅស្អុយ ក្នុងប្រឡាយបង្ហូរជ្រាំស្អុយក៏មាន...។ល។ កំណើតបុគ្គលពាលមានឧបមា ដូចគ្នា។

ម្នាលភិក្ខុទាំងឡាយ ដូចបុរសដាក់នឹមដែលមានច្បោះ (សម្រាប់

ទប់អ្វីៗឲ្យនឹង ) តែមួយទៅក្នុងមហាសមុទ្រ។ ខ្យល់ពីខាងកើតបក់បន្សាត់នឹមនោះទៅខាងលិច ខ្យល់ពីខាងលិចបក់បន្សាត់ទៅខាងកើត ខ្យល់ពីខាងជើងបក់បន្សាត់ទៅខាងត្បូង ខ្យល់ពីខាងត្បូង បក់បន្សាត់ទៅខាងជើង។ ក្នុងមហាសមុទ្រនោះ មានអណ្តើកមួយ អណ្តើកនោះអំណើះទៅមួយរយឆ្នាំទើបងើបឡើងម្តង។ អ្នកទាំងឡាយសម្គាល់សេចក្តីនោះដូចម្តេច? អណ្តើកខ្វាក់នោះ តើអាចប្រកកឲ្យចូលទៅក្នុងនឹម ដែលមានច្បោះតែមួយបានទេ?

ភិក្ខុទាំងឡាយទូលថា មិនបានទេ បើក្រែងតែកន្លងកាលទៅម្តងៗយូរអង្វែងណាស់ (ទើបអណ្តើកនោះប្រកកចូលទៅក្នុងច្បោះនឹមនោះបាន ព្រះអង្គត្រាស់ថា អណ្តើកខ្វាក់នោះប្រកកឲ្យចូលទៅក្នុងនឹមនោះ ទុកថាជាឆាប់ណាស់ផង។ បុគ្គលពាលទៅកើតក្នុងវិនិបាតម្តងហើយ កម្រនឹងបានអត្តភាពមកជាមនុស្សវិញ ជាងអណ្តើកនោះទៀត ដំណើរនោះព្រោះអ្វី? ព្រោះថាក្នុងវិនិបាតនោះ មិនមានការប្រព្រឹត្តធម៌ដ៏ស្មើ មិនមានការធ្វើកុសល... មិនមានការធ្វើបុណ្យទេ មានតែការខាំស៊ីនូវគ្នានឹងគ្នា សម្លាប់គ្នាដែលមានកម្លាំងថយតែងមាននៅក្នុងវិនិបាតនោះ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះឯង បើយូរអង្វែងទៅម្តងៗ ទើបបានមកជាមនុស្សក្នុងកាលជាខាងក្រោយ តែងកើតក្នុងត្រកូលថោកទាប គឺត្រកូលចណ្ឌាល ត្រកូលនេសាទ ត្រកូលអ្នកត្បាញផែង ត្រកូលអ្នកធ្វើរថត្រកូលអ្នកកើបសំរាម ជាត្រកូលកម្សត់ ឥតមានបាយទឹក ភោជន ប្រព្រឹត្តរស់នៅដោយលំបាក ជាត្រកូលរកបាយស៊ីមិនបាន និងមានសំពត់ស្លៀកបានដោយត្រដាបត្រដួស។ បុគ្គលនោះឯងជាមនុស្សមានសប្បុរអាក្រក់ មិនគួរអ្នកផងមៀងមើលជាមនុស្សតឿ មានជំងឺច្រើន ជាមនុស្សខ្វាក់ ក្អែង ខ្វក ខ្វិនជាអ្នកមិនបានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗទីដេក ទីអាស្រ័យនៅ គ្រឿងប្រទីប ។ បុគ្គលនោះប្រព្រឹត្តទុច្ចរិត ដោយកាយវាចា ចិត្ត ហើយដល់ស្លាប់ទៅ តែងទៅកើតតិរច្ឆាន ប្រេត អសុរកាយ នរក។

ម្នាលភិក្ខុទាំងឡាយ ដូចយ៉ាងអ្នកលេងល្បែងភ្នាល់ តែងធ្វើឲ្យកូនហិន ហោច ប្រពន្ធហិនហោចសម្បត្តិទាំងពួងផង ដោយការចាញ់ជាដំបូង តទៅជាប់វ័ណ្ឌខ្លួនឯងទៀតនោះ ឈ្មោះថាចាញ់បន្តិចបន្តួចទេ។ ចណែកខាងបុគ្គលពាលនោះប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត ហើយលុះដល់បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើត៤នេះឯង ទើបឈ្មោះថា ការចាញ់យ៉ាងធំជាងនោះទៅទៀត។ ម្នាលភិក្ខុទាំងឡាយនេះឯង ឈ្មោះថា **ពាលភូមិ** ដ៏បរិបូណ៌គ្រប់គ្រាន់។

ចប់ពាលសូត្រ

**ព្រះធម្មបទគាថា សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ ភាគ៥២ អំពីពាលវគ្គ ជាសេចក្តីសម្រាយដូចតទៅ ៖**

១-រាត្រីវែងចំពោះតែអ្នកភ្ញាក់រឭក(អ្នកដេកមិនលក់)យោជន៍វែង ចំពោះតែអ្នកនឿយហត់ សង្សារវដ្តវែង ចំពោះតែបុគ្គលពាលមិនដឹងច្បាស់នូវព្រះសទ្ធម្ម។

២- បុគ្គលពាលស្វះស្វែងរកកល្យាណមិត្ត បើមិនបានមិត្តដ៏ប្រសើរជាងខ្លួនឬមិត្ត ដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯង ឲ្យខ្ជាប់ខ្ជួនវិញ ព្រោះថា សហាយតាគុណ(ចុល្លសីល មជ្ឈិមសីល មហាសីល កថាវត្ថុ១០ ធុតង្គគុណ១៣ វិបស្សនាគុណ មគ្គ៤ ផល៤ អភិញ្ញា៦ ហៅថា សហាយតាគុណ)។ មិនមានក្នុងបុគ្គលពាលឡើយ។

៣- ជនពាលតែងព្រួយលំបាក ដោយសេចក្តីសម្គាល់ថា កូនទាំងឡាយរបស់អញមានទ្រព្យ តាមពិត សូម្បីខ្លួនឯងក៏មិនមាន (ព្រោះមិនអាចនឹងការពារទុក្ខបាន។ អដ្ឋកថា។) ចំណង់បើកូនទាំងឡាយ នឹងរាប់ថាមានអំពើណាបានទ្រព្យ នឹងរាប់ថាមានអំពើណាបាន។

៤- អ្នកណាជាមនុស្សពាល ហើយដឹងខ្លួនថាជាពាល អ្នកនោះនឹងទៅ

ជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួនថាជាពាលនោះ ម្យ៉ាងទៀត អ្នកណាជាមនុស្សពាល មានសេចក្តីប្រកាន់ថា ខ្លួនជាបណ្ឌិត អ្នកនោះ ឈ្មោះថាមនុស្សពាលដោយពិត។

៥- មនុស្សពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិត ក៏ឥតមានដឹងរសធម៌អ្វីឲ្យច្បាស់លាស់ឡើយ ដូចវែកដែលមិនដឹងរសសម្ល។

៦- វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច រមែងយល់រសធម៌ដោយឆាប់រហ័ស ដូចអណ្តាតដឹងនូវរសសម្ល។

៧- ពួកជនពាលមិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវតែងធ្វើកម្មលាមក ដែលជាអំពើមានផលក្តៅក្រហាយ។

៨- បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយ ឬមានមនុស្សប្រឡាក់ដោយទឹកភ្នែកស្រែកយំ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះ ឈ្មោះថាជាកម្មមិនល្អឡើយ។

៩- បុគ្គលធ្វើកម្មណាហើយ រមែងធ្វើចិត្តក្តៅក្រហាយ ឬដល់នូវសេចក្តីពេញចិត្តមានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថាជាកម្មល្អ។

១០- បាបមិនទាន់ឲ្យផលត្រឹមណា ជនពាលតែងសម្គាល់នូវបាបនោះឯងដូចទឹកឃ្មុំ លុះតែកាលណាបាបឲ្យផល ជនពាលនោះទើបប្រទះនូវសេចក្តីទុក្ខក្នុងកាលណោះ។

១១- ជនពាលទុកដូចជាបរិភោគភោជនដោយចុងស្បូវរាល់ៗខែ ( បានសេចក្តីថា យកចុងស្បូវទៅចាក់ភោជន ហើយយកមកតេះនឹងចុងអណ្តាត ចំពោះគាថានេះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងប្រារព្ធនឹងជម្ពុកាជីវក ដែលជាអ្នកប្រព្រឹត្តបរិភោគបែបនោះជាវត្ត ក្នុងពេលដែលមហាជននាំភោជនមកបូជា។ ) ជនពាលនោះក៏មិនដល់មួយចំណិតទី១៦ៗលើក របស់បុគ្គលទាំងឡាយដែលមានធម៌ បានដឹងឬបានពិចារណាហើយឡើយ។

១២- កម្មលាមកដែលជនពាលធ្វើហើយ មិនទាន់ឲ្យផលនោះក៏មាន ដូចទឹកដោះស្រស់ដែលមិនទាន់ប្រែក្លាយ (ក្នុង១រំពេច) ដូច្នេះ បាបកម្មនោះ តាមដុតបុគ្គលពាល ដូចរងើកភ្លើងដែលបិទបាំងទុកដោយផេះដូច្នោះ។

១៣-ការចេះដឹងកើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តីវិនាស ប៉ុណ្ណោះ រមែងញ៉ាំងបញ្ញាឲ្យធ្លាក់ចុះ បំផ្លិចបំផ្លាញចំណែកធម៌ស គឺកុសលរបស់ បុគ្គលពាលនោះ។

១៤- បដិបទា អាស្រ័យនូវលាភផ្សេង បដិបទា ជាដំណើរទៅកាន់ ព្រះនិព្វានផ្សេង ភិក្ខុជាសាវ័ករបស់ព្រះពុទ្ធ ដឹងច្បាស់នូវហេតុទាំងនុ៎ះយ៉ាងនេះ ហើយ មិនគួរត្រេកអរចំពោះសក្ការៈឡើយ គប្បីញុំាងវិវេកឲ្យចម្រើនដោយ លំដាប់។

មនុស្សល្អ គឺមនុស្សចេះទូន្មានខ្លួន
មនុស្សល្អ រមែងមិនត្រេកអរក្នុងអំពើអាក្រក់
អំពើល្អ មនុស្សល្អធ្វើបានដោយស្រួល
អំពើល្អ មនុស្សអាក្រក់ធ្វើបានដោយលំបាក
អំពើអាក្រក់ មនុស្សអាក្រក់ធ្វើបានដោយងាយ
អំពើអាក្រក់ ព្រះអរិយបុគ្គលបានកាត់ផ្តាច់បង់អស់ហើយ

«អ្នកប្រាជ្ញ កាលគិតដល់សេចក្តីចម្រើនហើយ ត្រូវគិតដល់សេចក្តី វិនាសផង កុំកល្ងង់គិតឃើញសេចក្តីចម្រើនតែម្យ៉ាង ត្រូវស្លាប់កូនខ្មុក»។ ស្រីហិតោបទេស។

# ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា

ព្រះគ្រូសង្ឃសត្ថា ប៉ុណ្យ សុម្ភាជ ធម្មារាម:
សាស្ត្រាចារ្យនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត នៅភ្នំពេញ
សមាជិកឆ្លើយឆ្លងនៃសាលាបារាំងសែសចុងបូព៌ាប្រទេស
សមាជិកនៃគណៈកម្មការវប្បធម៌ខ្មែរ

ប្រទេសកម្ពុជា ជាប្រទេសមួយតូច ទាំងមនុស្សក៏មានស្ដួចស្ដើង ប៉ុន្តែបើយកប្រទេសនេះទៅធៀបនឹងប្រទេស ដែលកាន់ព្រះពុទ្ធសាសនា ដូចគ្នានៅក្នុងសាកលលោក ឃើញថាជនជាតិខ្មែរយើងគោរពព្រះពុទ្ធសាសនា ដោយស្រុះស្រួលគ្នាជាងប្រជាជនក្នុងប្រទេសទាំងនោះពិតប្រាកដ។ បន្ទាប់មកទៀតគេពោលដោយឥតញញើតមាត់ហើយគ្មានបំផ្លើសផងថា ខ្មែរយើង៩៩ភាគរយកាន់លទ្ធិព្រះពុទ្ធសាសនា។

យើងដឹងច្បាស់ហើយថា កាលពី៤០០ឆ្នាំមុននោះ ស្រុកចម្ប៉ាដែលឋិតនៅត្រង់ប្រទេសយៀកណាមកណ្ដាលសព្វថ្ងៃនេះ មានប្រជាជនជាតិជ្វានិងចាមជាកូនចៅនៃអ្នកកាន់សាសនាអ៊ីស្លាម ដែលចេញចាកស្រុកចម្ប៉ានាំយកសាសនាអ៊ីស្លាម ចូលមកក្នុងប្រទេសកម្ពុជា នៅពេលដដែលនេះ ប្រជាជនជាតិអឺរ៉ុបក៏បាននាំយកសាសនាគ្រិស្តចូលមកប្រទេសកម្ពុជាដែរ។ ពួកបរិស័ទនៃសាសនាខាងលើនេះ បានសាងព្រះវិហាររបស់ខ្លួននៅជិតៗព្រះវិហារខ្មែរ តែជនជាតិខ្មែរដោយគាប់ចិត្តនឹងសាសនាព្រះពុទ្ធយ៉ាងស៊ប់ស្ងួន ក៏គ្មានបែរគំនិតទៅរកសាសនាអ៊ីស្លាមនិងសាសនាគ្រិស្តឡើយ។

តាមប្រវត្តិសាស្ត្រ មហាក្សត្រនិងមន្ត្រីធំៗសម័យនោះ បាននាំយកសាសនាព្រាហ្មណ៍ចូលមកប្រទេសកម្ពុជាយើង គឺតាំងពីដើមសករាជនៃស្រុកខ្មែររវាងឆ្នាំ៤៥០ ក្រោយព្រះយេស៊ូគ្រិស្ត គឺជាព្រះពុទ្ធសាសនាដែលគេហៅថា

ថេរវាទឬទក្ខិណនិកាយ។

ព្រះពុទ្ធសាសនានៃប្រទេសកម្ពុជា ចាប់មានពន្លឺរស្មីព្រោងព្រាយឡើង តាំងពីសតវត្សទី១៣ ក្នុងរជ្ជកាលនៃព្រះបាទជយវរ្ម័នទី៧។ ព្រះបាទជយវរ្ម័នទី ៧ មិនត្រឹមតែ ជាមហាក្សត្រខ្លាំងពូកែខាងសឹកសង្គ្រាមប៉ុណ្ណោះទេ ទ្រង់ប្រសប់គ្រប់គ្រងផែនដីណាស់ទៀតផង ទ្រង់បានប្រារព្ធឲ្យរៀបចំគ្រប់តំណែងសម្រាប់ព្រះនគរដែលធំទូលាយឲ្យចម្រើនឡើង ហើយទ្រង់ឲ្យសាងប្រាសាទសុទ្ធតែថ្មដើម្បីឧទ្ទិសចំពោះព្រះសមណគោតមជាអម្ចាស់នៃយើង។ ឯប្រាសាទដែលល្បីឈ្មោះជាងគេនោះគឺ ប្រាសាទបាយ័ន (បញ្ស៉ង់) ប្រាសាទនេះល្អអស្ចារ្យមួយ ហើយដែលនាំឲ្យសាកលលោកស្ញប់ស្ញែង។

នៅខាងមុខនេះ ខ្ញុំនឹងអធិប្បាយលាតត្រដាងអំពីស្ថាបនកម្មនៃបុព្វបុរសខ្មែរដោយសង្ខេបជូនអស់លោកអ្នកអាន ៖

ប្រាសាទអង្គរ បើយើងក្រឡេកមើលភ្លាមឃើញជាដុំថ្មដាក់គរលើគ្នា ប៉ុន្តែបើយើងដើរចូលទៅជិតនឹងឃើញជារបៀង បរិវេណ ឬប្រាសាទតូចៗ ពាសពេញទៅវិញ ហើយគ្រឹះស្ថានទាំងនេះនាំឲ្យយើងនឹកឃើញថា មហាក្សត្រប្រទេសកម្ពុជាកាលពីដើម មានភោគសម្បត្តិនិងឫទ្ធិចេស្តា ហើយចេះគ្រប់គ្រងប្រទេសដែលធំទូលាយអស្ចារ្យ។

កាលពីសតវត្សទី១២-១៣-១៤ ដែនកូសាំងស៊ីនទាំងមូលនិងទ្វីបអាស៊ីភាគអាគ្នេយ៍មួយផ្នែក ក៏ជាដែនដីប្រទេសកម្ពុជាដែរ។ តាំងពីយូរណាស់មកហើយ គេពុំអាចដឹងប្រវត្តិសាស្ត្រនៃសិល្បៈខ្មែរដោយច្បាស់លាស់ទេ គេគ្រាន់តែដឹងថា សិល្បៈនេះកើតមានឡើងជាយូរអង្វែងហើយ។ ដោយហេតុគេឃើញថា ប្រាសាទអង្គរ គេសាងឧទ្ទិសថ្វាយ អាទិទេតាមទំនៀមឥណ្ឌា ហើយនឹងគេឃើញមានសិលាចារឹកជាអក្សរសំស្ក្រឹត នាំឲ្យគេអាចសន្និដ្ឋានបានយ៉ាងឆាប់ថា ស្ថាបត្យកម្មខ្មែរ ជាសំណាកចម្លងអំពីស្ថាបត្យកម្មឥណ្ឌា។ ប៉ុន្តែការស្មាននេះមិនត្រូវទេ ព្រោះជនជាតិបរទេសដែលគេបានទៅបំពេញ

បេសកកម្មនៅប្រទេសឥណ្ឌាបានទទួលដឹងតាមផ្លូវការស្ថាបត្យកម្មឥណ្ឌា មានចិត្តគំនិត ការតាក់តែង និងទ្រង់ទ្រាយផ្សេងស្រឡះពីស្ថាបត្យកម្មរបស់ខ្មែរ។ ក្រោយពីនោះមក ក្រោមឥទ្ធិពលឥណ្ឌា ទើបស្ថាបត្យកម្មព្រះពុទ្ធសាសនាជ្រាបចូលមកប្រទេសកម្ពុជា។

រវាងព.ស. ៤៥០ ក្រោយព្រះពុទ្ធយេស៊ូគ្រិស្ត យើងសង្កេតឃើញថាស្ថាបត្យកម្មបានផ្លាស់ប្តូរទ្រង់ទ្រាយយ៉ាងច្បាស់លាស់ ឧទាហរណ៍ដូចជាពុទ្ធរូបដែលកើតមានឡើង ក្រោយរូបចម្លាក់នៃព្រះឥសូរ ព្រះព្រហ្ម និងព្រះនរាយណ៍។ យើងសូមរំឭកដល់អ្នកដើរមើលប្រទេសថា ក្នុងចំណោមប្រាសាទអង្គរ មានតែប្រាសាទកែវមួយទេដែលគ្មានចម្លាក់អ្វីសោះ គ្រាន់តែមានចលនាវិលវៀន៥ ជាន់នៅលើកំពូលប៉ុណ្ណោះ។ ប្រាសាទបក្សីចាំក្រុង ជាប្រសាទមួយយ៉ាងតូច ឋិតនៅមុខទ្វារខាងត្បូងក្រុងអង្គរធំ ហើយមានទ្រង់ទ្រាយស័ក្តិសមអស្ចារ្យ។ តាមគេស្មានថា ស្ថាបត្យកម្មខ្មែរកើតមានឡើងអំពីចិត្តនិងគំនិតមុនកសាងប្រាសាទដែលយើងបានអធិប្បាយខាងលើនេះ។ស្តេចអាឡិកហ្សង់ឡឺក្រង់ បាននាំសិល្បៈ «ក្រិច» ចូលទៅប្រទេសឥណ្ឌា ហើយគេស្មានថា ជាង «ក្រិច» ឬជាងឥណ្ឌាដែលនៅរៀនសូត្រក្នុងសាលានៅប្រទេស «ក្រិច» បានឆ្លាក់ព្រះពុទ្ធរូបជាដំបូង។ ហេតុនេះហើយបានជាព្រះពុទ្ធរូបដែលគេបានឆ្លាក់មុនគេ នាំឲ្យនឹកដល់ព្រះរូបនៃព្រះបាទ «អាប៉ូលឡុង»។ នៅទីបំផុត គេដឹងថាក្បាច់ចម្លាក់ខ្មែរ មានកំណើតមុនគេ ហើយដែលមាននៅក្នុងរវាងសតវត្សទី៩ និងទី១០ ជាចម្លាក់អស្ចារ្យ ហើយគេអាចយកទៅផ្ទឹមបានជាមួយនឹងចម្លាក់ប្រាសាទនៅប្រទេសលោកខាងលិច ដែលសាងនៅក្នុងរវាងសតវត្សទី ១៧ និង១៨។

នៅពេលនោះ រឿងព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា មានការទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងកោះសេរីលង្កា ដែលជាទីកន្លែងពុទ្ធសាសនាថេរវាទ ចំណែកខាងផ្លូវទូតវិញ ប្រទេសកម្ពុជានេះមានការទាក់ទងជាមួយនឹងប្រទេស

ចិន។ ពិតមែន ការទាក់ទងខាងលើនេះមានដំណើររអាក់រអួលនៅក្នុងសម័យខ្លះ តែមិនអាចនាំឲ្យបាត់មេត្រីភាពឡើយ នៅតែមានហូរហែរហូតមកដល់សព្វថ្ងៃនេះ។

តាំងពីសតវត្សទី៧ ក្រោយព្រះយេស៊ូគ្រិស្ត បើគេនាំយកឯកសារខ្លះមកពិនិត្យមើលឲ្យម៉ត់ចត់ទៅឃើញថា ភាសាខ្មែរគ្មានផ្លាស់ប្តូរគោលការណ៍ណាមួយនោះ មានតែលូតលាស់ចម្រើនឡើង។ ជួនកាលមានពាក្យពេចន៍ខ្លះឆ្លងទៅឆ្លងមក ជាមួយនឹងប្រទេសដែលជាអាណានិគម ឬដែលជាអាណាព្យាបាលរបស់កម្ពុជរដ្ឋ។ ប៉ុន្តែពាក្យបរទេសទាំងនោះពុំបានធ្វើឲ្យពាក្យពេចន៍ខ្មែរប្រែប្រួលឡើយ ពាក្យពេចន៍ខ្មែរសឹងឋិតទៅតាមភាពដើម ហើយច្រើនតែជាពាក្យព្យាង្គទោល ទោះបីពាក្យទាំងនោះមានដើមកំណើតអំពីបរទេស ជាពាក្យពហុព្យាង្គក៏ដោយ ក៏ច្រើនតែប្រែមកជាពាក្យឯកព្យាង្គតាមទម្លាប់ភាសាខ្មែរវិញ។

គម្ពីរខ្មែរបុរាណប្រើធ្វើតែពីស្លឹករឹត ហើយមានភាសាសំស្ក្រឹតនិងបាលី ៣០ភាគរយ។ គម្ពីរបែបនេះនាំឲ្យជនជាតិខ្មែរ ឬបរទេសដែលមានកំណើតនៅប្រទេសអាស៊ី និយាយគ្នាយល់ទៅវិញទៅមកបានយ៉ាងស្រួល។ យើងសូមបញ្ជាក់ថែមទៀតថា អត្ថបទបុរាណឬបច្ចុប្បន្ន ច្រើនតែអធិប្បាយពីរឿងព្រះពុទ្ធសាសនាដែលមានសព្វថ្ងៃនេះ។

ដើមកំណើតនៃអក្ខរៈខ្មែរ មានមកពីប្រទេសឥណ្ឌាខាងត្បូង។ អក្សរដែលមានគំនូសងាយ ឬពិបាកទុកដូចជាព្យាង្គមួយ។ ព្យញ្ជនៈនីមួយៗ មានស្រៈមួយ បើគ្មានស្រៈទេ ព្យញ្ជនៈនោះនឹងចេញសំឡេងពុំកើត តែមានអក្សរខ្លះស្រៈនោះត្រូវបាត់អង្គ។

ខ្មែរនិយាយភាសាខ្មែរដែលពោលសរុបខាងលើនេះ ហើយដែលប្រទេសនិងជនជាតិខាងលិចឲ្យឈ្មោះថា ប្រជាជនកម្ពុជា។

សព្វថ្ងៃ ខ្មែរមានចំនួន៤៥០០០០០នាក់ ដែលបែកព្រែកនៅគ្រប់

កន្លែងក្នុងដែនខ្មែរ។ នៅក្នុងប្រទេសខ្មែរ គេឃើញជនជាតិយួន៣៥០០០០នាក់ ជនជាតិចិន២០០០០០នាក់ ជនជាតិចាមនិងជ្វា១០០០០០នាក់ ជនជាតិលាវ២០០០០នាក់ ជនជាតិភូមា២០០នាក់ ហើយនឹងជនជាតិអឺរ៉ុបច្រើនពាន់នាក់ តែភាគច្រើនបារាំង។

នៅប្រទេសកម្ពុជាមានបព្វជិតជាគណៈថេរវាទ២គឺ

១-គណៈមហានិកាយ

២-គណៈធម្មយុត្តិកនិកាយ

គណៈទាំងពីរខាងលើនេះ ខុសគ្នាខ្លះតែត្រង់របៀបពោលជាភាសាបាលី និងការប្រព្រឹត្តតាមទំនៀមទម្លាប់ខ្លះៗប៉ុណ្ណោះ។

ព្រះរាជអាណាចក្រកម្ពុជា មានវត្តចំនួន២៨០០ មានភិក្ខុសាមណេរចំនួន៨២០០០អង្គ ក្នុងព្រះវិហារនៃវត្តនីមួយៗ គេបានសាងព្រះពុទ្ធរូបតម្កល់ទុកដើម្បីជាទីគោរពនៃព្រះសង្ឃ (ភិក្ខុសាមណេរ) ដែលចូលមកជ្រក។ ព្រះសង្ឃទាំងនោះមានសមណសក្តិទីរាជាគណៈទីឋានុក្រមដែលតាំងតាមព្រះរាជក្រឹត្យត្រឹមត្រូវ។

ព្រះពុទ្ធសាសនាយើងបានចម្រើនរុងរឿងឡើង ដោយថ្វីព្រះហស្តព្រះមហាក្សត្រិយ៍និងកម្លាំងរាជរដ្ឋាភិបាល ដែលកាន់លទ្ធិព្រះពុទ្ធសាសនាឥតមានល្អៀង។ កាលពីឆ្នាំ១៩១៤ ព្រះរាជានិងរាជរដ្ឋាភិបាលបានសង់សាលាបាលីជាន់ខ្ពស់នៅទីក្រុងភ្នំពេញ។ នៅក្នុងសាលានោះក្រៅពីបង្រៀនភាសាបាលី មានបង្រៀនចំណេះវិជ្ជាឯទៀតមួយពេលៗ។ ព្រះសង្ឃដែលបានបំពេញចំណេះវិជ្ជាចំនួន៤ឆ្នាំរួចហើយ បានសញ្ញាបត្រសាលាបាលីជាន់ខ្ពស់នោះ មានចំនួនច្រើនពាន់អង្គទៅហើយ។ សាលាបាលីជាន់ខ្ពស់នោះ ដែលមានសមណសិស្សចំនួន៥០០អង្គ ដល់មកឆ្នាំនេះបានផ្លាស់ឈ្មោះជា «ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត» តាមព្រះរាជបញ្ញត្តិ។ បន្ទាប់មកទៀត នៅក្នុងគ.ស.១៩២៥ រាជរដ្ឋាភិបាលបានបង្កើតព្រះរាជបណ្ណាល័យ និងមន្ទីរពុទ្ធសាសនបណ្ឌិត្យ នៅ

ក្នុងគ.ស.១៩៣០ ដោយស្នាដៃនៃនាងកញ្ញា «ស.កាបីឡែស» ជាសមាជិកនៃសាលាបារាំងសែសចុងបូព៌ាប្រទេស។ តមកទៀត បានបង្កើតមន្ទីរក្រុមជំនុំព្រះត្រៃបិដក ដែលមានព្រះសង្ឃអ្នកមានចំណេះវិជ្ជាយ៉ាងជ្រាលជ្រៅ ឲ្យចាប់ប្រែពីភាសាបាលី មកជាភាសាខ្មែរ។ ការប្រែព្រះត្រៃបិដកភាសាបាលីមកជាភាសាខ្មែរនោះ ចាប់ប្រែវិន័យបិដកជាមុន ក្នុងការប្រែនេះមានយកសៀវភៅបាលីអក្សរភូមា និងសៀវភៅបាលីអក្សរសៀម ដែលគេបោះផ្សាយរួចហើយមកប្រៀបធៀបនឹងគម្ពីរអក្សរខ្មែរផង ដើម្បីពិនិត្យផ្ទៀងផ្ទាត់ឲ្យត្រឹមត្រូវម៉ត់ចត់ហើយបោះពុម្ពផ្សាយក្នុងព្រះរាជអាណាចក្រទាំងមូល ព្រមទាំងផ្សាយទៅក្នុងប្រទេសទាំងឡាយខ្លះដែលកាន់ព្រះពុទ្ធសាសនាដូចគ្នា។

ដល់មកឆ្នាំ១៩៣៣ គេបានបង្កើតសាលាបាលីរងក្នុងវត្តទីក្រុងនិងខេត្រក្រៅចំនួន៤០០សាលា ស្ទើរតែគ្រប់វត្ត ហើយមានសមណសិស្សជាង ២០០០អង្គ បានបំពេញចំណេះវិជ្ជាគ្រប់៣ឆ្នាំ រួចបានទទួលសញ្ញាបត្រសាលាបាលីផង។ សាលាបាលីរងទាំងនោះបម្រុងនឹងផ្លាស់ទៅជាសាលាបឋមសិក្សាបាលីវិញ។

ក្រោយបង្អស់ គេបានបង្កើតសាលាធម្មវិន័យនៅគ្រប់វត្ត ក្នុងព្រះរាជអាណាចក្រកម្ពុជា ដើម្បីបង្រៀនភិក្ខុសាមណេរទាំងចាស់ទាំងក្មេងជាការចាំបាច់។

ក្នុងឆ្នាំ១៩៥៥ គេបានឃើញគ្រឹះស្ថានមួយខ្ពង់ខ្ពស់ទទុងនៅខាងមុខព្រះបរមរាជវាំង ហៅថា «ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ» ដែលគេបានសម្រេចនឹងបង្កើតតាំងពីឆ្នាំ១៩៥៤ នោះមក។ មហាវិទ្យាល័យថ្មីនេះ នឹងបើកឲ្យតែនិស្សិតដែលមានសញ្ញាបត្រមធ្យមវិជ្ជាខាងព្រះពុទ្ធសាសនា ឬក៏អ្នកដែលមានសញ្ញាបត្រមធ្យមវិជ្ជាខាងព្រះពុទ្ធ សាសនាឬអ្នកដែលមានសញ្ញាបត្រតម្លៃស្មើគ្នា ទើបចូលរៀនបាន។

ព្រះករុណាអម្ចាស់ជីវិតលើត្បូងជាអគ្គពុទ្ធសាសនូបត្ថម្ភក៍។ ព្រះមហាក្សត្រនរោត្តម សីហនុ វរ័ន្ម ដែលសព្វថ្ងៃបានទទួលតំណែងជាសម្តេចព្រះឧបយុ

វរាជ បានដាក់រាជសម្បត្តិ ហើយថ្វាយរាជ្យនោះចំពោះព្រះវរាជបិតានិងព្រះវររាជជននីនាថ ទ្រង់សោយរាជ្យសម្បត្តិពីព្រះអង្គមក។ កាលស្ដេចទ្រង់សោយរាជ្យនៅឡើយ ទ្រង់គ្មានអាឡោះអាល័យបានយាងចុះពីព្រះរាជបល្ល័ង្ក ទៅបំពេញអភិនេស្រ្កមអស់វារៈ៣ខែ គឺ១វស្សា។ ទ្រង់បានលើកទឹកចិត្តព្រះសង្ឃ និងលើកតម្កើងសាសនាឲ្យបានរុងរឿងឡើង ហើយថែមទាំងចំណាយព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ដើម្បីកសាងសាលាខាងពុទ្ធចក្រនិងខាងអាណាចក្រនៅក្នុងព្រះរាជអាណាចក្រទាំងមូល។ ពុទ្ធិកមហាវិទ្យាល័យ ដែលបានថ្លែងរួចមកហើយនោះ ក៏ជាស្នាព្រះហស្តនៃព្រះអង្គជាដើមគំនិត ព្រមទាំងបានចូលព្រះរាជទ្រព្យកសាងផង ទើបមហាវិទ្យាល័យនេះមានមានថា «ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ»។

ការស្ថាបនានិងសវិភាការខាងលើទាំងប៉ុន្មាននេះ នាំឲ្យមានប្រយោជន៍ដ៏ពិសេសដល់ព្រះពុទ្ធសាសនា ហើយនឹងនាំសមាជិកនៃគណៈសង្ឃឲ្យបានចម្រើនចំណេះវិជ្ជាស្មើៗគ្នា ព្រមទាំងឲ្យព្រះសង្ឃទាំងនោះកាន់ពុទ្ធបញ្ញត្តិត្រឹមត្រូវ តាមដែលព្រះបរមគ្រូនៃយើងសម្ដែងទុកមក។ តាំងពីពេលនេះទៅ គណៈសង្ឃគ្មានខ្វែងគំនិតគ្នាពីរឿងពាក្យ ប្រៀនប្រដៅឡើយ មានតែសេចក្ដីស្ងប់ស្ងាត់និងចម្រើនទៅអនាគតកាល។

ក្រៅពីស្ថាបនាការ ដែលបានរៀបរាប់ខាងលើរួចមកហើយនោះ មានបង្កើតសមាគមពីរទៀត ហៅថា

- សមាគមមិត្តសាលាបាលី
- ពុទ្ធិកសមាគមពិភពលោក។

សមាគមទី១ សម្រាប់លើកទឹកចិត្តព្រះសង្ឃ ដើម្បីឲ្យខំបំពេញចំណេះវិជ្ជា ជាភាសាបាលី ភាសាជាតិ ឬភាសាបរទេស។ ចំណែកខាងសមាគមទី២ សម្រាប់ធ្វើការទាក់ទងពីរឿងព្រះពុទ្ធសាសនាក្នុងសកលលោក។

ប្រជាជាតិខ្មែរធ្លាប់ធ្វើពិធីបុណ្យ ដែលត្រូវតាមព្រះពុទ្ធសាសនាទាំង

១២ខែ ក្នុងមួយឆ្នាំៗ។ ឯពិធីបុណ្យដែលមានឈ្មោះជាងគេនោះគឺ

១-បុណ្យចូលឆ្នាំ ធ្វើនៅថ្ងៃ១៣-១៤-១៥ ខែមេសា។ នៅឱកាសចូលឆ្នាំថ្មីនេះ គេធ្វើពិធីបុណ្យ «ពូនភ្នំខ្សាច់» ជាតំណាង «ព្រះចូឡាមណីចេតិយ» ដែលតម្កល់ព្រះកេសានៃព្រះសម្ពុទ្ធ កាលព្រះអង្គយាងចេញចាកមហាប្រាសាទទៅទ្រង់ព្រះផ្នួស។

២-បុណ្យវិសាខបូជា ធ្វើក្នុងខែឧសភានៅក្នុងព្រះបរមរាជវាំង ហើយនឹងក្នុងវត្តទាំងអស់ក្នុងព្រះរាជអាណាចក្រកម្ពុជា។ បុណ្យនេះជាបុណ្យខួបនៃកំណើតព្រះសម្ពុទ្ធ ដែលទ្រង់ប្រសូត ទ្រង់ត្រាស់ដឹងនូវសម្ពោធិញ្ញាណ និងទ្រង់ចូលព្រះបរមនិព្វាន។ ប្រទេសដទៃដែលកាន់លទ្ធិព្រះពុទ្ធសាសនាតែងធ្វើបុណ្យនេះដែរ។

៣-បុណ្យច្រត់ព្រះនង្គ័ល គេធ្វើនៅថ្ងៃ៤រោច ខែវិសាខ ( ឧសភា ) នៅក្រុងភ្នំពេញ។ បុណ្យនេះធ្វើតាមទម្លាប់ពីបុរាណ ដើម្បីរំឭកព្រះរាជប្រវត្តិនៃព្រះបាទសុទ្ធោទនៈ ដែលត្រូវជាព្រះបរមរាជបិតាដែលទ្រង់នាំព្រះសិទ្ធត្ថ កុមារនៅក្នុងពិធីបុណ្យច្រត់ព្រះនង្គ័លនោះ។

ក្នុងពិធីបុណ្យនោះ គេឃើញមានអ្នកតំណាងព្រះរាជាម្នាក់ ( ស្ដេចមាឃ ) កាន់យាមនង្គ័ល ដែលមានលក្ខណៈជានិមិត្តរូប ហើយភ្ជួរ៣ជុំ លើដីមួយកន្លែងដែលគេសន្មតជាព្រះស្រែ។ នៅខាងក្រោយស្ដេចមាឃនោះ មានស្ត្រីម្នាក់ស្លៀកពាក់សំពត់សម្រាប់ពិធីបុណ្យ ដើរពីមុខស្ត្រីឯទៀតដែលតាមហែហមហើយសាបព្រោះក្នុងគន្លងដែលទើបនឹងភ្ជួររួចថ្មី។ ពិធីបុណ្យនេះជាសញ្ញានៃការភ្ជួរស្រែចម្ការនៅក្នុងព្រះរាជអាណាចក្រកម្ពុជាទាំងមូល។

៤-បុណ្យបំបួសនាគ គេធ្វើនៅប្រទេសកម្ពុជា ក្នុងខែទាំងឡាយគ្រប់រដូវលើកលែងតែ៣ខែដែលចូលវស្សាចេញ តែចំណែកខាងព្រះរាជវង្សានុវង្ស ធ្លាប់ធ្វើបុណ្យនេះមុនថ្ងៃចូលវស្សាមួយថ្ងៃ។ បព្វជ្ជាបេក្ខៈខាងព្រះរាជវង្សានុវង្ស និងបព្វជ្ជាបេក្ខៈខាងគ្រួសារមន្ត្រី ដែលមានស័ក្តិយសខ្ពស់ ហើយដែលសុំអនុញ្ញាត

បួសនោះ ក្រោមអធិបតីភាពនៃព្រះករុណានាំជាម្ចាស់ជីវិតលើត្បូង ត្រូវមានចំនួនតែ១២នាក់យ៉ាងច្រើនបំផុត។ គេនិមន្តព្រះសង្ឃមកចម្រើនព្រះបរិត្តចំពោះបព្វជ្ជាបេក្ខៈទាំងនោះនៅពេលល្ងាច។ លុះព្រឹកឡើងនាគទាំងអស់ដើរជាក្បួនដង្ហែទៅវត្ត។ ដោយហេតុថា ព្រះសម្ពុទ្ធជាក្សត្រ ហើយទ្រង់ចេញពីជាតិក្សត្រនោះទៅដើម្បីស្រោចស្រង់សត្វលោក គួរតែក្បួនដង្ហែនាគនោះមានទំនងជាក្បួនដង្ហែស្តេច ប្រសិនបើអាចនឹងធ្វើបាន។ នៅក្នុងក្បួនដង្ហែនោះ មានភ្លេងនិងអ្នកវាយស្គរ មានប្រុសស្រីកាន់ជើងពានប្រាក់ដែលមានដាក់ស្បង់ បាត្រនិងទៀនធូប តុបតែងលម្អដើរពីមុខនាគដែលស្លៀកពាក់ដូចព្រះអង្គម្ចាស់ពីដើមហើយដែលជិះសេះមានបាំងក្លស់យ៉ាងធំផង។

បន្ទាប់មក នាគទាំងអស់ដើរចូលទៅក្នុងព្រះវិហារ ហើយអុជទៀននិងធូប រួចក្រាបថ្វាយបង្គំព្រះពុទ្ធរូប។ តពីនេះទៅ នាគនោះដើរឆ្ពោះទៅមុខឧបជ្ឈាយ៍ដែលមានព្រះសង្ឃចំនួន២០អង្គ ហើយក៏សុំបួស។

៥-បុណ្យចូលវស្សា មាននៅប្រទេសកម្ពុជា ដូចជាប្រទេសដែលកាន់លទ្ធិព្រះពុទ្ធសាសនាដែរ។ ព្រះសង្ឃត្រូវសម្រាកចំនួន៣ខែជាដំបូងក្នុងរដូវភ្លៀង។ នៅឱកាសបុណ្យនោះ ក្នុងវត្តនីមួយៗត្រូវមានអុជទៀនវស្សាដែលគេយកឈើមកធ្វើបំពង់លាបពណ៌ និងតុបតែងលម្អ ហើយគេចាក់ក្រមួនក្នុងបំពង់នោះជុំវិញប្រឆេះ។ ជួនណាទៀនវស្សានោះ គេធ្វើពីក្រមួនសុទ្ធតែម្តងហើយមានទំហំប៉ុនពីរធ្នាប់កម្ពស់ពីរហត្ថ។

នៅក្នុងព្រះបរមរាជវាំង ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ឬសមាជិកនៃព្រះរាជវង្សានុវង្ស អុជទៀនវស្សា៤ដើមដោយឧឡារិក។ ទៀនទី១ អុជទុកក្នុងហោព្រះ ក្នុងព្រះបរមរាជវាំង។ ទៀនទី២ អុជក្នុងហោព្រះអដ្ឋិក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ដែលមានកោដ្ឋព្រះធាតុនៃព្រះរាជវង្សានុវង្ស។ ទៀនទី៣ អុជទុកក្នុងហោព្រះខ័នរាជ្យ។ ទៀនទី៥ អុជទុកនៅក្នុងព្រះវិហារព្រះកែវមរកត។

ក្រៅពីនេះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានត្រាស់បង្គាប់ឲ្យនាំ

ទៀនវស្សា ទៅដាក់វត្តនៅក្នុងទីក្រុងនិងវត្តជិតខាង។ ចំនួនទៀនវស្សាព្រះរាជទ្រព្យទាំងអស់១៩ដើម។

មុនថ្ងៃចូលវស្សា គឺនៅថ្ងៃពេញបូណ៌មីខែអាសាឍ ការអ៊ូអរតែងមាននៅគ្រប់វត្តទាំងអស់។ នៅពេលព្រលប់គេធ្វើពិធីដង្ហែទៀនវស្សាជាមួយនឹងសាដកសម្រាប់ព្រះសង្ឃស្រង់ទឹក ហើយនឹងបរិក្ខារផ្សេងផង។

៦-បុណ្យភ្ជុំបិណ្ឌ ធ្វើនៅគ្រប់វត្តទាំងអស់ចំនួន១៥ថ្ងៃ គឺចាប់តាំងពីថ្ងៃ១រោចដល់ថ្ងៃ១៥ រោច ខែភទ្របទ (កញ្ញា) ដើម្បីឧទ្ទិសចំពោះញាតិសន្តានដែលបានអនិច្ចកម្មបាត់ទៅហើយ។

ព្រះបាទយសោវរ្ម័ន ដែលសោយរាជសម្បត្តិពីគ.ស.៨៨៩ដល់៩១០ (នៅអង្គរ) បានចារឹកទុកថា ព្រះអង្គបានប្រគេនចង្ហាន់រៀងរាល់ខែ ដល់ព្រះសង្ឃគង់នៅក្នុងកុដិជាច្រើន ដែលទ្រង់បានកសាង ដើម្បីឧទ្ទិសដល់មនុស្សស្លាប់ក្នុងចម្បាំង និងព្រលឹងមនុស្សដែលគេបោះបង់ចោល។

ក្រៅពីបុណ្យដែលបានរៀបរាប់ខាងលើនេះ មានបុណ្យផ្សេងៗឯទៀតៗជាច្រើន ដូចជាបុណ្យចេញវស្សា បុណ្យកឋិន បុណ្យសំពះព្រះខែ (អកអំបុក) ។ល។ បុណ្យទាំងនោះមានរបៀបធ្វើខុសគ្នាបន្តិចៗ ដោយមានបុណ្យខ្លះធ្វើតាមរបៀបសាសនាព្រាហ្មណ៍ តែការបញ្ចូលទម្លាប់សាសនាព្រាហ្មណ៍យ៉ាងនេះមិនអាចនាំឲ្យផ្ទុយគ្នានឹងច្បាប់ព្រះសម្ពុទ្ធឡើយ។

នៅប្រទេសកម្ពុជា សាសនាព្រះពុទ្ធបានរុងរឿងលូតលាស់យ៉ាងប្រសើរណាស់ ដោយគេបានកសាងវត្តនិងសាលាបាលីជាច្រើន នៅទីរួមខេត្រខ្លះក្នុងប្រទេសកម្ពុជា។ តាំងពីយូរណាស់មកហើយ បុណ្យពុទ្ធាជយន្តិ (បុណ្យវិសាខបូជា) គេធ្វើជាដរាបនៅគ្រប់តែវត្ត តែកាលពីខែតុលា គ.ស. ១៩៥២ នៅក្រុងភ្នំពេញ គេបានរៀបពិធីបុណ្យនេះដើម្បីទទួលព្រះសារីរិកធាតុព្រះសម្ពុទ្ធនិងព្រះអរហន្តធាតុនៃព្រះអគ្គសាវ័កទាំងពីរព្រះអង្គគឺ ព្រះសារីបុត្រនិងព្រះមោគ្គល្លាន។ ពិធីបុណ្យនេះ គេធ្វើនៅក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាជា

អម្ចាស់ជីវិតលើត្បូង និងសម្ដេចសង្ឃនាយកទាំងពីរគណៈ ព្រមទាំងវរជនបរទេសដែលកាន់លទ្ធិព្រះពុទ្ធសាសនាដែរ។ រួចពីនោះមក គេបានសង់ចេតិយមួយយ៉ាងខ្ពស់ត្រដឹម្ភ កណ្ដាលក្រុងភ្នំពេញ ដើម្បីបញ្ចុះព្រះសារីរិកធាតុ និងព្រះអរហន្តធាតុនោះ ទុកជាទីរឭកគោរពបូជាតទៅអនាគតកាល។ ក្នុងរឿងនេះយើងសូមបំភ្លឺដល់អ្នកអានថា បុណ្យសម្ពោធពុទ្ធសករាជគម្រប់ ២៥០០ ព្រះវស្សា ដែលធ្វើនៅក្នុងប្រទេសផ្សេងៗ មានកំណត់ពេលវេលាខុសពីគ្នា ដូចយ៉ាងនៅប្រទេសឥណ្ឌា កោះសេរីលង្កា និងភូមា សម័យដែលត្រូវធ្វើបុណ្យនេះនៅដើមឆ្នាំមុន តែនៅប្រទេសសៀម កម្ពុជា លាវ និងយៀកណាម បុណ្យនេះគេធ្វើនៅចុងឆ្នាំក្រោយ។ ហេតុដូច្នេះ បានជាកាលបរិច្ឆេទនោះខុសគ្នាមួយឆ្នាំ គឺប្រទេសឥណ្ឌា កោះសេរីលង្កា និងភូមា ត្រូវធ្វើពិធីបុណ្យនេះនៅថ្ងៃ ២៤ ឧសភា គ.ស.១៩៥៦ ចំណែកប្រទេសអាស៊ីភាគអាគ្នេយ៍ ដែលបានរៀបរាប់ខាងលើរួចមកហើយនោះ ត្រូវធ្វើបុណ្យសម្ពោធពុទ្ធសករាជគម្រប់ ២៥០០ព្រះវស្សានៅថ្ងៃ១៣ ឧសភា គ.ស.១៩៥៧។ យើងមានសេចក្ដីសោកស្ដាយជាទីបំផុត ចំពោះការដែលកំណត់ធ្វើបុណ្យខាងលើនេះខុសគ្នាមួយឆ្នាំដូច្នេះ។ រឿងនេះបើតាមយោបល់យើងយល់ថា មានតែអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនានៅប្រទេសខ្លះទេ ទើបវិនិច្ឆ័យបាន។

ម្យ៉ាងទៀត យើងសូមរំឭកថា នៅឱកាសពាក់កណ្ដាលសករាជនៃព្រះពុទ្ធសាសនា យើងត្រូវធ្វើបុណ្យខួបនៅក្នុងទីក្រុងណា ដែលមានសង់ចេតិយបញ្ចុះព្រះសារីរិកធាតុព្រះពុទ្ធ។ យើងសូមទទួលអំណរគុណដ៏ជ្រាលជ្រៅចំពោះសមាគម «មហាពោធិ» នៅប្រទេសឥណ្ឌា ដែលបានអញ្ជើញមកជាកិត្តិយសជួយឧបត្ថម្ភដល់ពិធីបុណ្យទទួលព្រះសារីរិកធាតុនេះពីឆ្នាំ១៩៥២។ ដើម្បីជាអនុស្សាវរីយ៍ចំពោះព្រះសារីរិកធាតុដែលបានស្ដេចមកកាន់ប្រទេសកម្ពុជានោះ គេបានសាងព្រះចេតិយ១យ៉ាងល្អកណ្ដាលក្រុងភ្នំពេញ ហើយគេបម្រុងនឹងធ្វើបុណ្យសម្ពោធទុកជាទីគោរពបូជាតទៅអនាគត។ យើងសង្ឃឹមថា គង់មាន

ឱកាសណាមួយ យើងនឹងបានទទួលព្រះសារីរិកធាតុជាពិសិដ្ឋ អំពីប្រទេសឥណ្ឌា ឬកោះសេរីលង្កា ឬក៏ប្រទេសភូមាមកបញ្ចុះក្នុងព្រះចេតិយនោះជាមិនខាន។

នៅទីបំផុតនេះ សូមបញ្ចប់សេចក្តីថ្លែងការណ៍ខាងលើ ហើយសូមប្រសិទ្ធពរចំពោះពិធីបុណ្យសម្ពោធពុទ្ធសករាជគម្រប់ ២៥០០ព្រះវស្សា ដែលជាគោលចារឹកនៃព្រះពុទ្ធសាសនា ហើយដែលនាំឲ្យបានសេចក្តីសុខក្សេមក្សាន្តក្នុងអនាគតកាល។

## បុរាណសុភាសិត

១-មនុស្សដែលស្វែងរកភោគទ្រព្យ ដោយល្បែងស៊ីសង។

២-មនុស្សដែលស្វែងរកកិត្តិយស ដោយដាក់ខ្លួនឲ្យអ្នកដទៃប្រើប្រាស់តាមត្រូវការ។

៣-មនុស្សដែលស្វែងរកសេចក្តីសប្បាយដោយធ្វើជាស្មូមយាចក( អ្នកសូមទាន )

៤-មនុស្សដែលស្វែងរកកិត្តិយស ដោយចោរកម្ម។

បុគ្គលទាំង៤ពួកនេះជាមនុស្សពាលអាប់ឥតប្រាជ្ញាត្រូវទទួលនូវសេចក្តីវិនាសក្នុងអនាគតជាប្រាកដ។

# រឿងគាមណិចន្ទ

## ជាតកដ្ឋកថា ចតុត្ថភាគ តិកនិបាតវណ្ណនា
## ការពិភាក្សាជ្រើសរើសរជ្ជទាយាទ

ក្រោយពេលដែលបានថ្វាយព្រះភ្លើងបូជាព្រះបរមសព នៃព្រះបាទជនសន្ធ ព្រះចៅក្រុងពារាណសីយ៉ាងឱឡារិកក្រៃលែងរួចហើយ នៅក្នុងទិវាទី៧ គណៈរដ្ឋមន្ត្រីចតុស្តម្ភ ព្រមទាំងព្រាហ្មណ៍ព្រឹទ្ធបណ្ឌិត កវី រាជានុសិទ្ធ ជាក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក បានមកជួបជុំប្រជុំគ្នានៅមហាសាលវិចិត្រ នាខាងមុខព្រះលានបរមរាជវាំង ដើម្បីជ្រើសរើសបេក្ខជនរជ្ជទាយាទ ទទួលគ្រងរាជសម្បត្តិទៅ។ បណ្តាឥស្សរជនទាំងនោះ ឥស្សរជនភាគមួយ ឲ្យយោបល់ថា «ព្រះករុណាជាម្ចាស់ជីវិត ដែលទ្រង់សោយព្រះទិវង្គតទៅ ទ្រង់មានព្រះរាជបុត្រមកុដរាជកុមារជាព្រះសន្តិវង្សដែរ ប៉ុន្តែព្រះរាជកុមារនេះ នៅជាព្រះកុមារតូចពេក ទើបនឹងមានព្រះជន្ម៧ឆ្នាំ ទោះបីទ្រង់បានសិក្សាគម្ពីរត្រៃវេទព្រមទាំងកិច្ចការលោកិយចេះចប់សព្វគ្រប់អំពីវររាជបិតាហើយ ក៏មិនគួរនឹងថ្វាយរាជ្យបានដែរ ពីព្រោះរាជសម្បត្តិ មិនមែនជាភ័ព្វវាសនាផ្ទាល់របស់បុគ្គលមួយរូបទេ តាមពិត គឺជាភ័ព្វវាសនានៃប្រជារាស្ត្រទូទៅដែរ បើព្រះរាជកុមារអង្គនេះនៅជាក្មេងពេក រមែងតែឆោតភ័ន្តច្រឡំ មិនយល់វែងឆ្ងាយ ចាត់ការរដ្ឋ ប្រទេសជាតិ នឹងធ្លាក់ចុះក្នុងអនាធិបតេយ្យ ដែលនាំឲ្យរាស្ត្រប្រជាក្តៅក្រហាយមិនលែងឡើយ។ ឥស្សរជនមួយភាគទៀតឲ្យយោបល់ថា «អស់លោកយល់ដូច្នេះ ក៏ប្រសើរហើយ ប៉ុន្តែតាមយោបល់យើងថា «មនុស្សពិសេស ដែលមានប្រាជ្ញា ស្មារតី ប៉ិនប្រសប់វាងវៃ មិនមែននៅចំពោះតែចាស់ព្រឹទ្ធាចារ្យទេ គង់ក្មេងខ្លះ អាចយល់ដឹងវាងវៃជាងក៏មាន។ អស់លោកជ្រាបហើយថា ហេតុអ្វីបានជាព្រះមកុដរាជកុមារនេះ ទ្រង់មានព្រះនាមថា «អាទាសមុខរាជកុមារ» ? មិនគឺគេថ្វាយព្រះ

នាម ដោយលក្ខណៈព្រះភក្ត្រថ្លាដូចផ្លែកញ្ចក់មានទេឬ? ត្រង់ន័យថា «ព្រះភ័ក្ត្រថ្លាឆ្លុះដូចកញ្ចក់នេះ ឃើញថាសមហេតុសមផលណាស់ទៅទៀត គឺព្រះរាជកុមារនេះវាងវៃហួសពីមនុស្សចាស់ បើទ្រង់សម្លឹងទតអ្វីមួយ របស់នោះដូចជាញែកជាតុប្រាប់ព្រះអង្គឥតសល់ បើទ្រង់ទតទឹកមុខមនុស្សវិញ ក៏ដូចជាមនុស្សនោះ ក្រាបទូលថ្លែងរឿងអាថ៌កំបាំងថ្វាយព្រះអង្គដែរ។ ហេតុដូច្នេះហើយ បានជាទ្រង់អាចសិក្សាត្រៃវេទនិងវិជ្ជាការទូទៅក្នុងលោក ចេះចប់សព្វគ្រប់ ដែលគ្មានក្មេងណាប្រដូចបានឡើយ។ តាមយោបល់ពួកយើងថា ការថ្វាយរាជសម្បត្តិចំពោះ អាទាសមុខរាជកុមារសមគួរណាស់ គ្មានការវិនាសអន្តរាយអ្វីឡើយ។

យោបល់ទាំងពីរនេះ បានចេញមិុតប្រាយប្រឆាំងគ្នាអស់រយៈវេលាជិត ២ម៉ោង គឺដល់ម៉ោង៧ល្ងាច ក៏បានស្របគ្នាវិញថា ត្រូវធ្វើការពិសោធ ចំពោះប្រាជ្ញាញាណរបស់ព្រះរាជកុមារជាមុនសិន សឹមសម្រេចយកលទ្ធផលជាខាងក្រោយ។

## វិញ្ញាសាពិសោធថ្វាយរាជសម្បត្តិ

កាំនៃចក្រ គឺវស្សានរដូវបានវិលមកដល់ ធម្មជាតិទាំងឡាយដែលត្រូវរស្មីព្រះអាទិត្យហួតហែងធ្វើឲ្យក្រៀមស្រពោន ក៏ប្រែជាចាប់បញ្ចេញស្លឹកស្រស់ខ្ចី បន្លេចបិុចចេញបុប្ផាប្រកបពណ៌ផ្សេងៗ និងផ្សាយក្លិនឈ្ងុយឈ្ងប់ រេចុះរេឡើងរេរាំតាមខ្សែព្រះពាយ ដូចជាបង្ហាញនូវក្តីរីករាយសប្បាយដែលវាទន្ទឹងយូរហើយ។

នៅមហាសាលវិនិច្ឆ័យខាងមុខព្រះបរមរាជវាំង ខាងក្នុង មានព្រះរាជវង្សានុវង្ស និងឥស្សរជនជាន់ខ្ពស់នៃព្រះរាជាណាចក្រជាច្រើនរយនាក់ អង្គុយលើជើងតាំងជាសង្កាត់ជួរៗ ហើយនៅខាងក្រៅវិញ មានប្រជាជន កកស្ទះខ្លះឈរ ខ្លះអង្គុយនៅជុំវិញសាល។

មិនយូរប៉ុន្មាន ក្រុមរាជបុរសបានឲ្យសញ្ញាថា ព្រះអាទាសមុខរាជកុមារ យាងមកដល់ហើយ។ ឧត្តមជនជាច្រើនរូប ឈរចាំថ្វាយព្រះកិត្តិយសនៅមាត់ផ្លូវចូលទៅកាន់មហាសាល។ គេនាំព្រះរាជដំណើរចូលទៅដល់ព្រះរាជបល្ល័ង្កមួយ ដែលវិចិត្ររចនារៀបចំយ៉ាងស្អាត នៅខាងមុខទីប្រជុំ។ ឥស្សរជនទាំងអស់ដែលក្រោកឈរចាំទទួលព្រះរាជដំណើរ ជាមួយនឹងសូរសព្ទជយឃោសនៃពួកប្រជារាស្ត្រក៏អង្គុយចុះទៅវិញតាមព្រះរាជបញ្ជា។ព្រះរាជកុមារទ្រង់មានព្រះសូរសីហនាទ ស្រស់ស្រាយរាក់ទាក់ជាមួយនឹងទីប្រជុំមួយសន្ទុះ ដោយសម្រួលព្រះឥរិយាបថបន្តិចមក។ លំដាប់នោះ ប្រធានទីប្រជុំ បានបញ្ជាឲ្យភ្នាក់ងារ នាំវិញ្ញាសាចូលមកថ្វាយព្រះរាជកុមារ។

## វិញ្ញាសាទី១

វាំងននខ្មៅអង្កាញ់ សន្ធឹងនៅនាចំហៀងខាងស្តាំ ដែលរចនាវិចិត្រដោយសរសៃអំបោះមាស ជាក្បូរក្បាច់រស់រវើក បានបន្លេចចេញនូវរូបមនុស្សចម្លែកម្នាក់ ដែលដើរកណ្តាលបុរសអ្នកអមពីរនាក់។ មនុស្សនោះ ពាក់អាវសកត្រង់ស្លៀកសំពត់ចងក្បិនស ហើយមានសំពត់សមួយផ្ទាំងពានា សមជាអាចារ្យ ប៉ុន្តែឫកពាក្រឡេមក្រឡឹម ត្រូវនឹងមុខកំប្លុចផង នាំឲ្យអ្នកទាំងពួងលួចសើចស្ទើរគ្រប់គ្នា។ លុះដើរចូលទៅដល់ខាងមុខព្រះភ័ក្ត្រព្រះរាជកុមារ អ្នកនាំទាំងពីរនាក់ ក៏បង្គាប់ឲ្យមនុស្សនោះអង្គុយចុះ ហើយឲ្យថ្វាយបង្គំព្រះរាជកុមារ រួចឲ្យអង្គុយនៅមួយកន្លែងយ៉ាងស្រួល។

ក្រោយដែលបុរសនោះអង្គុយស្រួលបួលហើយ លោកបុរោហិតបានចូលទៅក្រាបថ្វាយបង្គំទូលព្រះរាជកុមារថា

បពិត្រព្រះរាជកុមារជាម្ចាស់! សូមល្អងធូលីព្រះបាទ ទ្រង់ជ្រាប បុរសនេះនៅក្នុងរជ្ជកាលនៃព្រះបិតាព្រះអង្គ លោកជាវិស្វករបច្ចេកទេសយ៉ាងជំនាញ។ លោកចេះដឹងខាងវត្ថុវិជ្ជា អាចមើលស្គាល់ទឹកដីជយភូមិ រហូតដល់អាចមើល

ដឹងនូវភូមិឋានដែលមានកែវ៧ប្រការ។ លោកជាអាចារ្យយ៉ាងសំខាន់អាចស្គាល់នូវលក្ខណៈគុណទោសរបស់ដី សូម្បីតែទីវាំង ព្រះរាជដំណាក់ទាំងនេះក៏លោកអាចារ្យនេះបានកំណត់ឲ្យដែរ។ បពិត្រព្រះរាជកុមារជាម្ចាស់! ដោយអាស្រ័យហេតុនេះ សូមព្រះអង្គទ្រង់ប្រោសប្រណីតែងតាំងលោកអាចារ្យនេះក្នុងឋានន្តរស័ក្តិខ្ពង់ខ្ពស់ណាមួយ ដើម្បីជាប្រយោជន៍ដល់ព្រះរាជាណាចក្ររបស់ព្រះអង្គ។

ព្រះអង្គម្ចាស់ លុះទ្រង់ព្រះសណ្តាប់ពាក្យលោកបុរោហិតក្រាបទូលដូច្នោះ ទ្រង់ពិនិត្យមើលរូបបុរសនោះដោយព្រះប្រាជ្ញាញាណ ពុំឃើញលក្ខណៈត្រង់ណាឲ្យសមនឹងពាក្យបុរោហិតក្រាបទូលសោះ។ ផ្ទុយទៅវិញ ទោះបីព្រះអង្គនៅវ័យក្មេង ទើបនឹងមានព្រះជន្មវស្សា៧ឆ្នាំ ក៏អាចស្គាល់ច្បាស់ថា បុរសនោះ ពុំមែនជាជាតិមនុស្សទេ គឺពិតជាសត្វស្វា ពីព្រោះសត្វស្វា ទោះបីគេយកវាមកបង្ហាត់ឲ្យគ្រាប់តាមអាការៈនៃមនុស្សហើយ គេតុបតែងវាឲ្យដូចជាមនុស្សសុទ្ធសាធ ក៏វាពុំអាចចោលនូវលក្ខណៈជាស្វារបស់វាបានដែរ ហើយជាធម្មតារបស់សត្វស្វា វាមិនដែលចេះចាត់ការ ឬកសាងអ្វីមួយដែលពុំទាន់ស្រេច ឲ្យសម្រេចបានទេ ផ្ទុយទៅវិញ វាចេះដឹងតែខាងបំផ្លាញនូវអ្វីៗ ដែលគេធ្វើស្រេចហើយឲ្យហិនហោចទៅវិញតែប៉ុណ្ណោះ។ លុះទ្រង់ព្រះចិន្តាដូច្នេះហើយ ព្រះអង្គទ្រង់តបនឹងវិញ្ញាសានោះ ដោយព្រះគាថាថា

**នាយំ ឃរានំ កុសលោ លោលោ អយំ វលីមុខោ**
**កតំ កតំ ខោ បទូសេយ្យ ឯវំ ធម្មមិទំ កុលំ ។**

វានេះ ពុំមែនជាអ្នកប៉ិនប្រសប់ខាងការចាត់ការ ឬស្ថាបនាផ្ទះសំបែងបានទេ វាជាសត្វលីលា មានមុខកំប្លុច ពូកែតែបំផ្លាញនូវអ្វីៗដែលគេធ្វើស្រេចហើយតែប៉ុណ្ណោះ ត្រកូលវានេះ មានតែទំនៀមដូច្នេះឯង។

ឮព្រះបន្ទូលដូច្នោះ ឥស្សរជនទាំងអស់ក៏ទះដៃប្រស់ឡើង ជាសញ្ញានៃ

ការយល់ស្របព្រះយោបល់ ហើយក្រាបទូលថា ពិតប្រាកដដូចព្រះបន្ទូលមែនហើយ។ ព្រឹត្តិការណ៍នេះ ក៏ប្រកបដោយជោគជ័យយ៉ាងក្រៃលែង ដោយការថ្វាយសព្ទសាធុការពរអំពីប្រជានិករដែលនៅរង់ចាំដឹងក្នុងរឿងដោះស្រាយនោះ។ រួចហើយ គេក៏នាំសត្វស្វាក្លែងជាមនុស្សត្រឡប់ចូលទៅវិញ។

## វិញ្ញាសាទី២

ក្រោយពេលដែលស្ងប់ស្ងាត់ពាក្យខ្សិបខ្សៀវគ្នា ពណ៌នាសរសើរអំពីព្រះប្រាជ្ញាញាណរបស់ព្រះរាជកុមារដ៏តូចនោះមកបន្តិចវាំងននខ្មៅដដែល ក៏បន្លេចចេញរូបបុរសពិសេសម្នាក់ទៀត ដែលមានបុរសពីរនាក់ដើរអមចូលក្រាបទូលថ្វាយព្រះរាជកុមារដូចមុនទៀត។បុរសនោះស្លៀកពាក់តាមរបៀបមន្ត្រីកិត្តិយសយ៉ាងសង្ហា ប៉ុន្តែមានអាការៈប្រហែលគ្នានឹងបុរសលើកមុនដែរ។ ក្រោយដែលបានអង្គុយនៅមួយកន្លែងសមគួរហើយ លោកបុរោហិតព្រឹទ្ធាចារ្យ ក៏ចូលទៅប្រណមក្រាបទូលព្រះរាជកុមារថា

បពិត្រព្រះរាជកុមារជាអម្ចាស់! បុរសឧត្តមនេះ កាលក្នុងរាជ្យនៃព្រះបរមរាជបិតារបស់ព្រះអង្គ គាត់ធ្លាប់បានធ្វើជាមន្ត្រីខាងតុលាការ ទីជាឧកញ៉ាយោមរាជច្រើនដងហើយ គាត់ជាបុរសជំនាញ ចេះចាំច្បាស់លាស់ណាស់ខាងតម្រាកាត់ក្តី ហើយវាងវៃស្គាល់ចិត្តអធ្យាស្រ័យរបស់មនុស្សទូទៅ អាចកាត់ក្តីវិនិច្ឆ័យបានដោយយុត្តិធម៌ រកអ្នកណាមួយប្រដូចដោយកម្រ បពិត្រព្រះរាជកុមារជាអម្ចាស់! សូមព្រះអង្គទ្រង់សង្គ្រោះប្រោសប្រាណព្រះរាជទានឋានន្តរស័ក្តិដល់បុរសនេះ ឲ្យបានជាបរិនាយកក្រសួងតុលាការ ដើម្បីជាប្រយោជន៍ដល់ប្រជារាស្ត្រ រួមជាតិរបស់ព្រះអង្គ ដូចពេលមុនផង ទើបសមគួរ សូមទ្រង់ជ្រាប។

ព្រះរាជកុមារ ទ្រង់ពិចារណារូបលក្ខណៈ របស់បុរសចម្លែកនេះ ទ្រង់យល់ផ្ទុយអំពីពាក្យក្រាបបង្គំទូលរបស់លោកបុរោហិត ទ្រង់មានព្រះចិន្តាថា

«ជម្មតាមនុស្សទូទៅ ពុំឃើញមានមនុស្សណាម្នាក់មានរោមដុះស្រមូវដូចបុរសនេះសោះ បុរសនេះប្រាកដជាពុំមែនមនុស្សជាតិទេ វាជាសត្វស្វា ជាសត្វឥតចិត្ត។ វានេះប្រាកដជាពុំអាចធ្វើការកាត់ក្តី ដូចពាក្យគេថានេះបានឡើយ។ លុះទ្រង់ជ្រាបច្បាស់ដូច្នេះហើយ ទើបទ្រង់មានបន្ទូលតបវិញ្ញាសា ដោយព្រះគាថាជាលើកទីពីរថា

**នយិទំ ចិត្តវតោ លោមំ នាយំ អស្សាសិកោ មិគោ**
**សត្ថុំ មេ ជនសន្ធេន នាយំ កិញ្ចិ វិនាជាតិ ។**

រោមរបស់មនុស្សអ្នកមានចិត្ត ពុំមែនដូច្នេះទេ វានេះគឺជាម្រឹគដែលពុំអាចបេះសម្រួលចិត្តអធ្យាស្រ័យនៃជនទូទៅបានឡើយ ព្រះបាទជនសន្ធអម្ចាស់ ជាព្រះវររាជបិតារបស់ខ្ញុំ ទ្រង់បានពោលទុកនូវក្បួនតម្រាថា «វានេះជាសត្វឥតបេះដឹងអ្វីបន្តិចឡើយ»។

ឮព្រះបន្ទូលសូរសីហនាទដូច្នេះ ពួកឧត្តមជនទាំងអស់ ក៏ថ្វាយសទ្ធុសញ្ញាដូចមុន ជាមួយនឹងបណ្តារាស្ត្រ។ គេទាំងឡាយមានបីតិប្រាមោទ្យយ៉ាងក្រៃលែង ចំពោះការពោលភាសិតយ៉ាងជាក់លាក់របស់ព្រះរាជកុមារ ដែលឋិតនៅក្នុងកុមារភាពដូច្នេះ។ ក្រោយពេលដែលត្រូវនាំបុរសស្វានោះចេញទៅ និងពេលដែលស្ងប់ស្ងៀមបន្តិចមក គេក៏បញ្ជាក់ឲ្យនាំបុរសម្នាក់ ចូលមកក្រាបបង្គំគាល់ទៀត។

## វិញ្ញាសាទី៣

វាំននខ្មៅដ៏វិចិត្រដដែលនោះ ហាក់ដូចជាពុំអស់ចិត្ត ក៏បន្លេចចេញនូវបុរសម្នាក់ ជាមួយនឹងអ្នកដើរអមពីរនាក់មកទៀត។ បុរសនោះស្លៀកពាក់ស្អាតបាត តែសម្លៀកបំពាក់ពុំបានជាថ្លៃថ្នូរទេ តាមរបៀបដូចជាមនុស្សអ្នកស្រុកសាមញ្ញ។ បុរសទីបីនេះ ក៏មានជំហរទាបជាងអ្នកដើរអម ហើយមានដំណើរតេះ

តះៗ ដូចជាបុរសទាំងពីរមុនដែរ។ ក្រោយពេលដែលបុរសនោះ លុតជង្គង់ក្រាបថ្វាយបង្គំព្រះបរមរាជកុមាររួចអង្គុយក្នុងទីសមគួរហើយ លោកបុរោហិតក៏ចូលទៅក្រាបបង្គំទូលព្រះរាជកុមារថា

បពិត្រព្រះរាជកុមារជាអម្ចាស់! បុរសរូបនេះ ពិតមែនតែគាត់ជាមនុស្សមានរូបអាក្រក់ មិនសមជាទីពិតពិលរមិលមើលនៃជនទូទៅមែន ប៉ុន្តែ ក្នុងកាលរាជ្យរបស់ព្រះវររាជបិតាព្រះអង្គ គាត់មានកេរ្តិ៍ឈ្មោះល្បីទូទៅទាំងនគរថា ជាអ្នកមានវត្តប្រណិប័តន៍ បម្រើមាតាបិតា ព្រមទាំងមានការគោរពត្រកូលរៀមច្បងណាស់ នឹងរកបុរសណាមួយប្រដូចដោយកម្រ។ ហេតុនេះ គួរតែព្រះអង្គម្ចាស់! ទ្រង់មានព្រះមេត្តាប្រោសប្រណីសង្គ្រោះគាត់ផង។

ម្តងនេះ ព្រះរាជកុមារក៏ទ្រង់ពិនិត្យពិចារណារូបលក្ខណៈបុរសនោះដោយវិចារណញ្ញាណទៀត ទ្រង់យល់ច្បាស់ថា «ធម្មតាសត្វស្វាទាំងឡាយជាសត្វមានចិត្តរបុិលរប៉ូចខូចណាស់ វាពុំដែលស្គាល់គុណនិងទោសចំពោះឧបការគុណនៃជនណាមួយ ហើយមិនចេះដឹងធ្វើអំពើល្អតបតដល់គេវិញបានដូច្នេះទេ វាចេះធ្វើតែអំពើអាក្រក់ ទៅតាមចិត្តរបុិលរប៉ូចភ្លាមៗរបស់វាតែប៉ុណ្ណោះ។ លុះទ្រង់មានព្រះចិន្តាដូច្នេះហើយ ព្រះអង្គទ្រង់មានព្រះរាជបន្ទូលតបវិញ្ញាសា ដោយព្រះគាថាជាលើកទីបីថា

**ន មាតរំ បិតរំ វា ភាតរំ ភគិនី សកំ**
**ភរេយ្យ តាទិសោ បោសោ សិដ្ឋំ ទសរថេន មេ**

ព្រះបាទទសរថ ជាព្រះបរមរាជបិតារបស់ខ្ញុំ ទ្រង់បានប្រៀនប្រដៅដូច្នេះថា «សត្វរបៀបនេះ វាមិនអាចនឹងចេះចិញ្ចឹមម្តាយឪពុក ឬបងប្អូនប្រុស-ស្រីរបស់ខ្លួនបានទេ»។

ព្រះបន្ទូលសូរសីហនាទលើកទីបីនេះ ក៏ប្រៀបបាននឹងសូរសព្ទកងរំពងនៃមហាភេរីរាជដែលគេទូងឲ្យលាន់ឡើងនៅជិតផ្ការទឹកល្ហល្ហាច។ ឯសូរសម្រែក

គឹកកងហ៊ោ ថ្វាយជយឃោសនិងសព្ទសាធុការពររបស់ប្រជាជនដ៏ណែន ណាន់តាន់តាប់ ក៏លាន់ឡើងប្រៀបបាននឹងស្នូរលាន់តបរបស់មហាភេរីរាជ ដែលចេញមកពីផ្ទៃធំធេងនៃទឹកដែរ ក្រោយពេលដែលឥស្សរជនទាំងអស់ ថ្វាយយោបល់ស្រុបចំពោះព្រះរាជបន្ទូលហើយ លោកបុរោហិត បានសុំព្រះរាជ វរោកាសថ្វាយព្រះរាជស្វាមីភក្តិ និងប្រកាសជាឱឡារិក ចំពោះទីប្រជុំក្រុមប្រឹក្សា ទាំងអស់ថា

អស់លោកទាំងឡាយ! នេះជាវារៈបញ្ចប់នៃវិញ្ញាសាពិសោធថ្វាយរាជ្យ សម្បត្តិ អស់លោកភាគខ្លះដែលយល់ថា ព្រះរាជកុមារទ្រង់នៅក្នុងកុមារ ភាពពេក ក្រែងខ្សោយព្រះវិចារណញ្ញាណ ពុំអាចនឹងដឹកនាំប្រជារាស្ត្របាន នោះ ឥឡូវអស់លោកបានឃើញច្បាស់ផ្ទាល់ភ្នែកស្រាប់ហើយ។ អំបាល សត្វដែលមានអវយវៈដូចមនុស្ស ចេះដើរជើងពីរ ចេះក្រាបបង្គំ ចេះអង្គុយ ប្រណម ហើយតុបតែងស្លៀកពាក់ដូចជាមនុស្សសុទ្ធសាធ ក៏ព្រះរាជបុត្រទ្រង់ ស្គាល់ច្បាស់ ពុំអាចអ្នកណាយកមកបន្លំភ័ន្តបង្វិលព្រះសតិសម្បជញ្ញៈព្រះអង្គ បានឡើយ។ ជាពិសេសទៅទៀត ព្រះអង្គទ្រង់វាងវៃជាបំផុត អាចជ្រើសរើស យកភាសិតក្បួនតម្រាដំបូន្មានយ៉ាងសមក្រៃលែង មកដោះស្រាយវិញ្ញាសា នេះយ៉ាងត្រឹមត្រូវ ដែលនឹងរកបុគ្គលណាមួយមកប្រដូចបានដោយកម្រណាស់។ ដូច្នេះក្នុងទីនេះ យើងខ្ញុំនឹងសូមបញ្ចប់ការពិសោធ ហើយកំណត់វេលា៧ថ្ងៃខាង មុខទៀត នឹងសូមប្រកាសលទ្ធផលជាស្ថាពរ។

ទីប្រជុំទាំងអស់បានលាន់ដោយសព្ទស្នូរទះដៃ ជាសញ្ញានៃការយល់ ព្រម។ ប្រជានិករនៅខាងក្រៅ ក៏ស្រែកជយឃោសលាន់រំពងគឹកកង ព្រមទាំង នាំគ្នាស្រែកថ្វាយប្រជាមតិចំពោះព្រះរាជកុមារ ជាឱឡារិកស្ទើរភ្លូកភ្លឹកទីព្រះ លាននៃព្រះរាជវាំង។

បន្ទាប់មក ព្រះរាជកុមារទ្រង់មានព្រះបន្ទូលស្រស់ស្រាយ ជាមួយនឹង ក្រុមឥស្សរជន និងប្រជារាស្ត្រទាំងនោះយ៉ាងរីករាយរួចហើយ ទើបព្រះអង្គទ្រង់

និវត្តចូលកាន់ព្រះរាជដំណាក់វិញ ជាមួយនឹងព្រះរាជបរិពារយ៉ាងកុះករដូចកាលដែលព្រះអង្គយាងមកដែរ។

លុះកន្លង៧ថ្ងៃ គឺក្នុងពិធីទី៨ ក្រោយពេលដែលក្រុមប្រឹក្សាព្រះរាជបល្ល័ង្គ និងឧត្តមជននៃព្រះរាជាណាចក្រ បានមូលមតិគ្នាជាឯកច្ឆន្ទថា នឹងថ្វាយរាជសម្បត្តិចំពោះព្រះរាជកុមារមក ក្រុមអ្នកភេរីចរ ក៏ចេញដើរគ្រប់ច្រកល្ហកទិសទី ដើម្បីគោះគងទូងភេរី ប្រកាសលទ្ធផលនេះ ជូនជាដំណឹងដល់ប្រជារាស្ត្រក្នុងព្រះនគរ ហើយជាពិសេស នឹងបានស្ដាប់ប្រជាមតិនៃរាស្ត្រទូទៅផង។ ប៉ុន្តែប្រជារាស្ត្រខ្សត់ខ្សោយ រឹតតែត្រេកអរចំពោះការថ្វាយរាជសម្បត្តិនេះណាស់ទៅទៀត។ មនុស្សគ្រប់គ្នារង់ចាំតែនឹងទៅថ្វាយព្រះពរ ក្នុងថ្ងៃប្រាប្ដាភិសេកប៉ុណ្ណោះ។

## ព្រះកិត្តិនាមល្បីល្បាញ

កាលដែលព្រះមកុដរាជកុមាររជ្ជទាយាទ ទ្រង់បានទទួលប្រាប្ដាភិសេកជាឯកមហាក្សត្រិយ៍ តំណព្រះវររាជបិតា តាមប្រពៃណីរាជ្យហើយ ទ្រង់មានព្រះនាមថា ព្រះបាទអាទាសមុខរាជ បរមបពិត្រព្រះចៅក្រុងពារាណសី ជាអម្ចាស់ជីវិតលើត្បូង។ ទ្រង់មានព្រះកិត្តិនាមល្បីល្បាញខ្ចរខ្ចាយទូទៅពេញទាំងសកលជម្ពូទ្វីបថា ជាអ្នកប្រាជ្ញម្នាក់ លើកលែងអ្នកប្រាជ្ញទាំងពួង ការណ៍ណាដែលមានអាថ៌កំបាំងក្រៃលែង ក៏ព្រះអង្គអាចឆ្លុះមើលដោយព្រះវិចារណញ្ញាណឃើញច្បាស់ពិតៗ ដូចជាទេពតាទាយថ្វាយ។ ហេតុដូច្នេះហើយ បានជាអ្នកនិពន្ធបានចុះនូវហេតុ១៤រឿង ទុកជាព័ត៌មានក្នុងប្រវត្តិរបស់ព្រះអង្គ។

រឿងរ៉ាវ១៤នោះគឺ

**គោណោ បុត្តោ ហយោ ចេវ នឡការោ គាមភោជកោ**
**គណិកោ តរុណី សប្បោ មិគោ តិត្តិរទេវតា**
**នាគោ តបស្សិនោ ចេវ អថោ ព្រាហ្មណ មាណវោ។**

រឿងគោ១ រឿងកូន១ រឿងសេះ១ រឿងជាងផែង១ រឿងចៅសង្កាត់១

រឿងស្រីផ្កាមាស១ រឿងស្ត្រីក្មេង១ រឿងពស់១ រឿងសត្វម្រឹគ១ រឿងសត្វទទា១ រឿងទេវតា១ រឿងនាគ១ រឿងតាបស១ រឿងយុវជនព្រាហ្មណ៍១។

រឿងទាំង១៤នេះ មានប្រវត្តិទាក់ទងគ្នាជាលំដាប់លំដោយ ជាមួយនឹងលោកតាគាមណិចន្ទ ដូចពណ៌នាទៅខាងក្រោម។

## លោកតាគាមណិចន្ទ

លោកគាមណិចន្ទ (គាមណិ ប្រែថា អ្នកធំ) ជាបុរសចាស់ម្នាក់ អាយុប្រមាណជា៥០ឆ្នាំហើយ។ ជីវភាពរបស់គាត់សព្វថ្ងៃប្រកបរបរកសិកម្ម។ ភូមិផ្ទះរបស់គាត់ទើបនឹងកកើតឡើងថ្មី តាំងនៅចម្ងាយពីរាជធានី ប្រមាណជា៣យោជន៍ ឬ៤៨គីឡូម៉ែត្រ។ គាត់រស់នៅជាសុខសាន្តជាមួយនឹងភរិយាកម្សត់ដែលឥតកូនចៅម្នាក់សោះ។ បើតាមប្រវត្តិរបស់គាត់ ដើមឡើយគាត់ជាមនុស្សអ្នកវាំងម្នាក់ គឺកាលដែលព្រះបាទជនសន្ធ មហារាជទ្រង់គង់ព្រះជន្មនៅឡើយ គាត់នេះឯងជាមហាតឹ្លកយ៉ាងជិតស្និទ្ធរបស់ព្រះអង្គ ប៉ុន្តែដល់ព្រះមហាក្សត្រិយ៍ជាបិតានេះ ទ្រង់ទិវង្គតទៅព្រះបាទអាទាសមុខរាជ ជាបុត្ររបស់ព្រះអង្គសោយរាជ្យបន្ត គាត់ក៏ប្រែចិត្តទៅជាមនុស្សមានការនឿយណាយជីវភាព ក្នុងវាំងដោយយល់ឃើញថា កាលព្រះវររាជបិតាទ្រង់គង់នៅ រូបគាត់ក៏ជាមនុស្សចាស់សមគួរណាស់នឹងនៅបម្រើព្រះរាជា ប៉ុន្តែឥឡូវនេះព្រះរាជបុត្រឡើងសោយរាជ្យនៅក្មេងណាស់ មិនសមគួរនឹងគាត់ដែលជាមនុស្សកញ្ចាស់នៅបម្រើសោះ ព្រោះថា តាមទំនៀមរាជ្យនីមួយៗ គួរតែមនុស្សជារាជបម្រើមានវ័យស្របាលៗគ្នាដែរ។ គាត់គិតដូច្នេះហើយ ក៏ត្រិះរិះជ្រើសរើសមុខរបរដែលនឹងត្រូវប្រកបចិញ្ចឹមជីវិត។ ឃើញថា កសិកម្មជាការងារល្អបំផុត ក៏សម្រេចចិត្តដើរចេញពីជីវភាពក្នុងរាជវាំង នាំភរិយាសម្លាញ់ទៅនៅស្រុកស្រែនេះឯង។ គាត់កាប់កាយរាតព្រៃយកដីធ្វើស្រែចម្ការ ប៉ុន្តែដល់រដូវភ្ជួរាស់ គាត់លៃលករកគោពុំទាន់បាន ដូច្នេះហើយបានជាភរិយាគាត់គិតគ្នាព្រមឲ្យគាត់ទៅខ្ចីគោមួយនឹមពីមិត្តសម្លាញ់

របស់គាត់ម្នាក់ ដែលនៅមិនឆ្ងាយពីភូមិរបស់គាត់ប៉ុន្មាន។ លុះយកគោនោះមកភ្ជួររាស់រួចរាល់តាមសេចក្តីត្រូវការហើយគាត់ក៏ឲ្យគោស៊ីស្មៅដុសលាងសត្វពាហនៈយ៉ាងថ្នាក់ថ្នម នាំត្រឡប់យកទៅឲ្យម្ចាស់វាវិញ។ ទៅដល់មុខផ្ទះគោទាំងពីរក៏នាំគ្នាដើរចូលទៅក្នុងក្រោលវាតាមទម្លាប់យ៉ាងស្រួល។ ជួនជាពេលនោះម្ចាស់គោទាំងប្តីប្រពន្ធកំពុងតែរៀបនឹងបរិភោគអាហារពេលល្ងាចស្រាប់តែងាកទៅឃើញគាមណិចន្ទ ដែលនាំគោចូលមក បុរសជាប្តីក៏លើកចានឡើងហាមាត់ប្រុងនឹងស្រែកហៅអញ្ជើញឲ្យពិសាបាយ ស្រាប់តែប្រពន្ធទាញដៃចុះមកវិញ ជាសញ្ញាឲ្យឈប់។ លោកគាមណិចន្ទ ក្រឡេកទៅឃើញវិការៈដូច្នោះក៏យល់ភ្លាមថា «អ្នកទាំងនុ៎ះ បម្រុងនឹងហៅគាត់ឲ្យចូលហូបបាយ» ប៉ុន្តែ ដើម្បីកុំឲ្យគេទើសទាល់ចិត្តដោយហេតុអ្វីមួយ។ កាលបើឃើញគោចូលដល់ក្រោលហើយ គាត់ក៏ប្រញាប់ប្រញាល់ត្រឡប់ទៅផ្ទះវិញ ដោយឥតទាំងបានស្រែកប្រគល់ប្រាប់ ឬលាម្ចាស់គោមួយម៉ាត់សោះ។

ថៃដន្យពេលរាត្រីនោះ មានពួកចោរចូលទៅកាត់ក្រោល លួចយកគោទាំងនោះទៅបាត់ ព្រលឹមឡើង ម្ចាស់គោដែលពុំបានដឹងថា ចោរលួចគោសោះ ក៏ចុះទៅមើលក្រោល ស្រាប់តែពុំឃើញគោ ក៏នឹកគិតថា «អែយ៉ា! ចោរលួចគោអស់រ៉ឺ! ធ្វើយ៉ាងម៉េចអីចេះ នឹងបានគោប្រើទៀត? មានតែផ្លូវម្យ៉ាងគឺត្រូវទៅទារសំណងនេះ អំពីលោកគាមណិចន្ទទើបបាន។ គិតហើយ បុរសនោះក៏ប្រញឹបប្រញាប់ទៅរកលោកគាមណិចន្ទទាំងព្រលឹម ហើយសម្លុតទារគោយ៉ាងកំណាចថា

- នែ លោកគាមណិចន្ទ ឯណាគោយើង?

- ទេ! គោឯណាទៀត បើយើងយកទៅឲ្យវិញហើយ?

- ចុះអ្នកឯងយកទៅឲ្យយើងពីអង្កាល់ តើបានប្រាប់ប្រគល់គោនោះដល់យើងដែរឬទេ?

- យើងពុំបាននិយាយប្រគល់គោដល់អ្នកទេ ប៉ុន្តែគោទាំងពីរច្បាស់ជា

ចូលទៅក្នុងក្រោលអ្នកពិតប្រាកដហើយ សូម្បីអ្នកនិងប្រពន្ធរបស់អ្នកក៏បានឃើញនឹងភ្នែកដែរ?

- ទេ! យើងពុំបានឃើញទេ បើអ្នកពុំបាននិយាយប្រគល់គោដល់យើងហើយ ចាំបាច់ជជែកអ្វីត្រូវសងគោមកយើងវិញ ពីព្រោះគោពុំឃើញមាននៅក្នុងក្រោលទេ។

- ទេ! ម៉េចក៏ត្រូវឲ្យយើងសង ពិតមែនតែយើងមិនបានប្រគល់ឲ្យ ប៉ុន្តែគោទាំងពីរចូលក្រោលហើយតើ?

បុរសម្ចាស់គោ កាលដឹងថាលោកគាមណិចន្ទ ប្រកែកដាច់អហង្ការពុំព្រមសង ក៏ឱនរើសដុំក្រួសមួយដុំ លើកឡើងបង្ហាញលោកគាមណិចន្ទថា «នែ! នេះជារាជទូតនាំអ្នក បើអ្នកពុំព្រមសងដូច្នេះ ចូរអ្នកមកជាមួយនឹងយើង»។

តាមសេចក្តីតំណាលថា ទំនៀមទម្លាប់ក្នុងជនបទនោះ កាលបើមានការវិវាទ ចោទប្រកាន់រឿងហេតុណាមួយ រវាងគ្នានិងគ្នា អ្នកដើមចោទមានសិទ្ធិនឹងកោះហៅអ្នកចុងចោទ ឲ្យចូលខ្លួនទៅកាន់ព្រះរាជសម្នាក់ ហើយគេចាប់យកដុំក្រួស ឬអំបែងអ្វីមួយបង្ហាញអ្នកចុងចោទ ហើយប្រកាសប្រាប់ថា «ដុំក្រួសជាដើមនោះ ជារាជទូតនាំអ្នក ចូរអ្នកមក» តែប៉ុណ្ណោះ អ្នកចុងចោទត្រូវតែទៅតាមអ្នកដើមចោទជាកំហិត បើពុំទៅទេ អ្នកចុងចោទនឹងត្រូវដាក់រាជអាជ្ញាជាទម្ងន់។ ព្រោះហេតុដូច្នោះហើយ បានជាលោក គាមណិចន្ទ គ្រាន់តែឮពាក្យម្ចាស់គោថា «រាជទូត» ប៉ុណ្ណោះ មិនហ៊ានរឹង ទទឹងក៏ព្រមចេញទៅជាមួយនឹងគេភ្លាម។

គេដឹងចិត្តមិត្តភ័ក្តិ ក្នុងខណៈដែលជួយសម្រាលកិច្ចធុរៈ តែគេដឹងចិត្តអមិត្តក្នុងខណៈដែលជួយទម្ងន់តែទុក្ខសោកដល់គ្នានឹងគ្នាទៅវិញ។

លោកគាមណិចន្ទ ផ្តែផ្តាំភរិយាសម្លាញ់ឲ្យមើលកិច្ចការណាដែលចាំបាច់ជាស្រេច ក៏ចេញដំណើរទៅជាមួយនឹងម្ចាស់គោ ដោយទឹកមុខស្រពោនស្រពាប់ដែលបង្ហាញនូវសេចក្តីទុក្ខ តឹងចង្អៀតដើមទ្រូងជាទីបំផុត។ លោកដើរ

បណ្ឌិត នឹកឃើញវាសនាគំរក់របស់លោកបណ្ឌិត តើនឹងបានសំណាងមកពីណាសងគេ? សង្ឃឹមការវិនិច្ឆ័យប្រកបដោយយុត្តិធម៌នៃព្រះមហាក្សត្រិយ៍ក៏ពុំបាន ព្រោះទ្រង់នៅក្នុងកុមារភាពពេក ធ្វើម្ដេចនឹងយល់ហេតុការណ៍អាថ៌កំបាំងនេះបាន! ឱ! អាត្មាអញនេះអើយ! ដើមឡើយថា ប្រឹងចៀសវាងជីវភាពក្នុងវាំង គេចឲ្យឆ្ងាយពីវាំង ចុះចង្រៃអីក៏មកនាំបណ្ដាលឲ្យចូលទៅក្នុងវាំងវិញដូច្នេះ! តើអញមានអ្នកណាជាទីពឹង?។ គាត់គិតក្នុងពេលធ្វើដំណើរទៅរហូតដល់ភូមិមួយ។ ព្រះទិនករ ក៏រះជិតថ្ងៃត្រង់ទៅហើយ គាត់ឃ្លានបាយណាស់ ក៏និយាយប្រាប់ម្ចាស់គោថា មិត្តអើយ! សូមមិត្តឯងនៅរង់ចាំត្រង់ទីនេះសិនហើយណា! ខ្ញុំឃ្លានបាយណាស់ ខ្ញុំចូលទៅរកផ្ទះមិត្តសម្លាញ់ខ្ញុំតែមួយភ្លែត ទម្រាំតែខ្ញុំស្រស់ស្រូបបន្តិចហើយខ្ញុំវិលមកវិញ នឹងទៅជាមួយនឹងអ្នកទៀត។ ម្ចាស់គោយល់ព្រមឲ្យទៅ។ លោកក៏រួសរាន់ចូលទៅក្នុងភូមិ ដើរតម្រង់ទៅចំផ្ទះសម្លាញ់ចាស់។ ជួនជាវេលានោះ សម្លាញ់គាត់ពុំបាននៅផ្ទះ នៅតែភរិយា នាងភរិយាលុះឃើញលោកទៅដល់ ក៏ស្ទុះមកទទួលរាក់ទាក់សំណេះសំណាលសួរដំណើរ។ លោកក៏ប្រាប់ថា

- ខ្ញុំមានដំណើរទៅព្រះរាជវាំង ប៉ុន្តែចូលមកសុំបាយស្រស់ស្រូបបន្តិច ពីព្រោះខ្ញុំដើរមក វាកុនវេលាបាយទៅហើយ!។

- ឱ! លោកបងកុំបារម្ភថ្វី ទោះបីសម្លាញ់លោកពុំនៅ ក៏នៅរូបខ្ញុំដែរ សូមលោកនៅពិសាបាយនេះសិនចុះ ប៉ុន្តែបាយឆ្អិនស្រាប់ពុំទាន់មានទេ សូមសម្រាកខ្លួនបង្អង់បន្តិច ខ្ញុំនឹងដាំជូន។

- ណ្ហើយ! បើគ្មានបាយឆ្អិនស្រាប់ទេ ចូរនាងកុំខ្វល់ខ្វាយរវល់អី! ខ្ញុំសុំលាសិនហើយ ព្រោះដំណើរខ្ញុំប្រញាប់ណាស់។

-ទេ! ទេ! មិនព្រមទេ! មកដល់ផ្ទះខ្ញុំហើយ ទៅវិញភ្លាមដូច្នេះ ខ្ញុំមិនព្រមទេ សូមលោកបង្អង់តែបន្តិច ក៏ខ្ញុំអាចដាំឆ្អិនជូនបានភ្លាម ហើយបើលោករង់ចាំទៅ ក្រែងបានជួបនឹងសម្លាញ់របស់លោកផង សូមកុំអាលទៅណា!។

ថាតែប៉ុណ្ណោះ ភរិយានៃសម្លាញ់នោះ ក៏ស្ទុះស្ទាប្រញាប់ប្រញាល់បង្កាត់ភ្លើងចង្ក្រាន្ត ទាញផ្ទាំងឡើងទៅលើក្រង់អង្ករ ដើម្បីយកអង្ករដាក់ឆ្នាំងដាំបាយ។ គួរឲ្យអាសូរណាស់ ! មិនដឹងជាចង្រៃអី ឲ្យភ្លាត់ស្នៀតរបូតដៃជើងធ្លាក់រាំងខ្ទិចមកដី នាងទើបនឹងមានកូនក្នុងពោះ៧ខែផង ក៏រលូតកូនចេញមកយ៉ាងឈឺផ្សាស្ទើរបាត់ស្មារតី។ ស្រាប់តែពេលនោះ ប្ដីនាងក៏មកដល់ដែរ ឃើញដូច្នោះ ក៏ស្រែកឡូឡាថា

-ដើះ! លោកគាមណិចន្ទ! ហេតុអ្វីក៏មកវាយប្រពន្ធយើងឲ្យរលូតកូនឲ្យកូនយើងស្លាប់អីចឹង ?

- ទេ! លោកអើយ! ប្រពន្ធមិត្តឯងរបូតដៃធ្លាក់ពីលើក្រង់អង្ករមកខ្លួននាងទេតើ!

-ទេ! មិនមែនទេ ! អ្នកឯងច្បាស់ជាវាយប្រពន្ធខ្ញុំ ហើយបើទុកជាអ្នកឯងមិនវាយ ក៏អ្នកឯងប្រើប្រពន្ធខ្ញុំដែលមានផ្ទៃពោះធំប៉ុណ្ណឹង ឲ្យឡើងយកអង្ករដែរ!

- ទេ! ខ្ញុំឥតបានប្រើទេ នាងស្ម័គ្រចិត្តឃាត់ខ្ញុំហើយធ្វើខ្លួនឯងទាំងអស់ទេតើ!។

- ចុះបើកុំតែអ្នកឯងមកឲ្យរវល់ តើធ្វើម៉េចប្រពន្ធខ្ញុំនឹងទៅជាអីចឹង អ្នកឯងច្បាស់ជាវាយប្រពន្ធខ្ញុំហើយ ត្រូវសងកូនខ្ញុំដែលស្លាប់នោះមកវិញទើបបាន។

- លោកម្ចាស់អើយ! តើខ្ញុំនឹងធ្វើដូចម្ដេចកើត បើកូនស្លាប់ដូច្នេះ ហើយខ្ញុំទៀតក៏គ្មានកូនមួយនឹងយកមកសងអ្នកទៀត តើខ្ញុំធ្វើយ៉ាងម៉េចទៅ! ខ្ញុំឥតបានវាយប្រពន្ធអ្នកឯងទេ!។

បុរសប្ដីដឹងថា លោកចន្ទប្រកែករឹងរូស ក៏កើតក្ដៅក្ដួលឆួលឆេះសោកសង្រេង អាណិតប្រពន្ធ និងស្ដាយកូន ឱនរើសអំបែងឆ្នាំងមួយបង្ហាញទៅថា

- បើអ្នកឯងមិនព្រមសងទេ នេះជារាជទូតនាំអ្នក ចូរអ្នកឯងមកជាមួយនឹងយើង ថាតែប៉ុណ្ណោះ ក៏រៀបចំប្រពន្ធផ្ញើនឹងញាតិមិត្តរួចចេញដំណើរជាមួយនឹងលោកគាមណិចន្ទ។ លោកគាមណិចន្ទ ក៏ត្រូវបានបុរសដើមចោទទី២ អ្នក

ដើរអមនាំទៅ។ លុះចូលទៅដល់ជិតផ្លូវភូមិមួយទៀត ស្រាប់តែឃើញបុរសម្នាក់រត់ហត់គឃុំសដេញ ស្ទាក់សេះមួយដែល របូតដាច់ខ្សែចាប់ពុំបាន។ គង្វាលសេះ ឃើញសេះខ្លួនរត់តម្រង់មកជិតអ្នកទាំងបីក៏ស្រែកថា លោកអ៊ុំអើយ! ចោលសេះខ្ញុំឲ្យបែរមកវិញផង?

លោកចន្ទ ស្ទុះភ្លែតស្រែកបង្អើល ហើយរើសដុំថ្មមួយដុំចោលសេះនោះម៉ាំងជាបន្ទាន់ គួរឲ្យហួសចិត្តណាស់ ដុំថ្មតូចល្មមសោះស្រាប់តែទង្គិកនឹងជើងសេះ ធ្វើឲ្យជើងសេះបាក់ផស់ ដូចជាដើមល្ហុងខ្ទៃបាក់។ គង្វាលសេះ ឃើញសេះបាក់ជើងដួលស្រិប ដោយស្នាដៃលោកចន្ទ ក៏ក្តៅខ្លាំងណាស់ ស្រែកឡូឡាថា

- ជើះ! ម៉េចក៏អ៊ុំឯងចោលបំបាក់ជើងសេះខ្ញុំអីចឹង?

-ទេ! ក្មួយ អ៊ុំចោលនេះ មានបំណងថា នឹងជួយដេញសេះតាមពាក្យអង្វររបស់ក្មួយទេ! ស្រាប់តែទៅត្រូវចំជើងវាវិញ បាក់ខ្ទេចយ៉ាងនេះ អ៊ុំឥតមានបំណងនឹងចោលបំបាក់ជើងវាទេ!។

-ខ្ញុំគ្រាន់តែឲ្យដេញសេះឲ្យបែរទៅវិញប៉ុណ្ណោះ អ៊ុំឯងហ៊ានទៅចោលបំបាក់ជើងសេះខ្ញុំ ឥឡូវត្រូវតែអ៊ុំឯងសងសេះខ្ញុំវិញ ទើបខ្ញុំសុខចិត្ត។

- ក្មួយអើយ ! តើអ៊ុំបានសេះពីណានឹងសងក្មួយ!។

គង្វាលសេះ ខឹងប្រទ្បោត ស្តីបន្ទោសលោកចន្ទជាច្រើន រួចចាប់ក្រួសមួយដុំជារាជទូត នាំលោកចន្ទ ធ្វើដំណើរទៅដូចជាបុរសឯទៀតៗនោះដែរ។

ផ្ទៃវាលស្រឡះធំធេងល្ហល្ហេវ តែដោយចិត្តលោកគាមណិចន្ទណែនណាល់ដោយកង្វល់ទុក្ខព្រួយ គាត់មើលទៅសព្វទិសទីហាក់ដូចជាចង្អៀតណែនរកផ្លូវយាត្រាពុំបាន។ គាត់ដើរទាំងមុខស្រពោនស្រពាប់ នឹកទៅវាសនាអភ័ព្វរបស់គាត់ ដែលគាត់ចង់គេចចៀសវាងមិនឲ្យជួបប្រទះអ្វី វាចេះតែប្រានឲ្យទៅជួបប្រទះនឹងហេតុការណ៍នោះៗ ឱ! អញអើយ អំបាលត្រឹមតែសំណាងគោមួយនឹម រកមិនបានទៅហើយ តើចាំបាច់និយាយអ្វីទៅដល់ការត្រូវពិន័យ

រឿងរលូតកូន និងសំណាងសេះទៀត តើអញបានមកពីណាទៅ? អញនេះស្លាប់ទៅប្រសើរជាង ព្រោះថា ជីវិតនេះពិតជាមានតម្លៃខ្ពស់បំផុតជាងអ្វីទាំងអស់ តែចំពោះអញ ដែលជាប់រយោងដោយហេតុការណ៍ដ៏សែនទុក្ខយ៉ាងនេះ តើជីវិតអញវាមានតម្លៃអ្វី? ការស្លាប់ដោយខ្លួនឯង ពិតជាស្រួលជាងការស្លាប់ដោយទារុណកម្មរបស់អ្នកដទៃ។ លោកចន្ទ មានទឹកមុខឡើងខ្មៅជាំ គិតមួយរយ មួយសែនជំពូកពុំធ្លុះធ្លាយ លុះដើរទៅដល់ពាក់កណ្តាលផ្លូវ ងាកទៅឃើញភ្នំមួយមានជ្រោះ ម្ខាងចោតសន្លឹមនៅជិតផ្លូវទៅ។ គាត់ក៏បែរទៅនិយាយនឹងអ្នកដើមចោទទាំងបីនាក់ថា សូមអ្នកទាំងអស់គ្នាបង្អង់សិន ខ្ញុំឈឺបត់ជើងណាស់។ ថាហើយ ក៏ចូលទៅក្នុងព្រៃ រួចដើរវាងឡើងទៅលើកំពូលភ្នំចោត ឈរលើកដៃប្រណមចំពោះទេវតា សច្ចាមួយសន្ទុះ ក៏ហក់រឹងទៅក្នុងជ្រោះយ៉ាងជ្រៅ។ ទម្ងន់ខ្លួនរបស់គាត់ធ្លាក់ស្ទុំដូចជាដុំថ្ម ទោះប៉ះនឹងមែកឈើ មែកឫស្សី ក៏បាក់ប្រាវធ្លាយទៅគ្មានសល់។ ប៉ុន្តែ មិនដឹងជាចៃដន្យអ្វី កាលដែលធ្លាក់ប្រាវទៅ ស្រាប់តែជើងទាំងពីររបស់គាត់ ធ្លាក់ទៅចំលើស្មាជាងផែង (ជាងត្បាញកន្ទេលឫស្សី។) ម្នាក់ដែលកំពុងជញ្ជូនឫស្សី។ ជាងផែងដោយឥតដឹងខ្លួនសោះ ក៏ដួលផ្កាប់មុខទង្គុកក្បាលនឹងថ្មម៉ាំង ដាច់ខ្យល់ម៉ាត់ស្លាប់មួយរំពេច។ ឯលោកគាមណិចន្ទទៅជារួចខ្លួន តតេះតតះប្រវេប្រវាក្រោកឡើងបានវិញ។ កូនកំឡោះជាងផែងដែលកំពុងជញ្ជូនឫស្សីជាមួយនឹងឪពុក ងាកទៅឃើញដូច្នោះ ក៏ទ្រហោយំគក់ទ្រូងស្មុះទៅ ក្រសោបឪពុកដែលស្លាប់ ស្រែកចោទប្រកាន់លោកចន្ទថា

- យើ! អាចោរមនុស្សឃាត ម៉េចក៏អាឯងមកសម្លាប់ឪពុកអញ?

- មិនមែនទេ ក្មួយ! ខ្ញុំហក់ពីលើកំពូលភ្នំមកនេះ ដោយបំណងថា នឹងសម្លាប់ខ្លួនឯងទេ? តែមិនដឹងជាកាលកម្មអ្វី បានជាមកធ្លាក់ចំលើឪពុកក្មួយនេះទៅវិញ។

- ទេ! ខ្ញុំមិនសុខចិត្តទេ! កន្លែងឯទៀតម៉េចក៏មិនលោត មកលោតលើឪពុកខ្ញុំឯណោះវិញ ខ្ញុំមិនព្រមទេ ត្រូវសងឪពុកខ្ញុំវិញ។

- ឱ! ព្រះម្ចាស់អើយ មនុស្សស្លាប់ទៅហើយ តើឲ្យខ្ញុំសងយ៉ាងម៉េចកើត។

កូនជាងផែងខឹងណាស់ ប្រទេចផ្ដាសាលោកចន្ទជាច្រើន រួចលើកសព ឪពុកដាក់មួយកន្លែងស្រួលបួល ហើយកាន់ថ្មមួយដុំ បង្ហាញជារាជទូតនាំលោកចន្ទចេញទៅដូចអ្នកមុនៗដែរ។

## បណ្ដាំលោកចៅសង្កាត់

ឥឡូវ លោកគាមណិចន្ទ ទៅជាមានអ្នកដើមចោទដល់ទៅ៤នាក់ ចោមរោមជុំវិញនាំបណ្ដើរទៅ។ លុះទៅដល់ភូមិមួយ បានជួបនឹងចៅសង្កាត់ម្នាក់ ក្រោយដែលដឹងព័ត៌មានថា លោកចន្ទទៅគាល់ស្ដេច លោកចៅសង្កាត់ ក៏អង្វរសុំឲ្យលោកចន្ទនាំពាក្យបណ្ដាំទៅទូលព្រះរាជាផង។ លោកចន្ទ ក៏សុខចិត្តព្រមទទួលយកទៅ។ លោកចៅសង្កាត់ ត្រេកអរណាស់ និយាយប្រាប់ថា

- កាលពីដើម ខ្ញុំនេះជាអ្នកមានរូបសម្បត្តិស្អាតបាត មានទ្រព្យធនជានច្រើន មានយសបរិវារ ហើយគ្មានរោគាអ្វីបៀតបៀនទេ ស្រាប់តែមកដល់ឥឡូវនេះ ខ្ញុំនេះបែរទៅជាអ្នកក្រីក្រទុគ៌តថែមទាំងកើតរោគលឿងទៀតផង តើវាមានហេតុយ៉ាងម៉េចក្នុងរឿងហ្នឹង សូមលោកមេត្តានាំទៅទូលព្រះរាជាឲ្យព្រះអង្គប្រោសដោះស្រាយឲ្យខ្ញុំផង ព្រោះឮល្បីល្បាញថា ព្រះរាជា ទ្រង់ជាអ្នកប្រាជ្ញ ព្រះអង្គនឹងដោះស្រាយបានពុំខាន ហើយលោក កាលបើវិលមកវិញ សូមមេត្តាយកព្រះរាជសាសន៍នោះមកប្រាប់ខ្ញុំផង។

- បាទ! មិនថ្វីទេ ចាំខ្ញុំនាំទៅទូលព្រះអង្គឲ្យ។

## បណ្ដាំស្រីពេស្យា

លោកគាមណិចន្ទ លុះទទួលបណ្ដាំលោកមេស្រុកហើយ ក៏នាំគ្នាទៅរហូតដល់ភូមិមួយទៀត។ ស្ត្រីផ្កាមាសម្នាក់ក្នុងភូមិនោះ បានឃើញលោចន្ទទៅដល់ ក៏សាកសួរព័ត៌មានដូចមេស្រុកដែរ។ លុះបានដឹងថា លោកទៅគាល់ហ្លួង

ក៏អបអរណាស់ អង្វករសូមផ្ញើពាក្យបណ្តាំមួយទៅទូលព្រះរាជាឲ្យទ្រង់ដោះស្រាយថា

- លោកអ៊ុំ! ខ្ញុំឮកិត្តិសព្ទល្បីថា ហ្លួងថ្មីយើងមានប្រាជ្ញាណាស់ សូមលោកអ៊ុំមេត្តានាំយកបណ្តាំរបស់ខ្ញុំទៅផងថា កាលពីដើម ខ្ញុំនេះរកថ្លៃឈ្នួលកបណាស់ ក៏ប៉ុន្តែដល់មកឥឡូវនេះ ស្ទើតែរកស្លាមួយម៉ាត់ឥពុំបានផង មិនសូវមានគេមករកស្នេហ៍ស្និទ្ធនឹងខ្ញុំសោះ តើរឿងហ្នឹងវាយ៉ាងម៉េច? សូមលោកអ៊ុំទូលសួរព្រះរាជាហើយមកប្រាប់ខ្ញុំផង។

- បាទ! ចាំខ្ញុំទូលថ្វាយតាមបណ្តាំនាង។

## បណ្តាំស្រីក្មេង

លោកគាមណិចន្ទ ទទួលបណ្តាំស្រីផ្កាមាសរួច ក៏នាំគ្នាស្រូតដំណើរទៅទៀត លុះដល់ភូមិមួយ បានឃើញស្ត្រីក្មេងម្នាក់ក្នុងភូមិនោះ ។ស្ត្រីក្មេងនោះឃើញលោកចន្ទទៅដល់ហើយដឹងព័ត៌មានថា ទៅគាល់ហ្លួង ក៏សុំផ្តាំពាក្យបណ្តាំទៅទូលព្រះរាជាថា

- សូមលោកអ៊ុំ មេត្តាក្រាបទូលសួរព្រះរាជាផងថា នាងខ្ញុំនេះដូចជារសាប់រសល់ តក់ក្រហល់ក្តៅក្រហាយ មិនអាចនៅនឹងផ្ទះរបស់ប្តីខ្លួនបានសោះ ហើយនឹងទៅនៅផ្ទះម៉ែឪខ្លួនឯណោះក៏មិនកើតដែរ តើរឿងហ្នឹង វាមានហេតុបច្ច័យយ៉ាងម៉េច? សូមលោកក្រាបទូលព្រះរាជា ហើយមកប្រាប់សេចក្តីដោះស្រាយដល់ខ្ញុំផង។

- មិនអីទេនាង ! ចាំខ្ញុំទូលស្តេចឲ្យ។

## រឿងពស់

ក្រោយដែលទទួលបណ្តាំស្ត្រីក្មេងនោះហើយ លោកចន្ទនិងពួកអ្នកដើមចោទ ក៏ស្រូតដំណើរទៅដល់ផ្លូវធំមួយ។ កសិករម្នាក់ឃើញអ្នកទាំងបួនរូបកំពុង

ដើរទៅ ក៏ស្រែកសួរព័ត៌មាន។ លុះបានដឹងថា ទៅគាល់ព្រះរាជា កសិករនោះក៏សូមផ្តាំពាក្យទៅក្រាបទូលព្រះរាជាដោយតំណាលប្រាប់ថា

- លោកអ៊ុំ! ន៏! នៅក្នុងដំបូកធំនោះ ដែលមានព្រៃស៊ុបទ្រុបជិតផ្លូវនេះ មានសត្វពស់មួយធំណាស់អាស្រ័យនៅ។ តាមការសង្កេតរបស់ខ្ញុំ ក៏ដូចជាអ្នកភូមិទាំងអស់គ្នាដែរ ឃើញអាការៈរបស់ពស់នោះចម្លែកណាស់ គឺពស់នោះកាលបើនឹងចេញអំពីដំបូកទៅស្វែងរកចំណីអាហារ សូម្បីតែកំពុងត្រូវស្រេកឃ្លាន មានពោះជូរស្ងួត មានសរីរាង្គស្គមស្គិតយ៉ាងណា ក៏ចេញទៅពីដំបូកលំបាកណាស់ ហាក់ដូចជាប្រឹងប្រអូស ប្រទាញរាងកាយ ដែលពេញណែនចង្អៀតនឹងរន្ធពេក ប៉ុន្តែដល់ពេលត្រឡប់មកវិញ ទោះបីឆ្អែតស្កប់ស្កល់មានរាងកាយជាត់ថ្លោសធំយ៉ាងណាក៏ដោយ ក៏បែរជាចូលទៅយ៉ាងឆាប់រហ័សស្រួលពេក ហាក់ដូចជាគ្មានប៉ះនឹងមាត់រន្ធសោះ។ លោកអ៊ុំ! សូមលោកអ៊ុំមេត្តាក្រាបទូលសួរព្រះរាជាផងថា តើវាមានហេតុភេទយ៉ាងម៉េចក្នុងរឿងហ្នឹង? ខ្ញុំសង្ឃឹមថា ហ្លួងថ្មីយើង ទ្រង់មានព្រះប្រាជ្ញាញាណ នឹងប្រោសព្រះរាជទានពាក្យដោះស្រាយបានពុំខាន ហើយសូមលោកអ៊ុំមកប្រាប់ខ្ញុំផង។

## រឿងសត្វម្រឹគ

លោកគាមណិចន្ទ ក៏បានព្រមទទួលបណ្តាំរឿងពស់នោះហើយ នាំគ្នាធ្វើដំណើរតទៅទៀត លុះចេញពីនោះបន្តិចទៅ បានជួបនឹងបុរសម្នាក់ បុរសនោះឃើញលោកចន្ទ និងបុរសទាំង៤នាក់ទៅដល់ ក៏រាក់ទាក់សួរដំណើរដូចអ្នកទាំងពួងដែរ ហើយក្រោយដែលបានឮថា ទៅថ្វាយបង្គំព្រះមហាក្សត្រិយ៍ ក៏មានចិត្តរីករាយ និយាយផ្តាំឲ្យក្រាបទូលសួរព្រះអង្គថា

- លោកអ៊ុំជាទីគោរព ! សូមលោកអ៊ុំនាំយកពាក្យខ្ញុំទៅទូលស្តេចផងថា មានម្រឹគមួយ ជាសត្វរស់នៅអាស្រ័យនឹងស្មៅ តែវាអាចអាស្រ័យស៊ីស្មៅបានចំពោះតែស្មៅនៅក្រោមដើមឈើធំមួយដើមនេះប៉ុណ្ណោះ វាពុំអាចស៊ីស្មៅនៅ

ទីឯណាទៀតបានសោះ ហាក់ដូចជាស្មោងទៀតពុំមែនជាធម្មជាតិសម្រាប់ញ៉ាំង ជីវិតវាឲ្យរស់នៅបានទេ តើរឿងហ្នឹង វាមកពីហេតុបច្ច័យដូចម្តេច?។ ព្រះរាជាជាម្ចាស់ ទ្រង់នឹងជ្រាបរឿងនេះពុំខាន ព្រោះបានឮកិត្តិនាមល្បីល្បាញថា ព្រះអង្គមានប្រាជ្ញាណាស់ ហើយសូមលោកអ៊ុំវិលមកប្រាប់ព្រះរាជសាសន៍នោះដល់ខ្ញុំផង។

## រឿងសត្វទទា

លោកគាមណិចន្ទ ទទួលពាក្យបណ្តាំនោះស្រេច ក៏ចេញពីទីនោះទៅទៀតបន្តិច បានជួបនឹងបុរសម្នាក់ទៀត ។ បុរសនោះឃើញលោកចន្ទ ទៅដល់ក៏សាកសួរអំពីដំណើរទៅដូចគ្នា រួចសូមផ្តាំផ្ញើពាក្យទៅទូលស្តេចថា

- លោកអ៊ុំដ៏ចម្រើន! មានសត្វទទាមួយ បើទំនៅលើដំបូកនោះដូចជាពេញចិត្ត សប្បាយរីករាយចិត្តនឹងទំនៅដោយសុខស្រួលណាស់ តែបើទៅទំនៅកន្លែងដទៃក្រៅពីនេះវិញ ហាក់ដូចជាតក់ក្រហល់ទំនៅពុំបានសោះ សូមលោកអ៊ុំក្រាបទូលសួរព្រះរាជាផងថា តើរឿងហ្នឹងវាយ៉ាងម៉េចបានជាដូច្នោះ? រួចមកប្រាប់ខ្ញុំផង!។

## រឿងទុក្ខទេវតា

លោកគាមណិចន្ទ ទទួលបណ្តាំនោះរួច ក៏ស្រូតរូតដំណើរទៅមុខទៀត។ ដោយព្រះទិនករចរជ្រេរសៀលបន្តិចទៅ កម្តៅក៏ផ្សាយខ្លាំង នាំឲ្យអ្នកទាំងនោះនឿយហត់ក្នុងដំណើរ ក៏នាំគ្នាចូលឈប់សម្រាកនៅក្រោមម្លប់ដើមឈើមួយដែលនៅជិតផ្លូវធំ។ រុក្ខទេវតាមួយអង្គ ដែលអាស្រ័យនៅនឹងព្រឹក្សានោះលុះឃើញបុរសទាំងបួនចូលមកសម្រាកនៅទីនោះ ក៏និម្មិតឲ្យប្រាកដរូប ហើយចូលទៅសួរដំណើររបស់អ្នកទាំងនោះ។ លុះដឹងដំណើរសព្វគ្រប់ ក៏សូមផ្តាំផ្ញើពាក្យទៅទូលសួរព្រះចៅជាអម្ចាស់ដែរថា

- ខ្ញុំបានឮព្រះកិត្តិនាមល្បីល្បាញថា ព្រះរាជា ជាមហាបណ្ឌិត សូមលោកយកបណ្ដាំខ្ញុំទៅក្រាបទូលព្រះអង្គផងថា ខ្ញុំនេះ ពីដើមតែងតែបានទទួលលាភសក្ការបូជា អធិកច្រើនណាស់ ឥឡូវនេះ ស្រាប់តែមកអត្ត:ខាត់ក្រីក្រ សូម្បីតែស្លឹកឈើមួយក្ដាប់ស្មើរតែគ្មានគេបូជាផង តើរឿងនេះវាមកពីអ្វី? សូមលោកទូលសួរព្រះរាជាហើយមកប្រាប់ខ្ញុំវិញផង។

## រឿងនាគរាជ

ក្រោយដែលបានទទួលបណ្ដាំរុក្ខទេវតាហើយ បន្ទាប់ពីការឈប់សម្រាកស្រួលបន្តិច លោកចន្ទក៏នាំគ្នាបន្តដំណើរទៅទៀត រហូតដល់ស្រះមួយ។ ទាំងអស់គ្នាក៏ចុះសំដៅទៅរកទឹកក្នុងស្រះ ក្បង់ផឹកនិងលាបស្រឡាបខ្លួន ដើម្បីបន្ទោបង់ក្ដីក្ដៅក្រហាយដោយកម្ដៅព្រះអាទិត្យ។ ស្រាប់តែពេលនោះ នាគមួយដែលអាស្រ័យនៅក្នុងស្រះនោះ ផុសចេញពីផ្ទៃទឹកឡើង ហើយស្រែកសួរអំពីដំណើររបស់អ្នកទាំបួន។ អ្នកទាំងបួន ក៏ប្រាប់តាមដំណើរហូរហែដូចមុន។ នាគឮថា គេនាំគ្នាទៅគាល់ព្រះនរបតី ក៏មានចិត្តរីករាយ សូមផ្ដាំផ្ញើពាក្យទៅក្រាប-ទូលហើយរៀបរាប់ថា

- លោកអ៊ុំអើយ! ខ្ញុំឮឈ្មោះបោះសំឡេងថា ព្រះរាជាទ្រង់ជាអ្នកប្រាជ្ញ សូមលោកក្រាបទូលសួរព្រះអង្គថា នៅក្នុងស្រះដ៏រមណីយដ្ឋាននេះ កាលពីដើម មានទឹកស្អាតថ្លាឆ្វង់ពណ៌ដូចកែវមណី ស្រាប់តែឥឡូវនេះ ប្រែជាល្អក់ខ្វល់ដេរដាសដោយចកបាយទា សូមលោកសួរបញ្ជាក់ព្រះរាជាថា តើវាមានរឿងហេតុភេទយ៉ាងម៉េច បានជាអីចឹងទៅវិញ ហើយសូមលោកមកប្រាប់ខ្ញុំផង។

## រឿងតាបស

បន្ទាប់អំពីបានទទួលពាក្យបណ្ដាំនាគមក លោកចន្ទក៏នាំគ្នាដើរមកដល់អារាមមួយនៅជិតព្រះរាជធានី បានជួបនឹងពួកតាបសដែលអាស្រ័យនៅ

ក្នុងទីនោះ។ ពួកតាបសបានសាកសួរអំពីដំណើរអ្នកទាំងនោះ លុះបានព័ត៌មានហើយ ក៏សូមផ្ដាំពាក្យទៅទូលថ្វាយព្រះរាជាដែរ ដោយរៀបរាប់ប្រាប់ថា

- ពីដើមឡើយ នៅក្នុងទីអារាមនេះ ផលព្រឹក្សតូចធំ មានផ្លែរយោនរយាន ប្រកបដោយរសជាតិឆ្ងាញ់ពិសា ផ្អែមក្រអូបឈ្ងុយឈ្ងប់ពន់ពេកណាស់ ស្រាប់តែឥឡូវនេះ រុក្ខជាតិទាំងនេះ ក៏ក្លាយទៅដូចជាកាកសំណល់ គ្មានឱជារសផ្អែមឆ្ងាញ់ពិសាអ្វីសោះ សូមលោកទូលសួរព្រះរាជាផង តើវាមានហេតុភេទយ៉ាងម៉េចក្នុងរឿងហ្នឹង ? ហើយសូមមកប្រាប់អាត្មាទាំងឡាយផង។

## រឿងយុវជនព្រាហ្មណ៍

លុះបានទទួលពាក្យបណ្ដាំពួកតាបស ហើយចេញផុតពីនោះទៅ លោកចន្ទក៏នាំគ្នាដើរសំដៅទៅទ្វារព្រះរាជធានីតាមមហាវិថីមួយ។មានវិទ្យាល័យមួយតាំងនៅប្រឫនឹងផ្លូវនោះ។ ក្រុមយុវជនព្រាហ្មណ៍ជាច្រើននាក់ ដែលនៅសិក្សាក្នុងវិទ្យាល័យនោះ បានឃើញលោកគាមណិចន្ទ ក៏នាំគ្នាស្រែកសួរ។ លុះដឹងថាលោកចន្ទចូលវាំងដូច្នោះក៏សូមផ្ដាំពាក្យទៅទូលសួរព្រះសម្មតិទេព ដោយតំណាលប្រាប់ថា

- លោកអ៊ុំជាទីគោរពអើយ! ពួកយើងខ្ញុំនេះ កាលពីដើមឲ្យតែបានសិក្សាស្វាធ្យាយមន្តវិជ្ជាការណាៗហើយ មន្តវិជ្ជាការនោះនោះសុទ្ធតែនៅចាំប្រាកដជាក់ច្បាស់ណាស់ មិនដឹងជាបុព្វហេតុដូចម្ដេច ? ឥឡូវនេះ ស្រាប់តែបែរជាប្រឹងរៀនសូត្រមិនព្រមជក់ជាប់ចាំសោះ ដូចជាដាក់ទឹកក្នុងក្អមធ្លុះ លែងប្រាកដ-ប្រជា ភ្លេចភ្លាំងងងឹងដូចយប់ទៅវិញ សូមលោកទូលសួរព្រះរាជាផង ថាតើរឿងហ្នឹង វាមានបុព្វហេតុយ៉ាងម៉េច? ហើយសូមវិលមកប្រាប់ពួកយើងខ្ញុំផង។

- មិនថ្វីទេ ខ្ញុំនឹងនាំយកពាក្យបណ្ដាំនេះ ទៅទូលសួរព្រះរាជាឲ្យអ្នកទាំងអស់គ្នាបាន។

## ព្រះរាជវិនិច្ឆ័យ

លោកគាមណិចន្ទ លុះបានទទួលបណ្ដាំទីដប់នេះហើយ ក៏យាត្រាចូលរាជធានី ឆ្ពោះទៅកាន់ព្រះបរមរាជវាំង។ ពេលនោះ ព្រះរាជាស្ដេចចេញប្រថាប់ក្នុងមហាសាលវិនិច្ឆ័យ។

## រឿងគោ

ក្រោយដែលបានព្រះរាជានុញ្ញាតហើយ បុរសជាម្ចាស់គោ ក៏នាំគាមណិចន្ទចូលទៅគាល់។ រីឯព្រះរាជា អាទាសមុខ ទ្រង់ទតឃើញលោកចន្ទភ្លាម ក៏ទ្រង់ស្គាល់ច្បាស់ថា លោកតានេះធ្លាប់ធ្វើជាមហាតលិកបិតាអញ គាត់ធ្លាប់បានបីពថ្នាក់ថ្នមអញពីមុនមកខ្លះដែរ ចុះគាត់ទៅនៅឯណាអេ្ហះ បានជាបាត់ដំណឹងឈឹងអឺចឹង។ ព្រះអង្គទ្រង់ព្រះចិន្ដាហើយ ទ្រង់មានព្រះរាជឱង្ការសាកសួររឿងរ៉ាវ ដោយស្និទ្ធស្នាលថា

- យី! លោកតាចន្ទទេតើ! ចុះលោកអញ្ជើញទៅណា បានជាបាត់ខ្លួនឈឹងយ៉ាងនេះ ខ្ញុំខានឃើញលោកយូរហើយ ហើយលោកអញ្ជើញមកនេះមានកិច្ចការធុរៈអ្វីដែរ?

- សូមទ្រង់ព្រះមេត្តាប្រោស ចាប់តាំងតែអំពីព្រះសម្មតិទេពជាអម្ចាស់ទ្រង់សោយព្រះទិវង្គតទៅម្ល៉េះ ដែលទូលព្រះបង្គំជាខ្ញុំល្អងធូលីព្រះបាទ បានចេញពីនេះទៅនៅអាស្រ័យឯជនបទ ប្រកបការកសិកម្មចិញ្ចឹមជីវិត តាមបែបជីវភាពនៃកសិករសាមញ្ញ ឯដំណើរដែលទូលព្រះបង្គំជាខ្ញុំមកនេះ ដោយបុរសម្ចាស់គោនេះ បានបង្ហាញរាជទូតបង្ខំឲ្យខ្ញុំព្រះអង្គមកកាន់ព្រះរាជសម្នាក់នៃល្អធូលីព្រះបាទ ព្រោះមានបុព្វហេតុក្ដីក្ដាំងអំពីរឿងគោ។

- ល្អហើយលោកតា! លោកតាមានគំនិតល្អណាស់ មិនជំពាក់នឹងបុណ្យស័ក្តិ ស្ម័គ្រចិត្តទៅប្រកបរបរកសិកម្ម ដែលជារបស់អាយុជីវិតនៃមនុស្សលោក ខ្ញុំសូមសរសើរលោក សូមចាត់ទុកលោកជាជនគំរូដ៏ក្លាហាន ហើយខ្ញុំសូម

អំពាវនាវ អស់អំពីដួងហឫទ័យ សូមឲ្យតម្រាប់ដ៏ល្អរបស់លោកនេះ មានប្រសិទ្ធភាពដល់យុវជននិងឥស្សរជនទូទៅ ឱ! លោកតា បើកុំតែមានគេបង្ខំឲ្យមក ប្រហែលជាលោកមិនមកជិតខ្ញុំទេ មើលទៅ! ដូច្នេះ ការដែលគេបង្ខំឲ្យលោកតាមកនេះ ជាការល្អវិសេសដែរ ព្រោះជាហេតុឲ្យខ្ញុំបានជួបមុខលោកតាក្នុងពេលនេះ! ចុះបុរសម្ចាស់គោនោះមួយណា? នៅឯណា?។

លោចន្ទ បង្ហាញរូបម្ចាស់គោ

- បពិត្រព្រះសម្មតិទេព, នេះ!

ព្រះរាជាទ្រង់សួរបញ្ជាក់ទៅម្ចាស់គោ

-មើល៍អ្នក! ឮថាអ្នកបានបង្ហាញរាជទូតដល់លោកតានេះ អ៊ីចឹងមែនឬទេ?

ម្ចាស់គោក្រាបទូល

- បពិត្រព្រះសម្មតិទេព! ពិតមែន!

ព្រះរាជា

- ចុះមានរឿងហេតុយ៉ាងម៉េចទៅ?

ម្ចាស់គោ

- បពិត្រព្រះសម្មតិទេព! ព្រោះហេតុលោកនេះ ពុំព្រមសងគោមួយនឹមដល់ទូលព្រះបង្គំវិញសោះ។

ព្រះរាជា

- ម៉េចលោកតា! ដូចពាក្យគេថាអ៊ីចឹងមែនឬ?

លោកតាគាមណិចន្ទ

- បពិត្រព្រះសម្មតិទេព! រឿងនេះសូមព្រះបពិត្រទ្រង់សណ្ដាប់នូវទូលព្រះបង្គំជាខ្ញុំ រួចលោកចន្ទក៏ក្រាបទូលប្រវត្តិសព្វគ្រប់តាំងពីទៅខ្ចីគោ រហូតយកគោទៅសងវិញ និងរហូតដល់ម្ចាស់គោទៅទាមទារយកសំណង។

ព្រះរាជាទ្រង់បែរមកសួរម្ចាស់គោវិញ

- នែអ្នក! កាលគោចូលទៅក្នុងក្រោលក្រោយផ្ទះរបស់អ្នក តើអ្នកបាន
ឃើញដែរឬទេ?

ម្ចាស់គោ

- ទូលព្រះបង្គំពុំបានឃើញទេ!

ព្រះរាជា ទ្រង់បញ្ចេញព្រះសូរសីហនាទយ៉ាងក្តៀវក្លាថា

- នែអ្នក! អ្នកឯងមិនធ្លាប់ឮអ្នកផងនិយាយថា យើងជាស្តេចមាននាម ប្រាកដថា ព្រះរាជានាមព្រះភគ្គ្រាថ្លាផ្លុះមុះមុតដូចកញ្ចក់ទេឬអ្វី? ចូរកុំនិយាយ កុហក ហើយចូរកុំភិតភ័យរង្កៀសចិត្តអី ចូរនិយាយឲ្យត្រង់មក?

ម្ចាស់គោភ័យរន្ធត់ ពុំអាចនឹងលាក់បាន ក៏ក្រាបទូលថា

-បពិត្រព្រះសម្មតិទេព! ទូលព្រះបង្គំបានឃើញដែរ ប៉ុន្តែលោកគាមណិចន្ទ ពុំបានប្រគល់គោឲ្យទូលព្រះបង្គំទេ។

ព្រះរាជាទ្រង់បន្ទូលទៅកាន់លោកចន្ទ

- អើ! លោកតាគាមណិ រឿងគោនោះ ត្រូវតែពិន័យលោកឲ្យសងគេចុះ ព្រោះលោកមិនបានប្រគល់ដោយសទ្ធវាចាទៅម្ចាស់គោ ប៉ុន្តែចំពោះរូបបុរស ម្ចាស់គោនេះវិញបានឃើញដែរ បែរជានិយាយកុហកដោយចេតនាថា មិនបាន ឃើញទៅវិញ ដូច្នេះ ចំពោះពួកចោរដែលជាអ្នកលួចគោ ជាភារៈរបស់រាជការ មានសមត្ថកិច្ចដេញអង្កេតរក តែចំពោះរូបបុរសម្ចាស់គោនេះ ត្រូវលោកតា ទទួលសិទ្ធិជាព្រះរាជអាជ្ញាធ្វើកម្មការ ខ្វៀលភ្នែកគាត់ទាំងប្រពន្ធទាំងប្តីឲ្យអស់ រួចលោកសងតម្លៃគោ២៥កហាបណៈទៅគាត់ចុះ។

លុះព្រះរាជាទ្រង់មានព្រះរាជឱង្ការដូចនេះហើយ ពួករាជបុរសក៏នាំ បុរសម្ចាស់គោនោះឲ្យចេញមកក្រៅវិញ។ បុរសម្ចាស់គោ ភ័យរន្ធត់ស្ទើរស្លុត ប្រាណ គិតថា «តើវាមានប្រយោជន៍អ្វីអំពីតម្លៃគោ២៥កហាបណៈហ្នឹង បើ អាត្មាអញត្រូវគេខ្វៀលភ្នែកខ្វាក់អស់ទៅហើយ»។ គាត់ឱនក្បាលក្រាបលូនទៅ ជិតបាទជើងលោកគាមណិចន្ទអង្វរករថា «លោកម្ចាស់អើយ! រឿងសំណងគោ

នោះ ខ្ញុំឈប់ទារហើយ សូមឲ្យតែរួចគ្នាប៉ុណ្ណឹងទៅ ហើយសូមលោកយកប្រាក់ប៉ុណ្ណោះទៀតទៅចុះ សូមកុំឲ្យតែខ្ញៀលភ្នែកខ្ញុំ និងភ្នែកប្រពន្ធខ្ញុំធ្វើអ្វី»។ គាត់សូកប្រាក់ថែមទៀត ដើម្បីអង្វករចិត្តលោកចន្ទ ហើយលែងទៅទទាក់ទទាម ក៏ប្រញាប់ប្រញាល់មឹតទៅផ្ទះវិញ។

## រឿងកូន

បន្ទាប់មក បុរសទីពីរក៏នាំលោកចន្ទចូលទៅទៀត។ ព្រះរាជាទ្រង់សួរបុរសនោះថា

- អើអ្នក! ចុះអ្នកមានរឿងអ្វីដែរ?

បុរសក្រាបទូល

- បពិត្រព្រះសម្មតិទេព លោកគាមណិចន្ទនេះ បានវាយប្រពន្ធទូលព្រះបង្គំឲ្យរលូតកូន។

ព្រះរាជាទ្រង់សួរទៅលោចន្ទ

- អ៊ីចឹងមែនទេ លោកតា?

លោចន្ទ

- សូមព្រះមហារាជទ្រង់ព្រះសណ្ដាប់ទូលព្រះបង្គំ...។

គាត់បានក្រាបទូលដំណើរយ៉ាងពិស្ដារសព្វគ្រប់ទូលព្រះរាជា ព្រះរាជាទ្រង់បញ្ជាក់ទៀតថា

- ក្រែងលោកតាបានវាយប្រពន្ធបុរសនោះឲ្យរលូតកូនមែនទេអ្ហី! ចូរប្រាប់ឲ្យត្រង់មកកុំលាក់ថ្វី?

លោកចន្ទ

- បពិត្រព្រះសម្មតិទេព! ទូលព្រះបង្គំប្រាកដជាពុំបានវាយទេ! ព្រះរាជាទ្រង់បែរទៅសួរបុរសនោះវិញ:

-នែអ្នក! អ្នកអាចធ្វើគភ៌ដែលអ្នកចោទថា លោកតានេះវាយឲ្យរលូតកូន

នោះឲ្យបានឡើងវិញភ្លាមឬទេ ?

បុរស

- ខ្ញុំព្រះអង្គពុំអាចធ្វើបានទេ!

ព្រះរាជា

- បើអីចឹង ឥឡូវនេះ អ្នកនឹងគិតយ៉ាងម៉េចទៅវិញ ?

បុរស

- ទូលព្រះបង្គំជាខ្ញុំ សូមឲ្យតែបានកូននោះមកវិញប៉ុណ្ណោះ!

ព្រះរាជា

- បើអីចឹងងាយទេ! នែលោកតា! ត្រូវលោកទៅនាំយកប្រពន្ធបុរសនោះទៅទុកធ្វើជាគ្រួសាររបស់លោក ដរាបតែដល់នាងនោះកើតកូនមួយ សឹមនាំត្រឡប់ឲ្យបុរសនោះវិញណា៎!។

ពួករាជបុរសក៏នាំបុរសទីពីរនោះចេញទៅក្រៅវិញ បុរសនោះមានសេចក្ដីព្រួយដ៏ក្រៃលែង ក្រាបលូនចូលទៅជិតបាតជើងលោកចន្ទ សូមអង្វរករកុំឲ្យលោកចន្ទបំបែកបំបាក់គ្រួសារខ្លួន រួចជូនប្រាក់សូកចិត្តខ្លះទៀ ទើបប្រញាប់ប្រញាល់រត់ទៅផ្ទះវិញ ដូចជាអ្នកម្ចាស់គោដែរ។

## រឿងសេះ

បន្ទាប់ពីនោះបុរសទីបីជាគង្វាលសេះក៏នាំលោកចន្ទចូលទៅគាល់ទៀត រួចក្រាបទូលព្រះរាជាថា

-បពិត្រព្រះសម្មតិទេព!លោកតាគាមណិចន្ទនេះចោលបំបាក់ជើងសេះរបស់ទូលព្រះបង្គំ!

ព្រះរាជាទ្រង់សួរលោកតាចន្ទ

- ម៉េចលោកតា ? ដូចជាពាក្យគេថាអីចឹងមែនទេ ?

លោកចន្ទ ក៏ថ្វាយបង្គំក្រាបទូលព្រះរាជារឿងហូរហែ។

ព្រះរាជាទ្រង់បញ្ជាក់ទៅអ្នកគង្វាលសេះថា

- ឮថា អ្នកឯងបាននិយាយសុំឲ្យលោកចន្ទ វាយបំបែរសេះឲ្យមែនទេ ?

គង្វាលសេះ

- ទូលព្រះបង្គំ ពុំបាននិយាយទេ ?

ព្រះរាជា

- និយាយឲ្យត្រង់មក! មែនឬពុំមែន ?

ឮព្រះសូរសីហនាទដូច្នោះ គង្វាលសេះស្ទើរស្លុតស្មារតី ពុំអាចនឹងលាក់លៀមសេចក្ដីពិតបាន ក៏ក្រាបទូលតាមត្រង់ថា

- បពិត្រព្រះសម្មតិទេព! ទូលព្រះបង្គំបាននិយាយមែន!

ព្រះរាជា

- អើលោកតា! អ្នកនេះបាននិយាយមែន បែរជាហ៊ាននិយាយមុសាវាទថាពុំបាននិយាយទៅវិញ បើដូច្នោះត្រូវលោកកាត់អណ្ដាតបុរសនេះចោលចេញរួចទៅយកសេះនោះមក ហើយចេញថ្លៃមួយពាន់កហាបណៈសងទៅបុរសនេះចុះ។

គង្វាលសេះភ័យណាស់ លុះរាជបុរសនាំមកក្រៅហើយ ក៏យកប្រាក់កាសទៅសូកលោកចន្ទ សូមឲ្យតែរួចគ្នា កុំឲ្យលោកកាត់អណ្ដាតខ្លួន រួចប្រញាប់រួសរាន់វិលទៅផ្ទះវិញភ្លាម។

## រឿងជាងផែង

ក្រោយដែលគង្វាលសេះចេញទៅផុត កូនជាងផែង ក៏នាំលោកចន្ទចូលទៅក្រាបបង្គំគាល់ទៀត។ ក្រោយដែលបានព្រះរាជវរោកាសហើយ ក៏ក្រាបទូលព្រះរាជាថា

- បពិត្រព្រះសម្មតិទេព! លោកតានេះ ជាចោរមនុស្សឃាត បានធ្វើឃាតកម្មចំពោះរូបឪពុកទូលព្រះបង្គំ។

ព្រះរាជាទ្រង់សួរទៅលោកចន្ទ

- ម៉េចលោកតា! អ៊ីចឹងមែនទេ?

លោកចន្ទ ក៏ក្រាបបង្គំទូលដោយពិស្តារ។

ព្រះរាជាទ្រង់មានព្រះបន្ទូលសួរកូនជាងផែងថា

- បើអ៊ីចឹង ឥឡូវនេះ អ្នកគិតយ៉ាងណាទៅវិញ?

កូនជាងផែង

- ទូលព្រះបង្គំ ចង់បានតែឪទុកមកវិញប៉ុណ្ណោះ!

ព្រះរាជា

- នែអ្នក! ឮថាអ្នកចង់បានតែឪពុកមកវិញប៉ុណ្ណោះ ក៏ប៉ុន្តែជម្មតាមនុស្ស ដែលស្លាប់ទៅហើយ អ្នកណាឡើយ នឹងអាចត្រឡប់ឲ្យរស់មកវិញបាន បើអ៊ីចឹង មានតែលោកតាទៅនាំយកម្ដាយអ្នកនេះ មកធ្វើជាមេផ្ទះលោក ដើម្បីនឹងឲ្យលោកបានជាឪពុកអ្នកនេះផងចុះ។

កូនជាងផែងភ័យណាស់ លុះពួករាជបុរសនាំមកខាងក្រៅ ក៏ក្រាបអង្វរករលោកចន្ទថា «ឱលោកម្ចាស់អើយ! សូមលោកមេត្តាកុំបំបាក់បំបែកគ្រួសាររបស់ឪពុកខ្ញុំដែលទើបនឹងទទួលអនិច្ចកម្មដូច្នេះអី!រឿងនេះខ្ញុំសូមរួចគ្នាទៅចុះ ហើយខ្ញុំសូមជូនប្រាក់នេះចំពោះលោក សូមឲ្យតែលោកមេត្តាគ្រួសារឪពុកខ្ញុំផង»។ កូនជាងផែងអង្វរករលោកចន្ទរួច ក៏រួសរាន់វិលទៅផ្ទះវិញ ដូចជាបុរសមុនៗដែរ។

ក្នុងថ្ងៃនេះ លោកគាមណិចន្ទ មានជោគជ័យលើគូក្ដីយ៉ាងត្រចះត្រចង់ជាអស្ចារ្យ លោកមានចិត្តរីករាយណាស់ បានចូលទៅក្រាបបង្គំទូលព្រះរាជាថា

- បពិត្រព្រះសម្មតិទេព មានអ្នកខ្លះទៀតពុំបានមកទេ ប៉ុន្តែបានផ្ញើពាក្យបណ្ដាំមកសូមទូលសួរព្រះអង្គ បើព្រះសម្មតិទេពពុំមានព្រះរាជហឫទ័យយល់ទាស់ទេ ទូលព្រះបង្គំជាខ្ញុំនឹងសូមព្រះរាជវរោកាសក្រាបទូល?

ព្រះរាជា

- មិនជាអ្វីទេ លោកតា! បាន! សូមលោកនិយាយចុះ។

លោកគាមណិចន្ទ លុះបានព្រះរាជវរោកាសហើយ ក៏ក្រាបបង្គំទូលនូវរឿងមួយៗជាលំដាប់ហូរហែ ដោយទូលយករឿងយុវជនព្រាហ្មណ៍ជាទីមួយតទៅ។ រីឯព្រះរាជា ក៏ទ្រង់ព្រះសណ្តាប់ហើយ ទ្រង់ដោះស្រាយជាលំដាប់លំ-ដោយ ដរាបអស់រឿងទាំងនោះ។

តើព្រះអង្គទ្រង់ដោះស្រាយយ៉ាងម៉េចខ្លះ?

## រឿងយុវជនព្រាហ្មណ៍

ជាដំបូង ព្រះអង្គទ្រង់សវនាការនូវពាក្យបណ្តាំទី១ ហើយទ្រង់ព្យាករព្រះបន្ទូលថា

កាលពីដើម នៅក្នុងទីអាស្រ័យរបស់យុវជនទាំងនោះ មានមាន់ឈ្មោលមួយ ជាសត្វដឹងស្គាល់ពេលវេលាត្រឹមត្រូវ ហើយតែងតែរងាវដាស់ពួកយុវជនទាំងនោះជាប្រក្រតីទៀងទាត់។ ពួកយុវជនទាំងនោះកាលបើឮសព្ទមាន់នោះរងាវដាស់ហើយ ក៏ភ្ញាក់ពីនិទ្រាក្រោកឡើង ធ្វើនូវការសិក្សាស្វាធ្យាយនូវមន្តវិជ្ជាដែលគេរៀងៗខ្លួនបានសិក្សាហើយ និងត្រូវសិក្សាតទៅទៀត រួចស្រួលបួលទើបអរុណរះឡើងច្បាស់។ ហេតុដូច្នេះហើយបានជាមន្តវិជ្ជាការទាំងឡាយណាៗដែលគេបានរៀនរួចហើយ មន្តវិជ្ជាការនោះ មិនងាយនឹងភ្លេចភ្លាំងបាត់ទៅវិញឡើយ ហើយវិជ្ជាដែលចាប់រៀនទៅមុខ ក៏ឆាប់ដក់ជាប់យ៉ាងចាំបានងាយពុំសូវលំបាក ប៉ុន្តែលុះដល់មកសព្វថ្ងៃនេះ នៅក្នុងទីអាស្រ័យរបស់គេទាំងនោះ បែរជាមានតែមាន់ដែលរងាវពុំទៀងទាត់ តាមពេលវេលាទៅវិញ។ មាន់នោះជួនកាលរងាវនៅពេលយប់ជ្រៅពេក ជួនកាលក៏រងាវនៅពេលភ្លឺច្បាស់ហួសហើយ។ ពួកយុវជនទាំងនោះរវល់តែវិលវល់តាមសំឡេងមាន់ គឺកាលបើក្រោកឡើងសិក្សា តាមសំឡេងមាន់នោះរងាវក្នុងពេលយប់ជ្រៅពេក ក៏សិក្សាពុំស្រួលព្រោះងងុយងោក ម្ល៉ោះហើយ ក៏រៀនទាំងងោកងក់ដេកលក់ទៅវិញអស់

តែបើក្រោកឡើងសិក្សាតាមសំឡេងមាន់នោះរងាវក្នុងពេលភ្លឺច្បាស់ហួសហើយ ក៏ខំប្រឹងសិក្សាសូត្រសានូវមន្តវិជ្ជាការដែលរៀនហើយពុំទាន់ ព្រោះផុតពេលនឹងស្វាយធ្យាយ ដូច្នេះហើយបានជាមន្តវិជ្ជាដែលពួកគេទាំងនោះ បានសិក្សារួចហើយ ក៏រផាត់ទាំងភ្លាំងភ្លេចទៅវិញអស់យ៉ាងនេះ។

## រឿងតាបស

ចំពោះពាក្យបណ្តាំទី២នេះ ព្រះអង្គទ្រង់មានព្រះបន្ទូលថា

- ពួកតាបសទាំងនោះ កាលពីដើម ឧស្សាហ៍នាំគ្នាធ្វើសមណធម៌ ប្រកបរឿយៗនូវកសិណបរិកម្មណាស់ ប៉ុន្តែលុះដល់មកសព្វថ្ងៃនេះ បែរជានាំគ្នាទៅធ្វើតែអំពើមិនមែនជាសមណកិច្ចទៅវិញ។ ផ្លែឈើតូចធំទាំងឡាយ ដែលកើតមាននៅក្នុងអារាមនោះ ក៏លោកទាំងនោះ ចេះតែនាំគ្នាបេះបោចហុចឲ្យឧបដ្ឋាករៀងៗខ្លួន ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ តាមវិធីឲ្យទៅឲ្យមក។ ព្រោះហេតុដូច្នោះហើយ បានជាឈើតូចធំក្នុងអារាមនោះ ចេះតែរីលរេចហិនហោចទៅ ហើយទាំងផ្លែសោតទៀត ក៏ខ្សោះអស់រសជាតិផ្អែមឆ្ងាញ់ពិសា លែងដូចពីកាលមុន ប៉ុន្តែប្រសិនណាជាពួកលោកទាំងនោះត្រឡប់ជានាំគ្នាប្រឹងប្រែងប្រកបសមណធម៌ដូចពេលមុនទៅវិញ ឈើទាំងនោះ ក៏នឹងបានលូតលាស់ត្រឈឹងត្រឈៃមានផ្លែរយោនរយាន ប្រកបដោយជាតិឱជារសផ្អែមឆ្ងាញ់ពិសាឡើងវិញពុំខាន តើពួកតាបសទាំងនោះពុំបានជ្រាបថា រាជត្រកូលយើងជាអ្នកប្រាជ្ញទេឬ? ចូរលោកតាទៅប្រាប់ពួកតាបសទាំងនោះ ឲ្យនាំគ្នាខំធ្វើសមណធម៌វិញទៅ!។

## រឿងនាគរាជ

ចំពោះពាក្យបណ្តាំទី៣ ព្រះអង្គទ្រង់បំភ្លឺថា

បុព្វហេតុដែលបណ្តាលឲ្យស្រះដ៏រមណីយនោះ ទៅជាមានទឹកកករល្អក់ខ្វល់ដេរដាសដោយចកបាយទា គឺមកពីពួកនាគទាំងនោះ ចេះតែឈ្លោះទាស់

ទែងដេញប្រខាំគ្នា ប្រសិនជាពួកនាគទាំងនោះ មានសាមគ្គីស្រុះស្រួលគ្នា ដូចកាលពីដើមវិញ ទឹកស្រះនោះគង់នឹងរងថ្លាឆ្វង់វិញពុំខាន។

## រឿងរុក្ខទេវតា

ចំពោះពាក្យបណ្តាំទី៤នេះ ព្រះអង្គទ្រង់ពន្យល់ថា

រុក្ខទេវតានោះ ពីដើមតែងជួយការពារក្សាអ្នកដំណើរទាំងឡាយ ដែលដើរមកតាមផ្លូវជិតដងព្រៃនោះហេតុដូច្នោះបានជាពួកមនុស្សទូទៅដែលដើរមកដល់ទីនោះ ក៏នាំគ្នាធ្វើពលិកម្មជាច្រើនប្រការដល់រុក្ខទេវតានោះ ដល់មកឥឡូវនេះ រុក្ខទេវតានោះ លែងរវល់ការពាររក្សាគេ បានជាលែងបានពលិកម្មអំពីគេដែរ តែប្រសិនណាបើរុក្ខទេវតានោះ ខំប្រឹងថែរក្សាការពារមនុស្សទាំងឡាយដូចពីមុនទៀតនោះ ក៏នឹងបានបរិបូណ៌លាភសក្ការៈដ៏លើសលុបវិញពុំខាន។ រុក្ខទេវតានោះមិនបានដឹងថា ព្រះរាជាជាអ្នកប្រាជ្ញទេ ហេតុដូច្នេះ ចូរលោកតាទៅប្រាប់រុក្ខទេវតានោះឲ្យប្រឹងថែរក្សាការពារពួកមនុស្ស ដែលធ្វើដំណើរតាមដងព្រៃនោះវិញទៅ។

## រឿងសត្វទទា

ចំពោះពាក្យបណ្តាំទី៥នេះ ព្រះអង្គទ្រង់ដោះស្រាយថា

សត្វទទានោះ ដែលចូលចិត្តតែទំនៅលើដំបូកធំនោះ ពីព្រោះនៅខាងក្រោមដំបូកនោះ មានកំណប់ទ្រព្យដ៏ល្អជាច្រើនកប់នៅ។ ចូរលោកតាទៅហើយគាស់យកកំណប់ទ្រព្យទាំងនោះទុកជាសម្បត្តិរបស់ខ្លួនទៅចុះ។

## រឿងម្រឹគ

ចំពោះពាក្យបណ្តាំទី៦នេះ ព្រះអង្គទ្រង់បញ្ជាក់ថា

នៅទីនោះ មានដើមឈើមួយដើមយ៉ាងធំ ប្រកបដោយមែកនិងស្លឹក

សាខា មានឃ្មុំមួយសំបុកធំណាស់នៅលើដើមឈើនោះ ម្រឹគនោះ វាជាប់ចិត្ត ស្អិតឆ្វាញ់តែនឹងស្មៅ ដែលផ្សាយផ្សើមដោយជាតិដ៏ផ្អែមនៃទឹកឃ្មុំនៅជុំវិញក្រោម ព្រឹក្សានោះ បានជាពុំអាចនឹងទៅស៊ីស្មៅនៅទីដទៃទៀតបាន។ ចូរលោកទៅ យកផ្លិតនៃឃ្មុំដ៏ធំនោះ ហើយបញ្ជូនទឹកឃ្មុំដ៏ថ្មោងមកឲ្យយើងខ្លះ រួចសេស សល់អំពីនោះ ចូរយកទៅបរិភោគខ្លួនឯងចុះ។

## រឿងពស់

ចំពោះពាក្យបណ្តាំទី៧នេះ ព្រះអង្គទ្រង់បំភ្លឺថា

នៅក្រោមដំបូក ដែលពស់នោះអាស្រ័យនៅ មានកំណប់ទ្រព្យដ៏ល្អ ជាច្រើន សត្វពស់នោះជាសត្វនៅរក្សាទ្រព្យនោះ ព្រោះហេតុដូច្នេះឯង បាន ជាក្នុងកាលដែលវានឹងចេញទៅស្វែងយកចំណីអាហារ ដោយការជាប់ជំពាក់ ចិត្តខ្លាំងនឹងទ្រព្យពេក ក៏ចេញទៅទាំងទើសទាល់ ហាក់ដូចជាមានសរីរៈរាង- កាយធំសម្បើមណាស់ លុះស្វែងរកចំណីអាហារបានហើយ ក្នុងកាលដែលនឹង ចូលទៅវិញ ដោយចិត្តប្រតិព័ទ្ធស្នេហានឹងទ្រព្យ នោះខ្លាំងពេក វារួសរាន់វារចូល ទៅយ៉ាងរហ័ស ហាក់ដូចគ្មានទើសទាល់នឹងអ្វីសោះ ចូរលោកតាទៅគាស់ កាយយកកំណប់ទ្រព្យនោះចុះ។

## រឿងស្ត្រីក្មេង

ចំពោះពាក្យបណ្តាំទី៨នេះ ព្រះអង្គទ្រង់វិនិច្ឆ័យថា

មានបុរសកំលោះដ៏កុំផានម្នាក់ ជាសហាយរបស់ស្រីក្មេងនោះ។ បុរស នោះ នៅក្នុងស្រុកមួយ ត្រង់រវាងចន្លោះកណ្តាលផ្លូវពីស្រុកខាងប្តីនាង ទៅស្រុក ខាងម្តាយឪពុកនាង។ នាងនោះ កាលណានឹងមានសាហាយ វាមិនអាចនៅ នឹងផ្ទះប្តីបាន ក៏ប្រាប់ប្តីថា វានឹងទៅលេងម្តាយឪពុក ប៉ុន្តែវាត្រូវទៅដេកនៅរួម ស្នេហានឹងសាហាយវា ប្រមាណពីរបីយប់ ទើបវាទៅដល់ផ្ទះម្តាយឪពុក។ លុះ

ទៅនៅនឹងផ្ទះម្ដាយឪពុកបានពីរបីថ្ងៃហើយ វានឹកមកសាហាយវាទៀត ទើបលាម្ដាយឪពុកវាថា វាទៅផ្ទះប្ដីវាវិញ ប៉ុន្តែបំណងវាចង់មក ដេកស្នេហាតែនឹងផ្ទះសាហាយវាជានិច្ចកាល លុះវានៅរួមស្នេហ៍ស្និទ្ធអស់ចិត្តនឹងប្រុសវាពីរបីថ្ងៃរួច ទើបវាទៅដល់ផ្ទះប្ដី។ ចូរលោកទៅប្រាប់ស្រីនោះផងថា នគរនេះជានគរមានស្ដេចសោយរាជ្យដែរ ចូរនាងនៅតែនឹងផ្ទះប្ដីបានហើយ កុំប្រហែសធ្វេសប្រព្រឹត្តអនាចារតទៅទៀតឲ្យសោះ ប្រយ័ត្នតែអ្នករាជការចាប់បាន មុខជានាងគ្មានជីវិតរស់នៅទេ។

## រឿងស្រីពេស្យា

ចំពោះពាក្យបណ្ដាំទី៩នេះ ព្រះអង្គទ្រង់បង្ហាញន័យថា

ស្រីពេស្យានោះ បានជាពីដើមបានថ្លៃឈ្នួល យ៉ាងច្រើនបរិបូណ៌ ពីព្រោះមានទំនៀមទម្លាប់ទៀងទាត់ល្អ គឺបើទទួលថ្លៃឈ្នួលអំពីដៃប្រុសណាហើយ ក៏ព្រមទទួលស្នេហ៍ស្និទ្ធតែនឹងប្រុសនោះជាមុន មិនព្រមទទួលយកថ្លៃឈ្នួលអំពីដៃប្រុសដទៃទៀតឡើយ ប៉ុន្តែដល់មកឥឡូវនេះ នាងនោះបានបោះបង់ទំនៀមធម្មតារបស់ខ្លួនចោលអស់ គឺបើបានទទួលថ្លៃឈ្នួលប្រចាំចិត្តពីប្រុសនេះហើយ មិនទាន់បានជាអ្វីនឹងគ្នាផង ក៏ទៅទទួលថ្លៃឈ្នួលពីដៃប្រុសម្នាក់ទៀត ហើយបើកដៃឲ្យប្រុសក្រោយនេះបានឱកាសមុន បណ្ដោះបណ្ដោយឲ្យប្រុសមុនខកប្រាណទៅជាបានឱកាសក្រោយវិញ។ អំពើនេះឯងដែលនាំបណ្ដាលឲ្យស្រីនោះ ធ្វើរបរឥតដើមទុននេះពុំប្រកប ហើយថ្លៃឈ្នួលក៏ចេះតែខ្សត់ទៅ រហូតដល់លែងមានប្រុសណាម្នាក់ទៅជិតស្នេហ៍ស្និទ្ធទាក់ទងសោះ ប៉ុន្តែ បើបែរជាតាំងនៅក្នុងទំនៀមធម្មតាដូចពីកាលមុនវិញ ស្រីនោះនឹងបានថ្លៃឈ្នួលបរិបូណ៌ដូចមុនវិញដែរ។ ចូរលោកទៅណែនាំស្រីពេស្យានោះ ឲ្យប្រែទៅឋិតនៅក្នុងទំនៀមធម្មតាវិញទៅ!។

## រឿងចៅសង្កាត់

ចំពោះពាក្យបណ្ដាំទី១០នោះ ព្រះអង្គទ្រង់បើកកកាយយ៉ាងច្បាស់ថា លោកចៅសង្កាត់នោះ កាលពីដើមឡើយគាត់ជាមនុស្សទៀងត្រង់ កាត់ក្ដីដោយសុចរិតយុត្តិធម៌ សមរម្យតាមច្បាប់ មនុស្សក្នុងស្រុកទូទៅមានស្វាមីភក្តិស្រឡាញ់ពេញចិត្តនឹងគាត់ណាស់ តែងនាំគ្នាយកគ្រឿងបណ្ណាការជំនូនដ៏ច្រើនទៅជូនគាត់ដោយស្មោះស្ម័គ្រ ហេតុដូច្នោះហើយ បានជាគាត់មានធនធានច្រើន មានរូបសម្បត្តិស្រស់បស់ បរិបូណ៌ដោយយសបរិវារ ប៉ុន្តែក្រោយមកគាត់នេះទៅជាមនុស្សគំរក់ ចូលចិត្តតែស៊ីសំណូកសូកប៉ាន់ លែងកាត់ក្ដីតាមច្បាប់ត្រឹមត្រូវទៅវិញ។ ហេតុនេះ បានជាគាត់ទៅជាមនុស្សក្រទុគ៌ត៌កំព្រា ទាំងត្រូវរោគលឿងញ៉ាំញីផង។ ការណ៍នេះ ប្រសិនជាគាត់ប្រែចិត្តគំនិតឲ្យល្អ កាត់ក្ដីក្ដាំតាមចំណាំច្បាប់ដល់អ្នកស្រុកដូចពីដើមវិញ គាត់ក៏គង់នឹងមានសភាពដូចពីដើមវិញដែរ។ ចូរលោកទៅប្រាប់គាត់ ឲ្យកាត់ក្ដីត្រឹមត្រូវតាម ច្បាប់វិញទៅ!។

## ដំណើរនិវត្តន៍នៃលោកគាមណិចន្ទ

ព្រះបាទអាទាសមុខរាជ ជាអម្ចាស់ជីវិតលើត្បូង ទ្រង់បានដោះស្រាយបញ្ហាទាំងអស់សព្វគ្រប់ដោយព្រះប្រាជ្ញាញាណ ដូចជាអង្គសព្វញ្ញុពុទ្ធ តាមពាក្យបង្គំក្រាបទូល របស់លោកគាមណិចន្ទ ហើយស្ដេចទ្រង់ព្រះរាជទានទ្រព្យសម្បត្តិជាច្រើនដល់លោកគាមណិចន្ទ រួចទ្រង់ប្រទានស្រុកដែលគាត់ទៅតាំងភូមិផ្ទះនៅហើយនោះ ឲ្យជាព្រហ្មទានដល់គាត់ទៀត រួចទ្រង់ព្រះរាជានុញ្ញាតឲ្យគាត់ត្រឡប់ទៅផ្ទះវិញ។ លោកគាមណិចន្ទ ក៏បានធ្វើដំណើរចេញអំពីព្រះរាជធានីទៅគេហដ្ឋានវិញដោយសុវត្ថិភាព ប៉ុន្តែនៅតាមផ្លូវ គាត់បានឆៀងចូលប្រាប់ព្រះរាជសាសន៍ ដែលទ្រង់ប្រទានទៅនោះ ដល់ក្រុមយុវជនព្រាហ្មណ៍ ដល់ពួកតាបស ដល់នាគរាជ និងដល់រុក្ខទេវតាហើយ ទើបទៅគាល់កកាយយកកំណប់ទ្រព្យអំពីដំបូកដែលជាទ្រនំរបស់សត្វទទា រួចទៅយកឃ្មុំអំពីមហាព្រឹក្សាជាទី

ដែលម្រឹគស៊ីស្មៅ ហើយបញ្ជូនទឹកឃ្មុំដ៏ថ្មោងនោះ ទៅថ្វាយព្រះរាជា។ លោកទៅគាស់ទម្លាយដំបូកដែលជាទីនៅអាស្រ័យរបស់ពស់ កាយយកទ្រព្យកំណប់ទាំងនោះជាស្រេច ទើបឆៀងដំណើរចូលទៅប្រាប់ព្រះរាជសាសន៍ ដល់ស្ត្រីក្មេង ដល់ស្ត្រីពេស្យា និងដល់ចៅសង្កាត់ តាមលម្អានសេចក្តី ដែលព្រះរាជាទ្រង់មានព្រះរាជឱង្ការ។ គាត់បានធ្វើដំណើរទៅកាន់ស្រុកភូមិរបស់គាត់ ដោយយសស័ក្តិយ៉ាងអធិកឧត្តម ហើយក៏ចាត់ចែងទីឋានតាំងនៅជាស្ថាពរក្នុងស្រុកដែលជាព្រហ្មទានរបស់ព្រះរាជានោះ ជាសុខក្សេមក្សាន្តដរាបដល់អស់ជន្មាយុ។

## ជាអវសាន

ព្រះបាទអាទាសមុខរាជ ជាបរមក្សត្រិយ៍អម្ចាស់ជីវិត ព្រះអង្គទ្រង់មានព្រះបរមនាមកាន់តែល្បីល្បាញខ្លាំងទូទៅពេញសកលជម្ពូទ្វីប ហើយព្រះអង្គទ្រង់បំពេញព្រះរាជកុសលមានទាននិងសីលជាដើម ជារៀងរាបដរាបដល់អវសាននៃព្រះជន្មាយុ។ លុះទ្រង់សោយព្រះទិវង្គតទៅ ស្តេចទៅកើតនៅនាឋានសួគ៌ទេវលោក ជាសុខក្សេមក្សាន្តហោង៕

ចប់




ONLINE
IN TOUCH WITH YOUR WORLD
អ្នកផ្តល់សេវាអ៊ីនធើណែតឈានមុខគេនៅកម្ពុជា
The leading Internet Service & VoIP Provider in Cambodia
WWW.ONLINE.COM.KH

Find us at
facebook.com/ideabookpublishing

ISBN 978999-6331-86-2
9 789996 331862

១២ ៥០០ រៀល